ព្រះ
ត្រៃបិដកបាលី
និង
សេចក្ដីប្រែជាភាសាខ្មែរ
អភិធម្មបិដក
កថាវត្ថុ តតិយភាគ

៨៦

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស ២៥០៩

អភិធម្មបិដកេ

កថាវត្ថុស្ស ទុតិយោ ភាគោ

តិស្សោបិ អនុសយកថា

---

(១) អនុសយា អព្យាកតាតិ ។ អាមន្តា ។ វិបាកាព្យាកតា កិរិយាព្យាកតា រូបំ និព្វានំ ចក្ខាយតនំ ។បេ។ ផោដ្ឋព្វាយតនន្តិ ។ ន ហេវំ វត្តព្វេ ។បេ។

(២) កាមរាគានុសយោ អព្យាកតោតិ ។ អាមន្តា ។ កាមរាគោ កាមរាគបរិយុដ្ឋានំ កាមរាគសញ្ញោជនំ កាមោឃោ កាមយោគោ កាមច្ឆន្ទនីវរណំ អព្យាកតន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ កាមរាគោ កាមរាគបរិយុដ្ឋានំ ។បេ។ កាមច្ឆន្ទនីវរណំ អកុសលន្តិ ។ អាមន្តា ។ កាមរាគានុសយោ អកុសលោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៣) បដិឃានុសយោ អព្យាកតោតិ ។ អាមន្តា ។ បដិឃំ បដិឃបរិយុដ្ឋានំ បដិឃសញ្ញោជនំ អព្យាកតន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ បដិឃំ បដិឃបរិយុដ្ឋានំ បដិឃសញ្ញោជនំ អកុសលន្តិ ។ អាមន្តា ។ បដិឃានុសយោ អកុសលោតិ ។ ន ហេវំ វត្តព្វេ ។បេ។

អភិធម្មបិដក

កថាវត្ថុ ទុតិយភាគ

តិស្សោបិ អនុសយកថា

---

(១) សក: អនុស័យ ជាអព្យាក្រឹត ឬ ។ បរ: អើ ។ វិបាកនិងអព្យាក្រឹត កិរិយានិងអព្យាក្រឹត រូប និព្វាន ចក្ខាយតនៈ ។បេ។ ផោដ្ឋព្វាយតនៈ (ជាអព្យាក្រឹត) ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(២) កាមរាគានុស័យ ជាអព្យាក្រឹតឬ ។ អើ ។ កាមរាគៈ កាមរាគបរិយុដ្ឋានៈ កាមរាគសញ្ញោជនៈ កាមោឃៈ កាមយោគៈ កាមច្ឆន្ទនីវរណៈ ជាអព្យាក្រឹតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាមរាគៈ កាមរាគបរិយុដ្ឋានៈ ។បេ។ កាមច្ឆន្ទនីវរណៈ ជាអកុសលឬ ។ អើ ។ កាមរាគានុស័យ ជាអកុសលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៣) បដិឃានុស័យ ជាអព្យាក្រឹតឬ ។ អើ ។ បដិឃៈ បដិឃបរិយុដ្ឋានៈ បដិឃសញ្ញោជនៈ ជាអព្យាក្រឹតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បដិឃៈ បដិឃបរិយុដ្ឋានៈ បដិឃសញ្ញោជនៈ ជាអកុសលដែរឬ ។ អើ ។ បដិឃានុស័យ ជាអកុសលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៤) មានានុសយោ អព្យាកតោតិ ។ អាមន្តា ។ មានោ មានបរិយុដ្ឋានំ មានសញ្ញោជនំ អព្យាកតន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ មានោ មានបរិយុដ្ឋានំ មានសញ្ញោជនំ អកុសលន្តិ ។ អាមន្តា ។ មានានុសយោ អកុសលោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៥) ទិដ្ឋានុសយោ អព្យាកតោតិ ។ អាមន្តា ។ ទិដ្ឋិ ទិដ្ឋោឃោ ទិដ្ឋិយោគោ ទិដ្ឋិបរិយុដ្ឋានំ ទិដ្ឋិសញ្ញោជនំ អព្យាកតន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ ទិដ្ឋិ ទិដ្ឋោឃោ ទិដ្ឋិយោគោ ទិដ្ឋិបរិយុដ្ឋានំ ទិដ្ឋិសញ្ញោជនំ អកុសលន្តិ ។ អាមន្តា ។ ទិដ្ឋានុសយោ អកុសលោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៦) វិចិកិច្ឆានុសយោ អព្យាកតោតិ ។ អាមន្តា ។ វិចិកិច្ឆា វិចិកិច្ឆាបរិយុដ្ឋានំ វិចិកិច្ឆាសញ្ញោជនំ វិចិកិច្ឆានីវរណំ អព្យាកតន្តិ ។ ន ហេវំ វត្តព្វេ ។បេ។ វិចិកិច្ឆា វិចិកិច្ឆាបរិយុដ្ឋានំ វិចិកិច្ឆាសញ្ញោជនំ វិចិកិច្ឆានីវរណំ អកុសលន្តិ ។ អាមន្តា ។ វិចិកិច្ឆានុសយោ អកុសលោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៤) មានានុស័យ ជាអព្យាក្រឹតឬ ។ អើ ។ មានះ មានបរិយុដ្ឋានះ មានសញ្ញោជនះ ជាអព្យាក្រឹតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ មានះ មានបរិយុដ្ឋានះ មានសញ្ញោជនះ ជាអកុសលឬ ។ អើ ។ មានានុស័យ ជាអកុសលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៥) ទិដ្ឋានុស័យ ជាអព្យាក្រឹតឬ ។ អើ ។ ទិដ្ឋិ ទិដ្ឋោឃះ ទិដ្ឋិយោគះ ទិដ្ឋិបរិយុដ្ឋានះ ទិដ្ឋិសញ្ញោជនះ ជាអព្យាក្រឹតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ទិដ្ឋិ ទិដ្ឋោឃះ ទិដ្ឋិយោគះ ទិដ្ឋិបរិយុដ្ឋានះ ទិដ្ឋិសញ្ញោជនះ ជាអកុសលឬ ។ អើ ។ ទិដ្ឋានុស័យ ជាអកុសលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦) វិចិកិច្ឆានុស័យ ជាអព្យាក្រឹតឬ ។ អើ ។ វិចិកិច្ឆា វិចិកិច្ឆាបរិយុដ្ឋានះ វិចិកិច្ឆាសញ្ញោជនះ វិចិកិច្ឆានីវរណះ ជាអព្យាក្រឹតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិចិកិច្ឆា វិចិកិច្ឆាបរិយុដ្ឋានះ វិចិកិច្ឆាសញ្ញោជនះ វិចិកិច្ឆានីវរណះ ជាអកុសលឬ ។ អើ ។ វិចិកិច្ឆានុស័យ ជាអកុសលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៧) ភវរាគានុសយោ អព្យាកតោតិ ។ អាមន្តា ។ ភវរាគោ ភវរាគបរិយុដ្ឋានំ ភវរាគសញ្ញោជនំ អព្យាកតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ភវរាគោ ភវរាគបរិយុដ្ឋានំ ភវរាគសញ្ញោជនំ អកុសលន្តិ ។ អាមន្តា ។ ភវរាគានុសយោ អកុសលោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៨) អវិជ្ជានុសយោ អព្យាកតោតិ ។ អាមន្តា ។ អវិជ្ជា អវិជ្ជោឃោ អវិជ្ជាយោគោ អវិជ្ជាបរិយុដ្ឋានំ អវិជ្ជាសញ្ញោជនំ អវិជ្ជានីវរណំ អព្យាកតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អវិជ្ជា អវិជ្ជោឃោ អវិជ្ជាយោគោ អវិជ្ជាបរិយុដ្ឋានំ អវិជ្ជាសញ្ញោជនំ អវិជ្ជានីវរណំ អកុសលន្តិ ។ អាមន្តា ។ អវិជ្ជានុសយោ អកុសលោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៩) ន វត្តព្វំ អនុសយា អព្យាកតាតិ ។ អាមន្តា ។ បុថុជ្ជនោ កុសលាព្យាកតេ ចិត្តេ វត្តមានេ សានុសយោតិ វត្តព្វោតិ ។ អាមន្តា ។

(៧) ភវរាគានុស័យ ជាអព្យាក្រឹតឬ ។ អើ ។ ភវរាគៈ ភវរាគបរិយុដ្ឋានៈ ភវរាគសញ្ញោជនៈ ជាអព្យាក្រឹតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ភវរាគៈ ភវរាគបរិយុដ្ឋានៈ ភវរាគសញ្ញោជនៈ ជាអកុសលឬ ។ អើ ។ ភវរាគានុស័យ ជាអកុសលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨) អវិជ្ជានុស័យ ជាអព្យាក្រឹតឬ ។ អើ ។ អវិជ្ជា អវិជ្ជោឃៈ អវិជ្ជាយោគៈ អវិជ្ជាបរិយុដ្ឋានៈ អវិជ្ជាសញ្ញោជនៈ អវិជ្ជានីវរណៈ ជាអព្យាក្រឹតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អវិជ្ជា អវិជ្ជោឃៈ អវិជ្ជាយោគៈ អវិជ្ជាបរិយុដ្ឋានៈ អវិជ្ជាសញ្ញោជនៈ អវិជ្ជានីវរណៈ ជាអកុសលឬ ។ អើ ។ អវិជ្ជានុស័យ ជាអកុសលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៩) បុគ្គលមិនគួរពោលថា អនុស័យ ជាអព្យាក្រឹតទេ ឬ ។ អើ ។ បុថុជ្ជន កាលបើចិត្ត ជាកុសលនិងអព្យាក្រឹត កំពុងប្រព្រឹត្តទៅ បុគ្គលគួរពោលថា ប្រកបដោយអនុស័យឬ ។ អើ ។

កុសលាកុសលា ធម្មា សម្មុខីភាវំ អាគច្ឆន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ អនុសយា អព្យាកតាតិ ។ បុថុជ្ជនោ កុសលាព្យាកតេ ចិត្តេ វត្តមានេ សរាគោតិ វត្តព្វោតិ ។ អាមន្តា ។ កុសលាកុសលា ធម្មា សម្មុខីភាវំ អាគច្ឆន្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ រាគោ អព្យាកតោតិ ។

(១០) អនុសយា អហេតុកាតិ ។ អាមន្តា ។ រូបំ និព្វានំ ចក្ខាយតនំ ។ បេ ។ ផោដ្ឋព្វាយតនន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កាមរាគានុសយោ អហេតុកោតិ ។ អាមន្តា ។ កាមរាគោ កាមរាគបរិយុដ្ឋានំ កាមរាគសញ្ញោជនំ ។ បេ ។ កាមច្ឆន្ទនីវរណំ អហេតុកន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កាមរាគោ កាមរាគបរិយុដ្ឋានំ ។ បេ ។ កាមច្ឆន្ទនីវរណំ សហេតុកន្តិ ។ អាមន្តា ។ កាមរាគានុសយោ សហេតុកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ បដិឃានុសយោ ។ បេ ។ មានានុសយោ ទិដ្ឋានុសយោ វិចិកិច្ឆានុសយោ ភវរាគានុសយោ ។ បេ ។

កុសលធម៌ និងអកុសលធម៌ មកកាន់ភាពចំពោះមុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ អនុស័យ ជាអព្យាក្រឹត ។ បុថុជ្ជន កាលបើចិត្ត ជាកុសលនិងអព្យាក្រឹត កំពុងប្រព្រឹត្តទៅ បុគ្គល គួរពោលថា ប្រកបដោយរាគៈដែរឬ ។ អើ ។ កុសលធម៌និងអកុសលធម៌ មកកាន់ភាពចំពោះមុខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ រាគៈ ជាអព្យាក្រឹត ។

(១០) អនុស័យ មិនមានហេតុទេឬ ។ អើ ។ រូប និព្វាន ចក្ខាយតនៈ ។ បេ ។ ផោដ្ឋព្វាយតនៈ (មិនមានហេតុ) ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កាមរាគានុស័យ មិនមានហេតុឬ ។ អើ ។ កាមរាគៈ កាមរាគបរិយុដ្ឋានៈ កាមរាគសញ្ញោជនៈ ។ បេ ។ កាមច្ឆន្ទនីវរណៈ មិនមានហេតុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កាមរាគៈ កាមរាគបរិយុដ្ឋានៈ ។ បេ ។ កាមច្ឆន្ទនីវរណៈ ប្រកបដោយហេតុឬ ។ អើ ។ កាមរាគានុស័យ ប្រកបដោយហេតុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បដិឃានុស័យ ។ បេ ។ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆានុស័យ ភវរាគានុស័យ ។ បេ ។

អវិជ្ជានុសយោ អហេតុកោតិ ។ អាមន្តា ។ អវិជ្ជា អវិជ្ជោឃោ អវិជ្ជាយោគោ អវិជ្ជាបរិយុដ្ឋានំ អវិជ្ជា-សញ្ញោជនំ អវិជ្ជានីវរណំ អហេតុកន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អវិជ្ជា អវិជ្ជោឃោ ។ បេ ។ អវិជ្ជានី-វរណំ សហេតុកន្តិ ។ អាមន្តា ។ អវិជ្ជានុសយោ សហេតុកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(១១) ន វត្តព្វំ អនុសយា អហេតុកាតិ ។ អាមន្តា ។ បុថុជ្ជនោ កុសលាព្យាកតេ ចិត្តេ វត្តមានេ សានុ-សយោតិ វត្តព្វោតិ ។ អាមន្តា ។ អនុសយា តេន ហេតុនា សហេតុកាតិ ។ ន ហេវំ វត្តព្វេ ។ ប ។ តេន ហិ អនុសយា អហេតុកាតិ ។ បុថុជ្ជនោ កុសលាព្យាកតេ ចិត្តេ វត្តមានេ សរាគោតិ វត្តព្វោតិ ។ អាមន្តា ។ រាគោ តេន ហេតុនា សហេតុកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ រាគោ អហេតុកោតិ ។

(១២) អនុសយា ចិត្តវិប្បយុត្តាតិ ។ អាមន្តា ។ រូបំ និព្វានំ ចក្ខាយតនំ ។ បេ ។ ផោដ្ឋព្វាយតនន្តិ ។

អវិជ្ជានុស័យ មិនមានហេតុឬ ។ អើ ។ អវិជ្ជា អវិជ្ជោឃៈ អវិជ្ជាយោគៈ អវិជ្ជាបរិយុដ្ឋានៈ អវិជ្ជាសញ្ញោជនៈ អវិជ្ជានីវរណៈ មិនមានហេតុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អវិជ្ជា អវិជ្ជោឃៈ ។ បេ ។ អវិជ្ជា-នីវរណៈ ប្រកបដោយហេតុឬ ។ អើ ។ អវិជ្ជានុស័យ ប្រកបដោយហេតុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(១១) បុគ្គលមិនគួរពោលថា អនុស័យមិនមានហេតុទេឬ ។ អើ ។ បុថុជ្ជន កាលបើចិត្ត ជាកុសលនិងអព្យាក្រឹត កំពុងប្រព្រឹត្តទៅ បុគ្គលគួរពោលថា ប្រកបដោយអនុស័យដែរឬ ។ អើ ។ អនុស័យប្រកបដោយហេតុ ដោយហេតុនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ អនុស័យ មិនមានហេតុ ។ បុថុជ្ជន កាលបើចិត្ត ជាកុសល និងអព្យាក្រឹត កំពុងប្រព្រឹត្តទៅ បុគ្គល គួរពោលថា ប្រកបដោយរាគៈដែរឬ ។ អើ ។ រាគៈ ប្រកបដោយហេតុ ដោយហេតុនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ រាគៈ មិនមានហេតុទេ ។

(១២) អនុស័យ ប្រាសចាកចិត្តឬ ។ អើ ។ រូប និព្វាន ចក្ខា-យតនៈ ។ បេ ។ ផោដ្ឋព្វាយតនៈ (ប្រាសចាកចិត្ត) ដែរឬ ។

ន ហេវំ វត្តព្វេ ។បេ។ កាមរាគានុសយោ ចិត្ត-
វិប្បយុត្តោតិ ។ អាមន្តា ។ កាមរាគោ កាមរាគ-
បរិយុដ្ឋានំ កាមរាគសញ្ញោជនំ កាមោឃោ កាម-
យោគោ កាមច្ឆន្ទនីវរណំ ចិត្តវិប្បយុត្តន្តិ ។ ន ហេវំ
វត្តព្វេ ។បេ។ កាមរាគោ កាមរាគបរិយុដ្ឋានំ
។បេ។ កាមច្ឆន្ទនីវរណំ ចិត្តសម្បយុត្តន្តិ ។
អាមន្តា ។ កាមរាគានុសយោ ចិត្តសម្បយុត្តោតិ ។
ន ហេវំ វត្តព្វេ ។បេ។

(១៣) កាមរាគានុសយោ ចិត្តវិប្បយុត្តោតិ ។
អាមន្តា ។ កតមក្ខន្ធបរិយាបន្នោតិ ។ សង្ខារក្ខន្ធ-
បរិយាបន្នោតិ ។ សង្ខារក្ខន្ធោ ចិត្តវិប្បយុត្តោតិ ។
ន ហេវំ វត្តព្វេ ។បេ។ សង្ខារក្ខន្ធោ ចិត្តវិប្ប-
យុត្តោតិ ។ អាមន្តា ។ វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ
ចិត្តវិប្បយុត្តោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(១៤) កាមរាគានុសយោ សង្ខារក្ខន្ធបរិយាបន្នោ
ចិត្តវិប្បយុត្តោតិ ។ អាមន្តា ។ កាមរាគោ សង្ខារក្ខន្ធ-
បរិយាបន្នោ ចិត្តវិប្បយុត្តោតិ ។ ន ហេវំ វត្តព្វេ ។បេ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាមរាគានុស័យ ប្រាសចាកចិត្ត
ដែរឬ ។ អើ ។ កាមរាគៈ កាមរាគបរិយុដ្ឋានៈ កាមរាគសញ្ញោជនៈ
កាមោឃៈ កាមយោគៈ កាមច្ឆន្ទនីវរណៈ ប្រាសចាកចិត្តដែរឬ ។
អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ កាមរាគៈ កាមរាគបរិយុដ្ឋានៈ
។បេ។ កាមច្ឆន្ទនីវរណៈ ប្រកបដោយចិត្តឬ ។ អើ ។ កាមរាគា-
នុស័យ ប្រកបដោយចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(១៣) កាមរាគានុស័យ ប្រាសចាកចិត្តឬ ។ អើ ។ កាមរាគានុ-
ស័យ រាប់បញ្ចូលក្នុងខន្ធណា ។ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ។ សង្ខារ-
ក្ខន្ធ ប្រាសចាកចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។
សង្ខារក្ខន្ធ ប្រាសចាកចិត្តឬ ។ អើ ។ វេទនាខន្ធ សញ្ញាខន្ធ ប្រាស
ចាកចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(១៤) កាមរាគានុស័យ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រាស
ចាកចិត្តឬ ។ អើ ។ កាមរាគៈ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ
ប្រាសចាកចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

កាមរាគោ សង្ខារក្ខន្ធបរិយាបន្នោ ចិត្តវិប្បយុត្តោតិ ។ អាមន្តា ។ កាមរាគានុសយោ សង្ខារក្ខន្ធបរិយាបន្នោ ចិត្តសម្បយុត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(១៥) កាមរាគានុសយោ សង្ខារក្ខន្ធបរិយាបន្នោ ចិត្តវិប្បយុត្តោ កាមរាគោ សង្ខារក្ខន្ធបរិយាបន្នោ ចិត្តសម្បយុត្តោតិ ។ អាមន្តា ។ សង្ខារក្ខន្ធោ ឯកទេ-សោ ចិត្តសម្បយុត្តោ ឯកទេសោ ចិត្តវិប្បយុត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សង្ខារក្ខន្ធោ ឯកទេសោ ចិត្តសម្បយុត្តោ ឯកទេសោ ចិត្តវិប្បយុត្តោតិ ។ អាមន្តា ។ វេទនាខន្ធោ សញ្ញាខន្ធោ ឯកទេសោ ចិត្តសម្បយុត្តោ ឯកទេសោ ចិត្តវិប្បយុត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(១៦) បដិឃានុសយោ មានានុសយោ ទិដ្ឋានុ-សយោ វិចិកិច្ឆានុសយោ ភវរាគានុសយោ អវិជ្ជា-នុសយោ ចិត្តវិប្បយុត្តោតិ ។ អាមន្តា ។ អវិជ្ជា អវិជ្ជោឃោ អវិជ្ជាយោគោ ។ បេ ។ អវិជ្ជានីវរណំ ចិត្តវិប្បយុត្តន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

កាមរាគៈ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រាសចាកចិត្តដែរឬ ។ អើ ។ កាមរាគានុស័យ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(១៥) កាមរាគានុស័យ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រាសចាកចិត្ត កាមរាគៈ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយចិត្តឬ ។ អើ ។ សង្ខារក្ខន្ធខ្លះ ប្រកបដោយចិត្ត ខ្លះប្រាសចាកចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សង្ខារក្ខន្ធខ្លះ ប្រកបដោយចិត្ត ខ្លះប្រាសចាកចិត្តឬ ។ អើ ។ វេទនាខន្ធ សញ្ញាខន្ធ ខ្លះប្រកបដោយចិត្ត ខ្លះប្រាសចាកចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(១៦) បដិឃានុស័យ មានានុស័យ ទិដ្ឋានុស័យ វិចិកិច្ឆា-នុស័យ ភវរាគានុស័យ អវិជ្ជានុស័យ ប្រាសចាកចិត្តឬ ។ អើ ។ អវិជ្ជា អវិជ្ជោឃៈ អវិជ្ជាយោគៈ ។ បេ ។ អវិជ្ជានីវរណៈ ប្រាសចាកចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

អវិជ្ជា អវិជ្ជោឃោ អវិជ្ជាយោគោ ។ បេ ។ អវិជ្ជានី-
វរណំ ចិត្តវិប្បយុត្តន្តិ ។ អាមន្តា ។ អវិជ្ជានុសយោ
ចិត្តសម្បយុត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។
អវិជ្ជានុសយោ ចិត្តវិប្បយុត្តោតិ ។ អាមន្តា ។
កតមក្ខន្ធបរិយាបន្នោតិ ។ សង្ខារក្ខន្ធបរិយាបន្នោតិ ។
សង្ខារក្ខន្ធោ ចិត្តវិប្បយុត្តោតិ ។ ន ហេវំ វត្តព្វេ
។ បេ ។ សង្ខារក្ខន្ធោ ចិត្តវិប្បយុត្តោតិ ។ អាមន្តា ។
វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ ចិត្តវិប្បយុត្តោតិ ។ ន
ហេវំ វត្តព្វេ ។ បេ ។ អវិជ្ជានុសយោ សង្ខារក្ខន្ធ-
បរិយាបន្នោ ចិត្តវិប្បយុត្តោតិ ។ អាមន្តា ។ អវិជ្ជា
សង្ខារក្ខន្ធបរិយាបន្នា ចិត្តវិប្បយុត្តាតិ ។ ន ហេវំ
វត្តព្វេ ។ បេ ។ អវិជ្ជា សង្ខារក្ខន្ធបរិយាបន្នា ចិត្ត-
សម្បយុត្តាតិ ។ អាមន្តា ។ អវិជ្ជានុសយោ សង្ខារ-
ក្ខន្ធបរិយាបន្នោ ចិត្តសម្បយុត្តោតិ ។ ន ហេវំ វត្តព្វេ
។ បេ ។ អវិជ្ជានុសយោ សង្ខារក្ខន្ធបរិយាបន្នោ ចិត្ត-
វិប្បយុត្តោ អវិជ្ជា សង្ខារក្ខន្ធបរិយាបន្នា ចិត្តសម្ប-
យុត្តាតិ ។ អាមន្តា ។ សង្ខារក្ខន្ធោ ឯកទេសោ

អវិជ្ជា អវិជ្ជោឃៈ អវិជ្ជាយោគៈ ។ បេ ។ អវិជ្ជានីវរណៈ ប្រាសចាក
ចិត្តឬ ។ អើ ។ អវិជ្ជានុស័យ ប្រកបដោយចិត្តឬ ។ អ្នកមិនគួរពោល
យ៉ាងនេះទេ ។ បេ ។ អវិជ្ជានុស័យ ប្រាសចាកចិត្តឬ ។ អើ ។ អវិជ្ជា-
នុស័យ រាប់បញ្ចូលក្នុងខន្ធណា ។ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ។ សង្ខា-
រក្ខន្ធ ប្រាសចាកចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។
សង្ខារក្ខន្ធ ប្រាសចាកចិត្តឬ ។ អើ ។ វេទនាខន្ធ សញ្ញាខន្ធ ប្រាស
ចាកចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អវិជ្ជានុស័យ
ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រាសចាកចិត្តឬ ។ អើ ។ អវិជ្ជា ដែល
រាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រាសចាកចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះ
ទេ ។ បេ ។ អវិជ្ជា ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយចិត្តដែរ
ឬ ។ អើ ។ អវិជ្ជានុស័យ ដែលរាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយ
ចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អវិជ្ជានុស័យ ដែលរាប់
បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រាសចាកចិត្តឬ ចុះអវិជ្ជា ដែលរាប់បញ្ចូលក្នុង
សង្ខារក្ខន្ធ ប្រកបដោយចិត្តឬ ។ អើ ។ សង្ខារក្ខន្ធខ្លះ ប្រកបដោយចិត្ត

ចិត្តសម្បយុត្តោ ឯកទេសោ ចិត្តវិប្បយុត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សង្ខារក្ខន្ធោ ឯកទេសោ ចិត្តសម្បយុត្តោ ឯកទេសោ ចិត្តវិប្បយុត្តោតិ ។ អាមន្តា ។ វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ ឯកទេសោ ចិត្តសម្បយុត្តោ ឯកទេសោ ចិត្តវិប្បយុត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(១៧) ន វត្តព្វំ អនុសយា ចិត្តវិប្បយុត្តាតិ ។ អាមន្តា ។ បុថុជ្ជនោ កុសលាព្យាកតេ ចិត្តេ វត្តមានេ សានុសយោតិ វត្តព្វោតិ ។ អាមន្តា ។ អនុសយា តេន ចិត្តេន សម្បយុត្តាតិ ។ ន ហេវំ វត្តព្វេ ។ តេន ហិ អនុសយា ចិត្តវិប្បយុត្តាតិ ។ បុថុជ្ជនោ កុសលាព្យាកតេ ចិត្តេ វត្តមានេ សរាគោតិ វត្តព្វោតិ ។ អាមន្តា ។ រាគោ តេន ចិត្តេន សម្បយុត្តោតិ ។ ន ហេវំ វត្តព្វេ ។ តេន ហិ រាគោ ចិត្តវិប្បយុត្តោតិ ។

តិស្សោបិ អនុសយកថា ។

ខ្លះប្រាសចាកចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សង្ខារក្ខន្ធខ្លះ ប្រកបដោយចិត្ត ខ្លះប្រាសចាកចិត្តឬ ។ អើ ។ វេទនាខន្ធ សញ្ញាខន្ធខ្លះ ប្រកបដោយចិត្ត ខ្លះប្រាសចាកចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(១៧) បុគ្គលមិនគួរពោលថា អនុស័យ ប្រាសចាកចិត្តទេឬ ។ អើ ។ បុថុជ្ជន កាលបើចិត្ត ជាកុសលនិងអព្យាក្រឹត កំពុងប្រព្រឹត្តទៅ បុគ្គលគួរនិយាយថា ប្រកបដោយអនុស័យដែរឬ ។ អើ ។ អនុស័យ ប្រកបដោយចិត្តនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ អនុស័យ ប្រាសចាកចិត្ត ។ បុថុជ្ជន កាលបើចិត្ត ជាកុសលនិងអព្យាក្រឹត កំពុងប្រព្រឹត្តទៅ បុគ្គលគួរនិយាយថា ប្រកបដោយរាគៈដែរឬ ។ អើ ។ រាគៈ ប្រកបដោយចិត្តនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ព្រោះហេតុនោះ រាគៈ ប្រាសចាកចិត្ត ។

ចប់ តិស្សោបិ អនុសយកថា ។

(១៨) អញ្ញាណេ វិគតេ ញាណវិប្បយុត្តេ ចិត្តេ វត្តមានេ ន វត្តព្វំ ញាណីតិ ។ អាមន្តា ។ រាគេ វិគតេ ន វត្តព្វំ វីតរាគោតិ ។ ន ហេវំ វត្តព្វេ ។បេ។ អញ្ញាណេ វិគតេ ញាណវិប្បយុត្តេ ចិត្តេ វត្តមានេ ន វត្តព្វំ ញាណីតិ ។ អាមន្តា ។ ទោសេ វិគតេ ។បេ។ មោហេ វិគតេ ។បេ។ កិលេសេ វិគតេ ន វត្តព្វំ និក្កិលេសោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(១៩) រាគេ វិគតេ វត្តព្វំ វីតរាគោតិ ។ អាមន្តា ។ អញ្ញាណេ វិគតេ ញាណវិប្បយុត្តេ ចិត្តេ វត្តមានេ វត្តព្វំ ញាណីតិ ។ ន ហេវំ វត្តព្វេ ។បេ។ ទោសេ វិគតេ ។បេ។ មោហេ វិគតេ ។បេ។ កិលេសេ វិគតេ វត្តព្វំ និក្កិលេសោតិ ។ អាមន្តា ។

ញាណកថា

(១៨) កាលបើសេចក្តីមិនដឹង ប្រាសចេញហើយ មានតែចិត្តដែលប្រាសចាកញាណ កំពុងប្រព្រឹត្តទៅ បុគ្គល មិនគួរនិយាយថា មានញាណទេឬ ។ អើ ។ កាលបើរាគៈ ប្រាសចេញហើយ បុគ្គលមិនគួរនិយាយថា មានរាគៈទៅប្រាសហើយទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កាលបើសេចក្តីមិនដឹង ប្រាសចេញហើយ មានតែចិត្តដែលប្រាសចាកញាណ កំពុងប្រព្រឹត្តទៅ បុគ្គលមិនគួរនិយាយថា មានញាណទេឬ ។ អើ ។ កាលបើទោសៈ ប្រាសចេញហើយ ។ បេ ។ កាលបើមោហៈ ប្រាសចេញហើយ ។ បេ ។ កាលបើកិលេស ប្រាសចេញហើយ បុគ្គលមិនគួរនិយាយថា មិនមានកិលេសទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(១៩) កាលបើរាគៈ ប្រាសចេញហើយ បុគ្គលគួរនិយាយថា មានរាគៈទៅប្រាសហើយឬ ។ អើ ។ កាលបើសេចក្តីមិនដឹង ប្រាសចេញហើយ មានតែចិត្តដែលប្រាសចាកញាណ កំពុងប្រព្រឹត្តទៅ បុគ្គលគួរនិយាយថា មានញាណដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កាលបើទោសៈ ប្រាសចេញហើយ ។ បេ ។ កាលបើមោហៈ ប្រាសចេញហើយ ។ បេ ។ កាលបើកិលេស ប្រាសចេញហើយ បុគ្គលគួរនិយាយថា មិនមានកិលេសទេឬ ។ អើ ។

អញ្ញាណេ វិគតេ ញាណវិប្បយុត្តេ ចិត្តេ វត្តមានេ វត្តព្វំ ញាណីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អញ្ញាណេ វិគតេ ញាណវិប្បយុត្តេ ចិត្តេ វត្តមានេ វត្តព្វំ ញាណីតិ ។ អាមន្តា ។ អតីតេន ញាណេន ញាណី និរុទ្ធេន វិគតេន បដិប្បស្សទ្ធេន ញាណេន ញាណីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ញាណកថា ។

ញាណំ ចិត្តវិប្បយុត្តិកថា

(២០) ញាណំ ចិត្តវិប្បយុត្តន្តិ ។ អាមន្តា ។ រូបំ និព្វានំ ចក្ខាយតនំ ។ បេ ។ ផោដ្ឋព្វាយតនន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ញាណំ ចិត្តវិប្បយុត្តន្តិ ។ អាមន្តា ។ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញាពលំ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គោ ចិត្តវិប្បយុត្តោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញាពលំ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គោ ចិត្តសម្បយុត្តោតិ ។ អាមន្តា ។ ញាណំ ចិត្តសម្បយុត្តន្តិ ។ ន ហេវំ វត្តព្វេ ។បេ។

កាលបើសេចក្ដីមិនដឹង ប្រាសចេញហើយ មានតែចិត្តដែលប្រាសចាកញាណ កំពុងប្រព្រឹត្តទៅ បុគ្គលគួរនិយាយថា មានញាណដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ កាលបើសេចក្ដីមិនដឹង ប្រាសចេញហើយ មានតែចិត្តដែលប្រាសចាកញាណ កំពុងប្រព្រឹត្តទៅ បុគ្គលគួរនិយាយថា មានញាណដែរឬ ។ អើ ។ បុគ្គលមានញាណ ដោយញាណ ជាអតីត មានញាណដោយញាណ ដែលរលត់ហើយ ប្រាសចេញហើយ ស្ងប់រម្ងាប់ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ចប់ ញាណកថា ។

ញាណ ចិត្តវិប្បយុត្តិកថា

(២០) ញាណ ប្រាសចាកចិត្តឬ ។ អើ ។ រូប និព្វាន ចក្ខាយតនៈ ។ បេ ។ ផោដ្ឋព្វាយតនៈ (ប្រាសចាកចិត្ត) ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ញាណ ប្រាសចាកចិត្តដែរឬ ។ អើ ។ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពលៈ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គៈ ប្រាសចាកចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពលៈ សម្មាទិដ្ឋិ ធម្មវិចយសម្ពោជ្ឈង្គៈ ប្រកបដោយចិត្តឬ ។ អើ ។ ញាណប្រកបដោយចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦១) ញាណំ ចិត្តវិប្បយុត្តំ ។ អាមន្តា ។ ញាណំ កតមក្ខន្ធបរិយាបន្នំ ។ សង្ខារក្ខន្ធបរិយាបន្នំ ។ សង្ខារក្ខន្ធោ ចិត្តវិប្បយុត្តោ ។ ន ហេវំ វត្តព្វេ ។ បេ ។ សង្ខារក្ខន្ធោ ចិត្តវិប្បយុត្តោ ។ អាមន្តា ។ វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ ចិត្តវិប្បយុត្តោ ។ ន ហេវំ វត្តព្វេ ។ បេ ។ ញាណំ សង្ខារក្ខន្ធបរិយាបន្នំ ចិត្តវិប្បយុត្តំ ។ អាមន្តា ។ បញ្ញា សង្ខារក្ខន្ធបរិយាបន្នា ចិត្តវិប្បយុត្តា ។ ន ហេវំ វត្តព្វេ ។ បេ ។ បញ្ញា សង្ខារក្ខន្ធបរិយាបន្នា ចិត្តសម្បយុត្តា ។ អាមន្តា ។ ញាណំ សង្ខារក្ខន្ធបរិយាបន្នំ ចិត្តសម្បយុត្តំ ។ ន ហេវំ វត្តព្វេ ។ បេ ។ ញាណំ សង្ខារក្ខន្ធបរិយាបន្នំ ចិត្តវិប្បយុត្តំ បញ្ញា សង្ខារក្ខន្ធបរិយាបន្នា ចិត្តសម្បយុត្តា ។ អាមន្តា ។ សង្ខារក្ខន្ធោ ឯកទេសោ ចិត្តសម្បយុត្តោ ឯកទេសោ ចិត្តវិប្បយុត្តោ ។ ន ហេវំ វត្តព្វេ ។ បេ ។ សង្ខារក្ខន្ធោ ឯកទេសោ ចិត្តសម្បយុត្តោ ឯកទេសោ ចិត្តវិប្បយុត្តោ ។ អាមន្តា ។ វេទនាក្ខន្ធោ សញ្ញាក្ខន្ធោ ឯកទេសោ ចិត្តសម្បយុត្តោ ឯកទេសោ ចិត្តវិប្បយុត្តោ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦១) ញាណ ប្រាសចាកចិត្តឬ ។ អើ ។ ញាណ កប់បញ្ចូលក្នុងខន្ធណា ។ កប់បញ្ចូលក្នុងសង្ខារក្ខន្ធ ។ សង្ខារក្ខន្ធ ប្រាសចាកចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សង្ខារក្ខន្ធ ប្រាសចាកចិត្តឬ ។ អើ ។ វេទនាខន្ធ សញ្ញាខន្ធ ប្រាសចាកចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ញាណដែលកប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រាសចាកចិត្តដែរឬ ។ អើ ។ បញ្ញាដែលកប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រាសចាកចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បញ្ញាដែលកប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយចិត្តដែរឬ ។ អើ ។ ញាណដែលកប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយចិត្តដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ញាណដែលកប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រាសចាកចិត្តហើយ ចុះបញ្ញាដែលកប់បញ្ចូលក្នុងសង្ខារក្ខន្ធ ប្រកបដោយចិត្តឬ ។ អើ ។ សង្ខារក្ខន្ធខ្លះ ប្រកបដោយចិត្ត ខ្លះប្រាសចាកចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សង្ខារក្ខន្ធខ្លះ ប្រកបដោយចិត្ត ខ្លះប្រាសចាកចិត្តឬ ។ អើ ។ វេទនាខន្ធ សញ្ញាខន្ធខ្លះ ប្រកបដោយចិត្ត ខ្លះប្រាសចាកចិត្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(២២) ន វត្តព្វំ ញាណំ ចិត្តវិប្បយុត្តន្តិ ។ អាមន្តា ។ អរហា ចក្ខុវិញ្ញាណសមង្គី ញាណីតិ វត្តព្វោតិ ។ អាមន្តា ។ ញាណំ តេន ចិត្តេន សម្បយុត្តន្តិ ។ ន ហេវំ វត្តព្វេ ។ តេន ហិ ញាណំ ចិត្តវិប្បយុត្តន្តិ ។ អរហា ចក្ខុវិញ្ញាណសមង្គី បញ្ញវាតិ វត្តព្វោតិ ។ អាមន្តា ។ បញ្ញា តេន ចិត្តេន សម្បយុត្តាតិ ។ ន ហេវំ វត្តព្វេ ។ តេន ហិ បញ្ញា ចិត្តវិប្បយុត្តាតិ ។

ញាណំ ចិត្តវិប្បយុត្តន្តិកថា ។

ឥទំ ទុក្ខន្តិកថា

(២៣) ឥទំ ទុក្ខន្តិ វាចំ ភាសតោ ឥទំ ទុក្ខន្តិ ញាណំ បវត្តតីតិ ។ អាមន្តា ។ អយំ សមុទយោតិ វាចំ ភាសតោ អយំ សមុទយោតិ ញាណំ បវត្តតីតិ ។ ន ហេវំ វត្តព្វេ ។បេ។ ឥទំ ទុក្ខន្តិ វាចំ ភាសតោ ឥទំ ទុក្ខន្តិ ញាណំ បវត្តតីតិ ។ អាមន្តា ។ អយំ និរោធោតិ វាចំ ភាសតោ អយំ និរោធោតិ ញាណំ បវត្តតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(២២) បុគ្គលមិនគួរនិយាយថា ញាណ ប្រាសចាកចិត្តទេឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយចក្ខុវិញ្ញាណ បុគ្គលគួរនិយាយថា មានញាណដែរឬ ។ អើ ។ ញាណ ប្រកបដោយចិត្តនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ ញាណ ប្រាសចាកចិត្ត ។ ព្រះអរហន្ត ប្រកបដោយចក្ខុវិញ្ញាណ បុគ្គលគួរនិយាយថា មានបញ្ញាដែរឬ ។ អើ ។ បញ្ញា ប្រកបដោយចិត្តនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ បញ្ញា ប្រាសចាកចិត្ត ។

ចប់ ញាណចិត្តវិប្បយុត្តន្តិកថា ។

ឥទំ ទុក្ខន្តិកថា

(២៣) បុគ្គលកាលនិយាយវាចាថា នេះជាទុក្ខ ញាណប្រព្រឹត្តទៅថា នេះជាទុក្ខដែរឬ ។ អើ ។ បុគ្គលកាលនិយាយវាចាថា នេះជាហេតុនាំឲ្យកើតទុក្ខ ញាណ ប្រព្រឹត្តទៅថា នេះជាហេតុនាំឲ្យកើតទុក្ខដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលកាលនិយាយវាចាថា នេះជាទុក្ខ ញាណ ប្រព្រឹត្តទៅថា នេះជាទុក្ខដែរឬ ។ អើ ។ បុគ្គលកាលនិយាយវាចាថា នេះជាទីរលត់ទុក្ខ ញាណ ប្រព្រឹត្តទៅថា នេះជាទីរលត់ទុក្ខដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ឥទំ ទុក្ខន្តិ ភណំ ភាសតោ ឥទំ ទុក្ខន្តិ ញាណំ បវត្តតីតិ ។ អាមន្តា ។ អយំ មគ្គោតិ ភណំ ភាសតោ អយំ មគ្គោតិ ញាណំ បវត្តតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(២៤) អយំ សមុទយោតិ ភណំ ភាសតោ ន ច អយំ សមុទយោតិ ញាណំ បវត្តតីតិ ។ អាមន្តា ។ ឥទំ ទុក្ខន្តិ ភណំ ភាសតោ ន ច ឥទំ ទុក្ខន្តិ ញាណំ បវត្តតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អយំ និរោធោតិ ។ បេ ។ អយំ មគ្គោតិ ភណំ ភាសតោ ន ច អយំ មគ្គោតិ ញាណំ បវត្តតីតិ ។ អាមន្តា ។ ឥទំ ទុក្ខន្តិ ភណំ ភាសតោ ន ច ឥទំ ទុក្ខន្តិ ញាណំ បវត្តតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(២៥) ឥទំ ទុក្ខន្តិ ភណំ ភាសតោ ឥទំ ទុក្ខន្តិ ញាណំ បវត្តតីតិ ។ អាមន្តា ។ រូបំ អនិច្ចន្តិ ភណំ ភាសតោ រូបំ អនិច្ចន្តិ ញាណំ បវត្តតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ឥទំ ទុក្ខន្តិ ភណំ ភាសតោ ឥទំ ទុក្ខន្តិ ញាណំ បវត្តតីតិ ។ អាមន្តា ។

បុគ្គលកាលនិយាយកថាថា នេះជាទុក្ខ ញាណ ប្រព្រឹត្តទៅថា នេះជាទុក្ខដែរឬ ។ អើ ។ បុគ្គលកាលនិយាយកថាថា នេះជាមគ្គ ញាណ ប្រព្រឹត្តទៅថា នេះជាមគ្គដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(២៦) បុគ្គលកាលនិយាយកថាថា នេះជាហេតុនាំឲ្យកើតទុក្ខ តែញាណ មិនប្រព្រឹត្តទៅថា នេះជាហេតុនាំឲ្យកើតទុក្ខឬ ។ អើ ។ បុគ្គលកាលនិយាយកថាថា នេះជាទុក្ខ តែញាណ មិនប្រព្រឹត្តទៅថា នេះជាទុក្ខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលកាលនិយាយកថាថា នេះជាទីរលត់ទុក្ខ ។ បេ ។ នេះជាមគ្គ តែញាណ មិនប្រព្រឹត្តទៅថា នេះជាមគ្គឬ ។ អើ ។ បុគ្គលកាលនិយាយកថាថា នេះជាទុក្ខ តែញាណ មិនប្រព្រឹត្តទៅថា នេះជាទុក្ខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(២៧) បុគ្គលកាលនិយាយកថាថា នេះជាទុក្ខ ញាណ ប្រព្រឹត្តទៅថា នេះជាទុក្ខដែរឬ ។ អើ ។ បុគ្គលកាលនិយាយកថាថា រូបមិនទៀង ញាណ ប្រព្រឹត្តទៅថា រូបមិនទៀងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលកាលនិយាយកថាថា នេះជាទុក្ខ ញាណ ប្រព្រឹត្តទៅថា នេះជាទុក្ខដែរឬ ។ អើ ។

វេទនំ ។ បេ ។ សញ្ញំ សង្ខារេ ។ បេ ។ វិញ្ញាណំ អនិច្ចន្តិ វាចំ ភាសតោ វិញ្ញាណំ អនិច្ចន្តិ ញាណំ បវត្តតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៦) ឥទំ ទុក្ខន្តិ វាចំ ភាសតោ ឥទំ ទុក្ខន្តិ ញាណំ បវត្តតីតិ ។ អាមន្តា ។ រូបំ អនត្តាតិ វាចំ ភាសតោ រូបំ អនត្តាតិ ញាណំ បវត្តតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ឥទំ ទុក្ខន្តិ វាចំ ភាសតោ ឥទំ ទុក្ខន្តិ ញាណំ បវត្តតីតិ ។ អាមន្តា ។ វេទនា ។ បេ ។ សញ្ញា ។ បេ ។ សង្ខារា ។ បេ ។ វិញ្ញាណំ អនត្តាតិ វាចំ ភាសតោ វិញ្ញាណំ អនត្តាតិ ញាណំ បវត្តតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦៧) រូបំ អនិច្ចន្តិ វាចំ ភាសតោ ន ច រូបំ អនិច្ចន្តិ ញាណំ បវត្តតីតិ ។ អាមន្តា ។ ឥទំ ទុក្ខន្តិ វាចំ ភាសតោ ន ច ឥទំ ទុក្ខន្តិ ញាណំ បវត្តតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ វេទនា ។ បេ ។ សញ្ញា ។ បេ ។ សង្ខារា ។ បេ ។ វិញ្ញាណំ អនិច្ចន្តិ

បុគ្គលកាលនិយាយពាក្យថា វេទនា ។ បេ ។ សញ្ញា សង្ខារ ។ បេ ។ វិញ្ញាណ មិនទៀង ញាណ ប្រព្រឹត្តទៅថា វិញ្ញាណ មិនទៀងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៦) បុគ្គលកាលនិយាយពាក្យថា នេះជាទុក្ខ ញាណ ប្រព្រឹត្តទៅថា នេះជាទុក្ខដែរឬ ។ អើ ។ បុគ្គលកាលនិយាយពាក្យថា រូបមិនមែនជារបស់ខ្លួន ញាណ ប្រព្រឹត្តទៅថា រូបមិនមែនជារបស់ខ្លួនដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលកាលនិយាយពាក្យថា នេះជាទុក្ខ ញាណ ប្រព្រឹត្តទៅថា នេះជាទុក្ខដែរឬ ។ អើ ។ បុគ្គលកាលនិយាយពាក្យថា វេទនា ។ បេ ។ សញ្ញា ។ បេ ។ សង្ខារ ។ បេ ។ វិញ្ញាណ មិនមែនជារបស់ខ្លួន ញាណ ប្រព្រឹត្តទៅថា វិញ្ញាណ មិនមែនជារបស់ខ្លួនដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៧) បុគ្គលកាលនិយាយពាក្យថា រូបមិនទៀង តែញាណ មិនប្រព្រឹត្តទៅថា រូបមិនទៀងទេឬ ។ អើ ។ បុគ្គលកាលនិយាយពាក្យថា នេះជាទុក្ខ តែញាណ មិនប្រព្រឹត្តទៅថា នេះជាទុក្ខឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលកាលនិយាយពាក្យថា វេទនា ។ បេ ។ សញ្ញា ។ បេ ។ សង្ខារ ។ បេ ។ វិញ្ញាណ មិនទៀង

វាចំ ភាសតោ ន ច វិញ្ញាណំ អនត្តាតិ ញាណំ បវត្តតីតិ ។ អាមន្តា ។ ឥទំ ទុក្ខន្តិ វាចំ ភាសតោ ន ច ឥទំ ទុក្ខន្តិ ញាណំ បវត្តតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ រូបំ អនត្តាតិ វាចំ ភាសតោ ន ច រូបំ អនត្តាតិ ញាណំ បវត្តតីតិ ។ អាមន្តា ។ ឥទំ ទុក្ខន្តិ វាចំ ភាសតោ ន ច ឥទំ ទុក្ខន្តិ ញាណំ បវត្តតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ វេទនា ។ បេ ។ សញ្ញា ។ បេ ។ សង្ខារា ។ បេ ។ វិញ្ញាណំ អនត្តាតិ វាចំ ភាសតោ ន ច វិញ្ញាណំ អនត្តាតិ ញាណំ បវត្តតីតិ ។ អាមន្តា ។ ឥទំ ទុក្ខន្តិ វាចំ ភាសតោ ន ច ឥទំ ទុក្ខន្តិ ញាណំ បវត្តតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(២៨) ឥទំ ទុក្ខន្តិ វាចំ ភាសតោ ឥទំ ទុក្ខន្តិ ញាណំ បវត្តតីតិ ។ អាមន្តា ។ ឥតិ ច ទន្តិ ច ទុតិ ច ខន្តិ ច ញាណំ បវត្តតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ឥទំ ទុក្ខន្តិកថា ។

តែញាណ មិនប្រព្រឹត្តទៅថា វិញ្ញាណមិនទៀងទេឬ ។ អើ ។ បុគ្គលកាលនិយាយពាក្យថា នេះជាទុក្ខ តែញាណ មិនប្រព្រឹត្តទៅថា នេះជាទុក្ខទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលកាលនិយាយពាក្យថា រូបមិនមែនជារបស់ខ្លួន តែញាណ មិនប្រព្រឹត្តទៅថា រូបមិនមែនជារបស់ខ្លួនទេឬ ។ អើ ។ បុគ្គលកាលនិយាយពាក្យថា នេះជាទុក្ខ តែញាណ មិនប្រព្រឹត្តទៅថា នេះជាទុក្ខទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលកាលនិយាយពាក្យថា វេទនា ។ បេ ។ សញ្ញា ។ បេ ។ សង្ខារ ។ បេ ។ វិញ្ញាណ មិនមែនជារបស់ខ្លួន តែញាណ មិនប្រព្រឹត្តទៅថា វិញ្ញាណមិនមែនជារបស់ខ្លួនទេឬ ។ អើ ។ បុគ្គលកាលនិយាយពាក្យថា នេះជាទុក្ខ តែញាណ មិនប្រព្រឹត្តទៅថា នេះជាទុក្ខទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(២៨) បុគ្គលកាលនិយាយពាក្យថា ឥទំ ទុក្ខំ (នេះជាទុក្ខ) ញាណ ប្រព្រឹត្តទៅថា ឥទំ ទុក្ខំ (នេះជាទុក្ខ) ដែរឬ ។ អើ ។ ញាណ ប្រព្រឹត្តទៅថា ឥ ផង ថា ទំ ផង ថា ទុ ផង ថា ខំ ផងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ ឥទំ ទុក្ខន្តិកថា ។

ឥទ្ធិពលកថា

(៤៩) ឥទ្ធិពលេន សមន្នាគតោ កប្បំ តិដ្ឋេយ្យាតិ ។ អាមន្តា ។ ឥទ្ធិមយិកោ សោ អាយុ ឥទ្ធិមយិកា សា គតិ ឥទ្ធិមយិកោ សោ អត្តភាវប្បដិលាភោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ឥទ្ធិពលេន សមន្នាគតោ កប្បំ តិដ្ឋេយ្យាតិ ។ អាមន្តា ។ អតីតំ កប្បំ តិដ្ឋេយ្យ អនាគតំ កប្បំ តិដ្ឋេយ្យាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ឥទ្ធិពលេន សមន្នាគតោ កប្បំ តិដ្ឋេយ្យាតិ ។ អាមន្តា ។ ទ្វេ កប្បេ តិដ្ឋេយ្យ តយោ កប្បេ តិដ្ឋេយ្យ ចត្តារោ កប្បេ តិដ្ឋេយ្យាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ឥទ្ធិពលេន សមន្នាគតោ កប្បំ តិដ្ឋេយ្យាតិ ។ អាមន្តា ។ សតិ ជីវិតេ ជីវិតាវសេសេ តិដ្ឋេយ្យ អសតិ ជីវិតេ ជីវិតាវសេសេ តិដ្ឋេយ្យាតិ ។ សតិ ជីវិតេ ជីវិតាវសេសេ តិដ្ឋេយ្យាតិ ។ ហញ្ចិ សតិ ជីវិតេ ជីវិតាវសេសេ តិដ្ឋេយ្យ នោ វត រេ វត្តព្វេ ឥទ្ធិពលេន សមន្នាគតោ កប្បំ តិដ្ឋេយ្យាតិ ។ បេ ។ អសតិ ជីវិតេ ជីវិតាវសេសេ តិដ្ឋេយ្យាតិ ។ មរណំ តិដ្ឋេយ្យ កាលកតោ តិដ្ឋេយ្យាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ឥទ្ធិពលកថា

(៤៩) បុគ្គល ប្រកបដោយកម្លាំងឫទ្ធិ គប្បីឋិតនៅអស់កប្ប (មហាកប្ប) ឬ ។ អើ ។ អាយុដែលសម្រេចដោយឫទ្ធិនោះ គតិដែលសម្រេចដោយឫទ្ធិនោះ ការបាននូវអត្តភាពដែលសម្រេចដោយឫទ្ធិនោះ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ប្រកបដោយកម្លាំងឫទ្ធិ គប្បីឋិតនៅអស់កប្បឬ ។ អើ ។ បុគ្គល គប្បីឋិតនៅអស់កប្បជាអតីត គប្បីឋិតនៅអស់កប្បជាអនាគតឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ប្រកបដោយកម្លាំងឫទ្ធិ គប្បីឋិតនៅអស់កប្បឬ ។ អើ ។ បុគ្គល គប្បីឋិតនៅអស់ ២ កប្ប គប្បីឋិតនៅអស់ ៣ កប្ប គប្បីឋិតនៅអស់ ៤ កប្បដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ប្រកបដោយកម្លាំងឫទ្ធិ គប្បីឋិតនៅអស់កប្បឬ ។ អើ ។ បុគ្គល កាលបើជីវិតមាននៅ គប្បីឋិតនៅអស់ជីវិតដ៏សេសសល់ កាលបើជីវិតមិនមានទេ គប្បីឋិតនៅអស់ជីវិតដ៏សេសសល់ ។ បុគ្គលកាលបើជីវិតមាន គប្បីឋិតនៅអស់ជីវិតដ៏សេសសល់ ។ ប្រសិនបើ បុគ្គល កាលបើជីវិតមាននៅ គប្បីឋិតនៅអស់ជីវិតដ៏សេសសល់ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល ប្រកបដោយកម្លាំងឫទ្ធិ គប្បីឋិតនៅអស់កប្បទេ ។ បេ ។ បុគ្គល កាលបើជីវិតមិនមានទេ គប្បីឋិតនៅអស់ជីវិតដ៏សេសសល់ ។ មានតែបុគ្គលស្លាប់ហើយ គប្បីឋិតនៅ បុគ្គល មានមរណកាលធ្វើហើយ គប្បីឋិតនៅដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣០) ឥទ្ធិពលេន សមន្នាគតោ កប្បំ តិដ្ឋេយ្យាតិ ។ អាមន្តា ។ ឧប្បន្នោ ផស្សោ មា និរុជ្ឈីតិ លព្ភា ឥទ្ធិយា បគ្គហេតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ឧប្បន្នា វេទនា ។ បេ ។ ឧប្បន្នា សញ្ញា ។ បេ ។ ឧប្បន្នា ចេតនា ។ បេ ។ ឧប្បន្នំ ចិត្តំ ឧប្បន្នា សទ្ធា ឧប្បន្នំ វីរិយំ ឧប្បន្នា សតិ ឧប្បន្នោ សមាធិ ។ បេ ។ ឧប្បន្នា បញ្ញា មា និរុជ្ឈីតិ លព្ភា ឥទ្ធិយា បគ្គហេតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣១) ឥទ្ធិពលេន សមន្នាគតោ កប្បំ តិដ្ឋេ-យ្យាតិ ។ អាមន្តា ។ រូបំ និច្ចំ ហោតូតិ លព្ភា ឥទ្ធិយា បគ្គហេតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ វេទនា ។ បេ ។ សញ្ញា ។ បេ ។ សង្ខារា ។ បេ ។ វិញ្ញាណំ និច្ចំ ហោតូតិ លព្ភា ឥទ្ធិយា បគ្គហេតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣២) ឥទ្ធិពលេន សមន្នាគតោ កប្បំ តិដ្ឋេយ្យាតិ ។

(៣០) បុគ្គល ប្រកបដោយកម្លាំងឫទ្ធិ គប្បីឋិតនៅអស់កប្បដែរឬ ។ អើ ។ ផស្សៈកើតឡើងហើយ បុគ្គល គប្បីបាន ដើម្បីផ្គងឡើង ដោយឫទ្ធិថា កុំរលត់ទៅវិញដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វេទនាកើតឡើងហើយ ។ បេ ។ សញ្ញាកើតឡើងហើយ ។ បេ ។ ចេតនាកើតឡើងហើយ ។ បេ ។ ចិត្តកើតឡើងហើយ សទ្ធាកើតឡើងហើយ វីរិយៈកើតឡើងហើយ សតិកើតឡើងហើយ សមាធិកើតឡើងហើយ ។ បេ ។ បញ្ញាកើតឡើងហើយ បុគ្គល គប្បីបាន ដើម្បីផ្គងឡើង ដោយឫទ្ធិថា កុំរលត់ទៅវិញឡើយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣១) បុគ្គល ប្រកបដោយកម្លាំងឫទ្ធិ គប្បីឋិតនៅអស់កប្បឬ ។ អើ ។ រូប បុគ្គលគប្បីបាន ដើម្បីផ្គងឡើង ដោយឫទ្ធិថា ចូរទៀងចុះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វេទនា ។ បេ ។ សញ្ញា ។ បេ ។ សង្ខារ ។ បេ ។ វិញ្ញាណ បុគ្គលគប្បីបាន ដើម្បីផ្គងឡើង ដោយឫទ្ធិថា ចូរទៀងចុះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣២) បុគ្គលប្រកបដោយកម្លាំងឫទ្ធិ គប្បីឋិតនៅអស់កប្បដែរឬ ។

កាលប្បោ ។ ជាតិធម្មា សត្តា មា ជាយឹសូតិ លព្ភា ឥទ្ធិយា បត្តហេតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ជរាធម្មា សត្តា មា ជីរីសូតិ ។ បេ ។ ព្យាធិធម្មា សត្តា មា ព្យាធិយីសូតិ ។ បេ ។ មរណធម្មា សត្តា មា មិយ្យីសូតិ លព្ភា ឥទ្ធិយា បត្តហេតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៣) ន វត្តព្វំ ឥទ្ធិពលេន សមន្នាគតោ កប្បំ តិដ្ឋេយ្យាតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា យស្ស កស្សចិ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា សោ អាកង្ខមានោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វាតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ឥទ្ធិពលេន សមន្នាគតោ កប្បំ តិដ្ឋេយ្យាតិ ។

(៣៤) ឥទ្ធិពលេន សមន្នាគតោ កប្បំ តិដ្ឋេយ្យាតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ចតុន្នំ ភិក្ខវេ ធម្មានំ នត្ថិ កោចិ បាដិភោគោ សមណោ វា ព្រាហ្មណោ វា ទេវោ វា មារោ វា

ឥទ្ធិពលកថា

ហើ ។ ពួកសត្វមានកិរិយាកើតជាធម្មតា បុគ្គលគប្បីបាន ដើម្បីផ្សះឡើង ដោយឫទ្ធិថា កុំកើតឡើយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពួកសត្វមានសេចក្ដីគ្រាំគ្រាជាធម្មតាថា កុំគ្រាំគ្រាទៅឡើយ ។ បេ ។ ពួកសត្វមានសេចក្ដីឈឺចាប់ជាធម្មតាថា កុំឈឺចាប់ឡើយ ។ បេ ។ ពួកសត្វមានសេចក្ដីស្លាប់ជាធម្មតា បុគ្គលគប្បីបាន ដើម្បីផ្សង់ឡើងដោយឫទ្ធិថា កុំស្លាប់ឡើយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៣) បុគ្គលមិនគួរនិយាយថា បុគ្គល ប្រកបដោយកម្លាំងឫទ្ធិ គប្បីឋិតនៅអស់កប្បទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ ឥទ្ធិបាទទាំង៤ បុគ្គលណាមួយ បានបម្រើន បានធ្វើឲ្យច្រើន បានឲ្យប្រព្រឹត្តទៅ បានធ្វើឲ្យជាទីតាំង បានដ្ឋនឡើង បានសន្សំ បានប្រារព្ធដោយល្អហើយ បុគ្គលនោះ កាលប្រាថ្នា គប្បីឋិតនៅអស់ ១កប្ប ឬ អស់កប្បដ៏សេសសល់បាន ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បុគ្គល ដែលប្រកបដោយកម្លាំងឫទ្ធិ គប្បីឋិតនៅអស់កប្បបាន ។

(៣៤) បុគ្គល ប្រកបដោយកម្លាំងឫទ្ធិ គប្បីឋិតនៅអស់កប្បឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មិនមានបុគ្គលទីមួយ ទោះជាសមណៈក្ដី ព្រាហ្មណ៍ក្ដី ទេវតាក្ដី មារក្ដី

ព្រហ្មុនា វា កេនចិ វា លោកស្មឹ ។ កតមេសំ
ចតុន្នំ ។ ជរាធម្មំ មា ជីរីតិ នត្ថិ កោចិ បាដិ-
ភោគោ សមណោ វា ព្រាហ្មណោ វា ទេវោ វា
មារោ វា ព្រហ្មា វា កោចិ វា លោកស្មឹ ព្យាធិ-
ធម្មំ មា ព្យាធិយីតិ ។ បេ ។ មរណធម្មំ មា
មិយ្យីតិ ។ បេ ។ យានិ ខោ បន តានិ បុព្វេ
កតានិ បាបកានិ កម្មានិ សង្កិលេសិកានិ បោ-
នោព្ភវិកានិ ទុក្ខុទ្រយានិ ទុក្ខវិបាកានិ អាយតឹ
ជាតិជរាមរណិយានិ តេសំ វិបាកោ មា និព្វត្តីតិ
នត្ថិ កោចិ បាដិភោគោ សមណោ វា ព្រាហ្មណោ វា
ទេវោ វា មារោ វា ព្រហ្មា វា កោចិ វា លោកស្មឹ
ឥមេសំ ខោ ភិក្ខវេ ចតុន្នំ ឋានានំ នត្ថិ កោចិ
បាដិភោគោ សមណោ វា ព្រាហ្មណោ វា ទេវោ វា
មារោ វា ព្រហ្មា វា កោចិ វា លោកស្មិន្តិ អត្ថេវ
សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ
ឥទ្ធិពលេន សមន្នាគតោ កប្បំ តិដ្ឋេយ្យាតិ ។

ឥទ្ធិពលកថា ។

ព្រហ្មក្ដី ឬក៏ បុគ្គលឯណាមួយ ក្នុងលោក ជាអ្នកធានា ដល់ធម៌ទាំង
៤ បានឡើយ ។ ធម៌ទាំង ៤ តើដូចម្ដេច ។ មិនមានបុគ្គលណាទីមួយ
ទោះជាសមណៈក្ដី ព្រាហ្មណ៍ក្ដី ទេវតាក្ដី មារក្ដី ព្រហ្មក្ដី ឬក៏ បុគ្គលឯ
ណាមួយក្នុងលោក ជាអ្នកធានាថា សភាវៈមានសេចក្ដីគ្រាំគ្រាជាធម្មតា
កុំគ្រាំគ្រាឡើយ សភាវៈមានសេចក្ដីឈឺចាប់ជាធម្មតា កុំឈឺចាប់ឡើយ
។ បេ ។ សភាវៈមានសេចក្ដីស្លាប់ជាធម្មតា កុំស្លាប់ឡើយ ។ បេ ។
កម្មដ៏លាមកទាំងឡាយឯណា ដែលបុគ្គលធ្វើហើយក្នុងកាលមុន ជាកម្ម
ប្រកបដោយសេចក្ដីសៅហ្មង អាចធ្វើឲ្យទៅកើតក្នុងភពថ្មីទៀត មានទុក្ខជា
កម្រៃ មានវិបាកជាទុក្ខ មានជាតិជរានិងមរណៈតទៅ មិនមាន បុគ្គល
ណាទីមួយ ទោះជាសមណៈក្ដី ព្រាហ្មណ៍ក្ដី ទេវតាក្ដី មារក្ដី ព្រហ្ម
ក្ដី ឬក៏ បុគ្គលឯណាមួយ ក្នុងលោក ជាអ្នកធានាថា វិបាករបស់បាប-
កម្មទាំងនោះ កុំកើតបានឡើយ ម្នាលភិក្ខុទាំងឡាយ មិនមានបុគ្គលណា
ទីមួយ ទោះជាសមណៈក្ដី ព្រាហ្មណ៍ក្ដី ទេវតាក្ដី មារក្ដី ព្រហ្មក្ដី ឬក៏
បុគ្គលឯណាមួយ ក្នុងលោក ជាអ្នកធានា ដល់ធម៌ទាំង៤នេះឡើយ
ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរ
ពោលថា បុគ្គល ប្រកបដោយកម្លាំងឫទ្ធិ គប្បីឋិតនៅអស់កប្បឡើយ ។

ចប់ ឥទ្ធិពលកថា ។

(៣៥) ចិត្តសន្តតិ សមាធីតិ ។ អាមន្តា ។ អតីតា ចិត្តសន្តតិ សមាធីតិ ។ ន ហេវំ វត្តព្វេ ។បេ។ ចិត្តសន្តតិ សមាធីតិ ។ អាមន្តា ។ អនាគតា ចិត្តសន្តតិ សមាធីតិ ។ ន ហេវំ វត្តព្វេ ។បេ។ ចិត្តសន្តតិ សមាធីតិ ។ អាមន្តា ។ ននុ អតីតំ និរុទ្ធំ អនាគតំ អជាតន្តិ ។ អាមន្តា ។ ហញ្ចិ អតីតំ និរុទ្ធំ អនាគតំ អជាតំ នោ វត រេ វត្តព្វេ ចិត្តសន្តតិ សមាធីតិ ។

(៣៦) ឯកចិត្តក្ខណិកោ សមាធីតិ ។ អាមន្តា ។ ចក្ខុវិញ្ញាណសមង្គី សមាបន្នោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សោតវិញ្ញាណសមង្គី ។ បេ ។ ឃានវិញ្ញាណសមង្គី ។ បេ ។ ជិវ្ហាវិញ្ញាណសមង្គី ។ បេ ។ កាយវិញ្ញាណសមង្គី ។ បេ ។ អកុសលចិត្តសមង្គី ។ បេ ។ រាគសហគតចិត្តសមង្គី ។ បេ ។ ទោសសហគតចិត្តសមង្គី ។ បេ ។ មោហសហគតចិត្តសមង្គី ។ បេ ។ អនោត្តប្បសហគតចិត្តសមង្គី សមាបន្នោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៥) តំណនៃចិត្ត ជាសមាធិឬ ។ អើ ។ តំណនៃចិត្ត ជាអតីត ជាសមាធិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ តំណនៃចិត្ត ជាសមាធិឬ ។ អើ ។ តំណនៃចិត្ត ជាអនាគត ជាសមាធិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ តំណនៃចិត្ត ជាសមាធិឬ ។ អើ ។ ក្រែងអតីតរលត់ហើយ អនាគតមិនទាន់កើតទេឬ ។ អើ ។ ប្រសិនបើ អតីតរលត់ហើយ អនាគតមិនទាន់កើតទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា តំណនៃចិត្ត ជាសមាធិទេ ។

(៣៦) សមាធិ ប្រកបដោយខណៈនៃចិត្តមួយឬ ។ អើ ។ បុគ្គល ប្រកបដោយចក្ខុវិញ្ញាណ ចូលកាន់សមាបត្តិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល ប្រកបដោយសោតវិញ្ញាណ ។បេ។ ប្រកបដោយឃានវិញ្ញាណ ។បេ។ ប្រកបដោយជិវ្ហាវិញ្ញាណ ។បេ។ ប្រកបដោយកាយវិញ្ញាណ ។បេ។ ប្រកបដោយអកុសលចិត្ត ។បេ។ ប្រកបដោយរាគសហគតចិត្ត ។បេ។ ប្រកបដោយទោសសហគតចិត្ត ។បេ។ ប្រកបដោយមោហសហគតចិត្ត ។បេ។ ប្រកបដោយអនោត្តប្បសហគតចិត្ត ចូលកាន់សមាបត្តិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៣៧) ចិត្តសន្តតិ សមាធីតិ ។ អាមន្តា ។ អកុសលចិត្តសន្តតិ សមាធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ រាគសហគតា ។ បេ ។ ទោសសហគតា ។ បេ ។ មោហសហគតា ។ បេ ។ អនោត្តប្បសហគតា ចិត្តសន្តតិ សមាធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៨) ន វត្តព្វំ ចិត្តសន្តតិ សមាធីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា អហំ ខោ អាវុសោ និគណ្ឋា បហោមិ អនិញ្ជមានោ កាយេន អភាសមានោ វាចំ សត្តរត្តិន្ទិវានិ ឯកន្តសុខប្បដិសំវេទី វិហរិតុន្តិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេនហិ ចិត្តសន្តតិ សមាធីតិ ។

សមាធិកថា ។

ធម្មដ្ឋិតតាកថា .

(៣៩) ធម្មដ្ឋិតតា បរិនិប្ផន្នាតិ ។ អាមន្តា ។ តាយ ឋិតតា បរិនិប្ផន្នាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តាយ ឋិតតា បរិនិប្ផន្នាតិ ។ អាមន្តា ។

(៣៧) តំណនៃចិត្ត ជាសមាធិឬ ។ អើ ។ តំណនៃអកុសលចិត្ត ជាសមាធិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ តំណនៃចិត្ត ដែលប្រកបដោយរាគៈ ។ បេ ។ ប្រកបដោយទោសៈ ។ បេ ។ ប្រកបដោយមោហៈ ។ បេ ។ ប្រកបដោយអនោត្តប្បៈ ជាសមាធិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៨) បុគ្គលមិនគួរនិយាយថា តំណនៃចិត្ត ជាសមាធិទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលអាវុសោនិគ្រន្ថទាំងឡាយ តថាគត មិនញាប់ញ័រដោយកាយ មិនពោលវាចា អាចដើម្បីនៅជាអ្នកទទួលសេចក្តីសុខតែម្យ៉ាង អស់យប់និងថ្ងៃទាំងឡាយ៧ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ តំណនៃចិត្ត ជាសមាធិ ។

ចប់ សមាធិកថា ។

ធម្មដ្ឋិតតាកថា

(៣៩) ធម្មដ្ឋិតតា (ការតាំងនៅនៃធម៌ គឺបដិច្ចសមុប្បាទ) សម្រេចឬ ។ អើ ។ ការតាំងនៅនៃធម្មដ្ឋិតតានោះ សម្រេចឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការតាំងនៅនៃធម្មដ្ឋិតតានោះ សម្រេចឬ ។ អើ ។

តាយ តាយេវ នត្ថិ ទុក្ខស្ស អន្តកិរិយា នត្ថិ វដ្ដុ-
បច្ឆេទោ នត្ថិ អនុបាទាបរិនិព្វានន្តិ ។ ន ហេវំ
វត្តព្វេ ។ បេ ។

(៤០) រូបស្ស ឋិតតា បរិនិប្ផន្នាតិ ។ អាមន្តា ។
តាយ ឋិតតា បរិនិប្ផន្នាតិ ។ ន ហេវំ វត្តព្វេ
។ បេ ។ តាយ ឋិតតា បរិនិប្ផន្នាតិ ។ អាមន្តា ។
តាយ តាយេវ នត្ថិ ទុក្ខស្ស អន្តកិរិយា នត្ថិ វដ្ដុ-
បច្ឆេទោ នត្ថិ អនុបាទាបរិនិព្វានន្តិ ។ ន ហេវំ វត្តព្វេ
។ បេ ។ វេទនាយ ឋិតតា ។ បេ ។ សញ្ញាយ
ឋិតតា ។ បេ ។ សង្ខារានំ ឋិតតា ។ បេ ។ វិញ្ញា-
ណស្ស ឋិតតា បរិនិប្ផន្នាតិ ។ អាមន្តា ។ តាយ ឋិត-
តា បរិនិប្ផន្នាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តាយ
ឋិតតា បរិនិប្ផន្នាតិ ។ អាមន្តា ។ តាយ តាយេវ
នត្ថិ ទុក្ខស្ស អន្តកិរិយា នត្ថិ វដ្ដុបច្ឆេទោ នត្ថិ
អនុបាទាបរិនិព្វានន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ធម្មដ្ឋិតតាកថា ។

ការធ្វើនូវទីបំផុតនៃទុក្ខ មិនមាន ការផ្តិលផ្តាច់នូវវដ្តៈ មិនមាន អនុបាទាបរិនិព្វាន មិនមាន ដល់ធម្មដ្ឋិតតានោះៗទេឬ ។ អ្នកមិនគួរពោល
យ៉ាងនេះទេ ។ បេ ។

(៤០) ការតាំងនៅនៃរូប សម្រេចឬ ។ អើ ។ ការតាំងនៅនៃ
ធម្មដ្ឋិតតានោះ សម្រេចដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។
ការតាំងនៅនៃធម្មដ្ឋិតតានោះ សម្រេចឬ ។ អើ ។ ការធ្វើនូវទីបំផុតនៃ
ទុក្ខ មិនមាន ការផ្តិលផ្តាច់នូវវដ្តៈ មិនមាន អនុបាទាបរិនិព្វាន មិនមាន
ដល់ការតាំងនៅនៃរូបនោះៗទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ
។ បេ ។ ការតាំងនៅនៃវេទនា ។ បេ ។ ការតាំងនៅនៃសញ្ញា ។ បេ ។
ការតាំងនៅនៃសង្ខារ ។ បេ ។ ការតាំងនៅនៃវិញ្ញាណ សម្រេចឬ ។
អើ ។ ការតាំងនៅនៃធម្មដ្ឋិតតានោះ សម្រេចដែរឬ ។ អ្នកមិនគួរ
ពោលយ៉ាងនេះទេ ។ បេ ។ ការតាំងនៅនៃធម្មដ្ឋិតតានោះ សម្រេចឬ ។
អើ ។ ការធ្វើនូវទីបំផុតនៃទុក្ខ មិនមាន ការផ្តិលផ្តាច់នូវវដ្តៈ មិនមាន
អនុបាទាបរិនិព្វាន មិនមាន ដល់ការតាំងនៅនៃវិញ្ញាណនោះៗទេឬ ។
អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ ធម្មដ្ឋិតតាកថា ។

(៤១) អនិច្ចតា បរិនិដ្ឋិតា ។ អាមន្តា ។ តាយ អនិច្ចតាយ អនិច្ចតា បរិនិដ្ឋិតាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តាយ អនិច្ចតាយ អនិច្ចតា បរិនិដ្ឋិតា ។ អាមន្តា ។ តាយ តាយេវ នត្ថិ ទុក្ខស្ស អន្តកិរិយា នត្ថិ វដ្ដុបច្ឆេទោ នត្ថិ អនុបាទាបរិនិព្វានន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤២) ជរា បរិនិដ្ឋិតា ។ អាមន្តា ។ ជរាយ ជរា បរិនិដ្ឋិតាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តាយ ជរាយ ជរា បរិនិដ្ឋិតា ។ អាមន្តា ។ តាយ តាយេវ នត្ថិ ទុក្ខស្ស អន្តកិរិយា នត្ថិ វដ្ដុបច្ឆេទោ នត្ថិ អនុបាទាបរិនិព្វានន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៣) មរណំ បរិនិដ្ឋិតំ ។ អាមន្តា ។ តស្ស មរណស្ស មរណំ បរិនិដ្ឋិតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តស្ស មរណស្ស មរណំ បរិនិដ្ឋិតំ ។ អាមន្តា ។ តស្ស តស្សេវ នត្ថិ ទុក្ខស្ស អន្តកិរិយា នត្ថិ វដ្ដុបច្ឆេទោ នត្ថិ អនុបាទាបរិនិព្វានន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤១) សេចក្តីមិនទៀង សម្រេចហើយឬ ។ អើ ។ សេចក្តីមិនទៀង នៃសេចក្តីមិនទៀងនោះ សម្រេចហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សេចក្តីមិនទៀង នៃសេចក្តីមិនទៀងនោះ សម្រេចហើយឬ ។ អើ ។ ការធ្វើនូវទីបំផុតនៃទុក្ខ មិនមាន ការផ្តិលផ្តាច់នូវវដ្ដៈ មិនមាន អនុបាទាបរិនិព្វាន មិនមាន ដល់សេចក្តីមិនទៀងនោះៗទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤២) ជរា សម្រេចហើយឬ ។ អើ ។ ជរា នៃជរានោះ សម្រេចហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ជរា នៃជរានោះ សម្រេចហើយឬ ។ អើ ។ ការធ្វើនូវទីបំផុតនៃទុក្ខ មិនមាន ការផ្តិលផ្តាច់នូវវដ្ដៈ មិនមាន អនុបាទាបរិនិព្វាន មិនមាន ដល់ជរានោះៗទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៣) មរណៈ សម្រេចហើយឬ ។ អើ ។ មរណៈ នៃមរណៈនោះ សម្រេចហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ មរណៈ នៃមរណៈនោះ សម្រេចហើយឬ ។ អើ ។ ការធ្វើនូវទីបំផុតនៃទុក្ខ មិនមាន ការផ្តិលផ្តាច់នូវវដ្ដៈ មិនមាន អនុបាទាបរិនិព្វាន មិនមាន ដល់មរណៈនោះៗទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៤) រូបំ បរិនិប្ផន្នំ រូបស្ស អនិច្ចតា អត្ថីតិ ។ អាមន្តា ។ អនិច្ចតា បរិនិប្ផន្នា អនិច្ចតាយ អនិច្ចតា អត្ថីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ រូបំ បរិនិប្ផន្នំ រូបស្ស ជរា អត្ថីតិ ។ អាមន្តា ។ ជរា បរិនិប្ផន្នា ជរាយ ជរា អត្ថីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ រូបំ បរិនិប្ផន្នំ រូបស្ស ភេទោ អត្ថិ អន្តរធានំ អត្ថីតិ ។ អាមន្តា ។ មរណំ បរិនិប្ផន្នំ មរណស្ស ភេទោ អត្ថិ អន្តរធានំ អត្ថីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ វេទនា ។ បេ ។ សញ្ញា ។ បេ ។ សង្ខារា ។ បេ ។ វិញ្ញាណំ បរិនិប្ផន្នំ វិញ្ញាណស្ស អនិច្ចតា អត្ថីតិ ។ អាមន្តា ។ អនិច្ចតា បរិនិប្ផន្នា អនិច្ចតាយ អនិច្ចតា អត្ថីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ វិញ្ញាណំ បរិនិប្ផន្នំ វិញ្ញាណស្ស ជរា អត្ថីតិ ។ អាមន្តា ។ ជរា បរិនិប្ផន្នា ជរាយ ជរា អត្ថីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ វិញ្ញាណំ បរិនិប្ផន្នំ វិញ្ញា-ណស្ស ភេទោ អត្ថិ អន្តរធានំ អត្ថីតិ ។ អាមន្តា ។

(៤៤) រូប សម្រេចហើយ ចុះសេចក្ដីមិនទៀង នៃរូប មានដែរឬ ។ អើ ។ សេចក្ដីមិនទៀង សម្រេចហើយ ចុះសេចក្ដីមិនទៀង នៃសេចក្ដីមិនទៀង មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ រូប សម្រេចហើយ ចុះជរា នៃរូប មានដែរឬ ។ អើ ។ ជរា សម្រេចហើយ ចុះជរា នៃជរា មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ រូប សម្រេចហើយ ចុះការបែកធ្លាយ និងសេចក្ដីអន្តរធាន នៃរូប មានដែរឬ ។ អើ ។ មរណៈ សម្រេចហើយ ចុះការបែកធ្លាយ និងសេចក្ដីអន្តរធាន នៃមរណៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វេទនា ។ បេ ។ សញ្ញា ។ បេ ។ សង្ខារ ។ បេ ។ វិញ្ញាណ សម្រេចហើយ ចុះសេចក្ដីមិនទៀង នៃវិញ្ញាណ មានដែរឬ ។ អើ ។ សេចក្ដីមិនទៀង សម្រេចហើយ ចុះសេចក្ដីមិនទៀង នៃសេចក្ដីមិនទៀង មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិញ្ញាណ សម្រេចហើយ ចុះជរា នៃវិញ្ញាណ មានដែរឬ ។ អើ ។ ជរា សម្រេចហើយ ចុះជរា នៃជរា មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិញ្ញាណ សម្រេចហើយ ចុះការបែកធ្លាយ និងសេចក្ដីអន្តរធាន នៃវិញ្ញាណ មានដែរឬ ។ អើ ។

មរណំ បរិច្ឆិន្ទតិ មរណាសន្នេ កាលេ អត្ថិ អន្តរាយោ

អត្ថីតិ ។ ឧ ហោរាំ វត្តព្វេ ។ បេ ។

អនិច្ចតាកថា ។

ឯកាទសមោ វគ្គោ ។

តស្សុទ្ទានំ

អនុសយា អព្យាកតា អហេតុកា ចិត្តវិប្បយុត្តា

អញ្ញាណេ វិគតេ ញាណី ញាណំ ចិត្តវិប្បយុត្តំ

យក្ខោ សទ្ទេ ញាណំ បវត្តតិ ឥទ្ធិពលេន សមន្នា-

គតោ កប្បំ តិដ្ឋេយ្យ ចិត្តសន្តតិ សមាធិ ធម្មដ្ឋិ-

តតា អនិច្ចតាតិ ។

មរណៈ សម្រេចហើយ ចុះការបែកធ្លាយ ខិនសេចក្តីអន្តរាយ នៃ

មរណៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ អនិច្ចតាកថា ។

ចប់ ឯកាទសមវគ្គ ។

ឧទ្ទាននៃឯកាទសមវគ្គនោះ គឺ

អនុស័យ ជាអព្យាក្រឹត ជាអហេតុកៈ ប្រាសចាកចិត្ត ១ កាលបើសេចក្តី

មិនដឹង ប្រាសចេញហើយ បុគ្គលមានញាណ ១ ញាណ ប្រាសចាក

ចិត្ត ១ ញាណ ប្រព្រឹត្តទៅក្នុងស័ព្ទណា ១ បុគ្គល ប្រកបដោយ

កម្លាំងនៃឫទ្ធិ គប្បីឋិតនៅអស់កប្ប ១ តំណនៃចិត្ត ជាសមាធិ ១

ធម្មដ្ឋិតតា ១ និងអនិច្ចតា ១ ។

(២៨) សំវរោ កម្មន្តិ ៗ អាមន្តា ៗ ចក្ខុន្ទ្រិយសំវរោ ចក្ខុកម្មន្តិ ៗ ន ហេវំ វត្តព្វេ ៗ បេ ៗ សោតិន្ទ្រិយសំវរោ ៗ បេ ៗ ឃានិន្ទ្រិយសំវរោ ៗ បេ ៗ ជិវ្ហិន្ទ្រិយសំវរោ ៗ បេ ៗ កាយិន្ទ្រិយសំវរោ កាយកម្មន្តិ ៗ ន ហេវំ វត្តព្វេ ៗ បេ ៗ កាយិន្ទ្រិយសំវរោ កាយកម្មន្តិ ៗ អាមន្តា ៗ ចក្ខុន្ទ្រិយសំវរោ ចក្ខុកម្មន្តិ ៗ ន ហេវំ វត្តព្វេ ៗ បេ ៗ កាយិន្ទ្រិយសំវរោ កាយកម្មន្តិ ៗ អាមន្តា ៗ សោតិន្ទ្រិយសំវរោ ៗ បេ ៗ ឃានិន្ទ្រិយសំវរោ ៗ បេ ៗ ជិវ្ហិន្ទ្រិយសំវរោ ជិវ្ហាកម្មន្តិ ៗ ន ហេវំ វត្តព្វេ ៗ បេ ៗ មនិន្ទ្រិយសំវរោ មនោកម្មន្តិ ៗ ន ហេវំ វត្តព្វេ ៗ បេ ៗ មនិន្ទ្រិយសំវរោ មនោកម្មន្តិ ៗ អាមន្តា ៗ ចក្ខុន្ទ្រិយសំវរោ ចក្ខុកម្មន្តិ ៗ ន ហេវំ វត្តព្វេ ៗ បេ ៗ មនិន្ទ្រិយសំវរោ មនោកម្មន្តិ ៗ អាមន្តា ៗ សោតិន្ទ្រិយសំវរោ ៗ បេ ៗ ឃានិន្ទ្រិយសំវរោ ៗ បេ ៗ ជិវ្ហិន្ទ្រិយសំវរោ ៗ បេ ៗ កាយិន្ទ្រិយសំវរោ កាយកម្មន្តិ ៗ ន ហេវំ វត្តព្វេ ៗ បេ ៗ

(២៨) ការសង្រួម ជាកម្ម ឬ ។ អើ ។ ការសង្រួមចក្ខុន្ទ្រិយ ជាចក្ខុកម្ម ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការសង្រួមសោតិន្ទ្រិយ ។ បេ ។ ការសង្រួមឃានិន្ទ្រិយ ។ បេ ។ ការសង្រួមជិវ្ហិន្ទ្រិយ ។ បេ ។ ការសង្រួមកាយិន្ទ្រិយ ជាកាយកម្ម ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការសង្រួមកាយិន្ទ្រិយ ជាកាយកម្ម ។ អើ ។ ការសង្រួមចក្ខុន្ទ្រិយ ជាចក្ខុកម្ម ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការសង្រួមកាយិន្ទ្រិយ ជាកាយកម្ម ។ អើ ។ ការសង្រួមសោតិន្ទ្រិយ ។ បេ ។ ការសង្រួមឃានិន្ទ្រិយ ។ បេ ។ ការសង្រួមជិវ្ហិន្ទ្រិយ ជាជិវ្ហាកម្ម ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការសង្រួមមនិន្ទ្រិយ ជាមនោកម្ម ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការសង្រួមមនិន្ទ្រិយ ជាមនោកម្ម ។ អើ ។ ការសង្រួមចក្ខុន្ទ្រិយ ជាចក្ខុកម្ម ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការសង្រួមមនិន្ទ្រិយ ជាមនោកម្ម ។ អើ ។ ការសង្រួមសោតិន្ទ្រិយ ។ បេ ។ ការសង្រួមឃានិន្ទ្រិយ ។ បេ ។ ការសង្រួមជិវ្ហិន្ទ្រិយ ។ បេ ។ ការសង្រួមកាយិន្ទ្រិយ ជាកាយកម្ម ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៦) អសំវរោ កម្មន្តិ ។ អាមន្តា ។ ចក្ខុន្ទ្រិយអសំវរោ ចក្ខុកម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សោតិន្ទ្រិយអសំវរោ ។ បេ ។ ឃានិន្ទ្រិយអសំវរោ ។ បេ ។ ជិវ្ហិន្ទ្រិយអសំវរោ ។ បេ ។ កាយិន្ទ្រិយអសំវរោ កាយកម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កាយិន្ទ្រិយអសំវរោ កាយកម្មន្តិ ។ អាមន្តា ។ ចក្ខុន្ទ្រិយអសំវរោ ចក្ខុកម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កាយិន្ទ្រិយអសំវរោ កាយកម្មន្តិ ។ អាមន្តា ។ សោតិន្ទ្រិយអសំវរោ ។ បេ ។ ឃានិន្ទ្រិយអសំវរោ ។ បេ ។ ជិវ្ហិន្ទ្រិយអសំវរោ ជិវ្ហាកម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មនិន្ទ្រិយអសំវរោ មនោកម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មនិន្ទ្រិយអសំវរោ មនោកម្មន្តិ ។ អាមន្តា ។ ចក្ខុន្ទ្រិយអសំវរោ ចក្ខុកម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ មនិន្ទ្រិយអសំវរោ មនោកម្មន្តិ ។ អាមន្តា ។ សោតិន្ទ្រិយអសំវរោ ។ បេ ។ ឃានិន្ទ្រិយអសំវរោ ។ បេ ។ ជិវ្ហិន្ទ្រិយអសំវរោ ។ បេ ។ កាយិន្ទ្រិយអសំវរោ កាយកម្មន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៦) ការមិនសង្រួម ជាកម្មដែរឬ ។ អើ ។ ការមិនសង្រួមចក្ខុន្ទ្រិយ ជាចក្ខុកម្មដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការមិនសង្រួមសោតិន្ទ្រិយ ។ បេ ។ ការមិនសង្រួមឃានិន្ទ្រិយ ។ បេ ។ ការមិនសង្រួមជិវ្ហិន្ទ្រិយ ។ បេ ។ ការមិនសង្រួមកាយិន្ទ្រិយ ជាកាយកម្មដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការមិនសង្រួមកាយិន្ទ្រិយ ជាកាយកម្មដែរឬ ។ អើ ។ ការមិនសង្រួមចក្ខុន្ទ្រិយ ជាចក្ខុកម្មដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការមិនសង្រួមកាយិន្ទ្រិយ ជាកាយកម្មដែរឬ ។ អើ ។ ការមិនសង្រួមសោតិន្ទ្រិយ ។ បេ ។ ការមិនសង្រួមឃានិន្ទ្រិយ ។ បេ ។ ការមិនសង្រួមជិវ្ហិន្ទ្រិយ ជាជិវ្ហាកម្មដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការមិនសង្រួមមនិន្ទ្រិយ ជាមនោកម្មដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការមិនសង្រួមមនិន្ទ្រិយ ជាមនោកម្មដែរឬ ។ អើ ។ ការមិនសង្រួមចក្ខុន្ទ្រិយ ជាចក្ខុកម្មដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការមិនសង្រួមមនិន្ទ្រិយ ជាមនោកម្មឬ ។ អើ ។ ការមិនសង្រួមសោតិន្ទ្រិយ ។ បេ ។ ការមិនសង្រួមឃានិន្ទ្រិយ ។ បេ ។ ការមិនសង្រួមជិវ្ហិន្ទ្រិយ ។ បេ ។ ការមិនសង្រួមកាយិន្ទ្រិយ ជាកាយកម្មដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៧) ន វត្តព្វំ សំវរោបិ អសំវរោបិ កម្មន្តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ឥធ ភិក្ខវេ ភិក្ខុ ចក្ខុនា រូបំ ទិស្វា និមិត្តគ្គាហី ហោតិ ។បេ។ ន និមិត្តគ្គាហី ហោតិ សោតេន សទ្ទំ សុត្វា ។បេ។ មនសា ធម្មំ វិញ្ញាយ និមិត្តគ្គាហី ហោតិ ។បេ។ ន និមិត្តគ្គាហី ហោតីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ សំវរោបិ អសំវរោបិ កម្មន្តិ ។

សំវរោ កម្មន្តិកថា ។

កម្មកថា

(៤៨) សព្វំ កម្មំ សវិបាកន្តិ ។ អាមន្តា ។ សព្វា ចេតនា សវិបាកាតិ ។ ន ហេវំ វត្តព្វេ ។បេ។ សព្វា ចេតនា សវិបាកាតិ ។ អាមន្តា ។ វិបាកាព្យាកតា ចេតនា សវិបាកាតិ ។ ន ហេវំ វត្តព្វេ ។បេ។ សព្វា ចេតនា សវិបាកាតិ ។ អាមន្តា ។ កិរិយាព្យាកតា ចេតនា សវិបាកាតិ ។ ន ហេវំ វត្តព្វេ ។បេ។ សព្វា ចេតនា សវិបាកាតិ ។ អាមន្តា ។ កាមាវចរា វិបាកាព្យាកតា ចេតនា សវិបាកាតិ ។

(៤៧) បុគ្គលមិនគួរនិយាយថា ការសង្រួមក្តី ការមិនសង្រួមក្តី ជាកម្មទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ក្នុងសាសនានេះ ឃើញនូវរូប ដោយចក្ខុ ហើយកាន់យកនូវនិមិត្ត ។បេ។ មិនកាន់យកនូវនិមិត្ត ឮនូវសំឡេង ដោយត្រចៀក ។បេ។ ដឹងច្បាស់នូវធម៌ ដោយចិត្ត កាន់យកនូវនិមិត្ត ។បេ។ មិនកាន់យកនូវនិមិត្ត ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ការសង្រួមក្តី ការមិនសង្រួមក្តី ក៏ជាកម្មដែរ ។

ចប់ សំវរកម្មន្តិកថា ។

កម្មកថា

(៤៨) កម្មទាំងអស់ ប្រកបដោយវិបាកដែរឬ ។ អើ ។ ចេតនាទាំងអស់ ប្រកបដោយវិបាកដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចេតនាទាំងអស់ ប្រកបដោយវិបាកដែរឬ ។ អើ ។ ចេតនា ប្រកបដោយវិបាកនិងអព្យាក្រឹត ប្រកបដោយវិបាកដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចេតនាទាំងអស់ ប្រកបដោយវិបាកដែរឬ ។ អើ ។ ចេតនាជាកិរិយានិងអព្យាក្រឹត ប្រកបដោយវិបាកដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចេតនាទាំងអស់ ប្រកបដោយវិបាកដែរឬ ។ អើ ។ ចេតនា ជាកាមាវចរៈ ជាវិបាកនិងអព្យាក្រឹត ប្រកបដោយវិបាកដែរឬ ។

ន ហេវំ វត្តព្វេ ។ បេ ។ សព្វា ចេតនា សវិបាកាតិ ។ អាមន្តា ។ រូបាវចរា អរូបាវចរា អបរិយាបន្នា វិបាកាព្យាកតា ចេតនា សវិបាកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សព្វា ចេតនា សវិបាកាតិ ។ អាមន្តា ។ កាមាវចរា កិរិយាព្យាកតា ចេតនា សវិបាកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សព្វា ចេតនា សវិបាកាតិ ។ អាមន្តា ។ រូបាវចរា អរូបាវចរា កិរិយាព្យាកតា ចេតនា សវិបាកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤៩) វិបាកាព្យាកតា ចេតនា អវិបាកាតិ ។ អាមន្តា ។ ហញ្ចិ វិបាកាព្យាកតា ចេតនា អវិបាកា នោ ច វត រេ វត្តព្វេ សព្វា ចេតនា សវិបាកាតិ ។

(៥០) កិរិយាព្យាកតា ចេតនា អវិបាកាតិ ។ អាមន្តា ។ ហញ្ចិ កិរិយាព្យាកតា ចេតនា អវិបាកា នោ ច វត រេ វត្តព្វេ សព្វា ចេតនា សវិបាកាតិ ។

(៥១) កាមាវចរា រូបាវចរា អរូបាវចរា អបរិយាបន្នា វិបាកាព្យាកតា ចេតនា អវិបាកាតិ ។ អាមន្តា ។ ហញ្ចិ អបរិយាបន្នា វិបាកាព្យាកតា ចេតនា អវិបាកា នោ ច វត រេ វត្តព្វេ សព្វា ចេតនា សវិបាកាតិ ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ចេតនាទាំងអស់ ប្រកបដោយវិបាកដែរឬ ។ អើ ។ ចេតនា ជារូបាវចរៈ អរូបាវចរៈ អបរិយាបន្នៈ ជាវិបាកនិងអព្យាក្រឹត ប្រកបដោយវិបាកដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ចេតនាទាំងអស់ ប្រកបដោយវិបាកឬ ។ អើ ។ ចេតនា ជាកាមាវចរៈ ជាកិរិយានិងអព្យាក្រឹត ប្រកបដោយវិបាកដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ចេតនាទាំងអស់ ប្រកបដោយវិបាកដែរឬ ។ អើ ។ ចេតនា ជារូបាវចរៈ អរូបាវចរៈ ជាកិរិយានិងអព្យាក្រឹត ប្រកបដោយវិបាកដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤៩) ចេតនា ជាវិបាកនិងអព្យាក្រឹត មិនមានវិបាកទេឬ ។ អើ ។ ប្រសិនបើ ចេតនា ជាវិបាកនិងអព្យាក្រឹត មិនមានវិបាកទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចេតនាទាំងអស់ ប្រកបដោយវិបាកទេ ។

(៥០) ចេតនា ជាកិរិយានិងអព្យាក្រឹត មិនមានវិបាកទេឬ ។ អើ ។ ប្រសិនបើ ចេតនា ជាកិរិយានិងអព្យាក្រឹត មិនមានវិបាកទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចេតនាទាំងអស់ ប្រកបដោយវិបាកទេ ។

(៥១) ចេតនា ជាកាមាវចរៈ រូបាវចរៈ អរូបាវចរៈ អបរិយាបន្នៈ ជាវិបាកនិងអព្យាក្រឹត មិនមានវិបាកទេឬ ។ អើ ។ ប្រសិនបើ ចេតនា ជាអបរិយាបន្នៈ ជាវិបាកនិងអព្យាក្រឹត មិនមានវិបាកទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចេតនាទាំងអស់ ប្រកបដោយវិបាកទេ ។

(៤២) កាមាវចរា រូបាវចរា អរូបាវចរា វិបា-ព្យាកតា ចេតនា អវិបាកាតិ ។ អាមន្តា ។ ហញ្ចិ អរូបាវចរា កិរិយាព្យាកតា ចេតនា អវិបាកា នោ វត រេ វត្តព្វេ សព្វា ចេតនា សវិបាកាតិ ។

(៤៣) ន វត្តព្វំ សព្វំ កម្មំ សវិបាកន្តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា នាហំ ភិក្ខវេ សញ្ចេត-និកានំ កម្មានំ កតានំ ឧបចិតានំ អប្បដិសំវេទិត្វា ព្យន្តីភាវំ វទាមិ តញ្ច ខោ ទិដ្ឋេវ ធម្មេ ឧបបជ្ជេ វា អបរេ វា បរិយាយេតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ សព្វំ កម្មំ សវិបាកន្តិ ។

កម្មកថា ។

សទ្ទោ វិបាកោតិកថា

(៤៤) សទ្ទោ វិបាកោតិ ។ អាមន្តា ។ សុខ-វេទនិយោ ទុក្ខវេទនិយោ អទុក្ខមសុខវេទនិយោ សុខាយ វេទនាយ សម្បយុត្តោ ទុក្ខាយ វេទនាយ សម្បយុត្តោ អទុក្ខមសុខាយ វេទនាយ សម្បយុត្តោ ផស្សេន សម្បយុត្តោ វេទនាយ សម្បយុត្តោ សញ្ញាយ

(៤២) ចេតនា ជាកាមាវចរៈ រូបាវចរៈ អរូបាវចរៈ ជាកិរិយានិង អព្យាក្រឹត មិនមានវិបាកទេឬ ។ អើ ។ ប្រសិនបើ ចេតនា ជាអរូ-បាវចរៈ ជាកិរិយានិងអព្យាក្រឹត មិនមានវិបាកទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ចេតនាទាំងអស់ ប្រកបដោយវិបាកទេ ។

(៤៣) បុគ្គលមិនគួរនិយាយថា កម្មទាំងអស់ ប្រកបដោយវិបាក ទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត មិនពោលថា កម្មទាំងឡាយ ដែលប្រកបដោយចេតនា ដែលសត្វធ្វើហើយ សន្សំហើយ អស់ទៅ ព្រោះមិនបានទទួលផលឡើយ កម្ម នោះឯង គប្បីកើតឡើង ក្នុងបច្ចុប្បន្ន ឬក្នុងបរិយាយដទៃ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ កម្មទាំងអស់ ប្រកប ដោយវិបាក ។

ចប់ កម្មកថា ។

សទ្ទវិបាកោតិកថា

(៤៤) សំឡេង ជាវិបាកឬ ។ អើ ។ សំឡេង គួរដល់ការ ទទួលសុខ គួរដល់ការទទួលទុក្ខ គួរដល់ការទទួលអទុក្ខមសុខ ប្រកប ដោយសុខវេទនា ប្រកបដោយទុក្ខវេទនា ប្រកបដោយអទុក្ខមសុខ-វេទនា ប្រកបដោយផស្សៈ ប្រកបដោយវេទនា ប្រកបដោយសញ្ញា

សម្បយុត្តោ ចេតនាយ សម្បយុត្តោ ចិត្តេន សម្ប-យុត្តោ សារម្មណោ អត្ថិ តស្ស អាវជ្ជនា អាភោគោ ស-មន្នាហារោ មនសិការោ ចេតនា បត្ថនា បណិធិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ ន សុខវេទនិយោ ន ទុក្ខវេទនិយោ ។ បេ ។ អនារម្មណោ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធិ ។ អាមន្តា ។ ហញ្ចិ ន សុខវេទនិយោ ។ បេ ។ អនារម្មណោ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធិ តេន វត រេ វត្តព្វេ សទ្ធា វិបាកោតិ ។

(៨៥) ផស្សោ វិបាកោ ផស្សោ សុខវេទនិ-យោ ។ បេ ។ សារម្មណោ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ សទ្ធា វិបាកោ សទ្ធា សុខវេទនិយោ ។ បេ ។ សារម្មណោ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៨៦) សទ្ធា វិបាកោ សទ្ធា ន សុខវេទនិ-យោ ។ បេ ។ អនារម្មណោ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ ផស្សោ វិបាកោ

ប្រកបដោយចេតនា ប្រកបដោយចិត្ត ប្រកបដោយអារម្មណ៍ ការកើត ការស៊ើប ការពិចារណា ការធ្វើទុកក្នុងចិត្ត ការគិត ការប្រាថ្នា ការតាំងចិត្តទុក មានដល់សទ្ធានោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងសទ្ធា មិនគួរដល់ការទទួលសុខ មិនគួរដល់ការទទួលទុក្ខ ។ បេ ។ មិនមានអារម្មណ៍ ការកើត ។ បេ ។ ការតាំងចិត្តទុក មិនមានដល់សទ្ធានោះទេឬ ។ អើ ។ ប្រសិនបើ សទ្ធា មិនគួរដល់ការទទួលសុខ ។ បេ ។ មិនមានអារម្មណ៍ទេ ការកើត ។ បេ ។ ការតាំងចិត្តទុក មិនមានដល់សទ្ធានោះទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សទ្ធា ជាវិបាកទេ ។

(៨៥) ផស្សៈ ជាវិបាក ចុះផស្សៈ គួរដល់ការទទួលសុខ ។ បេ ។ ប្រកបដោយអារម្មណ៍ ការកើត ។ បេ ។ ការតាំងចិត្តទុក មានដល់ផស្សៈនោះដែរឬ ។ អើ ។ សទ្ធា ជាវិបាក ចុះសទ្ធា គួរដល់ការទទួលសុខ ។ បេ ។ ប្រកបដោយអារម្មណ៍ ការកើត ។ បេ ។ ការតាំងចិត្តទុក មានដល់សទ្ធានោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៨៦) សទ្ធា ជាវិបាក ចុះសទ្ធា មិនគួរដល់ការទទួលសុខ ។ បេ ។ មិនមានអារម្មណ៍ ការកើត ។ បេ ។ ការតាំងចិត្តទុក មិនមានដល់សទ្ធានោះទេឬ ។ អើ ។ ផស្សៈ ជាវិបាក

ផស្សោ ន សុខវេទនិយោ ន ទុក្ខវេទនិយោ ។ បេ ។
អនារម្មណោ នត្ថិ តស្ស អាវដ្ដនា ។ បេ ។ បណិ-
ធិតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៨៧) ន វត្តព្វំ សទ្ទោ វិបាកោតិ ។ អាមន្តា ។
ននុ វុត្តំ ភគវតា សោ តស្ស កម្មស្ស កតត្តា
ឧបចិតត្តា ឧស្សន្នត្តា វិបុលត្តា ព្រហ្មស្សរោ ហោតិ
ករវិកភាណីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។
តេន ហិ សទ្ទោ វិបាកោតិ ។

សទ្ទោ វិបាកោតិកថា ។

សឡាយតនកថា

(៨៨) ចក្ខាយតនំ វិបាកោតិ ។ អាមន្តា ។
សុខវេទនិយំ ទុក្ខវេទនិយំ ។ បេ ។ សារម្មណំ
អត្ថិ តស្ស អាវដ្ដនា ។ បេ ។ បណិធីតិ ។ ន ហេវំ
វត្តព្វេ ។ បេ ។ ននុ ន សុខវេទនិយំ ។ បេ ។
អនារម្មណំ នត្ថិ តស្ស អាវដ្ដនា ។ បេ ។ បណិ-
ធិតិ ។ អាមន្តា ។ ហញ្ចិ ន សុខវេទនិយំ ។ បេ ។

ផស្សៈ មិនគួរដល់ការទទួលសុខ មិនគួរដល់ការទទួលទុក្ខ ។ បេ ។
មិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក មិនមានដល់
(៦៦៧) ន វត្តព្វំ រូបំ វិបាកោតិ ។ អាមន្តា ។ ននុ កម្មស្ស កតត្តា ឧប្បន្នា ចិត្តចេតសិកា ធម្មា វិបាកាតិ ។ អាមន្តា ។ ហញ្ចិ កម្មស្ស កតត្តា ឧប្បន្នា ចិត្តចេតសិកា ធម្មា វិបាកា តេន វត រេ វត្តព្វេ កម្មស្ស កតត្តា ឧប្បន្នំ រូបំ វិបាកោតិ ។

រូបំ វិបាកោតិកថា ។

(៦៦៥) ផស្សៈ ជាវិបាក ផស្សៈ គួរដល់ការរងសុខ គួរដល់ការរងទុក្ខ ។ បេ ។ ប្រកបដោយអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះផស្សៈនោះ មានដែរឬ ។ អើ ។ រូប ជាវិបាក រូប គួរដល់ការរងសុខ គួរដល់ការរងទុក្ខ ។ បេ ។ ប្រកបដោយអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៦៦) រូប ជាវិបាក រូប មិនគួរដល់ការរងសុខ មិនគួរដល់ការរងទុក្ខ ។ បេ ។ មិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះរូបនោះ មិនមានទេឬ ។ អើ ។ ផស្សៈ ជាវិបាក ផស្សៈ មិនគួរដល់ការរងសុខ មិនគួរដល់ការរងទុក្ខ ។ បេ ។ មិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក ចំពោះផស្សៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦៦៧) បុគ្គលមិនគួរនិយាយថា រូប ជាវិបាកទេឬ ។ អើ ។ ក្រែងធម៌ទាំងឡាយ ប្រកបដោយចិត្តនិងចេតសិកដែលកើតឡើងព្រោះធ្វើនូវកម្ម ជាវិបាកឬ ។ អើ ។ ប្រសិនបើធម៌ទាំងឡាយ ប្រកបដោយចិត្តនិងចេតសិកដែលកើតឡើងព្រោះធ្វើនូវកម្ម ជាវិបាកមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា រូប ដែលកើតឡើងព្រោះធ្វើនូវកម្ម ជាវិបាក ។

ចប់ រូបំវិបាកោតិកថា ។

(៦៦៨) អត្ថិ រូបំ រូបាវចរន្តិ ។ អាមន្តា ។ ស-
មាបត្តេសិយំ ឧបបត្តេសិយំ ទិដ្ឋធម្មសុខវិហារំ សមា-
បត្តេសិយេន ចិត្តេន ឧបបត្តេសិយេន ចិត្តេន ទិដ្ឋ-
ធម្មសុខវិហារេន ចិត្តេន សហគតំ សហជាតំ សំ-
សដ្ឋំ សម្បយុត្តំ ឯកុប្បាទំ ឯកនិរោធំ ឯកវត្ថុកំ
ឯការម្មណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ ន
សមាបត្តេសិយំ ន ឧបបត្តេសិយំ ន ទិដ្ឋធម្មសុខ-
វិហារំ ន សមាបត្តេសិយេន ចិត្តេន(១) ឧបបត្តេសិ-
យេន ចិត្តេន(២) ទិដ្ឋធម្មសុខវិហារេន ចិត្តេន សហ-
គតំ សហជាតំ សំសដ្ឋំ សម្បយុត្តំ ឯកុប្បាទំ ឯក-
និរោធំ ឯកវត្ថុកំ ឯការម្មណន្តិ ។ អាមន្តា ។ ហញ្ចិ
ន សមាបត្តេសិយំ ន ឧបបត្តេសិយំ ន ទិដ្ឋធម្មសុខ-
វិហារំ ន សមាបត្តេសិយេន ចិត្តេន ។ បេ ។ ឯកា-
រម្មណំ នោ ច វត រេ វត្តព្វេ អត្ថិ រូបំ រូបាវចរន្តិ ។

១-២ ឱ. ម. ឯត្តន្តរេ ចសទ្ទោ អត្ថិ ។

(៦៦៨) រូប ជារូបាវចរៈ មានដែរឬ ។ អើ ។ រូប ស្វែងរក
សមាបត្តិ ស្វែងរកកំណើត នៅជាសុខក្នុងបច្ចុប្បន្ន ប្រព្រឹត្តទៅជាមួយ
គ្នា កើតជាមួយគ្នា លាយច្រឡំគ្នា ប្រកបព្រម មានកំណើតជាមួយ
គ្នា រលត់ទៅជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា
ដោយចិត្តដែលស្វែងរកសមាបត្តិ ចិត្តដែលស្វែងរកកំណើត ចិត្តដែល
នៅជាសុខក្នុងបច្ចុប្បន្នឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។
ក្រែងរូប មិនស្វែងរកសមាបត្តិ មិនស្វែងរកកំណើត មិននៅជាសុខក្នុង
បច្ចុប្បន្ន ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា លាយច្រឡំគ្នា ប្រ-
កបព្រម មានកំណើតជាមួយគ្នា រលត់ទៅជាមួយគ្នា មានវត្ថុជាមួយគ្នា
មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលមិនស្វែងរកសមាបត្តិ ចិត្តដែល
មិនស្វែងរកកំណើត ចិត្តដែលមិននៅជាសុខក្នុងបច្ចុប្បន្នឬ ។ អើ ។
ប្រសិនបើរូប មិនស្វែងរកសមាបត្តិ មិនស្វែងរកកំណើត មិននៅជាសុខ
ក្នុងបច្ចុប្បន្ន មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលមិនស្វែងរកសមា-
បត្តិ ។ បេ ។ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូប ជារូបាវចរៈ
មានទេ ។

[២៤៩] អត្ថិ រូបំ អរូបាវចរន្តិ ។ អាមន្តា ។ សមាបត្តេសិយំ ឧបបត្តេសិយំ ទិដ្ឋធម្មសុខវិហារំ សមាបត្តេសិយេន ចិត្តេន ឧបបត្តេសិយេន ចិត្តេន ទិដ្ឋធម្មសុខវិហារេន ចិត្តេន សហគតំ សហជាតំ សំសដ្ឋំ សម្បយុត្តំ ឯកុប្បាទំ ឯកនិរោធំ ឯកវត្ថុកំ ឯការម្មណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ ន សមាបត្តេសិយំ ន ឧបបត្តេសិយំ ន ទិដ្ឋធម្មសុខវិហារំ ន សមាបត្តេសិយេន ចិត្តេន ។ បេ ។ ឯការម្មណន្តិ ។ អាមន្តា ។ ហញ្ចិ ន សមាបត្តេសិយំ ន ឧបបត្តេសិយំ ។ បេ ។ ឯកវត្ថុកំ ឯការម្មណំ នោ វត រេ វត្តព្វេ អត្ថិ រូបំ អរូបាវចរន្តិ ។

[២៥០] ន វត្តព្វំ អត្ថិ រូបំ រូបាវចរំ អត្ថិ រូបំ អរូបាវចរន្តិ ។ អាមន្តា ។ ននុ កាមាវចរកម្មស្ស កតត្តា រូបំ កាមាវចរន្តិ ។ អាមន្តា ។ ហញ្ចិ កាមាវចរកម្មស្ស កតត្តា រូបំ កាមាវចរំ តេន វត រេ វត្តព្វេ រូបាវចរកម្មស្ស កតត្តា រូបំ រូបាវចរំ អរូបាវចរកម្មស្ស កតត្តា រូបំ អរូបាវចរន្តិ ។

រូបាវចរារូបាវចរន្តិកថា ។

(២៤៩) រូប ជាអរូបាវចរៈ មានមែនឬ ។ អើ ។ រូប ដែលស្វែងរកសមាបត្តិ ស្វែងរកកំណើត នៅជាសុខក្នុងបច្ចុប្បន្ន ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា លាយច្រឡំគ្នា ប្រកបព្រម មានកំណើតជាមួយគ្នា រលត់ទៅជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលស្វែងរកសមាបត្តិ ចិត្តដែលស្វែងរកកំណើត ចិត្តដែលនៅជាសុខក្នុងបច្ចុប្បន្នឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ ។ បេ ។ ក្រែងរូប មិនស្វែងរកសមាបត្តិ មិនស្វែងរកកំណើត មិននៅជាសុខក្នុងបច្ចុប្បន្ន ។ បេ ។ មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលមិនស្វែងរកសមាបត្តិ ឬ ។ អើ ។ ប្រសិនបើរូប មិនស្វែងរកសមាបត្តិ មិនស្វែងរកកំណើត ។ បេ ។ មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូប ជាអរូបាវចរៈ មានទេ ។

(២៥០) បុគ្គលមិនគួរនិយាយថា រូប ជារូបាវចរៈ ក៏មាន រូប ជាអរូបាវចរៈ ក៏មានទេឬ ។ អើ ។ ក្រែងរូប ជាកាមាវចរៈ ព្រោះធ្វើកម្មជាកាមាវចរៈឬ ។ អើ ។ ប្រសិនបើរូប ជាកាមាវចរៈ ព្រោះធ្វើកម្មជាកាមាវចរៈមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា រូប ជារូបាវចរៈ ព្រោះធ្វើកម្មជារូបាវចរៈ រូប ជាអរូបាវចរៈ ព្រោះធ្វើកម្មជាអរូបាវចរៈដែរ ។

ចប់ រូបាវចរារូបាវចរន្តិកថា ។

(៤៨១) រូបរាគោ រូបធាតុបរិយាបន្នោតិ ។ អាមន្តា ។ សមាបត្តេសិយោ ឧបបត្តេសិយោ ទិដ្ឋធម្មសុខវិហារោ សមាបត្តេសិយេន ចិត្តេន ឧបបត្តេសិយេន ចិត្តេន ទិដ្ឋធម្មសុខវិហារេន ចិត្តេន សហគតោ សហជាតោ សំសដ្ឋោ សម្បយុត្តោ ឯកុប្បាទោ ឯកនិរោធោ ឯកវត្ថុកោ ឯការម្មណោតិ ។ ន ហេវំ វត្តព្វេ ។បេ។ ននុ ន សមាបត្តេសិយោ ន ឧបបត្តេសិយោ ន ទិដ្ឋធម្មសុខវិហារោ ន សមាបត្តេសិយេន ចិត្តេន ។បេ។ ឯកវត្ថុកោ ឯការម្មណោតិ ។ អាមន្តា ។ ហញ្ចិ ន សមាបត្តេសិយោ ន ឧបបត្តេសិយោ ន ទិដ្ឋធម្មសុខវិហារោ ន សមាបត្តេសិយេន ចិត្តេន ។បេ។ ឯកវត្ថុកោ ឯការម្មណោ នោ ច វត រេ វត្តព្វេ រូបរាគោ រូបធាតុបរិយាបន្នោតិ ។

(៤៨២) រូបរាគោ រូបធាតុបរិយាបន្នោតិ ។ អាមន្តា ។ សទ្ទរាគោ សទ្ទធាតុបរិយាបន្នោតិ ។ ន ហេវំ វត្តព្វេ ។បេ។ រូបរាគោ រូបធាតុបរិយាបន្នោតិ ។ អាមន្តា ។ គន្ធរាគោ ។បេ។ រសរាគោ ។បេ។ ផោដ្ឋព្វរាគោ ផោដ្ឋព្វធាតុបរិយាបន្នោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៤៨១) រូបរាគៈ រាប់បញ្ចូលក្នុងរូបធាតុឬ ។ អើ ។ រូបរាគៈ ដែលស្វែងរកសមាបត្តិ ស្វែងរកកំណើត នៅជាសុខក្នុងបច្ចុប្បន្ន ប្រព្រឹត្តទៅជាមួយគ្នា កើតជាមួយគ្នា លាយច្រឡំគ្នា ប្រកបព្រម មានកំណើតជាមួយគ្នា រលត់ទៅជាមួយគ្នា មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលស្វែងរកសមាបត្តិ ចិត្តដែលស្វែងរកកំណើត ចិត្តដែលនៅជាសុខក្នុងបច្ចុប្បន្នឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងរូបរាគៈ មិនស្វែងរកសមាបត្តិ មិនស្វែងរកកំណើត មិននៅជាសុខក្នុងបច្ចុប្បន្ន មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលមិនស្វែងរកសមាបត្តិ ។បេ។ ទេឬ ។ អើ ។ ប្រសិនបើ រូបរាគៈ មិនស្វែងរកសមាបត្តិ មិនស្វែងរកកំណើត មិននៅជាសុខក្នុងបច្ចុប្បន្ន មានវត្ថុជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ដោយចិត្តដែលមិនស្វែងរកសមាបត្តិ ។បេ។ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា រូបរាគៈ រាប់បញ្ចូលក្នុងរូបធាតុទេ ។

(៤៨២) រូបរាគៈ រាប់បញ្ចូលក្នុងរូបធាតុឬ ។ អើ ។ សទ្ទរាគៈ រាប់បញ្ចូលក្នុងសទ្ទធាតុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ រូបរាគៈ រាប់បញ្ចូលក្នុងរូបធាតុដែរឬ ។ អើ ។ គន្ធរាគៈ ។បេ។ រសរាគៈ ។បេ។ ផោដ្ឋព្វរាគៈ រាប់បញ្ចូលក្នុងផោដ្ឋព្វធាតុដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៤៨៣) ន វត្តព្វំ រូបភាគោ រូបធាតុបរិយាបន្នោ អរូបភាគោ អរូបធាតុបរិយាបន្នោតិ ។ អាមន្តា ។ ននុ កាមភាគោ កាមធាតុបរិយាបន្នោតិ ។ អាមន្តា ។ ហញ្ចិ កាមភាគោ កាមធាតុបរិយាបន្នោ តេន វត វេ វត្តព្វេ រូបភាគោ រូបធាតុបរិយាបន្នោ អរូបភាគោ អរូបធាតុបរិយាបន្នោតិ ។

រូបភាគោ រូបធាតុបរិយាបន្នោតិអាទិកថា ។

សោឡសមោ វគ្គោ ។

តស្សុទ្ទានំ

ចិត្តនិគ្គហោ ចិត្តបគ្គហោ សុខានុប្បទានំ អធិគ្គយ្ហមនសិការោ រូបំ ហេតុ រូបំ សហេតុកំ រូបំ កុសលម្បិ អកុសលម្បិ រូបំ វិបាកោ អត្ថិ រូបំ រូបាវចរំ អត្ថិ រូបំ អរូបាវចរំ សព្វេ កិលេសា កាមធាតុបរិយាបន្នាតិ ។

(៤៨៣) បុគ្គលមិនគួរនិយាយថា រូបភាគៈ រាប់បញ្ចូលក្នុងរូបធាតុ អរូបភាគៈ រាប់បញ្ចូលក្នុងអរូបធាតុទេឬ ។ អើ ។ ក្រែងកាមភាគៈ រាប់បញ្ចូលក្នុងកាមធាតុឬ ។ អើ ។ ប្រសិនបើកាមភាគៈ រាប់បញ្ចូលក្នុងកាមធាតុមែន ម្នាលអ្នកដ៏ចំរើន ព្រោះហេតុនោះ អ្នកគួរពោលថា រូបភាគៈ រាប់បញ្ចូលក្នុងរូបធាតុ អរូបភាគៈ រាប់បញ្ចូលក្នុងអរូបធាតុបាន ។

ចប់ រូបភាគអរូបធាតុបរិយាបន្នោតិអាទិកថា ។

ចប់ សោឡសមវគ្គ ។

ឧទ្ទាននៃសោឡសមវគ្គនោះ គឺ

និយាយ អំពីការសង្កត់សង្កិនចិត្ត ១ ការទំនុកបម្រុងចិត្ត ១ ការប្រគល់ឲ្យនូវសេចក្ដីសុខ ១ ការត្រាស់ដឹងហើយទើបធ្វើទុកក្នុងចិត្ត ១ រូប ជាហេតុ ១ រូប ប្រកបដោយហេតុ ១ រូប ជាកុសលក៏មាន ជាអកុសលក៏មាន ១ រូប ជាវិបាក ១ រូប ជារូបាវចរក៏មាន [illegible] ១ [illegible]

[illegible]

អត្ថិ អរហតោ បុញ្ញូបចយោតិកថា

[illegible] បជហតីតិ ។ បេ ។ អរហា ឧបាទិយតីតិ ។ បេ ។ អរហា វិសិនេតីតិ ។ បេ ។ អរហា ឧស្សិនេតីតិ ។ បេ ។ អរហា វិធូបេតីតិ ។ បេ ។ អរហា សន្ធូបេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ អរហា នេវាចិនាតិ ន អបចិនាតិ អបចិនិត្វា ឋិតោតិ ។ អាមន្តា ។ ហញ្ចិ អរហា នេវាចិនាតិ ន អបចិនាតិ អបចិនិត្វា ឋិតោ នោ ច វត រេ វត្តព្វេ អត្ថិ អរហតោ បុញ្ញូបចយោតិ ។

[illegible] ននុ អរហា នេវ បជហតិ ន ឧបាទិ-[illegible] ឋិតោ នេវ វិសិនេតិ ន ឧស្សិនេតិ [illegible] នេវ វិធូបេតិ ន សន្ធូបេតិ វិធូបេត្វា [illegible] ហញ្ចិ អរហា នេវ វិធូបេតិ [illegible] វត រេ វត្តព្វេ [illegible]

អត្ថិអរហតោបុញ្ញូបចយោតិកថា

ព្រះអរហន្ត លះបង់ ។ បេ ។ ព្រះអរហន្ត ប្រកាន់ភ្ជាប់ ។ បេ ។ ព្រះអរហន្ត កកាយចេញ ។ បេ ។ ព្រះអរហន្ត ប្រមូលយក ។ បេ ។ ព្រះអរហន្ត កំចាត់ចេញ ។ បេ ។ ព្រះអរហន្ត ក្រសោបយកដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងព្រះអរហន្ត មិនសន្សំ មិនមែនជាមិនសន្សំ គឺលែងសន្សំហើយ ឋិតនៅឬ ។ អើ ។ ប្រសិនបើព្រះអរហន្ត មិនសន្សំ មិនមែនជាមិនសន្សំ គឺលែងសន្សំហើយ ឋិតនៅ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការសន្សំបុណ្យ របស់ព្រះអរហន្ត មានទេ ។

(២៦១) ក្រែងព្រះអរហន្ត មិនលះបង់ មិនប្រកាន់ភ្ជាប់ លុះលះបង់ហើយឋិតនៅ មិនកកាយចេញ មិនប្រមូលយក លុះកកាយចេញហើយឋិតនៅ មិនកំចាត់ចេញ មិនក្រសោបយក លុះកំចាត់ចេញហើយឋិតនៅឬ ។ អើ ។ ប្រសិនបើព្រះអរហន្ត មិនកំចាត់ចេញ មិនក្រសោបយក លុះកំចាត់ចេញហើយឋិតនៅមែន ម្នាលអ្នកដ៏ចម្រើន [illegible] ។

(៦៦២) នត្ថិ អរហតោ បុញ្ញូបចយោតិ ។ អាមន្តា ។ អរហា ទានំ ទទេយ្យាតិ ។ អាមន្តា ។ ហញ្ចិ អរហា ទានំ ទទេយ្យ នោ វត រេ វត្តព្វេ នត្ថិ អរហតោ បុញ្ញូបចយោតិ ។

(៦៦៣) អរហា ចីវរំ ទទេយ្យ ។ បេ ។ បិណ្ឌបាតំ ទទេយ្យ សេនាសនំ ទទេយ្យ គិលានបច្ចយភេសជ្ជបរិក្ខារំ ទទេយ្យ ខាទនីយំ ទទេយ្យ ភោជនីយំ ទទេយ្យ បានីយំ ទទេយ្យ ចេតិយំ វន្ទេយ្យ ចេតិយេ មាលំ អារោបេយ្យ គន្ធំ អារោបេយ្យ វិលេបនំ អារោបេយ្យ ។ បេ ។ ចេតិយំ អភិទក្ខិណំ ករេយ្យាតិ ។ អាមន្តា ។ ហញ្ចិ អរហា ចេតិយំ អភិទក្ខិណំ ករេយ្យ នោ វត រេ វត្តព្វេ នត្ថិ អរហតោ បុញ្ញូបចយោតិ ។

នត្ថិ អរហតោ បុញ្ញូបចយោតិកថា ។

នត្ថិ អរហតោ អកាលមច្ចូតិកថា

(៦៦៤) នត្ថិ អរហតោ អកាលមច្ចូតិ ។ អាមន្តា ។ នត្ថិ អរហន្តឃាតកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ អរហន្តឃាតកោតិ ។ អាមន្តា ។

(៦៦២) ការសន្សំបុណ្យ របស់ព្រះអរហន្ត មិនមានទេឬ ។ អើ ។ ព្រះអរហន្ត គប្បីឲ្យទានដែរឬ ។ អើ ។ ប្រសិនបើព្រះអរហន្ត គប្បីឲ្យទានដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការសន្សំបុណ្យ របស់ព្រះអរហន្ត មិនមានទេ ។

(៦៦៣) ព្រះអរហន្ត គប្បីឲ្យចីវរ ។ បេ ។ គប្បីឲ្យបិណ្ឌបាត ឲ្យសេនាសនៈ ឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារ ឲ្យវត្ថុគួរទំពាស៊ី ឲ្យវត្ថុគួរបរិភោគ ឲ្យទឹកគួរផឹក ថ្វាយបង្គំចេតិយ លើកឡើងនូវផ្កាកម្រង លើកឡើងនូវគ្រឿងក្រអូប លើកឡើងនូវគ្រឿងលាប ចំពោះចេតិយ ។ បេ ។ គប្បីធ្វើអភិទក្ខិណាចេតិយដែរឬ ។ អើ ។ ប្រសិនបើព្រះអរហន្ត គប្បីធ្វើអភិទក្ខិណាចេតិយដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការសន្សំបុណ្យ របស់ព្រះអរហន្ត មិនមានទេ ។

ចប់ នត្ថិ អរហតោ បុញ្ញូបចយោតិកថា ។

នត្ថិ អរហតោ អកាលមច្ចូតិកថា

(៦៦៤) សេចក្ដីស្លាប់ក្នុងកាលមិនគួរ របស់ព្រះអរហន្ត មិនមានទេឬ ។ អើ ។ បុគ្គលអ្នកសម្លាប់ព្រះអរហន្ត មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលអ្នកសម្លាប់ព្រះអរហន្ត មានដែរឬ ។ អើ ។

អត្ថិ អរហតោ អកាលមច្ចូតិ ។ ន ហេវំ វត្តព្វេ ។បេ ។ នត្ថិ អរហតោ អកាលមច្ចូតិ ។ អាមន្តា ។ យោ អរហន្តំ ជីវិតា វោរោបេតិ សោ សតិ ជីវិតេ ជីវិតាវសេសេ ជីវិតា វោរោបេតិ អសតិ ជីវិតេ ជីវិតាវសេសេ ជីវិតា វោរោបេតីតិ ។ សតិ ជីវិតេ ជីវិតាវសេសេ ជីវិតា វោរោបេតីតិ ។ ហញ្ចិ សតិ ជីវិតេ ជីវិតាវសេសេ ជីវិតា វោរោបេតិ នោ វត រេ វត្តព្វេ នត្ថិ អរហតោ អកាលមច្ចូតិ ។ អសតិ ជីវិតេ ជីវិតាវសេសេ ជីវិតា វោរោបេតីតិ ។ នត្ថិ អរហន្តឃាតកោតិ ។ ន ហេវំ វត្តព្វេ ។បេ ។

(៦៦៨) នត្ថិ អរហតោ អកាលមច្ចូតិ ។ អាមន្តា ។ អរហតោ កាយេ វិសំ ន កមេយ្យ សត្ថំ ន កមេយ្យ អគ្គិ ន កមេយ្យាតិ ។ ន ហេវំ វត្តព្វេ ។បេ ។ ននុ អរហតោ កាយេ វិសំ កមេយ្យ សត្ថំ កមេយ្យ អគ្គិ កមេយ្យាតិ ។ អាមន្តា ។ ហញ្ចិ អរហតោ កាយេ វិសំ កមេយ្យ សត្ថំ កមេយ្យ អគ្គិ កមេយ្យ

សេចក្តីស្លាប់ក្នុងកាលមិនគួរ របស់ព្រះអរហន្ត មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ ។ សេចក្តីស្លាប់ក្នុងកាលមិនគួរ របស់ព្រះអរហន្ត មិនមានទេឬ ។ អើ ។ បុគ្គលណា ផ្តាច់បង់ព្រះអរហន្តចាកជីវិត បុគ្គលនោះ កាលបើជីវិតនៅមាន តែងផ្តាច់បង់ជីវិតដ៏សេសសល់ចាកជីវិត កាលបើជីវិតមិនមាន តែងផ្តាច់បង់ជីវិតដ៏សេសសល់ចាកជីវិតដែរឬ ។ (បុគ្គលនោះ) កាលបើជីវិតនៅមាន តែងផ្តាច់បង់ជីវិតដ៏សេសសល់ចាកជីវិត ។ ប្រសិនបើ (បុគ្គលនោះ) កាលបើជីវិតនៅមាន តែងផ្តាច់បង់ជីវិតដ៏សេសសល់ចាកជីវិតដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សេចក្តីស្លាប់ក្នុងកាលមិនគួរ របស់ព្រះអរហន្ត មិនមានទេ ។ (បុគ្គលនោះ) កាលបើជីវិតមិនមាន តែងផ្តាច់បង់ជីវិតដ៏សេសសល់ចាកជីវិតដែរ ។ បុគ្គលអ្នកសម្លាប់ព្រះអរហន្ត មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ ។

(៦៦៨) សេចក្តីស្លាប់ក្នុងកាលមិនគួរ របស់ព្រះអរហន្ត មិនមានទេឬ ។ អើ ។ ថ្នាំពិសមិនគប្បីចូលទៅ គ្រឿងសស្ត្រាមិនគប្បីមុត ភ្លើងមិនគប្បីឆេះ ចំពោះកាយ របស់ព្រះអរហន្តទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ ។ ក្រែង ថ្នាំពិសគប្បីចូលទៅ គ្រឿងសស្ត្រាគប្បីមុត ភ្លើងគប្បីឆេះ ចំពោះកាយ របស់ព្រះអរហន្តដែរ ។ អើ ។ ប្រសិនបើ ថ្នាំពិសគប្បីចូលទៅ គ្រឿងសស្ត្រាគប្បីមុត ភ្លើងគប្បីឆេះ ចំពោះកាយ របស់ព្រះអរហន្តដែរ ម្នាលអ្នកដ៏ចម្រើន

ន ហេវំ វត្តព្វេ នត្ថិ អរហតោ អកាលមច្ចូតិ ។

(២៦៦) អរហតោ កាយេ វិសំ ន កមេយ្យ សត្ថំ ន កមេយ្យ អគ្គិ ន កមេយ្យាតិ ។ អាមន្តា ។ នត្ថិ អរហន្តឃាតកោតិ ។ ន ហេវំ វត្តព្វេ ។បេ។

(២៦៧) អត្ថិ អរហតោ អកាលមច្ចូតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា នាហំ ភិក្ខវេ សញ្ចេតនិកានំ កម្មានំ កតានំ ឧបចិតានំ អប្បដិសំវេទិត្វា ព្យន្តីភាវំ វទាមិ តញ្ច ខោ ទិដ្ឋេវ ធម្មេ ឧបបជ្ជេ វា អបរេ វា បរិយាយេតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ នត្ថិ អរហតោ អកាលមច្ចូតិ ។

នត្ថិ អរហតោ អកាលមច្ចូតិកថា ។

សព្វមិទំ កម្មតោតិកថា

(២៦៨) សព្វមិទំ កម្មតោតិ ។ អាមន្តា ។ កម្មម្បិ កម្មតោតិ ។ ន ហេវំ វត្តព្វេ ។បេ។ សព្វមិទំ កម្មតោតិ ។ អាមន្តា ។ សព្វមិទំ បុព្វេកតហេតូតិ ។ ន ហេវំ វត្តព្វេ ។បេ។

អ្នកមិនគួរពោលថា សេចក្តីស្លាប់ក្នុងកាលមិនគួរ របស់ព្រះអរហន្ត មិនមានទេ ។

(២៦៦) ថ្នាំពិសមិនគប្បីចូលទៅ គ្រឿងសស្ត្រាមិនគប្បីមុត ភ្លើងមិនគប្បីឆេះ ចំពោះកាយ របស់អរហន្តទេឬ ។ អើ ។ បុគ្គលអ្នកសម្លាប់ព្រះអរហន្ត មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(២៦៧) សេចក្តីស្លាប់ក្នុងកាលមិនគួរ របស់ព្រះអរហន្ត មានដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនបានពោលថា កម្មទាំងឡាយ ប្រកបដោយចេតនា ដែលសត្វធ្វើហើយ សន្សំហើយ អស់ទៅ ព្រោះតែមិនបានទទួលផលដូច្នេះឡើយ កម្មនោះឯង គប្បីឱ្យផល ក្នុងបច្ចុប្បន្ន ឬ ក្នុងអត្តភាពជាលំដាប់ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ សេចក្តីស្លាប់ក្នុងកាលមិនគួរ របស់ព្រះអរហន្ត មិនមានទេ ។

ចប់ នត្ថិ អរហតោ អកាលមច្ចូតិកថា ។

សព្វមិទំ កម្មតោតិកថា

(២៦៨) ធម្មជាត[១]ទាំងអស់នេះ មាន ព្រោះកម្មឬ ។ អើ ។ ចុះកម្ម មាន ព្រោះកម្មដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធម្មជាតទាំងអស់នេះ មាន ព្រោះកម្មឬ ។ អើ ។ ធម្មជាតទាំងអស់នេះ ជាហេតុដែលធ្វើក្នុងកាលមុនឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

---
១ សំដៅដល់ពួកកម្មក្កិលេស និងវិបាកវដ្ដៈ ។

សព្វមិទំ កម្មតោតិ ។ អាមន្តា ។ សព្វមិទំ កម្មវិ-
បាកតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សព្វមិទំ កម្មវិ-
បាកតោតិ ។ អាមន្តា ។ កម្មវិបាកេន បាណំ ហនេ-
យ្យាតិ ។ អាមន្តា ។ បាណាតិបាតោ សផលោតិ ។
អាមន្តា ។ កម្មវិបាកោ សផលោតិ ។ ន ហេវំ វត្តព្វេ
។ បេ ។ កម្មវិបាកោ អផលោតិ ។ អាមន្តា ។ បា-
ណាតិបាតោ អផលោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។
កម្មវិបាកេន អទិន្នំ អាទិយេយ្យ ។ បេ ។ មុសា
ភណេយ្យ បិសុណំ ភណេយ្យ ផរុសំ ភណេយ្យ
សម្ផំ បលបេយ្យ សន្ធឹ ឆិន្ទេយ្យ និល្លោបំ ហរេ-
យ្យ ឯកាគារិកំ ករេយ្យ បរិបន្ថេ តិដ្ឋេយ្យ បរទារំ
គច្ឆេយ្យ គាមឃាតកំ ករេយ្យ និគមឃាតកំ ក-
រេយ្យ កម្មវិបាកេន ទានំ ទទេយ្យ ចីវរំ ទទេយ្យ
បិណ្ឌបាតំ ទទេយ្យ សេនាសនំ ទទេយ្យ គិលាន-
ប្បច្ចយភេសជ្ជបរិក្ខារំ ទទេយ្យាតិ ។ អាមន្តា ។ គិលា-
នប្បច្ចយភេសជ្ជបរិក្ខារោ សផលោតិ ។ អាមន្តា ។
កម្មវិបាកោ សផលោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។
កម្មវិបាកោ អផលោតិ ។ អាមន្តា ។ គិលានប្បច្ចយ-
ភេសជ្ជបរិក្ខារោ អផលោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ធម្មជាតទាំងអស់នេះ មាន ព្រោះកម្មឬ ។ អើ ។ ធម្មជាតទាំងអស់នេះ
មាន ព្រោះវិបាករបស់កម្មឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។
ធម្មជាតទាំងអស់នេះ មាន ព្រោះវិបាករបស់កម្មឬ ។ អើ ។ បុគ្គល
សម្លាប់សត្វ ដោយវិបាករបស់កម្មឬ ។ អើ ។ បាណាតិបាត មាន
ផលដែរឬ ។ អើ ។ វិបាករបស់កម្ម មានផលដែរឬ ។ អ្នកមិនគួរ
ពោលយ៉ាងនេះទេ ។ បេ ។ វិបាករបស់កម្ម មិនមានផលទេឬ ។ អើ ។
បាណាតិបាត មិនមានផលទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។
បុគ្គល កាន់យកទ្រព្យដែលគេមិនបានឲ្យ ។ បេ ។ និយាយកុហក និយាយ
ពាក្យញុះញង់ និយាយពាក្យទ្រគោះ និយាយពាក្យឥតប្រយោជន៍ កាត់
ទ្វីទ-គាស់ផ្ទះ ប្លន់ក្នុងស្រុក ប្លន់យកទ្រព្យតែផ្ទះមួយ ឈរចាំក្បែរផ្លូវ
(ដើម្បីដណ្ដើមយកទ្រព្យ) លួចប្រពន្ធបុគ្គលដទៃ សម្លាប់អ្នកស្រុក
សម្លាប់អ្នកនិគម ដោយវិបាករបស់កម្ម បុគ្គល គប្បីឲ្យទាន គឺឲ្យចីវរ ឲ្យ
បិណ្ឌបាត ឲ្យសេនាសនៈ ឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារ ដោយវិបាក
របស់កម្មឬ ។ អើ ។ គិលានប្បច្ចយភេសជ្ជបរិក្ខារ មានផលដែរឬ ។
អើ ។ វិបាករបស់កម្ម មានផលដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះ
ទេ ។ បេ ។ វិបាករបស់កម្ម មិនមានផលទេឬ ។ អើ ។ គិលា-
នប្បច្ចយភេសជ្ជបរិក្ខារ មិនមានផលទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះ
ទេ ។ បេ ។

(៦៦៩) ន វត្តព្វំ សត្តមិទំ កម្មតោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

កម្មុនា វត្តតី លោកោ កម្មុនា វត្តតី បជា
កម្មនិពន្ធនា សត្តា រថស្សាណីវ យាយតោ
កម្មេន កិត្តឹ លភតេ បសំសំ
កម្មេន ជានិញ្ច វធញ្ច ពន្ធំ
តំ កម្មំ នានាករណំ វិទិត្វា
កស្មា វទេ នត្ថិ កម្មន្តិ លោកេតិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ សត្តមិទំ កម្មតោតិ ។

សត្តមិទំ កម្មតោតិកថា ។

ឥន្ទ្រិយពទ្ធកថា

(៦៧០) ឥន្ទ្រិយពទ្ធញ្ញេវ ទុក្ខន្តិ ។ អាមន្តា ។ ឥន្ទ្រិយពទ្ធញ្ញេវ អនិច្ចំ សង្ខតំ បដិច្ចសមុប្បន្នំ ខយធម្មំ វយធម្មំ វិរាគធម្មំ និរោធធម្មំ វិបរិណាមធម្មន្តិ ។

(៦៦៩) បុគ្គលមិនគួរនិយាយថា សត្វលោកនេះ មាន ព្រោះកម្មទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ត្រាស់ថា

លោក ប្រព្រឹត្តទៅដោយកម្ម ពពួកសត្វប្រព្រឹត្តទៅដោយកម្ម
សត្វទាំងឡាយ មានកម្មជាចំណង (ហេតុ) ដូចជាស្រែកទប់
របស់រថកាលប្រព្រឹត្តទៅ បុគ្គល រមែងបាននូវកិត្តិសព្ទដោយ
កម្ម បាននូវសេចក្តីសរសើរដោយកម្ម បាននូវសេចក្តីវិនាស
ផង បាននូវសេចក្តីបៀតបៀនផង បាននូវការជាប់ចំណងផង
ក៏ដោយកម្ម បុគ្គល បានដឹងនូវកម្មនោះថា មានកំណើតផ្សេង ៗ
គ្នាហើយ ហេតុអ្វីក៏និយាយថា កម្ម មិនមាន ក្នុងលោក

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ធម្មជាតទាំងអស់នេះ មាន ព្រោះកម្ម ។

ចប់ សត្តមិទំ កម្មតោតិកថា ។

ឥន្ទ្រិយពទ្ធកថា

(៦៧០) ធម្មជាតដែលជាប់ទាក់ទងដោយឥន្ទ្រិយ ទើបជាទុក្ខឬ ។ អើ ។ ធម្មជាតដែលជាប់ទាក់ទងដោយឥន្ទ្រិយ ជារបស់មិនទៀង មានបច្ច័យតាក់តែង កើតឡើងព្រោះអាស្រ័យហេតុ មានការអស់ទៅជាធម្មតា មានការសូន្យទៅជាធម្មតា មានការសាបរលាបទៅជាធម្មតា មានការរលត់ទៅជាធម្មតា មានការប្រែប្រួលទៅជាធម្មតាដែរឬ ។

ន ហេវំ វត្តព្វេ ។ បេ ។ ននុ អនិន្ទ្រិយពទ្ធំ អនិច្ចំ សង្ខតំ បដិច្ចសមុប្បន្នំ ខយធម្មំ វយធម្មំ វិរាគធម្មំ និរោធធម្មំ វិបរិណាមធម្មន្តិ ។ អាមន្តា ។ ហញ្ចិ អនិន្ទ្រិយពទ្ធំ អនិច្ចំ សង្ខតំ បដិច្ចសមុប្បន្នំ ខយធម្មំ វយធម្មំ វិរាគធម្មំ និរោធធម្មំ វិបរិណាមធម្មំ តេន វត រេ វត្តព្វេ ឥន្ទ្រិយពទ្ធញ្ញេវ ទុក្ខន្តិ ។

(៤៧១) អនិន្ទ្រិយពទ្ធំ អនិច្ចំ សង្ខតំ បដិច្ចសមុប្បន្នំ ។ បេ ។ វិបរិណាមធម្មំ តញ្ច ន ទុក្ខន្តិ ។ អាមន្តា ។ ឥន្ទ្រិយពទ្ធំ អនិច្ចំ សង្ខតំ ។ បេ ។ វិបរិណាមធម្មំ តញ្ច ន ទុក្ខន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ឥន្ទ្រិយពទ្ធំ អនិច្ចំ សង្ខតំ ។ បេ ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក៏ធម្មជាតដែលមិនជាប់ទាក់ទងដោយឥន្ទ្រិយ [1] ជារបស់មិនទៀង មានបច្ច័យតាក់តែង កើតឡើងដោយអាស្រ័យហេតុ មានការអស់ទៅជាធម្មតា មានការសូន្យទៅជាធម្មតា មានការសាបរលាបទៅជាធម្មតា មានការរលត់ទៅជាធម្មតា មានការប្រែប្រួលទៅជាធម្មតាដែរឬ ។ អើ ។ ប្រសិនបើ ធម្មជាតដែលមិនជាប់ទាក់ទងដោយឥន្ទ្រិយ ជារបស់មិនទៀង មានបច្ច័យតាក់តែង កើតឡើងដោយអាស្រ័យហេតុ មានការអស់ទៅជាធម្មតា មានការសូន្យទៅជាធម្មតា មានការសាបរលាបទៅជាធម្មតា មានការរលត់ទៅជាធម្មតា មានការប្រែប្រួលទៅជាធម្មតាមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ធម្មជាតដែលជាប់ទាក់ទងដោយឥន្ទ្រិយ ទើបជាទុក្ខទេ ។

(៤៧២) ធម្មជាតដែលមិនជាប់ទាក់ទងដោយឥន្ទ្រិយ ជារបស់មិនទៀង មានបច្ច័យតាក់តែង កើតឡើងដោយអាស្រ័យហេតុ ។ បេ ។ មានការប្រែប្រួលទៅជាធម្មតា នោះឯង មិនមែនជាទុក្ខទេឬ ។ អើ ។ ធម្មជាតដែលជាប់ទាក់ទងដោយឥន្ទ្រិយ ជារបស់មិនទៀង មានបច្ច័យតាក់តែង ។ បេ ។ មានការប្រែប្រួលទៅជាធម្មតា នោះឯង មិនមែនជាទុក្ខទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ធម្មជាតដែលជាប់ទាក់ទងដោយឥន្ទ្រិយ ជារបស់មិនទៀង មានបច្ច័យតាក់តែង ។ បេ ។

១ ដែនដី ភ្នំ ថ្មនិងដើម ជារបស់មិនជាប់ដោយឥន្ទ្រិយ គឺមិនមានឥន្ទ្រិយ ។

វិបរិណាមធម្មំ តញ្ច ទុក្ខន្តិ ។ អាមន្តា ។ អនិន្ទ្រិយ-ពទ្ធំ អនិច្ចំ សង្ខតំ ។ បេ ។ វិបរិណាមធម្មំ តញ្ច ទុក្ខន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(២៧២) ឥន្ទ្រិយពទ្ធញ្ចេវ ទុក្ខន្តិ ។ អាមន្តា ។ ននុ យទនិច្ចំ តំ ទុក្ខំ វុត្តំ ភគវតា អនិន្ទ្រិយពទ្ធំ អនិច្ចន្តិ ។ អាមន្តា ។ ហញ្ចិ យទនិច្ចំ តំ ទុក្ខំ វុត្តំ ភគវតា អនិន្ទ្រិយពទ្ធំ អនិច្ចំ តេន វត រេ វត្តព្វេ ឥន្ទ្រិយពទ្ធញ្ចេវ ទុក្ខន្តិ ។

(២៧៣) ន វត្តព្វំ ឥន្ទ្រិយពទ្ធញ្ចេវ ទុក្ខន្តិ ។ អាមន្តា ។ យថា ឥន្ទ្រិយពទ្ធស្ស ទុក្ខស្ស បរិញ្ញាយ ភគវតិ ព្រហ្មចរិយំ វុស្សតិ ឯវមេវ អនិន្ទ្រិយពទ្ធស្ស ទុក្ខស្ស បរិញ្ញាយ ភគវតិ ព្រហ្មចរិយំ វុស្សតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

មានការប្រែប្រួលទៅជាធម្មតា នោះឯង ជាទុក្ខឬ ។ អើ ។ របស់ដែលមិនជាប់ទាក់ទងដោយឥន្ទ្រិយ ជារបស់មិនទៀង មានបច្ច័យតាក់តែង ។ បេ ។ មានការប្រែប្រួលទៅជាធម្មតា នោះឯង ជាទុក្ខដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(២៧២) ធម្មជាតដែលជាប់ទាក់ទងដោយឥន្ទ្រិយ ទើបជាទុក្ខឬ ។ អើ ។ តែព្រះមានព្រះភាគ ទ្រង់ត្រាស់ថា របស់ណាមិនទៀង របស់នោះ ជាទុក្ខ ធម្មជាតដែលមិនជាប់ទាក់ទងដោយឥន្ទ្រិយ ជារបស់មិនទៀងឬ ។ អើ ។ ប្រសិនបើព្រះមានព្រះភាគ ទ្រង់ត្រាស់ថា របស់ណាមិនទៀង របស់នោះជាទុក្ខ ធម្មជាតដែលមិនជាប់ទាក់ទងដោយឥន្ទ្រិយ ជារបស់មិនទៀងមែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ធម្មជាតដែលជាប់ទាក់ទងដោយឥន្ទ្រិយ ទើបជាទុក្ខទេ ។

(២៧៣) បុគ្គលមិនគួរនិយាយថា ធម្មជាតដែលជាប់ទាក់ទងដោយឥន្ទ្រិយ ទើបជាទុក្ខទេឬ ។ អើ ។ បុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមានព្រះភាគ ដោយការកំណត់ដឹងនូវទុក្ខ ដែលជាប់ទាក់ទងដោយឥន្ទ្រិយ យ៉ាងណា បុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមានព្រះភាគ ដោយការកំណត់ដឹងនូវទុក្ខ ដែលមិនជាប់ទាក់ទងដោយឥន្ទ្រិយ ក៏យ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

យថា ឥន្ទ្រិយពទ្ធំ ទុក្ខំ បរិញ្ញាតំ ន បុន ឧប្បជ្ជតិ ឯវមេវ អនិន្ទ្រិយពទ្ធំ ទុក្ខំ បរិញ្ញាតំ ន បុន ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។បេ។ តេន ហិ ឥន្ទ្រិយពទ្ធញ្ញេវ ទុក្ខន្តិ ។

ឥន្ទ្រិយពទ្ធកថា ។

ឋបេត្វា អរិយមគ្គិកថា

(៤៧៤) ឋបេត្វា អរិយមគ្គំ អវសេសា សង្ខារា ទុក្ខន្តិ ។ អាមន្តា ។ ទុក្ខសមុទយោបិ ទុក្ខោតិ ។ ន ហេវំ វត្តព្វេ ។បេ។ ទុក្ខសមុទយោបិ ទុក្ខោតិ ។ អាមន្តា ។ តីណេវ អរិយសច្ចានីតិ ។ ន ហេវំ វត្តព្វេ ។បេ។ តីណេវ អរិយសច្ចានីតិ ។ អាមន្តា ។ ននុ ចត្តារិ អរិយសច្ចានិ វុត្តានិ ភគវតា ទុក្ខំ ទុក្ខសមុទយោ ទុក្ខនិរោធោ ទុក្ខនិរោធគាមិនី បដិបទាតិ ។ អាមន្តា ។ ហញ្ចិ ចត្តារិ អរិយសច្ចានិ វុត្តានិ ភគវតា ទុក្ខំ ទុក្ខសមុទយោ ទុក្ខនិរោធោ ទុក្ខនិរោធគាមិនី បដិបទា នោ ច វត រេ វត្តព្វេ តីណេវ អរិយសច្ចានីតិ ។

ទុក្ខ ដាច់ខាតចេញដោយឥន្ទ្រិយ ដែលបុគ្គលកំណត់ដឹងហើយ មិនកើតឡើងទៀត យ៉ាងណា ទុក្ខ មិនដាច់ខាតចេញដោយឥន្ទ្រិយ ដែលបុគ្គលកំណត់ដឹងហើយ មិនកើតឡើងទៀត គឺយ៉ាងនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ ធម្មជាតដែលដាច់ខាតចេញដោយឥន្ទ្រិយ ទើបជាទុក្ខមែន ។

ចប់ ឥន្ទ្រិយពទ្ធកថា ។

ឋបេត្វា អរិយមគ្គិកថា

(៤៧៤) សង្ខារទាំងឡាយដ៏សេសសល់ លើកលែងតែអរិយមគ្គចេញ ជាទុក្ខឬ ។ អើ ។ ចុះទុក្ខសមុទយៈ ក៏ជាទុក្ខដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ចុះទុក្ខសមុទយៈ ក៏ជាទុក្ខដែរឬ ។ អើ ។ អរិយសច្ច មានតែ ៣ យ៉ាងទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ អរិយសច្ច មានតែ ៣ យ៉ាងទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា អរិយសច្ច មាន ៤ យ៉ាង គឺ ទុក្ខ ១ ទុក្ខសមុទយៈ ១ ទុក្ខនិរោធ ១ ទុក្ខនិរោធគាមិនីបដិបទា ១ ឬ ។ អើ ។ ប្រសិនបើព្រះមានព្រះភាគ ទ្រង់ត្រាស់ថា អរិយសច្ច មាន ៤ យ៉ាង គឺ ទុក្ខ ១ ទុក្ខសមុទយៈ ១ ទុក្ខនិរោធ ១ ទុក្ខនិរោធគាមិនីបដិបទា ១ មែន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា អរិយសច្ច មានតែ ៣ យ៉ាងទេ ។

(២៨៦) ន វត្តព្វំ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិ ។ អាមន្តា ។ ននុ សង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។ អាមន្តា ។ ហញ្ចិ សង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស តេន វត រេ វត្តព្វេ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិ ។

(២៨៧) ន វត្តព្វំ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិ ។ អាមន្តា ។ ននុ ចត្តារោ បុរិសយុគា អដ្ឋ បុរិសបុគ្គលា ទក្ខិណេយ្យា វុត្តា ភគវតាតិ ។ អាមន្តា ។ ហញ្ចិ ចត្តារោ បុរិសយុគា អដ្ឋ បុរិសបុគ្គលា ទក្ខិណេយ្យា វុត្តា ភគវតា តេន វត រេ វត្តព្វេ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិ ។

(២៨៦) បុគ្គលមិនគួរនិយាយថា សង្ឃ ទទួលទក្ខិណាទានបាន ទេឬ ។ អើ ។ ក្រែងសង្ឃ ជាអាហុនេយ្យបុគ្គល បាហុនេយ្យបុគ្គល ទក្ខិណេយ្យបុគ្គល អញ្ជលិករណីយបុគ្គល ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោកឬ ។ អើ ។ ប្រសិនបើសង្ឃ ជាអាហុនេយ្យបុគ្គល បាហុនេយ្យបុគ្គល ទក្ខិណេយ្យបុគ្គល អញ្ជលិករណីយបុគ្គល ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោកមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃ ទទួលទក្ខិណាទានបាន ។

(២៨៧) បុគ្គលមិនគួរនិយាយថា សង្ឃ ទទួលទក្ខិណាទានបាន ទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បុរសបួនគូ ឬ បុរសបុគ្គលប្រាំបីពួក ជាទក្ខិណេយ្យបុគ្គលឬ ។ អើ ។ ប្រសិនបើព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បុរសបួនគូ ឬ បុរសបុគ្គលប្រាំបីពួក ជាទក្ខិណេយ្យបុគ្គលមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃ ទទួលទក្ខិណាទានបាន ។

(៦៧៩) ន វត្តព្វំ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិ ។ អាមន្តា ។ ននុ អត្ថិ កេចិ សង្ឃស្ស ទានំ ទេន្តីតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ កេចិ សង្ឃស្ស ទានំ ទេន្តិ តេន វត រេ វត្តព្វេ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិ ។ ននុ អត្ថិ កេចិ សង្ឃស្ស ចីវរំ ទេន្តិ ។បេ។ បិណ្ឌបាតំ ទេន្តិ សេនាសនំ ទេន្តិ គិលានប្បច្ចយភេសជ្ជបរិក្ខារំ ទេន្តិ ខាទនីយំ ទេន្តិ ភោជនីយំ ទេន្តិ ។បេ។ បានីយំ ទេន្តីតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ កេចិ សង្ឃស្ស បានីយំ ទេន្តិ តេន វត រេ វត្តព្វេ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិ ។

(៦៨០) ន វត្តព្វំ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

អាហុតិ ជាតវេទោវ មហាមេឃោវ មេទនី
សង្ឃោ សមាធិសម្បន្នោ បដិគ្គណ្ហាតិ ទក្ខិណន្តិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិ ។

(៦៧៩) បុគ្គលមិនគួរនិយាយថា សង្ឃ ទទួលទក្ខិណាទានបាន ទេឬ ។ អើ ។ ក្រែងជនពួកខ្លះ ឲ្យទានដល់សង្ឃ មានដែរឬ ។ អើ ។ ប្រសិនបើ ជនពួកខ្លះ ឲ្យទានដល់សង្ឃ មានដែរ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃ ទទួលទក្ខិណាទានបាន ។ ក្រែងជនពួកខ្លះ ឲ្យចីវរ ។បេ។ ឲ្យបិណ្ឌបាត ឲ្យសេនាសនៈ ឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារ ឲ្យខាទនីយៈ ឲ្យភោជនីយៈ ។បេ។ ឲ្យទឹកគួរផឹក ដល់សង្ឃ មានដែរឬ ។ អើ ។ ប្រសិនបើ ជនពួកខ្លះ ឲ្យទឹកគួរផឹក ដល់សង្ឃ មានមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃ ទទួលទក្ខិណាទានបាន ។

(៦៨០) បុគ្គលមិនគួរនិយាយថា សង្ឃ ទទួលទក្ខិណាទានបាន ទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

សង្ឃ បរិបូណ៌ដោយសមាធិ ទទួលទក្ខិណាទាន បីដូចជា
ភ្លើងទទួលគ្រឿងបូជា ឬ ដូចជាផែនដីទទួលភ្លៀងធំ

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ សង្ឃ ទទួលទក្ខិណាទានបាន ។

(៤៩១) សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិ ។ អា-
មន្តា ។ មគ្គោ បដិគ្គណ្ហាតិ ផលំ បដិគ្គណ្ហាតីតិ ។
ន ហេវំ វត្តព្វេ ។បេ។

៧ វគ្គំ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិកថា ។

៨ វគ្គំ សង្ឃោ ទក្ខិណំ វិសោធេតីតិកថា

(៤៩២) ន វត្តព្វំ សង្ឃោ ទក្ខិណំ វិសោធេ-
តីតិ ។ អាមន្តា ។ ននុ សង្ឃោ អាហុនេយ្យោ បា-
ហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អ-
នុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។ អាមន្តា ។ ហញ្ចិ
សង្ឃោ អាហុនេយ្យោ ។បេ។ អនុត្តរំ បុញ្ញក្ខេត្តំ
លោកស្ស តេន វត រេ វត្តព្វេ សង្ឃោ ទក្ខិណំ
វិសោធេតីតិ ។

(៤៩៣) ន វត្តព្វំ សង្ឃោ ទក្ខិណំ វិសោធេ-
តីតិ ។ អាមន្តា ។ ននុ ចត្តារោ បុរិសយុគា អដ្ឋ
បុរិសបុគ្គលា ទក្ខិណេយ្យា វុត្តា ភគវតាតិ ។
អាមន្តា ។ ហញ្ចិ ចត្តារោ បុរិសយុគា អដ្ឋ បុរិស-
បុគ្គលា ទក្ខិណេយ្យា វុត្តា ភគវតា តេន វត រេ
វត្តព្វេ សង្ឃោ ទក្ខិណំ វិសោធេតីតិ ។

(៤៩១) សង្ឃ ទទួលនូវទក្ខិណាដែរឬ ។ អើ ។ មគ្គ ទទួល
ទក្ខិណាទាន ផល ទទួលទក្ខិណាទានដែរឬ ។ អ្នកមិនគួរពោល
យ៉ាងនេះទេ ។បេ។

ចប់ ៧ វគ្គំ សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតីតិកថា ។

៨ វគ្គំ សង្ឃោ ទក្ខិណំ វិសោធេតីតិកថា

(៤៩២) បុគ្គលមិនគួរនិយាយថា សង្ឃ ញុំាងទក្ខិណាទានឲ្យស្អាត
ទេឬ ។ អើ ។ ក្រែងសង្ឃ ជាអាហុនេយ្យបុគ្គល បាហុនេយ្យបុគ្គល
ទក្ខិណេយ្យបុគ្គល អញ្ជលិករណីយបុគ្គល ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់
សត្វលោកឬ ។ អើ ។ ប្រសិនបើ សង្ឃ ជាអាហុនេយ្យបុគ្គល ។បេ។
ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោកមែន ម្នាលអ្នកដ៏ចម្រើន ព្រោះ
ហេតុនោះ អ្នកគួរពោលថា សង្ឃ ញុំាងទក្ខិណាទានឲ្យស្អាត ។

(៤៩៣) បុគ្គលមិនគួរនិយាយថា សង្ឃ ញុំាងទក្ខិណាទានឲ្យ
ស្អាតទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បុរសបួនគូ
ឬ បុរសបុគ្គលប្រាំបីរូប ជាទក្ខិណេយ្យបុគ្គលឬ ។ អើ ។ ប្រសិនបើ
ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បុរសបួនគូ ឬ បុរសបុគ្គលប្រាំបីរូប
ជាទក្ខិណេយ្យបុគ្គលមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរ
ពោលថា សង្ឃ ញុំាងទក្ខិណាទានឲ្យស្អាត ។

(៤៨៤) ន វត្តព្វំ សង្ឃោ ទក្ខិណំ វិសោធេតីតិ ។ អាមន្តា ។ ននុ អត្ថិ កេចិ សង្ឃស្ស ទានំ ទត្វា ទក្ខិណំ អារាធេន្តីតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ កេចិ សង្ឃស្ស ទានំ ទត្វា ទក្ខិណំ អារាធេន្តិ តេន វត រេ វត្តព្វេ សង្ឃោ ទក្ខិណំ វិសោធេតីតិ ។

(៤៨៥) ននុ អត្ថិ កេចិ សង្ឃស្ស ចីវរំ ទត្វា ។ បេ ។ បិណ្ឌបាតំ ទត្វា ។ បេ ។ សេនាសនំ ទត្វា គិលានប្បច្ចយភេសជ្ជបរិក្ខារំ ទត្វា ខាទនីយំ ទត្វា ភោជនីយំ ទត្វា ។ បេ ។ បានីយំ ទត្វា ទក្ខិណំ អារាធេន្តីតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ កេចិ សង្ឃស្ស បានីយំ ទត្វា ទក្ខិណំ អារាធេន្តិ តេន វត រេ វត្តព្វេ សង្ឃោ ទក្ខិណំ វិសោធេតីតិ ។

(៤៨៦) សង្ឃោ ទក្ខិណំ វិសោធេតីតិ ។ អាមន្តា ។ មគ្គោ វិសោធេតិ ផលំ វិសោធេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ន វត្តព្វំ សង្ឃោ ទក្ខិណំ វិសោធេតីតិកថា ។

(៤៨៤) បុគ្គលមិនគួរពោលថា សង្ឃ ញុំាងទក្ខិណាទានឲ្យស្អាតទេឬ ។ អើ ។ ក្រែងពួកខ្លះ បានឲ្យទានដល់សង្ឃ ហើយញុំាងសង្ឃឲ្យត្រេកអរនឹងទក្ខិណាទាន មានដែរឬ ។ អើ ។ ប្រសិនបើ ជនពួកខ្លះ បានឲ្យទានដល់សង្ឃ ហើយញុំាងសង្ឃឲ្យត្រេកអរនឹងទក្ខិណាទាន មានមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃ ញុំាងទក្ខិណាទានឲ្យស្អាត ។

(៤៨៥) ក្រែងជនពួកខ្លះ បានឲ្យចីវរ ។ បេ ។ ឲ្យបិណ្ឌបាត ។ បេ ។ ឲ្យសេនាសនៈ ឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារ ឲ្យខាទនីយៈ ឲ្យភោជនីយៈ ។ បេ ។ ឲ្យទឹកគួរផឹក ដល់សង្ឃ ហើយញុំាងសង្ឃឲ្យត្រេកអរនឹងទក្ខិណាទាន មានដែរឬ ។ អើ ។ ប្រសិនបើ ជនពួកខ្លះ បានឲ្យទឹកគួរផឹក ដល់សង្ឃ ហើយញុំាងសង្ឃឲ្យត្រេកអរនឹងទក្ខិណាទាន មានមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃ ញុំាងទក្ខិណាទានឲ្យស្អាត ។

(៤៨៦) សង្ឃ ញុំាងទក្ខិណាទានឲ្យស្អាតឬ ។ អើ ។ មគ្គ ញុំាងទក្ខិណាទានឲ្យស្អាត ផល ញុំាងទក្ខិណាទានឲ្យស្អាតដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ ន វត្តព្វំ សង្ឃោ ទក្ខិណំ វិសោធេតីតិកថា ។

ន វត្តព្វំ សង្ឃោ ភុញ្ជតីតិកថា

(៤៨៧) ន វត្តព្វំ សង្ឃោ ភុញ្ជតិ បិវតិ ខាទតិ សាយតីតិ ។ អាមន្តា ។ ននុ អត្ថិ កេចិ សង្ឃភត្តានិ ករោន្តិ ឧទ្ទេសភត្តានិ ករោន្តិ យាគុបានានិ ករោន្តីតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ កេចិ សង្ឃភត្តានិ ករោន្តិ ឧទ្ទេសភត្តានិ ករោន្តិ យាគុបានានិ ករោន្តិ តេន វត រេ វត្តព្វេ សង្ឃោ ភុញ្ជតិ បិវតិ ខាទតិ សាយតីតិ ។

(៤៨៨) ន វត្តព្វំ សង្ឃោ ភុញ្ជតិ បិវតិ ខាទតិ សាយតីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា គណភោជនំ បរម្បរភោជនំ អតិរិត្តភោជនំ អនតិរិត្តភោជនន្តិ ។ អាមន្តា ។ ហញ្ចិ វុត្តំ ភគវតា គណភោជនំ បរម្បរភោជនំ អតិរិត្តភោជនំ អនតិរិត្តភោជនំ តេន វត រេ វត្តព្វេ សង្ឃោ ភុញ្ជតិ បិវតិ ខាទតិ សាយតីតិ ។

(៤៨៩) ន វត្តព្វំ សង្ឃោ ភុញ្ជតិ បិវតិ ខាទតិ សាយតីតិ ។ អាមន្តា ។ ននុ អដ្ឋ បានានិ វុត្តានិ ភគវតា អម្ពបានំ ជម្ពុបានំ ចោចបានំ មោចបានំ មធុបានំ មុទ្ទិកបានំ សាលុកបានំ

ន វត្តព្វំ សង្ឃោ ភុញ្ជតីតិកថា

(៤៨៧) បុគ្គលមិនគួរនិយាយថា សង្ឃ បរិភោគ ផឹក ទំពាស៊ី លិទ្ធភ្លក់ទេឬ ។ អើ ។ ក្រែងជនពួកខ្លះ ធ្វើសង្ឃភត្ត ធ្វើឧទ្ទេសភត្ត ធ្វើបបរនិងទឹក មានដែរឬ ។ អើ ។ ប្រសិនបើ ជនពួកខ្លះ ធ្វើសង្ឃភត្ត ធ្វើឧទ្ទេសភត្ត ធ្វើបបរនិងទឹក មានដែរ ម្នាលអ្នកដ៏ចំរើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃ បរិភោគ ផឹក ទំពាស៊ី លិទ្ធភ្លក់ដែរ ។

(៤៨៨) បុគ្គលមិនគួរនិយាយថា សង្ឃ បរិភោគ ផឹក ទំពាស៊ី លិទ្ធភ្លក់ទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា គណភោជន បរម្បរភោជន អតិរិត្តភោជន អនតិរិត្តភោជន មែនឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា គណភោជន បរម្បរភោជន អតិរិត្តភោជន អនតិរិត្តភោជន មែន ម្នាលអ្នកដ៏ចំរើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃ បរិភោគ ផឹក ទំពាស៊ី លិទ្ធភ្លក់ដែរ ។

(៤៨៩) បុគ្គលមិនគួរនិយាយថា សង្ឃ បរិភោគ ផឹក ទំពាស៊ី លិទ្ធភ្លក់ ទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ទឹកបាន ប្រាំបីយ៉ាងគឺ ទឹកផ្លែស្វាយ ទឹកផ្លែព្រីង ទឹកផ្លែចេកមានគ្រាប់ ទឹកផ្លែចេកឥតគ្រាប់ ទឹកផ្លែស្រគំ ទឹកផ្លែចន ទឹកក្រអៅឈូក

ផារុសកបានន្តិ ។ អាមន្តា ។ ហញ្ចិ អដ្ឋ បានានិ វុត្តានិ ភគវតា អម្ពបានំ ជម្ពុបានំ ចោចបានំ មោចបានំ មធុបានំ មុទ្ទិកបានំ សាលុកបានំ ផារុសកបានំ តេន វត រេ វត្តព្វេ សង្ឃោ ភុញ្ជតិ បិវតិ ខាទតិ សាយតីតិ ។

(៤៩០) សង្ឃោ ភុញ្ជតិ បិវតិ ខាទតិ សាយតីតិ ។ អាមន្តា ។ មគ្គោ ភុញ្ជតិ បិវតិ ខាទតិ សាយតិ ផលំ ភុញ្ជតិ បិវតិ ខាទតិ សាយតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ន វត្តព្វំ សង្ឃោ ភុញ្ជតីតិកថា ។

ន វត្តព្វំ សង្ឃស្ស ទិន្នំ មហប្ផលន្តិកថា

(៤៩១) ន វត្តព្វំ សង្ឃស្ស ទិន្នំ មហប្ផលន្តិ ។ អាមន្តា ។ ននុ សង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។ អាមន្តា ។ ហញ្ចិ សង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស តេន វត រេ វត្តព្វេ សង្ឃស្ស ទិន្នំ មហប្ផលន្តិ ។

ទឹកផ្លែមាក់ប្រាង ដែរឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ទឹកបាន ប្រាំបីយ៉ាងគឺ ទឹកផ្លែស្វាយ ទឹកផ្លែព្រីង ទឹកផ្លែចេកមានគ្រាប់ ទឹកផ្លែចេកឥតគ្រាប់ ទឹកផ្លែស្រកំ ទឹកផ្លែចិន ទឹកក្រអៅឈូក ទឹកផ្លែមាក់ប្រាង មែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា សង្ឃ បរិភោគ ផឹក ទំពាស៊ី លិទ្ធភ្លក់ដែរ ។

(៤៩០) សង្ឃ បរិភោគ ផឹក ទំពាស៊ី លិទ្ធភ្លក់ ដែរឬ ។ អើ ។ មគ្គ បរិភោគ ផឹក ទំពាស៊ី លិទ្ធភ្លក់ ផល បរិភោគ ផឹក ទំពាស៊ី លិទ្ធភ្លក់ ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ ន វត្តព្វំ សង្ឃោ ភុញ្ជតីតិកថា ។

ន វត្តព្វំ សង្ឃស្ស ទិន្នំ មហប្ផលន្តិកថា

(៤៩១) បុគ្គលមិនគួរនិយាយថា ទាន ដែលបុគ្គលឲ្យដល់សង្ឃ ជាទានមានផលច្រើនទេឬ ។ អើ ។ ក្រែងព្រះសង្ឃ ជាអាហុនេយ្យបុគ្គល បាហុនេយ្យបុគ្គល ទក្ខិណេយ្យបុគ្គល អញ្ជលិករណីយបុគ្គល ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោកដែរឬ ។ អើ ។ ប្រសិនបើ ព្រះសង្ឃ ជាអាហុនេយ្យបុគ្គល បាហុនេយ្យបុគ្គល ។ បេ ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោកមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ទាន ដែលបុគ្គលឲ្យដល់សង្ឃ ជាទានមានផលច្រើនមែន ។

(៤៩២) ន វត្តព្វំ សង្ឃស្ស ទិន្នំ មហប្ផលន្តិ ។ អាមន្តា ។ ននុ ចត្តារោ បុរិសយុគា អដ្ឋ បុរិសបុគ្គលា ទក្ខិណេយ្យា វុត្តា ភគវតាតិ ។ អាមន្តា ។ ហញ្ចិ ចត្តារោ បុរិសយុគា អដ្ឋ បុរិសបុគ្គលា ទក្ខិណេយ្យា វុត្តា ភគវតា តេន វត រេ វត្តព្វេ សង្ឃស្ស ទិន្នំ មហប្ផលន្តិ ។

(៤៩៣) ន វត្តព្វំ សង្ឃស្ស ទិន្នំ មហប្ផលន្តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា សង្ឃេ គោតមិ ទេហិ សង្ឃេ តេ ទិន្នេ អហញ្ចេវ បូជិតោ ភវិស្សាមិ សង្ឃោ ចាតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ សង្ឃស្ស ទិន្នំ មហប្ផលន្តិ ។

(៤៩៤) ន វត្តព្វំ សង្ឃស្ស ទិន្នំ មហប្ផលន្តិ ។ អាមន្តា ។ ននុ សក្កោ ទេវានមិន្ទោ ភគវន្តំ ឯតទវោច

(៤៩២) បុគ្គលមិនគួរនិយាយថា ទាន ដែលបុគ្គលឲ្យដល់សង្ឃ ជាទានមានផលច្រើនទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា បុរសបួនគូ បុរសបុគ្គលប្រាំបីរូប ជាទក្ខិណេយ្យបុគ្គលឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បុរសបួនគូ ឬ បុរសបុគ្គលប្រាំបីរូប ជាទក្ខិណេយ្យបុគ្គលមែន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ទាន ដែលបុគ្គលឲ្យដល់សង្ឃ ជាទានមានផលច្រើនមែន ។

(៤៩៣) បុគ្គលមិនគួរនិយាយថា ទាន ដែលបុគ្គលឲ្យដល់សង្ឃ ជាទានមានផលច្រើនទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលគោតមី នាងចូរឲ្យទាន ចំពោះសង្ឃចុះ កាលបើនាងឲ្យទាន ចំពោះសង្ឃហើយ តថាគតឯងក្តី សង្ឃក្តី ក៏ឈ្មោះថានាងបូជាហើយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ទាន ដែលបុគ្គលឲ្យដល់សង្ឃ ជាទានមានផលច្រើនមែន ។

(៤៩៤) បុគ្គលមិនគួរនិយាយថា ទាន ដែលបុគ្គលឲ្យដល់សង្ឃ ជាទានមានផលច្រើនទេឬ ។ អើ ។ ក្រែងព្រះឥន្ទ ជាធំជាងទេវតា បានក្រាបបង្គំទូលព្រះមានព្រះភាគថា

យជមានានំ មនុស្សានំ បុញ្ញបេក្ខាន បាណិនំ

ករោតំ ឱបធិកំ បុញ្ញំ កត្ថ ទិន្នំ មហប្ផលន្តិ

ចត្តារោ ច បដិបន្នា ចត្តារោ ច ផលេ ឋិតា

ឯស សង្ឃោ ឧជុភូតោ បញ្ញាសីលសមាហិតោ

យជមានានំ មនុស្សានំ បុញ្ញបេក្ខាន បាណិនំ

ករោតំ ឱបធិកំ បុញ្ញំ សង្ឃេ ទិន្នំ មហប្ផលន្តិ

ឯសោ ហិ សង្ឃោ វិបុលោ មហគ្គតោ

ឯសប្បមេយ្យោ ឧទធីវ សាគរោ

ឯតេ ហិ សេដ្ឋា នរវីរសាវកា

បភង្ករា ធម្មមុទីរយន្តិ(១)

តេសំ សុទិន្នំ សុហុតំ សុយិដ្ឋំ

យេ សង្ឃមុទ្ទិស្ស ទទន្តិ ទានំ

សា ទក្ខិណា សង្ឃគតា បតិដ្ឋិតា

មហប្ផលា លោកវិទូន វណ្ណិតា

ឯតាទិសំ យញ្ញមនុស្សរន្តា

យេ វេទជាតា វិចរន្តិ លោកេ

វិនេយ្យ មច្ឆេរមលំ សមូលំ

១ ម. ធម្មមុទីរយិស្សុ ។

បុណ្យឲ្យផលក្នុងបច្ចុប្បន្ន ដែលពួកសត្វ គឺមនុស្ស អ្នកប្រាថ្នា
នូវបុណ្យ កាលបូជាធ្វើ គេឲ្យទាន ចំពោះបុគ្គលពួកណា ទើប
មានផលច្រើន បុគ្គលអ្នកប្រតិបត្តិដើម្បីផល ៤ ពួក បុគ្គលអ្នក
ឋិតនៅក្នុងផល ៤ ពួក បុគ្គលទាំងនុ៎ះ ជាសង្ឃ មានចិត្តត្រង់
មានចិត្តតំកល់មាំក្នុងបញ្ញានិងសីល បុណ្យឲ្យផលក្នុងបច្ចុប្បន្ន
ដែលពួកសត្វ គឺមនុស្សអ្នកប្រាថ្នានូវបុណ្យ កាលបូជាធ្វើ គេឲ្យ
ទានចំពោះសង្ឃ ទើបមានផលច្រើន ព្រោះបុគ្គលនុ៎ះ ជាសង្ឃ
មានគុណ ដ៏ធំទូលាយ ដល់នូវភាពដ៏ប្រសើរ សង្ឃនុ៎ះ មាន
គុណរាប់មិនបាន ដូចជាសាគរគ្រប់គ្រងនូវទឹក សង្ឃទាំងនុ៎ះឯង
ជាសាវ័ក របស់ព្រះពុទ្ធមានព្យាយាមជានរៈ អ្នកប្រសើរបំផុត
ជាអ្នកធ្វើនូវពន្លឺ រមែងសំដែងនូវធម៌ ទាន ដែលគេឲ្យដោយល្អ
ដែលគេបូជាតូចដោយល្អ ដែលគេបូជាធំដោយល្អ ចំពោះសង្ឃ
ទាំងនោះ (រមែងមានផលច្រើន) ពួកជនណា ឲ្យទាន ឧទ្ទិស
ចំពោះសង្ឃ ទក្ខិណាទាននោះ (របស់ពួកជននោះ) ឈ្មោះថា
តាំងនៅក្នុងសង្ឃ ជាទានមានផលច្រើន ដែលព្រះពុទ្ធអ្នកជ្រាប
ច្បាស់នូវលោក ទ្រង់សរសើរហើយ ពួកជនណា កាលរឭក
ឃើញនូវការបូជា ដូច្នោះហើយ ជាអ្នកមានចិត្តត្រេកអរ តែង
កំចាត់បង់នូវមន្ទិលគឺសេចក្ដីកំណាញ់ ព្រមទាំងឫស ក្នុងលោក

(២៩៦) ន វត្តព្វំ ពុទ្ធស្ស ទិន្នំ មហប្ផលន្តិ ។ អាមន្តា ។ អត្ថិ កោចិ ពុទ្ធេន សមសមោ សីលេន សមាធិនា បញ្ញាយាតិ ។ នត្ថិ ។ ហញ្ចិ នត្ថិ កោចិ ពុទ្ធេន សមសមោ សីលេន សមាធិនា បញ្ញាយ តេន វត រេ វត្តព្វេ ពុទ្ធស្ស ទិន្នំ មហប្ផលន្តិ ។

(២៩៧) ន វត្តព្វំ ពុទ្ធស្ស ទិន្នំ មហប្ផលន្តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

ឥមស្មឹ វា លោកស្មឹ បរស្មឹ វា បន
ពុទ្ធេន សេដ្ឋោ ច សមោ ច វិជ្ជតិ
យមាហុនេយ្យានំ អគ្គតំ គតោ
បុញ្ញត្ថិកានំ វិបុលផលេសិនន្តិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ពុទ្ធស្ស ទិន្នំ មហប្ផលន្តិ ។

ន វត្តព្វំ ពុទ្ធស្ស ទិន្នំ មហប្ផលន្តិកថា ។

(២៩៦) បុគ្គលមិនគួរនិយាយថា ទាន ដែលបុគ្គលថ្វាយចំពោះព្រះពុទ្ធ ជាទានមានផលច្រើនទេឬ ។ អើ ។ បុគ្គលណាមួយ សមស្មើនឹងព្រះពុទ្ធ ដោយសីល សមាធិ និងបញ្ញា មានដែរឬ ។ មិនមានទេ ។ ប្រសិនបើ បុគ្គលណាមួយ សមស្មើនឹងព្រះពុទ្ធ ដោយសីល សមាធិ និងបញ្ញា មិនមានទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ទាន ដែលបុគ្គលថ្វាយចំពោះព្រះពុទ្ធ ជាទានមានផលច្រើន ។

(២៩៧) បុគ្គលមិនគួរនិយាយថា ទាន ដែលបុគ្គលថ្វាយចំពោះព្រះពុទ្ធ ជាទានមានផលច្រើនទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

បុគ្គល ប្រសើរជាងព្រះពុទ្ធក្តី ស្មើនឹងព្រះពុទ្ធក្តី មិនមានក្នុង
លោកនេះ និងក្នុងលោកខាងមុខឡើយ ព្រោះថា ព្រះពុទ្ធ
ទ្រង់ដល់នូវភាពប្រសើរ ជាងពួកអាហុនេយ្យបុគ្គល របស់ពួក
ជនអ្នកត្រូវការដោយបុណ្យ អ្នកស្វែងរកផលដ៏ធំទូលាយ

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ទាន ដែលបុគ្គលថ្វាយចំពោះព្រះពុទ្ធ ជាទានមានផលច្រើន ។

ចប់ ន វត្តព្វំ ពុទ្ធស្ស ទិន្នំ មហប្ផលន្តិកថា ។

(៤៩៨) ទាយកតោ វ ទក្ខិណា វិសុជ្ឈតិ នោ បដិគ្គាហកតោតិ ។ អាមន្តា ។ ននុ អត្ថិ កេចិ បដិគ្គាហកា អាហុនេយ្យា បាហុនេយ្យា ទក្ខិណេយ្យា អញ្ជលិករណីយា អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ កេចិ បដិគ្គាហកា អាហុនេយ្យា បាហុនេយ្យា ទក្ខិណេយ្យា អញ្ជលិករណីយា អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស នោ វត រេ វត្តព្វេ ទាយកតោ វ ទក្ខិណា វិសុជ្ឈតិ នោ បដិគ្គាហកតោតិ ។

(៤៩៩) ទាយកតោ វ ទក្ខិណា វិសុជ្ឈតិ នោ បដិគ្គាហកតោតិ ។ អាមន្តា ។ ននុ ចត្តារោ បុរិសយុគា អដ្ឋ បុរិសបុគ្គលា ទក្ខិណេយ្យា វុត្តា ភគវតាតិ ។ អាមន្តា ។ ហញ្ចិ ចត្តារោ បុរិសយុគា អដ្ឋ បុរិសបុគ្គលា ទក្ខិណេយ្យា វុត្តា ភគវតា នោ វត រេ វត្តព្វេ ទាយកតោ វ ទក្ខិណា វិសុជ្ឈតិ នោ បដិគ្គាហកតោតិ

(៤៩៨) ទាន បរិសុទ្ធតែអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកៈទេឬ ។ អើ ។ ក្រែងបដិគ្គាហកៈពួកខ្លះ គួរទទួលចតុប្បច្ច័យដែលគេនាំមកបូជា គួរទទួលអាគន្តុកទាន គួរដល់ទក្ខិណាទាន គួរដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ ជាបុញ្ញក្ខេត្ត ដ៏ប្រសើរ របស់សត្វលោក មានដែរឬ ។ អើ ។ ប្រសិនបើ បដិគ្គាហកៈពួកខ្លះ គួរទទួលចតុប្បច្ច័យដែលគេនាំមកបូជា គួរទទួលអាគន្តុកទាន គួរដល់ទក្ខិណាទាន គួរដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ ជាបុញ្ញក្ខេត្ត ដ៏ប្រសើរ របស់សត្វលោក មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ទាន បរិសុទ្ធតែអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកៈទេ ។

(៤៩៩) ទាន បរិសុទ្ធតែអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកៈទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បុរស ៤ គូ ឬ បុរសបុគ្គល ៨ រូប ជាទក្ខិណេយ្យបុគ្គលឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បុរស ៤ គូ ឬ បុរសបុគ្គល ៨ រូប ជាទក្ខិណេយ្យបុគ្គល ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ទាន បរិសុទ្ធតែអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកៈទេ ។

(៣០០) ទាយកតោ វ ទានំ វិសុជ្ឈតិ នោ បដិគ្គាហកតោតិ ។ អាមន្តា ។ ននុ អត្ថិ កោចិ សោតាបន្នេ ទានំ ទត្វា ទក្ខិណំ អារាធេតីតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ កោចិ សោតាបន្នេ ទានំ ទត្វា ទក្ខិណំ អារាធេតិ នោ វត រេ វត្តព្វេ ទាយកតោ វ ទានំ វិសុជ្ឈតិ នោ បដិគ្គាហកតោតិ ។ ននុ អត្ថិ កោចិ សកទាគាមិស្ស ។បេ។ អនាគាមិស្ស ។បេ។ អរហតោ ទានំ ទត្វា ទក្ខិណំ អារាធេតីតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ កោចិ អរហតោ ទានំ ទត្វា ទក្ខិណំ អារាធេតិ នោ វត រេ វត្តព្វេ ទាយកតោ វ ទានំ វិសុជ្ឈតិ នោ បដិគ្គាហកតោតិ ។

(៣០១) បដិគ្គាហកតោ វ ទានំ វិសុជ្ឈតិ នោ ទាយកតោតិ ។ អាមន្តា ។ អញ្ញោ អញ្ញស្ស ការកោ បរកតំ សុខទុក្ខំ អញ្ញោ ករោតិ អញ្ញោ បដិសំវេទេតីតិ ។ ន ហេវំ វត្តព្វេ ។បេ។ ទាយកតោ វ ទានំ វិសុជ្ឈតិ នោ បដិគ្គាហកតោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ចតស្សោ ខោ ឥមា អានន្ទ ទក្ខិណាវិសុទ្ធិយោ ។ កតមា ចតស្សោ ។

(៣០០) ទាន បរិសុទ្ធតែអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកៈ ទេឬ ។ អើ ។ ក្រែងបុគ្គលពួកខ្លះ ឲ្យទាន ចំពោះសោតាបន្នបុគ្គល ហើយញ៉ាំងសោតាបន្នបុគ្គល ឲ្យត្រេកអរ ចំពោះទក្ខិណាទាន មានដែរឬ ។ អើ ។ ប្រសិនបើ បុគ្គលពួកខ្លះ ឲ្យទានចំពោះសោតាបន្នបុគ្គល ហើយញ៉ាំងសោតាបន្នបុគ្គល ឲ្យត្រេកអរ ចំពោះទក្ខិណាទាន មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ទាន បរិសុទ្ធតែអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកៈទេ ។ ក្រែងបុគ្គលពួកខ្លះ ឲ្យទាន ចំពោះសកទាគាមិបុគ្គល ។បេ។ ចំពោះអនាគាមិបុគ្គល ។បេ។ ចំពោះព្រះអរហន្ត ហើយញ៉ាំងព្រះអរហន្ត ឲ្យត្រេកអរ ចំពោះទក្ខិណាទាន មានដែរឬ ។ អើ ។ ប្រសិនបើ បុគ្គលពួកខ្លះ ឲ្យទាន ចំពោះព្រះអរហន្ត ហើយញ៉ាំងព្រះអរហន្ត ឲ្យត្រេកអរ ចំពោះទក្ខិណាទាន មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ទាន បរិសុទ្ធតែអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកៈទេ ។

(៣០១) ទាន បរិសុទ្ធតែអំពីបដិគ្គាហកៈ មិនបរិសុទ្ធអំពីទាយក ទេឬ ។ អើ ។ បុគ្គលដទៃ ជាអ្នកធ្វើ ដល់បុគ្គលដទៃ សុខទុក្ខដែលបុគ្គលដទៃធ្វើ បុគ្គលដទៃ ធ្វើ បុគ្គលដទៃ ទទួលផលឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ទាន បរិសុទ្ធតែអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកៈទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ត្រាស់ថា ម្នាលអានន្ទ ទក្ខិណាវិសុទ្ធិនេះ មាន ៤ យ៉ាង ។ ទក្ខិណាវិសុទ្ធិ ៤ យ៉ាង តើដូចម្តេច ។

អត្ថានន្ទ ទក្ខិណា ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ អត្ថានន្ទ ទក្ខិណា បដិគ្គាហកតោ វិសុជ្ឈតិ នោ ទាយកតោ អត្ថានន្ទ ទក្ខិណា នេវ ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ អត្ថានន្ទ ទក្ខិណា ទាយកតោ ចេវ វិសុជ្ឈតិ បដិគ្គាហកតោ ច កថញ្ចានន្ទ ទក្ខិណា ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ ឥធានន្ទ ទាយកោ ហោតិ សីលវា កល្យាណធម្មោ បដិគ្គាហកា ហោន្តិ ទុស្សីលា បាបធម្មា ឯវំ ខោ អានន្ទ ទក្ខិណា ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ កថញ្ចានន្ទ ទក្ខិណា បដិគ្គាហកតោ វិសុជ្ឈតិ នោ ទាយកតោ ឥធានន្ទ ទាយកោ ហោតិ ទុស្សីលោ បាបធម្មោ បដិគ្គាហកា ហោន្តិ សីលវន្តោ កល្យាណធម្មា ឯវំ ខោ អានន្ទ ទក្ខិណា បដិគ្គាហកតោ វិសុជ្ឈតិ នោ ទាយកតោ កថញ្ចានន្ទ ទក្ខិណា នេវ ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ ឥធានន្ទ ទាយកោ ច ហោតិ ទុស្សីលោ បាបធម្មោ បដិគ្គាហកា ច ហោន្តិ ទុស្សីលា បាបធម្មា ឯវំ ខោ អានន្ទ ទក្ខិណា នេវ ទាយកតោ វិសុជ្ឈតិ

ម្នាលអានន្ទ ទក្ខិណាទាន បរិសុទ្ធអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកៈ ក៏មាន ម្នាលអានន្ទ ទក្ខិណាទាន បរិសុទ្ធអំពីបដិគ្គាហកៈ មិនបរិសុទ្ធអំពីទាយក ក៏មាន ម្នាលអានន្ទ ទក្ខិណាទាន មិនបរិសុទ្ធអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកៈ ក៏មាន ម្នាលអានន្ទ ទក្ខិណាទាន បរិសុទ្ធ អំពីទាយកផង អំពីបដិគ្គាហកៈផង ក៏មាន ម្នាលអានន្ទ ទក្ខិណាទាន បរិសុទ្ធអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកៈ តើដូចម្តេច ម្នាលអានន្ទ ទាយកក្នុងលោកនេះ មានសីល មានធម៌ល្អ ពួកបដិគ្គាហកៈ ទ្រុស្តសីល មានធម៌អាក្រក់ ម្នាលអានន្ទ ទក្ខិណាទាន បរិសុទ្ធអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកៈ យ៉ាងនេះឯង ម្នាលអានន្ទ ទក្ខិណាទាន បរិសុទ្ធអំពីបដិគ្គាហកៈ មិនបរិសុទ្ធអំពីទាយក តើដូចម្តេច ម្នាលអានន្ទ ទាយកក្នុងលោកនេះ ទ្រុស្តសីល មានធម៌អាក្រក់ ពួកបដិគ្គាហកៈ មានសីល មានធម៌ល្អ ម្នាលអានន្ទ ទក្ខិណាទាន បរិសុទ្ធអំពីបដិគ្គាហកៈ មិនបរិសុទ្ធអំពីទាយក យ៉ាងនេះឯង ម្នាលអានន្ទ ទក្ខិណាទាន មិនបរិសុទ្ធអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហកៈ តើដូចម្តេច ម្នាលអានន្ទ ទាយកក្នុងលោកនេះ ទ្រុស្តសីល មានធម៌អាក្រក់ ពួកបដិគ្គាហកៈ ក៏ទ្រុស្តសីល មានធម៌អាក្រក់ដូចគ្នា ម្នាលអានន្ទ ទក្ខិណាទាន មិនបរិសុទ្ធអំពីទាយក

នោ បដិគ្គាហកតោ កថញ្ចានន្ទ ទក្ខិណា ទាយ-
កតោ ចេវ វិសុជ្ឈតិ បដិគ្គាហកតោ ច ឥធានន្ទ
ទាយកោ ច ហោតិ សីលវា កល្យាណធម្មោ បដិគ្គា-
ហកា ច ហោន្តិ សីលវន្តោ កល្យាណធម្មា ឯវំ ខោ
អានន្ទ ទក្ខិណា ទាយកតោ ចេវ វិសុជ្ឈតិ បដិគ្គា-
ហកតោ ច ឥមា ខោ អានន្ទ ចតស្សោ ទក្ខិណា-
វិសុទ្ធិយោតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន
ហិ ន វត្តព្វំ ទាយកតោ វ ទានំ វិសុជ្ឈតិ នោ
បដិគ្គាហកតោតិ ។

ទក្ខិណាវិសុទ្ធិកថា ។

សត្តមោ វគ្គោ ។

តស្ស ឧទ្ទានំ

អត្ថិ អរហតោ បុញ្ញូបចយោ នត្ថិ អរហតោ អកា-
លមច្ចុ សព្វមិទំ កម្មតោ ឥន្ទ្រិយពទ្ធញ្ច ទុក្ខំ
ឋបេត្វា អរិយមគ្គំ អវសេសា សង្ខារា ទុក្ខា
សង្ឃោ ទក្ខិណំ បដិគ្គណ្ហាតិ សង្ឃោ ទក្ខិណំ
វិសោធេតិ សង្ឃោ ភុញ្ជតិ បិវតិ ខាទតិ សាយតិ
សង្ឃស្ស ទិន្នំ មហប្ផលំ អត្ថិ ទានំ វិសុជ្ឈតីតិ ។

មិនបរិសុទ្ធអំពីបដិគ្គាហកៈ យ៉ាងនេះឯង ម្នាលអានន្ទ ទក្ខិណាទាន
បរិសុទ្ធ អំពីទាយកផង អំពីបដិគ្គាហកៈផង តើដូចម្តេច ម្នាលអានន្ទ
ទាយកក្នុងលោកនេះ មានសីល មានធម៌ល្អ ពួកបដិគ្គាហកៈ ក៏មាន
សីល មានធម៌ល្អដូចគ្នា ម្នាលអានន្ទ ទក្ខិណាទាន បរិសុទ្ធ អំពី
ទាយកផង អំពីបដិគ្គាហកៈផង យ៉ាងនេះឯង ម្នាលអានន្ទ ទក្ខិណាវិសុទ្ធិ
មាន ៤ យ៉ាងនេះឯង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។
ព្រោះហេតុនោះ អ្នកមិនគួរពោលថា ទាន បរិសុទ្ធអំពីតែទាយក មិន
បរិសុទ្ធអំពីបដិគ្គាហកៈទេ ។

ចប់ ទក្ខិណាវិសុទ្ធិកថា ។

ចប់ សត្តមវគ្គ ។

ឧទ្ទាននៃសត្តមវគ្គនោះ គឺ

និយាយ អំពីការសន្សំបុណ្យ របស់ព្រះអរហន្ត មាន ១ អកាល-
មច្ចុ របស់ព្រះអរហន្ត មិនមាន ១ ធម្មជាតទាំងអស់នេះមាន ព្រោះ
កម្ម ១ ធម្មជាតជាប់ដោយឥន្ទ្រិយ ជាទុក្ខ ១ សង្ខារដ៏សេស
វៀរលែងតែអរិយមគ្គ ជាទុក្ខ ១ ព្រះសង្ឃ តែងទទួលទក្ខិណា-
ទាន ១ ព្រះសង្ឃ តែងជម្រះទក្ខិណាទាន ១ ព្រះសង្ឃតែង
ឆាន់ ផឹក ទំពាស៊ី ភ្លក់ ១ ទាន ដែលបុគ្គលឲ្យដល់សង្ឃ មាន
ផលច្រើន ១ ទាន បរិសុទ្ធ ក៏មាន ១ ។

មនុស្សលោកកថា

(៣០២) ន វត្តព្វំ ពុទ្ធោ ភគវា មនុស្សលោកេ អដ្ឋាសីតិ ។ អាមន្តា ។ ននុ អត្ថិ ពុទ្ធវុត្ថានិ ចេតិយានិ អារាមវិហារគាមនិគមនគរានិ រដ្ឋានិ ជនបទានីតិ ។ អាមន្តា ។ ហញ្ចិ អត្ថិ ពុទ្ធវុត្ថានិ ចេតិយានិ អារាមវិហារគាមនិគមនគរានិ រដ្ឋានិ ជនបទានិ តេន វត រេ វត្តព្វេ ពុទ្ធោ ភគវា មនុស្សលោកេ អដ្ឋាសីតិ ។

(៣០៣) ន វត្តព្វំ ពុទ្ធោ ភគវា មនុស្សលោកេ អដ្ឋាសីតិ ។ អាមន្តា ។ ននុ ភគវា លុម្ពិនិយា ជាតោ ពោធិយា មូលេ អភិសម្ពុទ្ធោ ពារាណសិយំ ភគវតា ធម្មចក្កំ បវត្តិតំ ចាបាលេ ចេតិយេ អាយុសង្ខារោ ឱស្សដ្ឋោ កុសិនារាយំ ភគវា បរិនិព្វុតោតិ ។ អាមន្តា ។ ហញ្ចិ ភគវា លុម្ពិនិយា ជាតោ ។ បេ ។ កុសិនារាយំ ភគវា បរិនិព្វុតោ តេន វត រេ វត្តព្វេ ពុទ្ធោ ភគវា មនុស្សលោកេ អដ្ឋាសីតិ ។

(៣០៤) ន វត្តព្វំ ពុទ្ធោ ភគវា មនុស្សលោកេ អដ្ឋាសីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

មនុស្សលោកកថា

(៣០២) បុគ្គលមិនគួរនិយាយថា ព្រះពុទ្ធមានព្រះភាគ ទ្រង់គង់នៅក្នុងមនុស្សលោកទេឬ ។ អើ ។ ក្រែងចេតិយ អារាម វិហារ ស្រុក និគម នគរ ដែន ជនបទ ដែលព្រះពុទ្ធគង់នៅហើយ មានដែរឬ ។ អើ ។ ប្រសិនបើ ចេតិយ អារាម វិហារ ស្រុក និគម នគរ ដែន ជនបទ ដែលព្រះពុទ្ធគង់នៅហើយ មាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ព្រះពុទ្ធមានព្រះភាគ ទ្រង់គង់នៅក្នុងមនុស្សលោកដែរ ។

(៣០៣) បុគ្គលមិនគួរនិយាយថា ព្រះពុទ្ធមានព្រះភាគ ទ្រង់គង់នៅក្នុងមនុស្សលោកទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ប្រសូតក្នុងលុម្ពិនីវ័ន ត្រាស់ដឹងទៀបគល់ពោធិព្រឹក្ស ព្រះមានព្រះភាគ ទ្រង់ញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅជិតក្រុងពារាណសី ព្រះមានព្រះភាគ ទ្រង់ដាក់អាយុសង្ខារជិតចាបាលចេតិយ ព្រះមានព្រះភាគ ទ្រង់បរិនិព្វានជិតក្រុងកុសិនារាឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ទ្រង់ប្រសូតក្នុងលុម្ពិនីវ័ន ។ បេ ។ ព្រះមានព្រះភាគ ទ្រង់បរិនិព្វានជិតក្រុងកុសិនារា ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា ព្រះពុទ្ធមានព្រះភាគ ទ្រង់គង់នៅក្នុងមនុស្សលោកដែរ ។

(៣០៤) បុគ្គលមិនគួរនិយាយថា ព្រះពុទ្ធមានព្រះភាគ ទ្រង់គង់នៅក្នុងមនុស្សលោកទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

ឯកមិទាហំ ភិក្ខវេ សមយំ ឧក្កដ្ឋាយំ វិហរាមិ សុភ-
គវនេ សាលរាជមូលេតិ ឯកមិទាហំ ភិក្ខវេ សម-
យំ ឧរុវេលាយំ វិហរាមិ អជបាលនិគ្រោធេ បឋមា-
ភិសម្ពុទ្ធោតិ ឯកមិទាហំ ភិក្ខវេ សមយំ រាជគហេ
វិហរាមិ វេឡុវនេ កលន្ទកនិវាបេតិ ឯកមិទាហំ
ភិក្ខវេ សមយំ សាវត្ថិយំ វិហរាមិ ជេតវនេ អនាថ-
បិណ្ឌិកស្ស អារាមេតិ ឯកមិទាហំ ភិក្ខវេ សមយំ
វេសាលិយំ វិហរាមិ មហាវនេ កូដាគារសាលាយន្តិ
អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ពុទ្ធោ
ភគវា មនុស្សលោកេ អដ្ឋាសីតិ ។

(៣០៨) ពុទ្ធោ ភគវា មនុស្សលោកេ អដ្ឋាសីតិ ។
អាមន្តា ។ ននុ ភគវា លោកេ ជាតោ លោកេ
សំវឌ្ឍោ លោកំ អភិភុយ្យ វិហរតិ អនុបលិត្តោ
លោកេនាតិ ។ អាមន្តា ។ ហញ្ចិ ភគវា លោកេ
ជាតោ លោកេ សំវឌ្ឍោ លោកំ អភិភុយ្យ វិហរតិ
អនុបលិត្តោ លោកេន តេន វត រេ វត្តព្វេ ពុទ្ធោ
ភគវា មនុស្សលោកេ អដ្ឋាសីតិ ។

មនុស្សលោកកថា ។

ម្នាលភិក្ខុទាំងឡាយ សម័យមួយ តថាគត គង់នៅទៀបគល់សាល-
រាជព្រឹក្ស ក្នុងព្រៃសុភគៈ ជិតក្រុងឈ្មោះឧក្កដ្ឋា ម្នាលភិក្ខុទាំងឡាយ
សម័យមួយ តថាគត បានត្រាស់ដឹងជាដំបូង ទៀបអជបាលនិគ្រោធ
ក្នុងឧរុវេលប្រទេស ម្នាលភិក្ខុទាំងឡាយ សម័យមួយ តថាគត គង់
នៅក្នុងវេឡុវន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគហៈ ម្នាលភិក្ខុទាំង-
ឡាយ សម័យមួយ តថាគត គង់នៅក្នុងវត្តជេតពន ជាអារាម របស់
អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ម្នាលភិក្ខុទាំងឡាយ សម័យមួយ
តថាគត គង់នៅក្នុងកូដាគារសាលា ក្នុងមហាវន ជិតក្រុងវេសាលី
ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ព្រះពុទ្ធ
មានព្រះភាគ គង់នៅក្នុងមនុស្សលោកដែរ ។

(៣០៨) ព្រះពុទ្ធមានព្រះភាគ ទ្រង់គង់នៅ ក្នុងមនុស្សលោកដែរ
ឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ កើតក្នុងលោក ចម្រើនក្នុងលោក
គ្របសង្កត់លោក មិនជាប់ដោយលោកឬ ។ អើ ។ ប្រសិនបើ ព្រះ
មានព្រះភាគ កើតក្នុងលោក ចម្រើនក្នុងលោក គ្របសង្កត់លោក មិន
ជាប់ដោយលោក ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ព្រះពុទ្ធមាន
ព្រះភាគ ទ្រង់គង់នៅ ក្នុងមនុស្សលោកទេ ។

ចប់ មនុស្សលោកកថា ។

(៣០៦) ន វត្តព្វំ ពុទ្ធេន ភគវតា ធម្មោ ទេសិតោតិ ។ អាមន្តា ។ កេន ទេសិតោតិ ។ អភិនិម្មិតេន ទេសិតោតិ ។ អភិនិម្មិតោ ជិនោ សត្ថា សម្មាសម្ពុទ្ធោ សព្វញ្ញូ សព្វទស្សាវី ធម្មស្សាមី ធម្មប្បដិសរណោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ន វត្តព្វំ ពុទ្ធេន ភគវតា ធម្មោ ទេសិតោតិ ។ អាមន្តា ។ កេន ទេសិតោតិ ។ អាយស្មតា អានន្ទេន ទេសិតោតិ ។ អាយស្មា អានន្ទោ ជិនោ សត្ថា សម្មាសម្ពុទ្ធោ សព្វញ្ញូ សព្វទស្សាវី ធម្មស្សាមី ធម្មប្បដិសរណោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣០៧) ន វត្តព្វំ ពុទ្ធេន ភគវតា ធម្មោ ទេសិតោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា សង្ខិត្តេនបិ ខោ អហំ សារីបុត្ត ធម្មំ ទេសេយ្យំ វិត្ថារេនបិ ខោ អហំ សារីបុត្ត ធម្មំ ទេសេយ្យំ សង្ខិត្តវិត្ថារេនបិ ខោ អហំ សារីបុត្ត ធម្មំ ទេសេយ្យំ អញ្ញាតារោ ច ទុល្លភាតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ពុទ្ធេន ភគវតា ធម្មោ ទេសិតោតិ ។

(៣០៦) បុគ្គលមិនគួរនិយាយថា ព្រះពុទ្ធមានព្រះភាគ ទ្រង់សំដែងនូវធម៌ទេឬ ។ អើ ។ ចុះអ្នកណា សំដែងធម៌ ។ ព្រះពុទ្ធនិម្មិតសំដែង ។ ចុះព្រះពុទ្ធនិម្មិត ជាព្រះជិនស្រី ជាសាស្តា ជាសម្មាសម្ពុទ្ធ ជាសព្វញ្ញុពុទ្ធ ឃើញនូវធម៌ទាំងពួង ជាធម្មស្សាមី មានធម៌ជាទីរលឹកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលមិនគួរនិយាយថា ព្រះពុទ្ធមានព្រះភាគ ទ្រង់សំដែងនូវធម៌ទេឬ ។ អើ ។ ចុះអ្នកណា សំដែង ។ ព្រះអានន្ទមានអាយុ សំដែង ។ ព្រះអានន្ទមានអាយុ ជាព្រះជិនស្រី ជាសាស្តា ជាសម្មាសម្ពុទ្ធ ជាសព្វញ្ញុពុទ្ធ ឃើញនូវធម៌ទាំងពួង ជាធម្មស្សាមី មានធម៌ជាទីរលឹកឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣០៧) បុគ្គលមិនគួរនិយាយថា ព្រះពុទ្ធមានព្រះភាគ ទ្រង់សំដែងនូវធម៌ទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលសារីបុត្ត តថាគត គប្បីសំដែងធម៌ ដោយសង្ខេបខ្លះ ម្នាលសារីបុត្ត តថាគត គប្បីសំដែងធម៌ ដោយពិស្តារខ្លះ ម្នាលសារីបុត្ត តថាគត គប្បីសំដែងធម៌ ដោយសង្ខេបនិងពិស្តារខ្លះ ព្រោះបុគ្គលអ្នកត្រាស់ដឹង រកបានដោយកម្រ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ព្រះពុទ្ធមានព្រះភាគ ទ្រង់សំដែងនូវធម៌ ។

(៣០៨) ន វត្តព្វំ ពុទ្ធេន ភគវតា ធម្មោ ទេសិតោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា អភិញ្ញាយាហំ ភិក្ខវេ ធម្មំ ទេសេមិ នោ អនភិញ្ញាយ សនិទានាហំ ភិក្ខវេ ធម្មំ ទេសេមិ នោ អនិទានំ សប្បាដិហារិយាហំ ភិក្ខវេ ធម្មំ ទេសេមិ នោ អប្បាដិហារិយំ យញ្ច មយ្ហំ ភិក្ខវេ អភិញ្ញាយ ធម្មំ ទេសយតោ នោ អនភិញ្ញាយ សនិទានំ ធម្មំ ទេសយតោ នោ អនិទានំ សប្បាដិហារិយំ ធម្មំ ទេសយតោ នោ អប្បាដិហារិយំ ករណីយោ ឱវាទោ ករណីយា អនុសាសនី អលញ្ច បន វោ ភិក្ខវេ តុដ្ឋិយា អលំ អត្តមនតាយ អលំ សោមនស្សាយ សម្មាសម្ពុទ្ធោ ភគវា ស្វាក្ខាតោ ធម្មោ សុប្បដិបន្នោ សង្ឃោតិ ឥមស្មិំ ច បន វេយ្យាករណស្មិំ ភញ្ញមានេ ទសសហស្សី លោកធាតុ អកម្បិត្ថាតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ពុទ្ធេន ភគវតា ធម្មោ ទេសិតោតិ ។

ធម្មទេសនាកថា ។

(៣០៨) បុគ្គលមិនគួរនិយាយថា ព្រះពុទ្ធមានព្រះភាគ សំដែងនូវធម៌ទេ ឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត សំដែងធម៌ ដើម្បីត្រាស់ដឹង មិនសំដែងធម៌ ដើម្បីមិនត្រាស់ដឹងទេ ម្នាលភិក្ខុទាំងឡាយ តថាគត សំដែងធម៌ ប្រកបដោយហេតុ មិនសំដែងធម៌ មិនប្រកបដោយហេតុទេ ម្នាលភិក្ខុទាំងឡាយ តថាគត សំដែងធម៌ ប្រកបដោយបាដិហារ្យ មិនសំដែងធម៌ មិនប្រកបដោយបាដិហារ្យទេ ម្នាលភិក្ខុទាំងឡាយ តថាគត កាលសំដែងធម៌ណា ដើម្បីត្រាស់ដឹង មិនសំដែងធម៌ ដើម្បីមិនត្រាស់ដឹងទេ កាលសំដែងធម៌ ប្រកបដោយហេតុ មិនសំដែងធម៌ មិនប្រកបដោយហេតុទេ កាលសំដែងធម៌ ប្រកបដោយបាដិហារ្យ មិនសំដែងធម៌ មិនប្រកបដោយបាដិហារ្យទេ ឱវាទ អ្នកគួរធ្វើ អនុសាសនី អ្នកគួរធ្វើ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គួរត្រេកអរ គួរពេញចិត្ត គួរកើតយថា ព្រះសម្មាសម្ពុទ្ធមានព្រះភាគ ព្រះធម៌ គឺព្រះពុទ្ធសំដែងល្អហើយ ព្រះសង្ឃ ប្រតិបត្តិហើយដោយប្រពៃ កាលដែលព្រះមានព្រះភាគ ទ្រង់សំដែងវេយ្យាករណៈនេះ លោកធាតុដប់ពាន់ ក៏កម្រើក ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ព្រះពុទ្ធមានព្រះភាគ ទ្រង់សំដែងនូវធម៌ ។

ចប់ ធម្មទេសនាកថា ។

ករុណាកថា

(៣០៩) នត្ថិ ពុទ្ធស្ស ភគវតោ ករុណាតិ ។ អាមន្តា ។ នត្ថិ ពុទ្ធស្ស ភគវតោ មេត្តាតិ ។ ន ហេវំ វត្តព្វេ ។បេ។ នត្ថិ ពុទ្ធស្ស ភគវតោ ករុណាតិ ។ អាមន្តា ។ នត្ថិ ពុទ្ធស្ស ភគវតោ មុទិតា ។បេ។ ឧបេក្ខាតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៣១០) អត្ថិ ពុទ្ធស្ស ភគវតោ មេត្តាតិ ។ អាមន្តា ។ អត្ថិ ពុទ្ធស្ស ភគវតោ ករុណាតិ ។ ន ហេវំ វត្តព្វេ ។បេ។ អត្ថិ ពុទ្ធស្ស ភគវតោ មុទិតា ។បេ។ ឧបេក្ខាតិ ។ អាមន្តា ។ អត្ថិ ពុទ្ធស្ស ភគវតោ ករុណាតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៣១១) នត្ថិ ពុទ្ធស្ស ភគវតោ ករុណាតិ ។ អាមន្តា ។ ភគវា អការុណិកោតិ ។ ន ហេវំ វត្តព្វេ ។បេ។ ននុ ភគវា ការុណិកោ លោកហិតោ លោកានុកម្បកោ លោកត្ថចរោតិ ។ អាមន្តា ។ ហញ្ចិ ភគវា ការុណិកោ លោកហិតោ លោកានុកម្បកោ លោកត្ថចរោ តេន វត រេ វត្តព្វេ នត្ថិ ពុទ្ធស្ស ភគវតោ ករុណាតិ ។

ករុណាកថា

(៣០៩) ករុណា របស់ព្រះពុទ្ធមានព្រះភាគ មិនមានទេឬ ។ អើ ។ មេត្តា របស់ព្រះពុទ្ធមានព្រះភាគ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ករុណា របស់ព្រះពុទ្ធមានព្រះភាគ មិនមានទេឬ ។ អើ ។ មុទិតា របស់ព្រះពុទ្ធមានព្រះភាគ មិនមានទេឬ ។បេ។ ឧបេក្ខា (មិនមានទេឬ) ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៣១០) មេត្តា របស់ព្រះពុទ្ធមានព្រះភាគ មានដែរឬ ។ អើ ។ ករុណា របស់ព្រះពុទ្ធមានព្រះភាគ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ មុទិតា របស់ព្រះពុទ្ធមានព្រះភាគ មានដែរឬ ។បេ។ ឧបេក្ខា (មានដែរឬ) ។ អើ ។ ករុណា របស់ព្រះពុទ្ធមានព្រះភាគ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៣១១) ករុណា របស់ព្រះពុទ្ធមានព្រះភាគ មិនមានទេឬ ។ អើ ។ ព្រះមានព្រះភាគ មិនប្រកបដោយសេចក្តីករុណាទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្រែងព្រះមានព្រះភាគ ប្រកបដោយសេចក្តីករុណា ជាប្រយោជន៍ដល់សត្វលោក ជាអ្នកអនុគ្រោះដល់សត្វលោក ប្រព្រឹត្តប្រយោជន៍ដល់សត្វលោកដែរឬ ។ អើ ។ ប្រសិនបើព្រះមានព្រះភាគ ប្រកបដោយសេចក្តីករុណា ជាប្រយោជន៍ដល់សត្វលោក ជាអ្នកអនុគ្រោះដល់សត្វលោក ប្រព្រឹត្តប្រយោជន៍ដល់សត្វលោក ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ករុណា របស់ព្រះពុទ្ធមានព្រះភាគ មិនមានទេ ។

(៣១២) នត្ថិ ពុទ្ធស្ស ភគវតោ ករុណាតិ ។ អាមន្តា ។ ននុ ភគវា មហាករុណាសមាបត្តឹ សមាបជ្ជីតិ ។ អាមន្តា ។ ហញ្ចិ ភគវា មហាករុណាសមាបត្តឹ សមាបជ្ជិ នោ ច វត រេ វត្តព្វេ នត្ថិ ពុទ្ធស្ស ភគវតោ ករុណាតិ ។

(៣១៣) អត្ថិ ពុទ្ធស្ស ភគវតោ ករុណាតិ ។ អាមន្តា ។ ភគវា សរាគោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ នត្ថិ ពុទ្ធស្ស ភគវតោ ករុណាតិ ។

ករុណាកថា ។

គន្ធជាតកថា

(៣១៤) ពុទ្ធស្ស ភគវតោ ឧច្ចារបស្សាវោ អតិវិយ អញ្ញេ គន្ធជាតេ អធិគ្គណ្ហាតីតិ ។ អាមន្តា ។ ភគវា គន្ធភោជីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ ភគវា ឱទនកុម្មាសំ ភុញ្ជតីតិ ។ អាមន្តា ។ ហញ្ចិ ភគវា ឱទនកុម្មាសំ ភុញ្ជតិ នោ ច វត រេ វត្តព្វេ ពុទ្ធស្ស ភគវតោ ឧច្ចារបស្សាវោ អតិវិយ អញ្ញេ គន្ធជាតេ អធិគ្គណ្ហាតីតិ ។

(៣១២) ករុណា របស់ព្រះពុទ្ធមានព្រះភាគ មិនមានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ចូលមហាករុណាសមាបត្តិដែរឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ចូលមហាករុណាសមាបត្តិដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ករុណា របស់ព្រះពុទ្ធមានព្រះភាគ មិនមានទេ ។

(៣១៣) ករុណា របស់ព្រះពុទ្ធមានព្រះភាគ មានដែរឬ ។ អើ ។ ព្រះមានព្រះភាគ ប្រកបដោយរាគៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ ករុណា(១) របស់ព្រះពុទ្ធមានព្រះភាគ មិនមានទេ ។

ចប់ ករុណាកថា ។

គន្ធជាតកថា

(៣១៤) ឧច្ចារៈនិងបស្សាវៈ របស់ព្រះពុទ្ធមានព្រះភាគ គ្របសង្កត់នូវពួកគន្ធជាតដទៃក្រៃពេកឬ ។ អើ ។ ព្រះមានព្រះភាគ សោយគ្រឿងក្រអូបឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងព្រះមានព្រះភាគ សោយបាយនិងនំដែរឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ សោយបាយនិងនំដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ឧច្ចារៈនិងបស្សាវៈ របស់ព្រះពុទ្ធមានព្រះភាគ គ្របសង្កត់នូវពួកគន្ធជាតដទៃក្រៃពេកទេ ។

១ សំដៅយកករុណាដោយរាគៈ ។

(៣១៧) ពុទ្ធស្ស ភគវតោ ឧច្ចារបស្សាវោ អតិវិយ អញ្ញេ គន្ធជាតេ អធិគណ្ហាតីតិ ។ អាមន្តា ។ អត្ថិ កោចិ ពុទ្ធស្ស ភគវតោ ឧច្ចារបស្សាវំ ន្ហាយន្តិ វិលិម្បន្តិ ឧច្ឆាទេន្តិ បេឡាយ បដិសាមេន្តិ ករណ្ឌាយ និក្ខិបន្តិ អាបណេ បសារេន្តិ តេន ច គន្ធេន គន្ធករណីយំ ករោន្តីតិ ។ ន ហេវំ វត្តព្វេ ។បេ។

គន្ធជាតកថា ។

ឯកមគ្គកថា

(៣១៨) ឯកេន អរិយមគ្គេន ចត្តារិ សាមញ្ញផលានិ សច្ឆិករោតីតិ ។ អាមន្តា ។ ចតុន្នំ ផស្សានំ ។បេ។ ចតុន្នំ បញ្ញានំ សមោធានំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។បេ។ ឯកេន អរិយមគ្គេន ចត្តារិ សាមញ្ញផលានិ សច្ឆិករោតីតិ ។ អាមន្តា ។ សោតាបត្តិមគ្គេនាតិ ។ ន ហេវំ វត្តព្វេ ។បេ។ សកទាគាមិមគ្គេន ។បេ។ អនាគាមិមគ្គេនាតិ ។ ន ហេវំ វត្តព្វេ ។បេ។ កតមេន មគ្គេនាតិ ។ អរហត្តមគ្គេនាតិ ។ អរហត្តមគ្គេន សក្កាយទិដ្ឋឹ វិចិកិច្ឆំ សីលព្វតបរាមាសំ ជហាតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៣១៧) ឧច្ចារៈនិងបស្សាវៈ របស់ព្រះពុទ្ធមានព្រះភាគ គ្របសង្កត់នូវពួកគន្ធជាតដទៃទៀតក្រៃពេកឬ ។ អើ ។ ជនពួកខ្លះ ងូត លាប ផុសខាត់ នូវឧច្ចារៈនិងបស្សាវៈ របស់ព្រះពុទ្ធមានព្រះភាគ ទុកក្នុងពាង ដាក់ក្នុងថូ តាំងផ្សាយលក់ក្នុងផ្សារ ធ្វើនូវកិច្ចដែលគួរធ្វើ ដោយគ្រឿងក្រអូប ដោយគ្រឿងក្រអូបនោះដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ចប់ គន្ធជាតកថា ។

ឯកមគ្គកថា

(៣១៨) បុគ្គលធ្វើឲ្យជាក់ច្បាស់ នូវសាមញ្ញផល ៤ ដោយអរិយមគ្គ ១ ឬ ។ អើ ។ ការប្រជុំនៃផស្សៈទាំង ៤ ។បេ។ នៃបញ្ញាទាំង ៤ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គលធ្វើឲ្យជាក់ច្បាស់ នូវសាមញ្ញផល ៤ ដោយអរិយមគ្គ ១ ឬ ។ អើ ។ ដោយសោតាបត្តិមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ដោយសកទាគាមិមគ្គ ។បេ។ ដោយអនាគាមិមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ដោយមគ្គ ដូចម្តេច ។ ដោយអរហត្តមគ្គ ។ បុគ្គលលះបង់សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ដោយអរហត្តមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

អរហត្តមគ្គេន សក្កាយទិដ្ឋឹ វិចិកិច្ឆំ សីលព្វតបរា-មាសំ ជហតីតិ ។ អាមន្តា ។ ននុ តីណិ សញ្ញោ-ជនានិ បហាយ សោតាបត្តិផលំ វុត្តំ ភគវតាតិ ។ អាមន្តា ។ ហញ្ចិ តីណិ សញ្ញោជនានិ បហាយ សោតាបត្តិផលំ វុត្តំ ភគវតា នោ វត រេ វត្តព្វេ អ-រហត្តមគ្គេន សក្កាយទិដ្ឋឹ វិចិកិច្ឆំ សីលព្វតបរាមាសំ ជហតីតិ ។ បេ ។ អរហត្តមគ្គេន ឱឡារិកំ កាមរាគំ ឱឡារិកំ ព្យាបាទំ ជហតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរហត្តមគ្គេន ឱឡារិកំ កាមរាគំ ឱឡារិកំ ព្យាបាទំ ជហតីតិ ។ អាមន្តា ។ ននុ កាមរាគព្យាបាទានំ តនុភាវំ សកទាគាមិផលំ វុត្តំ ភគវតាតិ ។ អាមន្តា ។ ហញ្ចិ កាមរាគព្យាបាទានំ តនុភាវំ សកទាគាមិផលំ វុត្តំ ភគវតា នោ វត រេ វត្តព្វេ អរហត្តមគ្គេន ឱឡារិកំ កាមរាគំ ឱឡារិកំ ព្យាបាទំ ជហតីតិ ។ អរហត្តមគ្គេន អណុសហគតំ កាមរាគំ អណុ-សហគតំ ព្យាបាទំ ជហតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរហត្តមគ្គេន អណុសហគតំ កាមរាគំ អណុសហគតំ ព្យាបាទំ ជហតីតិ ។ អាមន្តា ។

បុគ្គល លះបង់សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ដោយអរហត្ត-មគ្គឬ ។ អើ ។ ក្រែងការលះបង់សញ្ញោជនៈ ៣ ព្រះមានព្រះភាគត្រាស់ថា សោតាបត្តិផលឬ ។ អើ ។ ប្រសិនបើ ការលះបង់សញ្ញោជនៈ ៣ ព្រះមានព្រះភាគត្រាស់ថា សោតាបត្តិផល ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល លះបង់សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសៈ ដោយអរហត្តមគ្គទេ ។ បេ ។ បុគ្គល លះបង់កាមរាគៈដ៏គ្រោតគ្រាត ព្យា-បាទដ៏គ្រោតគ្រាត ដោយអរហត្តមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលលះបង់កាមរាគៈដ៏គ្រោតគ្រាត ព្យាបាទដ៏គ្រោតគ្រាត ដោយអរហត្តមគ្គឬ ។ អើ ។ ក្រែងការស្រាលស្តើង នៃកាមរាគៈនិងព្យាបាទ ព្រះមានព្រះភាគត្រាស់ថា សកទាគាមិផលឬ ។ អើ ។ ប្រ-សិនបើ ការស្រាលស្តើង នៃកាមរាគៈនិងព្យាបាទ ព្រះមានព្រះភាគត្រាស់ថា សកទាគាមិផល ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល លះបង់កាមរាគៈដ៏គ្រោតគ្រាត ព្យាបាទដ៏គ្រោតគ្រាត ដោយអរ-ហត្តមគ្គទេ ។ បុគ្គល លះបង់កាមរាគៈប្រកបដោយប្រមាណតិច ព្យា-បាទប្រកបដោយប្រមាណតិច ដោយអរហត្តមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល លះបង់កាមរាគៈប្រកបដោយប្រមាណតិច ព្យាបាទប្រកបដោយប្រមាណតិច ដោយអរហត្តមគ្គឬ ។ អើ ។

(៣១៩) ឈានា ឈានំ សង្កមតីតិ ។ អាមន្តា ។ បឋមា ឈានា តតិយំ ឈានំ សង្កមតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ឈានា ឈានំ សង្កមតីតិ ។ អាមន្តា ។ ទុតិយា ឈានា ចតុត្ថំ ឈានំ សង្កមតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣២០) បឋមា ឈានា ទុតិយំ ឈានំ សង្កមតីតិ ។ អាមន្តា ។ យា បឋមស្ស ឈានស្ស ឧប្បាទាយ អាវជ្ជនា ។ បេ ។ បណិធិ សា វ ទុតិយស្ស ឈានស្ស ឧប្បាទាយ អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ បឋមា ឈានា ទុតិយំ ឈានំ សង្កមតីតិ ។ ន វត្តព្វំ យា បឋមស្ស ឈានស្ស ឧប្បាទាយ អាវជ្ជនា ។ បេ ។ បណិធិ សា វ ទុតិយស្ស ឈានស្ស ឧប្បាទាយ អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ ទុតិយំ ឈានំ អនាវជ្ជន្តស្ស ឧប្បជ្ជតិ ។ បេ ។ អបណិទហន្តស្ស ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទុតិយំ ឈានំ អាវជ្ជន្តស្ស ឧប្បជ្ជតិ ។ បេ ។

(៣១៩) បុគ្គល ចេញអំពីឈានមួយ ក៏ចូលទៅកាន់ឈានមួយ បានដែរឬ ។ អើ ។ បុគ្គល ចេញអំពីបឋមជ្ឈាន ក៏ចូលទៅកាន់តតិយជ្ឈាន បានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ចេញអំពីឈានមួយ ក៏ចូលទៅកាន់ឈានមួយ បានដែរឬ ។ អើ ។ បុគ្គលចេញអំពីទុតិយជ្ឈាន ក៏ចូលទៅកាន់ចតុត្ថជ្ឈាន បានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣២០) បុគ្គល ចេញអំពីបឋមជ្ឈាន ក៏ចូលទៅកាន់ទុតិយជ្ឈាន បានដែរឬ ។ អើ ។ ការរំពឹង ។ បេ ។ ការតាំងចិត្តទុកណា ដើម្បីញុំាងបឋមជ្ឈានឲ្យកើតឡើង ការរំពឹង ។ បេ ។ ការតាំងចិត្តទុកនោះឯង ដើម្បីញុំាងទុតិយជ្ឈានឲ្យកើតឡើង ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ចេញអំពីបឋមជ្ឈាន ក៏ចូលទៅកាន់ទុតិយជ្ឈានឬ ។ បុគ្គលមិនគួរនិយាយថា ការរំពឹង ។ បេ ។ ការតាំងចិត្តទុកណា ដើម្បីញុំាងបឋមជ្ឈានឲ្យកើតឡើង ការរំពឹង ។ បេ ។ ការតាំងចិត្តទុកនោះឯង ដើម្បីញុំាងទុតិយជ្ឈានឲ្យកើតឡើងឬ ។ អើ ។ ទុតិយជ្ឈាន របស់បុគ្គលកាលមិនរំពឹង កើតឡើង ។ បេ ។ របស់បុគ្គលកាលមិនតាំងចិត្តទុក កើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងទុតិយជ្ឈាន របស់បុគ្គលកាលរំពឹង កើតឡើង ។ បេ ។

បណិទហន្តស្ស ឧប្បជ្ជតីតិ ។ អាមន្តា ។ ហញ្ចិ ទុតិយំ ឈានំ អាវជ្ជន្តស្ស ឧប្បជ្ជតិ ។ បេ ។ បណិទហន្តស្ស ឧប្បជ្ជតិ នោ ច វត រេ វត្តព្វេ បឋមា ឈានា ទុតិយំ ឈានំ សង្កមតីតិ ។ បឋមា ឈានា ទុតិយំ ឈានំ សង្កមតីតិ ។ អាមន្តា ។ បឋមំ ឈានំ កាមេ អាទីនវតោ មនសិការោតោ ឧប្បជ្ជតីតិ ។ អាមន្តា ។ ទុតិយំ ឈានំ កាមេ អាទីនវតោ មនសិការោតោ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ បឋមំ ឈានំ សវិតក្កំ សវិចារន្តិ ។ អាមន្តា ។ ទុតិយំ ឈានំ សវិតក្កំ សវិចារន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ បឋមា ឈានា ទុតិយំ ឈានំ សង្កមតីតិ ។ អាមន្តា ។ តញ្ញេវ បឋមំ ឈានំ តំ ទុតិយំ ឈានន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

របស់បុគ្គលកាលតាំងចិត្តទុក កើតឡើងឬ ។ អើ ។ ប្រសិនបើ ទុតិយជ្ឈាន របស់បុគ្គលកាលរំពឹង កើតឡើង ។ បេ ។ របស់បុគ្គលកាលតាំងចិត្តទុក កើតឡើង ម្នាលអ្នកដ៏ចំរើន អ្នកមិនគួរពោលថា បុគ្គលចេញអំពីបឋមជ្ឈាន រំកិលទៅកាន់ទុតិយជ្ឈាន បានទេ ។ បុគ្គលចេញអំពីបឋមជ្ឈាន រំកិលទៅកាន់ទុតិយជ្ឈាន បានដែរឬ ។ អើ ។ បឋមជ្ឈាន របស់បុគ្គលកាលធ្វើទុកក្នុងចិត្ត នូវកាមទាំងឡាយ ថាជាទោស កើតឡើងដែរឬ ។ អើ ។ ទុតិយជ្ឈាន របស់បុគ្គលកាលធ្វើទុកក្នុងចិត្ត នូវកាមទាំងឡាយ ថាជាទោស កើតឡើងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បឋមជ្ឈាន ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈដែរឬ ។ អើ ។ ទុតិយជ្ឈាន ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ចេញអំពីបឋមជ្ឈាន រំកិលទៅកាន់ទុតិយជ្ឈាន បានដែរឬ ។ អើ ។ បឋមជ្ឈាននោះឯង គឺទុតិយជ្ឈាននោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៦១) ទុតិយា ឈានា តតិយំ ឈានំ សង្កមតីតិ ។ អាមន្តា ។ យា ទុតិយស្ស ឈានស្ស ឧប្បាទាយ អាវជ្ជនា ។បេ។ បណិធិ សា វ តតិយស្ស ឈានស្ស ឧប្បាទាយ អាវជ្ជនា ។បេ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។បេ។ ទុតិយា ឈានា តតិយំ ឈានំ សង្កមតីតិ ។ ន វត្តព្វំ ។ យា ទុតិយស្ស ឈានស្ស ឧប្បាទាយ អាវជ្ជនា ។បេ។ បណិធិ សា វ តតិយស្ស ឈានស្ស ឧប្បាទាយ អាវជ្ជនា ។បេ។ បណិធីតិ ។ អាមន្តា ។ តតិយំ ឈានំ អនាវជ្ជន្តស្ស ឧប្បជ្ជតិ ។បេ។ អបណិទហន្តស្ស ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។បេ។ ននុ តតិយំ ឈានំ អាវជ្ជន្តស្ស ឧប្បជ្ជតិ ។បេ។ បណិទហន្តស្ស ឧប្បជ្ជតីតិ ។ អាមន្តា ។ ហញ្ចិ តតិយំ ឈានំ អាវជ្ជន្តស្ស ឧប្បជ្ជតិ ។បេ។ បណិទហន្តស្ស ឧប្បជ្ជតិ នោ ច វត រេ វត្តព្វេ ទុតិយា ឈានា តតិយំ ឈានំ សង្កមតីតិ ។ ទុតិយា ឈានា តតិយំ ឈានំ សង្កមតីតិ ។ អាមន្តា ។

(៣៦១) បុគ្គល ចេញអំពីទុតិយជ្ឈាន រំកិលទៅកាន់តតិយជ្ឈាន បានដែរឬ ។ អើ ។ ការរំពឹង ។បេ។ ការតាំងចិត្តទុកណា ដើម្បីញុំាងទុតិយជ្ឈានឲ្យកើតឡើង ការរំពឹង ។បេ។ ការតាំងចិត្តទុកនោះឯង ដើម្បីញុំាងតតិយជ្ឈានឲ្យកើតឡើងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុគ្គល ចេញអំពីទុតិយជ្ឈាន រំកិលទៅកាន់តតិយជ្ឈាន ។ បុគ្គលមិនគួរនិយាយថា ការរំពឹង ។បេ។ ការតាំងចិត្តទុកណា ដើម្បីញុំាងទុតិយជ្ឈានឲ្យកើតឡើង ការរំពឹង ។បេ។ ការតាំងចិត្តទុកនោះឯង ដើម្បីញុំាងតតិយជ្ឈានឲ្យកើតឡើងដែរឬ ។ អើ ។ តតិយជ្ឈាន របស់បុគ្គលកាលមិនរំពឹង កើតឡើង ។បេ។ របស់បុគ្គលកាលមិនតាំងចិត្តទុក កើតឡើងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ តែក្រែងតតិយជ្ឈាន របស់បុគ្គលកាលរំពឹង កើតឡើង ។បេ។ របស់បុគ្គលកាលតាំងចិត្តទុក កើតឡើងឬ ។ អើ ។ ប្រសិនបើ តតិយជ្ឈាន របស់បុគ្គលកាលរំពឹង កើតឡើង ។បេ។ របស់បុគ្គលកាលតាំងចិត្តទុក កើតឡើង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល ចេញអំពីទុតិយជ្ឈាន រំកិលទៅកាន់តតិយជ្ឈានបានទេ ។ បុគ្គល ចេញអំពីទុតិយជ្ឈាន រំកិលទៅកាន់តតិយជ្ឈាន បានដែរឬ ។ អើ ។

ទុតិយំ ឈានំ វិតក្កវិចារេ អាទីនវតោ មនសិក-
រោតោ ឧប្បជ្ជតិ ។ អាមន្តា ។ តតិយំ ឈានំ
វិតក្កវិចារេ អាទីនវតោ មនសិករោតោ ឧប្បជ្ជតិ ។
ន ហេវំ វត្តព្វេ ។ បេ ។ ទុតិយំ ឈានំ សប្បីតិ-
កន្តិ ។ អាមន្តា ។ តតិយំ ឈានំ សប្បីតិកន្តិ ។
ន ហេវំ វត្តព្វេ ។ បេ ។ ទុតិយា ឈានា តតិយំ
ឈានំ សង្កមតីតិ ។ អាមន្តា ។ តញ្ញេវ ទុតិយំ
ឈានំ តំ តតិយំ ឈានន្តិ ។ ន ហេវំ វត្តព្វេ
។ បេ ។

(៣៦២) តតិយា ឈានា ចតុត្ថំ ឈានំ សង្ក-
មតីតិ ។ អាមន្តា ។ យា តតិយស្ស ឈានស្ស
ឧប្បាទាយ អាវជ្ជនា ។ បេ ។ បណិធិ សា វ ចតុត្ថស្ស
ឈានស្ស ឧប្បាទាយ អាវជ្ជនា ។ បេ ។ បណិ-
ធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តតិយា ឈានា
ចតុត្ថំ ឈានំ សង្កមតីតិ ។ ន វត្តព្វំ យា តតិ-
យស្ស ឈានស្ស ឧប្បាទាយ អាវជ្ជនា ។ បេ ។
បណិធិ សា វ ចតុត្ថស្ស ឈានស្ស ឧប្បាទាយ
អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។
ចតុត្ថំ ឈានំ អនាវជ្ជន្តស្ស ឧប្បជ្ជតិ ។ បេ ។

ទុតិយជ្ឈាន របស់បុគ្គលកាលធ្វើទុកក្នុងចិត្ត នូវវិតក្កៈនិងវិចារៈ ថាជា
ទោស កើតឡើងឬ ។ អើ ។ តតិយជ្ឈាន របស់បុគ្គលកាលធ្វើទុក
ក្នុងចិត្ត នូវវិតក្កៈនិងវិចារៈ ថាជាទោស កើតឡើងដែរឬ ។ អ្នកមិនគួរ
ពោលយ៉ាងនេះទេ ។ បេ ។ ទុតិយជ្ឈាន ប្រកបដោយបីតិដែរឬ ។
អើ ។ តតិយជ្ឈាន ប្រកបដោយបីតិដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះ
ទេ ។ បេ ។ បុគ្គល ចេញអំពីទុតិយជ្ឈាន រំកិលទៅកាន់តតិយជ្ឈាន
បានដែរឬ ។ អើ ។ ទុតិយជ្ឈាននោះឯង គឺតតិយជ្ឈាននោះឬ ។
អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៦២) បុគ្គល ចេញអំពីតតិយជ្ឈាន រំកិលទៅកាន់ចតុត្ថជ្ឈាន
បានដែរឬ ។ អើ ។ ការរំពឹង ។ បេ ។ ការតាំងចិត្តទុកណា
ដើម្បីញុំាងតតិយជ្ឈានឲ្យកើតឡើង ការរំពឹង ។ បេ ។ ការតាំងចិត្តទុក
នោះឯង ដើម្បីញុំាងចតុត្ថជ្ឈានឲ្យកើតឡើងដែរឬ ។ អ្នកមិនគួរពោល
យ៉ាងនេះទេ ។ បេ ។ បុគ្គល ចេញអំពីតតិយជ្ឈាន រំកិលទៅកាន់
ចតុត្ថជ្ឈានបានដែរឬ ។ បុគ្គលមិនគួរនិយាយថា ការរំពឹង ។ បេ ។
ការតាំងចិត្តទុកណា ដើម្បីញុំាងតតិយជ្ឈានឲ្យកើតឡើង ការរំពឹង
។ បេ ។ ការតាំងចិត្តទុកនោះឯង ដើម្បីញុំាងចតុត្ថជ្ឈានឲ្យកើតឡើងដែរ
ឬ ។ អើ ។ ចតុត្ថជ្ឈាន របស់បុគ្គលកាលមិនរំពឹង កើតឡើង ។ បេ ។

អប្បណិហិតានុបស្ស ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ ចតុត្ថំ ឈានំ អាវជ្ជន្តស្ស ឧប្បជ្ជតិ ។ បេ ។ បណិហិតានុបស្ស ឧប្បជ្ជតីតិ ។ អាមន្តា ។ ហញ្ចិ ចតុត្ថំ ឈានំ អាវជ្ជន្តស្ស ឧប្បជ្ជតិ ។ បេ ។ បណិហិតានុបស្ស ឧប្បជ្ជតិ តេន វត រេ វត្តព្វេ តតិយា ឈានា ចតុត្ថំ ឈានំ សង្កមតីតិ ។ តតិយា ឈានា ចតុត្ថំ ឈានំ សង្កមតីតិ ។ អាមន្តា ។ តតិយំ ឈានំ បីតិ អាទីនវតោ មនសិការោតោ ឧប្បជ្ជតីតិ ។ អាមន្តា ។ ចតុត្ថំ ឈានំ បីតិ អាទីនវតោ មនសិការោតោ ឧប្បជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តតិយំ ឈានំ សុខសហគតន្តិ ។ អាមន្តា ។ ចតុត្ថំ ឈានំ សុខសហគតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តតិយា ឈានា ចតុត្ថំ ឈានំ សង្កមតីតិ ។ អាមន្តា ។ តញ្ញេវ តតិយំ ឈានំ តំ ចតុត្ថំ ឈានន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

របស់បុគ្គលកាលមិនតាំងចិត្តទុក កើតឡើងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងចតុត្ថជ្ឈាន របស់បុគ្គលកាលរំពឹង កើតឡើង ។ បេ ។ របស់បុគ្គលកាលតាំងចិត្តទុក កើតឡើងឬ ។ អើ ។ ប្រសិនបើចតុត្ថជ្ឈាន របស់បុគ្គលកាលរំពឹង កើតឡើង ។ បេ ។ របស់បុគ្គលកាលតាំងចិត្តទុក កើតឡើង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលចេញអំពីតតិយជ្ឈាន រំកិលទៅកាន់ចតុត្ថជ្ឈានបានទេ ។ បុគ្គល ចេញអំពីតតិយជ្ឈាន រំកិលទៅកាន់ចតុត្ថជ្ឈាន បានដែរឬ ។ អើ ។ តតិយជ្ឈាន របស់បុគ្គលកាលធ្វើទុកក្នុងចិត្ត នូវបីតិ ថាជាទោស កើតឡើងដែរឬ ។ អើ ។ ចតុត្ថជ្ឈាន របស់បុគ្គលកាលធ្វើទុកក្នុងចិត្ត នូវបីតិ ថាជាទោស កើតឡើងដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ តតិយជ្ឈាន ប្រកបដោយសុខឬ ។ អើ ។ ចតុត្ថជ្ឈាន ប្រកបដោយសុខដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល ចេញអំពីតតិយជ្ឈាន រំកិលទៅកាន់ចតុត្ថជ្ឈាន បានដែរឬ ។ អើ ។ តតិយជ្ឈាននោះឯង គឺចតុត្ថជ្ឈាននោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៦៣) ន វត្តព្វំ ឈានា ឈានំ សង្កមតីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ឥធ ភិក្ខវេ ភិក្ខុ វិ-វិច្ចេវ កាមេហិ ។បេ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ឈានា ឈានំ សង្កមតីតិ ។

ឈានសង្កន្តិកថា ។

ឈានន្តរិកកថា

(៣៦៤) អត្ថិ ឈានន្តរិកាតិ ។ អាមន្តា ។ អត្ថិ ផស្សន្តរិកា ។បេ។ អត្ថិ បញ្ញន្តរិកាតិ ។ ន ហេវំ វត្តព្វេ ។បេ។ អត្ថិ ឈានន្តរិកាតិ ។ អា-មន្តា ។ ទុតិយស្ស ច ឈានស្ស តតិយស្ស ច ឈានស្ស អន្តរេ អត្ថិ ឈានន្តរិកាតិ ។ ន ហេវំ វត្តព្វេ ។បេ។ អត្ថិ ឈានន្តរិកាតិ ។ អាមន្តា ។ តតិ-យស្ស ច ឈានស្ស ចតុត្ថស្ស ច ឈានស្ស អន្តរេ អត្ថិ ឈានន្តរិកាតិ ។ ន ហេវំ វត្តព្វេ ។បេ។

(៣៦៣) បុគ្គលមិនគួរនិយាយថា បុគ្គល ចេញអំពីឈានមួយ រំកិលទៅកាន់ឈានមួយ បានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាម ទាំងឡាយ ។បេ។ ចូលកាន់ចតុត្ថជ្ឈាន ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បុគ្គល ចេញអំពីឈានមួយ រំកិលទៅកាន់ឈានមួយបាន ។

ចប់ ឈានសង្កន្តិកថា ។

ឈានន្តរិកកថា

(៣៦៤) ធម៌ជាចន្លោះនៃឈាន មានដែរឬ ។ អើ ។ ធម៌ជាចន្លោះនៃផស្សៈ មានដែរឬ ។បេ។ ធម៌ជាចន្លោះនៃបញ្ញា មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធម៌ជាចន្លោះនៃឈាន មានដែរឬ ។ អើ ។ ធម៌ជាចន្លោះនៃឈាន មានក្នុងចន្លោះ នៃទុតិយជ្ឈាននិងតតិយជ្ឈានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ធម៌ជាចន្លោះនៃឈាន មានដែរឬ ។ អើ ។ ធម៌ជាចន្លោះនៃឈាន មានក្នុងចន្លោះ នៃតតិយជ្ឈាននិងចតុត្ថជ្ឈានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៣២៥) ទុតិយស្ស ច ឈានស្ស តតិយស្ស ច ឈានស្ស អន្តរេ នត្ថិ ឈានន្តរិកាតិ ។ អាមន្តា ។ ហញ្ចិ ទុតិយស្ស ច ឈានស្ស តតិយស្ស ច ឈានស្ស អន្តរេ នត្ថិ ឈានន្តរិកា នោ វត រេ វត្តព្វេ អត្ថិ ឈានន្តរិកាតិ ។ តតិយស្ស ច ឈានស្ស ចតុត្ថស្ស ច ឈានស្ស អន្តរេ នត្ថិ ឈានន្តរិកាតិ ។ អាមន្តា ។ ហញ្ចិ តតិយស្ស ច ឈានស្ស ចតុត្ថស្ស ច ឈានស្ស អន្តរេ នត្ថិ ឈានន្តរិកា នោ វត រេ វត្តព្វេ អត្ថិ ឈានន្តរិកាតិ ។

(៣២៦) បឋមស្ស ច ឈានស្ស ទុតិយស្ស ច ឈានស្ស អន្តរេ អត្ថិ ឈានន្តរិកាតិ ។ អាមន្តា ។ ទុតិយស្ស ច ឈានស្ស តតិយស្ស ច ឈានស្ស អន្តរេ អត្ថិ ឈានន្តរិកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ បឋមស្ស ច ឈានស្ស ទុតិយស្ស ច ឈានស្ស អន្តរេ អត្ថិ ឈានន្តរិកាតិ ។ អាមន្តា ។ តតិយស្ស ច ឈានស្ស ចតុត្ថស្ស ច ឈានស្ស អន្តរេ អត្ថិ ឈានន្តរិកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣២៥) ធម៌ជាចន្លោះនៃឈាន មិនមានក្នុងចន្លោះ នៃទុតិយជ្ឈាននិងតតិយជ្ឈានទេឬ ។ អើ ។ ប្រសិនបើ ធម៌ជាចន្លោះនៃឈាន មិនមានក្នុងចន្លោះ នៃទុតិយជ្ឈាននិងតតិយជ្ឈានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ធម៌ជាចន្លោះនៃឈាន មានទេ ។ ធម៌ជាចន្លោះនៃឈាន មិនមានក្នុងចន្លោះ នៃតតិយជ្ឈាននិងចតុត្ថជ្ឈានទេឬ ។ អើ ។ ប្រសិនបើ ធម៌ជាចន្លោះនៃឈាន មិនមានក្នុងចន្លោះ នៃតតិយជ្ឈាននិងចតុត្ថជ្ឈានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ធម៌ជាចន្លោះនៃឈាន មានទេ ។

(៣២៦) ធម៌ជាចន្លោះនៃឈាន មានក្នុងចន្លោះ នៃបឋមជ្ឈាននិងទុតិយជ្ឈានឬ ។ អើ ។ ធម៌ជាចន្លោះនៃឈាន មានក្នុងចន្លោះ នៃទុតិយជ្ឈាននិងតតិយជ្ឈានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ធម៌ជាចន្លោះនៃឈាន មានក្នុងចន្លោះ នៃបឋមជ្ឈាននិងទុតិយជ្ឈានឬ ។ អើ ។ ធម៌ជាចន្លោះនៃឈាន មានក្នុងចន្លោះ នៃតតិយជ្ឈាននិងចតុត្ថជ្ឈានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៤៧) ទុតិយស្ស ច ឈានស្ស តតិយស្ស ច ឈានស្ស អន្តរា អត្ថិ ឈានន្តរិកាតិ ។ អាមន្តា ។ បឋមស្ស ច ឈានស្ស ទុតិយស្ស ច ឈានស្ស អន្តរា នត្ថិ ឈានន្តរិកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តតិយស្ស ច ឈានស្ស ចតុត្ថស្ស ច ឈានស្ស អន្តរា អត្ថិ ឈានន្តរិកាតិ ។ អាមន្តា ។ បឋមស្ស ច ឈានស្ស ទុតិយស្ស ច ឈានស្ស អន្តរា នត្ថិ ឈានន្តរិកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៤៨) អវិតក្កោ វិចារមត្តោ សមាធិ ឈានន្តរិកាតិ ។ អាមន្តា ។ សវិតក្កោ សវិចារោ សមាធិ ឈានន្តរិកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អវិតក្កោ វិចារមត្តោ សមាធិ ឈានន្តរិកាតិ ។ អាមន្តា ។ អវិតក្កោ អវិចារោ សមាធិ ឈានន្តរិកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៤៩) សវិតក្កោ សវិចារោ សមាធិ ន ឈានន្តរិកាតិ ។ អាមន្តា ។ អវិតក្កោ វិចារមត្តោ សមាធិ ន ឈានន្តរិកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អវិតក្កោ អវិចារោ សមាធិ

(៣៤៧) ធម៌ជាចន្លោះនៃឈាន មានក្នុងចន្លោះ នៃទុតិយជ្ឈាន និងតតិយជ្ឈានទេឬ ។ អើ ។ ធម៌ជាចន្លោះនៃឈាន មិនមានក្នុងចន្លោះ នៃបឋមជ្ឈាននិងទុតិយជ្ឈានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ធម៌ជាចន្លោះនៃឈាន មិនមានក្នុងចន្លោះ នៃតតិយជ្ឈាន និងចតុត្ថជ្ឈានទេឬ ។ អើ ។ ធម៌ជាចន្លោះនៃឈាន មិនមានក្នុងចន្លោះ នៃបឋមជ្ឈាននិងទុតិយជ្ឈានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៤៨) សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ ជាធម៌ជាចន្លោះនៃឈានឬ ។ អើ ។ សមាធិ ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ ជាធម៌ជាចន្លោះនៃឈានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ ជាធម៌ជាចន្លោះនៃឈានឬ ។ អើ ។ សមាធិ មិនមានវិតក្កៈ មិនមានវិចារៈ ជាធម៌ជាចន្លោះនៃឈានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៤៩) សមាធិ ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ មិនមែនជាធម៌ជាចន្លោះនៃឈានទេឬ ។ អើ ។ សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ មិនមែនជាធម៌ជាចន្លោះនៃឈានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សមាធិ មិនមានវិតក្កៈ មិនមានវិចារៈ

ច ឈានន្តរិកាតិ ។ អាមន្តា ។ អវិតក្កោ វិចារមត្តោ សមាធិ ច ឈានន្តរិកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៣០) ទ្វិន្នំ ឈានានំ បដុប្បន្នានំ អន្តរេ អវិតក្កោ វិចារមត្តោ សមាធីតិ ។ អាមន្តា ។ ននុ អវិតក្កេ វិចារមត្តេ សមាធិម្ហិ វត្តមានេ បឋមំ ឈានំ និរុទ្ធំ ទុតិយំ ឈានំ អនុប្បន្នន្តិ ។ អាមន្តា ។ ហញ្ចិ អវិតក្កេ វិចារមត្តេ សមាធិម្ហិ វត្តមានេ បឋមំ ឈានំ និរុទ្ធំ ទុតិយំ ឈានំ អនុប្បន្នំ តេន វត រេ វត្តព្វេ ទ្វិន្នំ ឈានានំ បដុប្បន្នានំ អន្តរេ អវិតក្កោ វិចារមត្តោ សមាធិ ឈានន្តរិកាតិ(១) ។

(៣៣១) អវិតក្កោ វិចារមត្តោ សមាធិ ន ឈានន្តរិកាតិ ។ អាមន្តា ។ អវិតក្កោ វិចារមត្តោ សមាធិ បឋមំ ឈានំ ។ បេ ។ ទុតិយំ ឈានំ ។ បេ ។ តតិយំ ឈានំ ។ បេ ។ ចតុត្ថំ ឈានន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ អវិតក្កោ វិចារមត្តោ សមាធិ ឈានន្តរិកាតិ ។

១ ឱ. អយំ បាឋោ នត្ថិ ។

មិនមែនជាធម៌ជាចន្លោះនៃឈានទេឬ ។ អើ ។ សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ មិនមែនជាធម៌ជាចន្លោះនៃឈានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៣០) សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ មានក្នុងចន្លោះ នៃឈានទាំងពីរ ដែលកើតចំពោះហើយឬ ។ អើ ។ ក្រែងកាលសមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ កំពុងប្រព្រឹត្តទៅ បឋមជ្ឈានរលត់ ទុតិយជ្ឈាន មិនទាន់កើតឡើងទេឬ ។ អើ ។ ប្រសិនបើ កាលសមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ កំពុងប្រព្រឹត្តទៅ បឋមជ្ឈានរលត់ ទុតិយជ្ឈានមិនទាន់កើតឡើង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ មានក្នុងចន្លោះ នៃឈានទាំងពីរ ដែលកើតចំពោះហើយ ជាធម៌ជាចន្លោះនៃឈានទេ ។

(៣៣១) សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ មិនមែនជាធម៌ជាចន្លោះនៃឈានទេឬ ។ អើ ។ សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ ជាបឋមជ្ឈាន ។ បេ ។ ជាទុតិយជ្ឈាន ។ បេ ។ ជាតតិយជ្ឈាន ។ បេ ។ ជាចតុត្ថជ្ឈានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ ជាធម៌ជាចន្លោះនៃឈាន ។

(៣៣៤) អវិតក្កោ វិចារមត្តោ សមាធិ ឈានន្តរិកាតិ ។ អាមន្តា ។ ននុ តយោ សមាធី វុត្តា ភគវតា សវិតក្កោ សវិចារោ សមាធិ អវិតក្កោ វិចារមត្តោ សមាធិ អវិតក្កោ អវិចារោ សមាធីតិ ។ អាមន្តា ។ ហញ្ចិ តយោ សមាធី វុត្តា ភគវតា សវិតក្កោ សវិចារោ សមាធិ អវិតក្កោ វិចារមត្តោ សមាធិ អវិតក្កោ អវិចារោ សមាធិ តេន វត រេ វត្តព្វេ អវិតក្កោ វិចារមត្តោ សមាធិ ឈានន្តរិកាតិ ។

ឈានន្តរិកកថា ។

សមាបន្នោ សទ្ទំ សុណាតីតិកថា

(៣៣៥) សមាបន្នោ សទ្ទំ សុណាតីតិ ។ អាមន្តា ។ សមាបន្នោ ចក្ខុនា រូបំ បស្សតីតិ ។ បេ ។ សោតេន ។ បេ ។ ឃានេន ។ បេ ។ ជិវ្ហាយ ។ បេ ។ កាយេន ផោដ្ឋព្វំ ផុសតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សមាបន្នោ សទ្ទំ សុណាតីតិ ។ អាមន្តា ។ សោតវិញ្ញាណសមង្គី សមាបន្នោតិ ។

(៣៣៤) សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ ជាចន្លោះនៃឈានឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ពួកសមាធិ ៣ យ៉ាងគឺ សមាធិ ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ ១ សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ ១ សមាធិ មិនមានវិតក្កៈ មិនមានវិចារៈ ១ ឬ ។ អើ ។ ប្រសិនបើ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ពួកសមាធិ ៣ យ៉ាងគឺ សមាធិ ប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ ១ សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ ១ សមាធិ មិនមានវិតក្កៈ មិនមានវិចារៈ ១ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សមាធិ មិនមានវិតក្កៈ មានត្រឹមតែវិចារៈ ជាចន្លោះនៃឈានទេ ។

ចប់ ឈានន្តរិកកថា ។

សមាបន្នោ សទ្ទំ សុណាតីតិកថា

(៣៣៥) បុគ្គលចូលកាន់សមាបត្តិ ឮសម្លេងដែរឬ ។ អើ ។ បុគ្គលចូលកាន់សមាបត្តិ ឃើញរូប ដោយចក្ខុ ។ បេ ។ ដោយត្រចៀក ។ បេ ។ ដោយច្រមុះ ។ បេ ។ ដោយអណ្តាត ។ បេ ។ ពាល់ត្រូវនូវផោដ្ឋព្វៈ ដោយកាយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលចូលកាន់សមាបត្តិ ឮសម្លេងដែរឬ ។ អើ ។ បុគ្គលចូលកាន់សមាបត្តិ ព្រមព្រៀងដោយសោតវិញ្ញាណដែរឬ ។

ន ហេវំ វត្តព្វេ ។ បេ ។ ននុ សមាធិ មនោវិញ្ញាណសមង្គិស្សាតិ ។ អាមន្តា ។ ហញ្ចិ សមាធិ មនោវិញ្ញាណសមង្គិស្ស តេន វត រេ វត្តព្វេ សមាបន្នោ សទ្ទំ សុណាតីតិ ។

(៣៣៤) សមាធិ មនោវិញ្ញាណសមង្គិស្ស សោតវិញ្ញាណសមង្គី សទ្ទំ សុណាតីតិ ។ អាមន្តា ។ ហញ្ចិ សមាធិ មនោវិញ្ញាណសមង្គិស្ស សោតវិញ្ញាណសមង្គី សទ្ទំ សុណាតិ តេន វត រេ វត្តព្វេ សមាបន្នោ សទ្ទំ សុណាតីតិ ។ សមាធិ មនោវិញ្ញាណសមង្គិស្ស សោតវិញ្ញាណសមង្គី សទ្ទំ សុណាតីតិ ។ អាមន្តា ។ ទ្វិន្នំ ផស្សានំ ។ បេ ។ ទ្វិន្នំ ចិត្តានំ សមោធានំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៣៥) ន វត្តព្វំ សមាបន្នោ សទ្ទំ សុណាតីតិ ។ អាមន្តា ។ ននុ បឋមស្ស ឈានស្ស សទ្ទោ កណ្ដកោ វុត្តោ ភគវតាតិ ។ អាមន្តា ។ ហញ្ចិ បឋមស្ស ឈានស្ស សទ្ទោ កណ្ដកោ វុត្តោ ភគវតា តេន វត រេ វត្តព្វេ សមាបន្នោ សទ្ទំ សុណាតីតិ ។

អភិធម្មបិដក កថាវត្ថុ

អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងសមាធិ របស់បុគ្គលដែលព្រមព្រៀងដោយមនោវិញ្ញាណឬ ។ អើ ។ ប្រសិនបើ សមាធិ របស់បុគ្គលដែលព្រមព្រៀងដោយមនោវិញ្ញាណ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលចូលកាន់សមាបត្តិ ឮសម្លេងទេ ។

(៣៣៤) សមាធិ របស់បុគ្គលដែលព្រមព្រៀងដោយមនោវិញ្ញាណ ចុះបុគ្គលដែលព្រមព្រៀងដោយសោតវិញ្ញាណ ឮសម្លេងដែរឬ ។ អើ ។ ប្រសិនបើ សមាធិ របស់បុគ្គលដែលព្រមព្រៀងដោយមនោវិញ្ញាណ បុគ្គលដែលព្រមព្រៀងដោយសោតវិញ្ញាណ ឮសម្លេងដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលចូលកាន់សមាបត្តិ ឮសម្លេងទេ ។ សមាធិ របស់បុគ្គលដែលព្រមព្រៀងដោយមនោវិញ្ញាណ ចុះបុគ្គលដែលព្រមព្រៀងដោយសោតវិញ្ញាណ ឮសម្លេងដែរឬ ។ អើ ។ ការប្រជុំ នៃផស្សៈទាំងពីរ ។ បេ ។ នៃចិត្តទាំងពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៣៥) បុគ្គលមិនគួរនិយាយថា បុគ្គលចូលកាន់សមាបត្តិ ឮសម្លេងទេឬ ។ អើ ។ ក្រែងសម្លេង ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ជាសត្រូវនៃបឋមជ្ឈានទេឬ ។ អើ ។ ប្រសិនបើ សម្លេង ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ជាសត្រូវនៃបឋមជ្ឈាន ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គលចូលកាន់សមាបត្តិ ឮសម្លេងដែរ ។

បឋមស្ស ឈានស្ស សទ្ទោ កណ្ដកោ វុត្តោ ភគវតាតិ ។ សមាបន្នោ សទ្ទំ សុណាតីតិ ។ អាមន្តា ។ ទុតិយស្ស ឈានស្ស វិតក្កា វិចារា កណ្ដកោ វុត្តោ ភគវតា អត្ថិ តស្ស វិតក្កវិចា-រាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ បឋមស្ស ឈា-នស្ស សទ្ទោ កណ្ដកោ វុត្តោ ភគវតាតិ ។ សមា-បន្នោ សទ្ទំ សុណាតីតិ ។ អាមន្តា ។ តតិយស្ស ឈានស្ស បីតិ កណ្ដកោ ចតុត្ថស្ស ឈានស្ស អស្សាសបស្សាសោ កណ្ដកោ អាកាសានញ្ចាយត-នំ សមាបន្នស្ស រូបសញ្ញា កណ្ដកោ វិញ្ញាណញ្ចា-យតនំ សមាបន្នស្ស អាកាសានញ្ចាយតនសញ្ញា កណ្ដកោ អាកិញ្ចញ្ញាយតនំ សមាបន្នស្ស វិញ្ញា-ណញ្ចាយតនសញ្ញា កណ្ដកោ នេវសញ្ញានាសញ្ញា-យតនំ សមាបន្នស្ស អាកិញ្ចញ្ញាយតនសញ្ញា កណ្ដ-កោ សញ្ញាវេទយិតនិរោធំ សមាបន្នស្ស សញ្ញា ច វេ-ទនា ច កណ្ដកោ វុត្តោ ភគវតា អត្ថិ តស្ស សញ្ញា ច វេទនា ចាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

សមាបន្នោ សទ្ទំ សុណាតីតិកថា ។

សម្លេង ព្រះមានព្រះភាគទ្រង់ត្រាស់ថា ជាសត្រូវនៃបឋមជ្ឈាន ។ ចុះបុគ្គលចូលកាន់សមាបត្តិ ឮសម្លេងដែរឬ ។ អើ ។ វិតក្កៈនិងវិចារៈ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ជាសត្រូវនៃទុតិយជ្ឈាន ចុះវិតក្កៈនិងវិចារៈរបស់ទុតិយជ្ឈាននោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សម្លេង ព្រះមានព្រះភាគទ្រង់ត្រាស់ថា ជាសត្រូវនៃបឋមជ្ឈាន ។ ចុះបុគ្គលចូលកាន់សមាបត្តិ ឮសម្លេងដែរឬ ។ អើ ។ បីតិ ជាសត្រូវនៃតតិយជ្ឈាន ខ្យល់ដកដង្ហើមចេញចូល ជាសត្រូវនៃចតុត្ថជ្ឈាន រូបសញ្ញា ជាសត្រូវនៃបុគ្គលចូលកាន់អាកាសានញ្ចាយតនៈ អាកាសានញ្ចាយតន-សញ្ញា ជាសត្រូវនៃបុគ្គលចូលកាន់វិញ្ញាណញ្ចាយតនៈ វិញ្ញាណញ្ចាយ-តនសញ្ញា ជាសត្រូវនៃបុគ្គលចូលកាន់អាកិញ្ចញ្ញាយតនៈ អាកិញ្ចញ្ញាយ-តនសញ្ញា ជាសត្រូវនៃបុគ្គលចូលកាន់នេវសញ្ញានាសញ្ញាយតនៈ សញ្ញានិងវេទនា ព្រះមានព្រះភាគទ្រង់ត្រាស់ថា ជាសត្រូវនៃបុគ្គលចូលកាន់សញ្ញាវេទយិតនិរោធ ចុះសញ្ញានិងវេទនា របស់បុគ្គលនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ សមាបន្នោ សទ្ទំ សុណាតីតិកថា ។

(៣៣៦) ចក្ខុនា រូបំ បស្សតីតិ ។ អាមន្តា ។ រូបេន រូបំ បស្សតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ រូបេន រូបំ បស្សតីតិ ។ អាមន្តា ។ រូបេន រូបំ បដិវិជានាតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ រូបេន រូបំ បដិវិជានាតីតិ ។ អាមន្តា ។ រូបំ មនោវិញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ចក្ខុនា រូបំ បស្សតីតិ ។ អាមន្តា ។ អត្ថិ ចក្ខុស្ស អាវដ្ដនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ នត្ថិ ចក្ខុស្ស អាវដ្ដនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ ហញ្ចិ នត្ថិ ចក្ខុស្ស អាវដ្ដនា ។ បេ ។ បណិធិ នោ វត រេ វត្តព្វេ ចក្ខុនា រូបំ បស្សតីតិ ។

(៣៣៧) សោតេន សទ្ទំ សុណាតីតិ ។ បេ ។ ឃានេន គន្ធំ ឃាយតីតិ ។ បេ ។ ជិវ្ហាយ រសំ សាយតីតិ ។ បេ ។

(៣៣៨) កាយេន ផោដ្ឋព្វំ ផុសតីតិ ។ អាមន្តា ។ រូបេន រូបំ ផុសតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ រូបេន រូបំ ផុសតីតិ ។ អាមន្តា ។ រូបេន រូបំ បដិវិជានាតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៣៦) បុគ្គលឃើញរូប ដោយចក្ខុឬ ។ អើ ។ បុគ្គលឃើញរូប ដោយរូបដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលឃើញរូប ដោយរូបឬ ។ អើ ។ បុគ្គលដឹងច្បាស់នូវរូប ដោយរូបដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលដឹងច្បាស់នូវរូប ដោយរូបឬ ។ អើ ។ រូប គឺមនោវិញ្ញាណឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលឃើញរូប ដោយចក្ខុឬ ។ អើ ។ ការរើង ។ បេ ។ ការតាំងចិត្តទុក នៃចក្ខុ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងការរើង ។ បេ ។ ការតាំងចិត្តទុក នៃចក្ខុ មិនមានទេឬ ។ អើ ។ ប្រសិនបើ ការរើង ។ បេ ។ ការតាំងចិត្តទុក នៃចក្ខុ មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលឃើញរូប ដោយចក្ខុទេ ។

(៣៣៧) បុគ្គលឮសម្លេង ដោយត្រចៀកឬ ។ បេ ។ ធុំក្លិន ដោយច្រមុះឬ ។ បេ ។ លិទ្ធភ្លក់រស ដោយអណ្ដាតឬ ។ បេ ។

(៣៣៨) បុគ្គលពាល់ត្រូវផោដ្ឋព្វៈ ដោយកាយឬ ។ អើ ។ បុគ្គលពាល់ត្រូវរូប ដោយរូបដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលពាល់ត្រូវរូប ដោយរូបឬ ។ អើ ។ បុគ្គលដឹងច្បាស់នូវរូប ដោយរូបដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

រូបេន រូបំ បដិវិជានាតីតិ ។ អាមន្តា ។ រូបំ មនោ-
វិញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កាយេន
ផោដ្ឋព្វំ ផុសតីតិ ។ អាមន្តា ។ អត្ថិ កាយស្ស
អាវដ្ដនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ
។ បេ ។ ននុ នត្ថិ កាយស្ស អាវដ្ដនា ។ បេ ។
បណិធីតិ ។ អាមន្តា ។ ហញ្ចិ នត្ថិ កាយស្ស
អាវដ្ដនា ។ បេ ។ បណិធិ នោ ច វត រេ វត្តព្វេ
កាយេន ផោដ្ឋព្វំ ផុសតីតិ ។ បេ ។

(៣៣៩) ន វត្តព្វំ ចក្ខុនា រូបំ បស្សតីតិ ។ បេ ។
កាយេន ផោដ្ឋព្វំ ផុសតីតិ ។ អាមន្តា ។ ននុ វុត្តំ
ភគវតា ឥធ ភិក្ខវេ ភិក្ខុ ចក្ខុនា រូបំ បស្សតិ
។ បេ ។ កាយេន ផោដ្ឋព្វំ ផុសតីតិ អត្ថេវ សុត្ត-
ន្តោតិ ។ អាមន្តា ។ តេន ហិ ចក្ខុនា រូបំ បស្ស-
តិ ។ បេ ។ កាយេន ផោដ្ឋព្វំ ផុសតីតិ ។

ចក្ខុនា រូបំ បស្សតីតិកថា ។

អដ្ឋារសមោ វគ្គោ ។

ដឹងច្បាស់នូវរូប ដោយរូបឬ ។ អើ ។ រូប គឺមនោវិញ្ញាណឬ ។
អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលពាល់ត្រូវផោដ្ឋព្វៈ ដោយ
កាយឬ ។ អើ ។ ការកើង ។ បេ ។ ការតាំងចិត្តទុក នៃកាយ មាន
ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងការកើង ។ បេ ។
ការតាំងចិត្តទុក នៃកាយ មិនមានទេឬ ។ អើ ។ ប្រសិនបើ ការកើង
។ បេ ។ ការតាំងចិត្តទុក នៃកាយ មិនមានទេ ម្នាលអ្នកដ៏ចម្រើន
អ្នកមិនគួរពោលថា បុគ្គលពាល់ត្រូវផោដ្ឋព្វៈ ដោយកាយទេ ។ បេ ។

(៣៣៩) បុគ្គលមិនគួរនិយាយថា បុគ្គលឃើញរូប ដោយចក្ខុ
។ បេ ។ ពាល់ត្រូវផោដ្ឋព្វៈ ដោយកាយទេឬ ។ អើ ។ ក្រែងព្រះមាន
ព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញ
រូប ដោយចក្ខុ ។ បេ ។ ពាល់ត្រូវផោដ្ឋព្វៈ ដោយកាយ ពាក្យដូច្នេះ
មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បុគ្គលឃើញរូប ដោយ
ចក្ខុ ។ បេ ។ ពាល់ត្រូវផោដ្ឋព្វៈ ដោយកាយ ។

ចប់ ចក្ខុនា រូបំ បស្សតីតិកថា ។

ចប់ អដ្ឋារសមវគ្គ ។

តស្ស ឧទ្ទានំ

ពុទ្ធោ ភគវា មនុស្សលោកេ អដ្ឋាសិ ពុទ្ធេន

ភគវតា ធម្មោ ទេសិតោ នត្ថិ ពុទ្ធស្ស ភគវតោ

ការុណា ពុទ្ធស្ស ភគវតោ ឧឡារបសាទេ

អច្ឆរិយ អញ្ញេ គន្ធជាតេ អភិគ្គណ្ហាតិ

ឯកេន អរិយមគ្គេន ចត្តារិ សាមញ្ញផលានិ

សច្ឆិករោតិ ឈានា ឈានំ សង្កមតិ អត្ថិ

ឈានន្តរិកា សមាបន្នោ សទ្ទំ សុណាតិ

ចក្ខុនា រូបំ បស្សតិ កាយេន ផោដ្ឋព្វំ ផុសតីតិ ។

ឧទ្ទាននៃអច្ឆរិយសមវគ្គនោះ គឺ

និយាយ អំពីព្រះពុទ្ធមានព្រះភាគគង់នៅក្នុងមនុស្សលោក ១ ព្រះពុទ្ធមានព្រះភាគ ទ្រង់សំដែងធម៌ ១ ករុណារបស់ព្រះពុទ្ធមានព្រះភាគ មិនមាន ១ ឧឡារៈនិងបសាទៈរបស់ព្រះពុទ្ធមានព្រះភាគ គ្របសង្កត់នូវពួកគន្ធជាតដទៃក្រៅពក ១ បុគ្គលៈនឹងឲ្យជាក់ច្បាស់នូវសាមញ្ញផលទាំង ៤ ដោយអរិយ-មគ្គតែមួយ ១ បុគ្គលចេញអំពីឈាន រំកិលទៅកាន់ឈាន ១ ធម៌ជាចន្លោះនៃឈាន មាន ១ បុគ្គលចូលកាន់សមាបត្តិ ឮសម្លេង ១ បុគ្គលឃើញរូប ដោយចក្ខុ បុគ្គលពាល់ត្រូវផោដ្ឋព្វៈ ដោយកាយ ១ ។

កិលេសជហនកថា

(៣៤០) អតីតេ កិលេសេ ជហាតីតិ ។ អាមន្តា ។ និរុទ្ធំ និរោធេតិ វិគតំ វិគមេតិ ខីណំ ខេបេតិ អត្ថង្គតំ អត្ថង្គមេតិ អព្ភត្ថង្គតំ អព្ភត្ថង្គមេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អតីតេ កិលេសេ ជហាតីតិ ។ អាមន្តា ។ ននុ អតីតំ និរុទ្ធន្តិ ។ អាមន្តា ។ ហញ្ចិ អតីតំ និរុទ្ធំ នោ ច វត រេ វត្តព្វេ អតីតេ កិលេសេ ជហាតីតិ ។ អតីតេ កិលេសេ ជហាតីតិ ។ អាមន្តា ។ ននុ អតីតំ នត្ថីតិ ។ អាមន្តា ។ ហញ្ចិ អតីតំ នត្ថិ នោ ច វត រេ វត្តព្វេ អតីតេ កិលេសេ ជហាតីតិ ។

(៣៤១) អនាគតេ កិលេសេ ជហាតីតិ ។ អាមន្តា ។ អជាតំ អជនេតិ អសញ្ជាតំ អសញ្ជនេតិ អនិព្វត្តំ អនិព្វត្តេតិ អបាតុភូតំ អបាតុភាវេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អនាគតេ កិលេសេ ជហាតីតិ ។

កិលេសជហនកថា

(៣៤០) បុគ្គល លះបង់នូវកិលេសជាអតីត (កន្លងទៅហើយ)ឬ ។ អើ ។ បុគ្គល ញុំាងរបស់ដែលរលត់ហើយ ឲ្យរលត់ទៅ ញុំាងរបស់ដែលទៅប្រាសហើយ ឲ្យទៅប្រាស ញុំាងរបស់ដែលអស់ហើយ ឲ្យអស់ទៅ ញុំាងរបស់ដែលវិនាសទៅហើយ ឲ្យវិនាសទៅ ញុំាងរបស់ដែលបាត់ទៅហើយ ឲ្យបាត់ទៅឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល លះបង់នូវកិលេសជាអតីតឬ ។ អើ ។ ក្រែងរបស់ជាអតីត រលត់ទៅហើយឬ ។ អើ ។ ប្រសិនបើ របស់ជាអតីតរលត់ទៅហើយ ម្នាលអ្នកដ៏ចំរើន អ្នកមិនគួរពោលថា បុគ្គលលះបង់នូវកិលេសជាអតីតទេ ។ បុគ្គល លះបង់នូវកិលេស ជាអតីតឬ ។ អើ ។ ក្រែងរបស់ជាអតីត មិនមានទេឬ ។ អើ ។ ប្រសិនបើ របស់ជាអតីត មិនមានទេ ម្នាលអ្នកដ៏ចំរើន អ្នកមិនគួរពោលថា បុគ្គល លះបង់នូវកិលេសជាអតីតទេ ។

(៣៤១) បុគ្គល លះបង់នូវកិលេសជាអនាគតឬ ។ អើ ។ បុគ្គល ញុំាងរបស់មិនទាន់កើត មិនឲ្យកើត ញុំាងរបស់មិនទាន់ផុះដាល មិនឲ្យផុះដាល ញុំាងរបស់មិនទាន់លូតលាស់ មិនឲ្យលូតលាស់ ញុំាងរបស់មិនទាន់កើតប្រាកដ មិនឲ្យកើតប្រាកដឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល លះបង់នូវកិលេសជាអនាគតឬ ។

អាមន្តា ។ នត្ថិ អនាគតំ អជាតន្តិ ។ អាមន្តា ។ ហញ្ចិ អនាគតំ អជាតំ នោ វត រេ វត្តព្វេ អនាគតេ កិលេសេ ជហតីតិ ។ អនាគតេ កិលេសេ ជហតីតិ ។ អាមន្តា ។ នត្ថិ អនាគតំ នត្ថីតិ ។ អាមន្តា ។ ហញ្ចិ អនាគតំ នត្ថិ នោ វត រេ វត្តព្វេ អនាគតេ កិលេសេ ជហតីតិ ។

(៣៤២) បច្ចុប្បន្នេ កិលេសេ ជហតីតិ ។ អាមន្តា ។ រត្តោ រាគំ ជហតិ ទុដ្ឋោ ទោសំ ជហតិ មូឡ្ហោ មោហំ ជហតិ កិលិដ្ឋោ កិលេសេ ជហតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ រាគេន រាគំ ជហតិ ទោសេន ទោសំ ជហតិ មោហេន មោហំ ជហតិ កិលេសេហិ កិលេសេ ជហតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ រាគោ ចិត្តសម្បយុត្តោ មគ្គោ ចិត្តសម្បយុត្តោតិ ។ អាមន្តា ។ ទ្វិន្នំ ផស្សានំ ។ បេ ។ ទ្វិន្នំ ចិត្តានំ សមោធានំ ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ រាគោ អកុសលោ មគ្គោ កុសលោតិ ។ អាមន្តា ។ កុសលាកុសលា សាវជ្ជានវជ្ជា ហីនប្បណីតា កណ្ហសុក្កសប្បដិភាគា ធម្មា សម្មុខីភាវំ អាគច្ឆន្តីតិ ។

តើ ។ វត្ថុគឺរបស់ជាអនាគត មិនទាន់កើតទេឬ ។ អើ ។ ប្រសិនបើ របស់ជាអនាគត មិនទាន់កើតទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល លះបង់នូវកិលេសជាអនាគតទេ ។ បុគ្គល លះបង់នូវកិលេសជាអនាគតឬ ។ អើ ។ វត្ថុគឺរបស់ជាអនាគត មិនមានទេឬ ។ អើ ។ ប្រសិនបើ របស់ជាអនាគត មិនមានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល លះបង់នូវកិលេសជាអនាគតទេ ។

(៣៤២) បុគ្គល លះបង់នូវកិលេសជាបច្ចុប្បន្នឬ ។ អើ ។ បុគ្គលត្រេកអរ លះបង់រាគៈ បុគ្គលប្រទូស្ត លះបង់ទោសៈ បុគ្គលវង្វេង លះបង់មោហៈ បុគ្គលសៅហ្មង លះបង់នូវកិលេសឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល លះបង់រាគៈ ដោយរាគៈ លះបង់ទោសៈ ដោយទោសៈ លះបង់មោហៈ ដោយមោហៈ លះបង់នូវកិលេស ដោយនូវកិលេសឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ រាគៈ ប្រកបដោយចិត្ត មគ្គ ប្រកបដោយចិត្តដែរឬ ។ អើ ។ ការប្រជុំ នៃផស្សៈពីរ ។ បេ ។ នៃចិត្តពីរមានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ រាគៈ ជាអកុសល មគ្គ ជាកុសលឬ ។ អើ ។ ពួកធម៌ ជាកុសលនិងអកុសល ប្រកបដោយទោសនិងមិនមានទោស ថោកទាបនិងឧត្តម មានចំណែកខ្មៅនិងស មកកាន់ភាពចំពោះមុខឬ ។

ន ហេវំ វត្តព្វេ ។ បេ ។ កុសលាកុសលា
។ បេ ។ សប្បដិភាគា ធម្មា សម្មុខីភាវំ អាគច្ឆន្តីតិ ។
អាមន្តា ។ ននុ វុត្តំ ភគវតា ចត្តារិមានិ ភិក្ខវេ
សុវិទូរវិទូរានិ ។ កតមានិ ចត្តារិ ។ នភញ្ច
ភិក្ខវេ បឋវី ច ឥទំ បឋមំ សុវិទូរវិទូរំ ។ បេ ។
តស្មា សតំ ធម្មោ អសព្ភិ អារកាតិ អត្ថេវ សុត្ត-
ន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ កុសលា-
កុសលា ។ បេ ។ សម្មុខីភាវំ អាគច្ឆន្តីតិ ។

(៣៤៣) ន វត្តព្វំ អតីតេ កិលេសេ ជហតិ
អនាគតេ កិលេសេ ជហតិ បច្ចុប្បន្នេ កិលេសេ
ជហតីតិ ។ អាមន្តា ។ នត្ថិ កិលេសេ ជហតីតិ ។
ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ អតីតេ កិ-
លេសេ ជហតិ អនាគតេ កិលេសេ ជហតិ បច្ចុ-
ប្បន្នេ កិលេសេ ជហតីតិ ។

កិលេសជហនកថា ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពួកធម៌ ជាកុសលនិងអកុសល
។ បេ ។ មានចំណែក (ទៀងនិងស) មកកាន់ភាវៈចំពោះមុខឬ ។ អើ ។
តែក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មជាតឆ្ងាយ
ក្រៃលែងឆ្ងាយ មាន ៤ ។ ធម្មជាតឆ្ងាយក្រៃលែងឆ្ងាយ ៤ តើដូចម្ដេច ។
ម្នាលភិក្ខុទាំងឡាយ មេឃនិងផែនដី នេះឈ្មោះថាឆ្ងាយក្រៃលែងឆ្ងាយ
ទី ១ ។ បេ ។ ព្រោះហេតុនោះ ធម៌ របស់សប្បុរសទាំងឡាយ ឆ្ងាយ
អំពីអសប្បុរសទាំងឡាយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។
ព្រោះហេតុនោះ អ្នកមិនគួរពោលថា ធម៌ ជាកុសលនិងអកុសល ។ បេ ។
មកកាន់ភាវៈចំពោះមុខទេ ។

(៣៤៣) បុគ្គលមិនគួរនិយាយថា បុគ្គល លះបង់ពួកកិលេសជា
អតីត លះបង់ពួកកិលេសជាអនាគត លះបង់ពួកកិលេសជាបច្ចុប្បន្នទេ
ឬ ។ អើ ។ បុគ្គល លះបង់ពួកកិលេស មិនមានទេឬ ។ អ្នកមិន
គួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ បុគ្គល លះបង់
ពួកកិលេសជាអតីត លះបង់ពួកកិលេសជាអនាគត លះបង់ពួកកិលេស
ជាបច្ចុប្បន្ន ។

ចប់ កិលេសជហនកថា ។

(៣៤៤) សុញ្ញតា សង្ខារក្ខន្ធបរិយាបន្នាតិ ។ អា-
មន្តា ។ អនិមិត្តំ សង្ខារក្ខន្ធបរិយាបន្នន្តិ ។ ន ហេវំ
វត្តព្វេ ។ បេ ។ សុញ្ញតា សង្ខារក្ខន្ធបរិយាបន្នាតិ ។
អាមន្តា ។ អប្បណិហិតោ សង្ខារក្ខន្ធបរិយាបន្នោ-
តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អនិមិត្តំ ន
វត្តព្វំ សង្ខារក្ខន្ធបរិយាបន្នន្តិ ។ អាមន្តា ។ សុញ្ញ-
តា ន វត្តព្វា សង្ខារក្ខន្ធបរិយាបន្នាតិ ។ ន ហេវំ
វត្តព្វេ ។ បេ ។ អប្បណិហិតោ ន វត្តព្វោ សង្ខារ-
ក្ខន្ធបរិយាបន្នោតិ ។ អាមន្តា ។ សុញ្ញតា ន វត្តព្វា
សង្ខារក្ខន្ធបរិយាបន្នាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។
សុញ្ញតា សង្ខារក្ខន្ធបរិយាបន្នាតិ ។ អាមន្តា ។ សង្ខា-
រក្ខន្ធោ ន អនិច្ចោ ន សង្ខតោ ន បដិច្ចសមុប្បន្នោ ន
ខយធម្មោ ន វយធម្មោ ន វិរាគធម្មោ ន និរោធធម្មោ
ន វិបរិណាមធម្មោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។
ននុ សង្ខារក្ខន្ធោ អនិច្ចោ សង្ខតោ បដិច្ចសមុប្បន្នោ

(៣៤៤) សេចក្តីសូន្យ(១) រាប់បញ្ចូលក្នុងសង្ខារក្ខន្ធដែរឬ ។
អើ ។ អនិមិត្តៈ (និព្វាន) រាប់បញ្ចូលក្នុងសង្ខារក្ខន្ធដែរឬ ។ អ្នកមិន
គួរពោលយ៉ាងនេះទេ ។ បេ ។ សេចក្តីសូន្យ រាប់បញ្ចូលក្នុងសង្ខា-
រក្ខន្ធឬ ។ អើ ។ អប្បណិហិតៈ (និព្វាន) រាប់បញ្ចូលក្នុងសង្ខារក្ខន្ធ
ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលមិនគួរនិយាយ
ថា អនិមិត្តៈ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធដែរឬ ។ អើ ។ បុគ្គលមិនគួរ
និយាយថា សេចក្តីសូន្យ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធទេឬ ។ អ្នកមិនគួរ
ពោលយ៉ាងនេះទេ ។ បេ ។ បុគ្គលមិនគួរនិយាយថា អប្បណិហិតៈ
រាប់បញ្ចូលក្នុងសង្ខារក្ខន្ធទេឬ ។ អើ ។ បុគ្គលមិនគួរនិយាយថា សេច-
ក្តីសូន្យ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះ
ទេ ។ បេ ។ សេចក្តីសូន្យ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធឬ ។ អើ ។
សង្ខារក្ខន្ធ មិនមែនជារបស់មិនទៀង មិនមែនជាបច្ច័យប្រជុំតាក់តែង មិន
មែនកើតឡើងដោយអាស្រ័យហេតុ មិនមែនមានសភាពអស់ទៅ មិនមែន
មានសភាពសូន្យទៅ មិនមែនមានសភាពប្រាសចាកតម្រេក មិនមែន
មានសភាពរលត់ មិនមែនមានសភាពប្រែប្រួលទេឬ ។ អ្នកមិនគួរពោល
យ៉ាងនេះទេ ។ បេ ។ ក្រែងសង្ខារក្ខន្ធ មិនទៀង បច្ច័យប្រជុំតាក់តែង

---

១ បានដល់ទុក្ខនិងអនត្តលក្ខណៈ ។

ខយធម្មោ វយធម្មោ វិរាគធម្មោ និរោធធម្មោ វិបរិណា-
មធម្មោតិ ។ អាមន្តា ។ ហញ្ចិ សង្ខារក្ខន្ធោ អ-
និច្ចោ ។ បេ ។ វិបរិណាមធម្មោ តេន វត រេ វត្តព្វេ
សុញ្ញតា សង្ខារក្ខន្ធបរិយាបន្នាតិ ។

(៣៤៨) រូបក្ខន្ធស្ស សុញ្ញតា សង្ខារក្ខន្ធបរិ-
យាបន្នាតិ ។ អាមន្តា ។ សង្ខារក្ខន្ធស្ស សុញ្ញតា
រូបក្ខន្ធបរិយាបន្នាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។
វេទនាក្ខន្ធស្ស ។ បេ ។ សញ្ញាក្ខន្ធស្ស ។ បេ ។ វិញ្ញា-
ណក្ខន្ធស្ស សុញ្ញតា សង្ខារក្ខន្ធបរិយាបន្នាតិ ។
អាមន្តា ។ សង្ខារក្ខន្ធស្ស សុញ្ញតា វិញ្ញាណក្ខន្ធ-
បរិយាបន្នាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៤៩) សង្ខារក្ខន្ធស្ស សុញ្ញតា ន វត្តព្វា
រូបក្ខន្ធបរិយាបន្នាតិ ។ អាមន្តា ។ រូបក្ខន្ធស្ស
សុញ្ញតា ន វត្តព្វា សង្ខារក្ខន្ធបរិយាបន្នាតិ ។ ន
ហេវំ វត្តព្វេ ។ បេ ។ សង្ខារក្ខន្ធស្ស សុញ្ញតា ន
វត្តព្វា វេទនាក្ខន្ធបរិយាបន្នា ។ បេ ។ សញ្ញាក្ខន្ធបរិ-
យាបន្នា ។ បេ ។ វិញ្ញាណក្ខន្ធបរិយាបន្នាតិ ។ អា-
មន្តា ។ វិញ្ញាណក្ខន្ធស្ស សុញ្ញតា ន វត្តព្វា សង្ខា-
រក្ខន្ធបរិយាបន្នាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

កើតឡើងដោយអាស្រ័យហេតុ មានការអស់ទៅ មានការសាបសូន្យទៅ
មានសភាពប្រាសចាកតម្រេក មានការរលត់ទៅ មានសភាពប្រែ-
ប្រួលឬ ។ អើ ។ ប្រសិនបើ សង្ខារក្ខន្ធមិនទៀង ។ បេ ។ មាន
សភាពប្រែប្រួលទៅ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សេចក្តី
សូន្យ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធទេ ។

(៣៤៨) សេចក្តីសូន្យ នៃរូបក្ខន្ធ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធឬ ។
អើ ។ សេចក្តីសូន្យ នៃសង្ខារក្ខន្ធ រាប់បញ្ចូលក្នុងរូបក្ខន្ធឬ ។ អ្នកមិន
គួរពោលយ៉ាងនេះទេ ។ បេ ។ សេចក្តីសូន្យ នៃវេទនាក្ខន្ធ ។ បេ ។
នៃសញ្ញាក្ខន្ធ ។ បេ ។ នៃវិញ្ញាណក្ខន្ធ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធឬ ។
អើ ។ សេចក្តីសូន្យ នៃសង្ខារក្ខន្ធ រាប់បញ្ចូលក្នុងវិញ្ញាណក្ខន្ធឬ ។
អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៤៩) បុគ្គលមិនគួរនិយាយថា សេចក្តីសូន្យ នៃសង្ខារក្ខន្ធ
រាប់បញ្ចូលក្នុងរូបក្ខន្ធទេឬ ។ អើ ។ បុគ្គលមិនគួរនិយាយថា សេចក្តី
សូន្យ នៃរូបក្ខន្ធ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធទេឬ ។ អ្នកមិនគួរពោល
យ៉ាងនេះទេ ។ បេ ។ បុគ្គលមិនគួរនិយាយថា សេចក្តីសូន្យ នៃសង្ខា-
រក្ខន្ធ រាប់បញ្ចូលក្នុងវេទនាក្ខន្ធ ។ បេ ។ រាប់បញ្ចូលក្នុងសញ្ញាក្ខន្ធ
។ បេ ។ រាប់បញ្ចូលក្នុងវិញ្ញាណក្ខន្ធទេឬ ។ អើ ។ បុគ្គលមិនគួរនិយាយ
ថា សេចក្តីសូន្យ នៃវិញ្ញាណក្ខន្ធ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធទេឬ ។
អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៤៧) ន វត្តព្វំ សុញ្ញតា សង្ខារក្ខន្ធបរិយាបន្នាតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា សុញ្ញមិទំ ភិក្ខវេ សង្ខារា អត្តេន វា អត្តនិយេន វាតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ សុញ្ញតា សង្ខារក្ខន្ធបរិយាបន្នាតិ ។

សុញ្ញតាកថា ។

សាមញ្ញផលកថា

(៣៤៨) សាមញ្ញផលំ អសង្ខតន្តិ ។ អាមន្តា ។ និព្វានំ តាណំ លេណំ សរណំ បរាយណំ អច្ចុតំ អមតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សាមញ្ញផលំ អសង្ខតំ និព្វានំ អសង្ខតន្តិ ។ អាមន្តា ។ ទ្វេ អសង្ខតានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទ្វេ អសង្ខតានីតិ ។ អាមន្តា ។ ទ្វេ តាណានិ ។ បេ ។ អន្តរិកា វាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៤៩) សាមញ្ញផលំ អសង្ខតន្តិ ។ អាមន្តា ។ សាមញ្ញំ អសង្ខតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សាមញ្ញំ សង្ខតន្តិ ។ អាមន្តា ។ សាមញ្ញផលំ សង្ខតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សោតាបត្តិផលំ អសង្ខតន្តិ ។ អាមន្តា ។

(៣៤៧) បុគ្គលមិនគួរនិយាយថា សេចក្ដីសូន្យ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយ នេះ សូន្យចាកខ្លួនផង ចាកវត្ថុរបស់ខ្លួនផង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ សេចក្ដីសូន្យ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ។

ចប់ សុញ្ញតាកថា ។

សាមញ្ញផលកថា

(៣៤៨) សាមញ្ញផល ជាអសង្ខតៈឬ ។ អើ ។ និព្វាន ជាទីពឹង ជាទីជ្រក ជាទីរលឹក ជាទីប្រព្រឹត្តទៅខាងមុខ មិនច្យុត មិនស្លាប់ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សាមញ្ញផល ជាអសង្ខតៈ ចុះនិព្វាន ជាអសង្ខតៈឬ ។ អើ ។ អសង្ខតៈ មានពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អសង្ខតៈ មានពីរឬ ។ អើ ។ ទីពឹង មានពីរ ។ បេ ។ ការរិទាសក្ដិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៤៩) សាមញ្ញផល ជាអសង្ខតៈឬ ។ អើ ។ សាមញ្ញ ជាអសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សាមញ្ញ ជាសង្ខតៈឬ ។ អើ ។ សាមញ្ញផល ជាសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សោតាបត្តិផល ជាអសង្ខតៈឬ ។ អើ ។

សោតាបត្តិមគ្គោ អសង្ខតោតិ ។ ឱ ហេវំ វត្តព្វេ ។ បេ ។ សោតាបត្តិមគ្គោ សង្ខតោតិ ។ អាមន្តា ។ សោតាបត្តិផលំ សង្ខតន្តិ ។ ឱ ហេវំ វត្តព្វេ ។ បេ ។ សកទាគាមិផលំ ។ បេ ។ អនាគាមិផលំ ។ បេ ។ អរហត្តផលំ អសង្ខតន្តិ ។ អាមន្តា ។ អរហត្តមគ្គោ អសង្ខតោតិ ។ ឱ ហេវំ វត្តព្វេ ។ បេ ។ អរហត្តមគ្គោ សង្ខតោតិ ។ អាមន្តា ។ អរហត្តផលំ សង្ខតន្តិ ។ ឱ ហេវំ វត្តព្វេ ។ បេ ។ សោតាបត្តិផលំ អសង្ខតំ សកទាគាមិផលំ ។ បេ ។ អនាគាមិផលំ ។ បេ ។ អរហត្តផលំ អសង្ខតំ និព្ពានំ អសង្ខតន្តិ ។ អាមន្តា ។ បញ្ច អសង្ខតានីតិ ។ ឱ ហេវំ វត្តព្វេ ។ បេ ។ បញ្ច អសង្ខតានីតិ ។ អាមន្តា ។ បញ្ច តាណានិ ។ បេ ។ អន្តរិកា វាតិ ។ ឱ ហេវំ វត្តព្វេ ។ បេ ។

សាមញ្ញផលកថា ។

បត្តិកថា

(៣៥០) បត្តិ អសង្ខតាតិ ។ អាមន្តា ។ និព្ពានំ តាណំ លេណំ សរណំ បរាយណំ អច្ចុតំ អមតន្តិ ។ ឱ ហេវំ វត្តព្វេ ។ បេ ។ បត្តិ អសង្ខតា

សោតាបត្តិមគ្គ ជាអសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សោតាបត្តិមគ្គ ជាសង្ខតៈឬ ។ អើ ។ សោតាបត្តិផល ជាសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សកទាគាមិផល ។ បេ ។ អនាគាមិផល ។ បេ ។ អរហត្តផល ជាអសង្ខតៈឬ ។ អើ ។ អរហត្តមគ្គ ជាអសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អរហត្តមគ្គ ជាសង្ខតៈឬ ។ អើ ។ អរហត្តផល ជាសង្ខតៈដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សោតាបត្តិផល ជាអសង្ខតៈ សកទាគាមិផល ។ បេ ។ អនាគាមិផល ។ បេ ។ អរហត្តផល ជាអសង្ខតៈ និព្វាន ជាអសង្ខតៈឬ ។ អើ ។ អសង្ខតៈ មាន ៥ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អសង្ខតៈ មាន ៥ ឬ ។ អើ ។ ទីពឹង មាន ៥ ។ បេ ។ កាពិទាសក្តិ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ សាមញ្ញផលកថា ។

បត្តិកថា

(៣៥០) ការបាន ជាអសង្ខតៈឬ ។ អើ ។ និព្វាន ជាទីពឹង ជាទីជ្រក ជាទីលាក់ ជាទីប្រព្រឹត្តទៅខាងមុខ មិនច្យុត មិនស្លាប់ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការបាន ជាអសង្ខតៈ

និព្វានំ អសង្ខតន្តិ ។ អាមន្តា ។ ទ្វេ អសង្ខតានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទ្វេ អសង្ខតានីតិ ។ អាមន្តា ។ ទ្វេ តាណានិ ។ បេ ។ អន្តរិកា ភតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៩១) ចីវរស្ស បត្តិ អសង្ខតាតិ ។ អាមន្តា ។ និព្វានំ ។ បេ ។ អមតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ចីវរស្ស បត្តិ អសង្ខតា និព្វានំ អសង្ខតន្តិ ។ អាមន្តា ។ ទ្វេ អសង្ខតានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទ្វេ អសង្ខតានីតិ ។ អាមន្តា ។ ទ្វេ តាណានិ ។ បេ ។ អន្តរិកា ភតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ បិណ្ឌបាតស្ស ។ បេ ។ សេនាសនស្ស ។ បេ ។ គិលានប្បច្ចយភេសជ្ជបរិក្ខារស្ស បត្តិ អសង្ខតាតិ ។ អាមន្តា ។ និព្វានំ ។ បេ ។ អមតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ គិលានប្បច្ចយភេសជ្ជបរិក្ខារស្ស បត្តិ អសង្ខតា និព្វានំ អសង្ខតន្តិ ។ អាមន្តា ។ ទ្វេ អសង្ខតានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទ្វេ អសង្ខតានីតិ ។ អាមន្តា ។ ទ្វេ តាណានិ ។ បេ ។ អន្តរិកា ភតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ចុះនិព្វាន ជាអសង្ខតៈដែរឬ ។ អើ ។ អសង្ខតៈ មានពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អសង្ខតៈ មានពីរឬ ។ អើ ។ ទីពឹង មានពីរ ។ បេ ។ ការវិនាសក្តី ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៩១) ការបាននូវចីវរ ជាអសង្ខតៈឬ ។ អើ ។ និព្វាន ។ បេ ។ មិនស្លាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការបាននូវចីវរ ជាអសង្ខតៈ ចុះនិព្វាន ជាអសង្ខតៈដែរឬ ។ អើ ។ អសង្ខតៈ មានពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អសង្ខតៈ មានពីរឬ ។ អើ ។ ទីពឹង មានពីរ ។ បេ ។ ការវិនាសក្តី ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការបាននូវបិណ្ឌបាត ។ បេ ។ នូវសេនាសនៈ ។ បេ ។ នូវគិលានប្បច្ចយភេសជ្ជបរិក្ខារ ជាអសង្ខតៈឬ ។ អើ ។ និព្វាន ។ បេ ។ មិនស្លាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការបាននូវគិលានប្បច្ចយភេសជ្ជបរិក្ខារ ជាអសង្ខតៈ ចុះនិព្វាន ជាអសង្ខតៈដែរឬ ។ អើ ។ អសង្ខតៈ មានពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អសង្ខតៈ មានពីរឬ ។ អើ ។ ទីពឹង មានពីរ ។ បេ ។ ការវិនាសក្តី ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចីវរស្ស លទ្ធំ អសង្ខតា បិណ្ឌបាតស្ស ។ បេ ។ សេ-
នាសនស្ស ។ បេ ។ គិលានប្បច្ចយភេសជ្ជបរិក្ខារស្ស
បត្តិ អសង្ខតា និព្វានំ អសង្ខតន្តិ ។ អាមន្តា ។ បញ្ច
អសង្ខតានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ បញ្ច
អសង្ខតានីតិ ។ អាមន្តា ។ បញ្ច តាណានិ ។ បេ ។
អន្តរិកា កាចិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៨៦) បឋមស្ស ឈានស្ស បត្តិ អសង្ខតា
ឯវំ សព្វំ វិត្ថារេតព្វំ ទុតិយស្ស ឈានស្ស តតិ-
យស្ស ឈានស្ស ចតុត្ថស្ស ឈានស្ស អាកាសា-
នញ្ចាយតនស្ស វិញ្ញាណញ្ចាយតនស្ស អាកិញ្ចញ្ញា-
យតនស្ស នេវសញ្ញានាសញ្ញាយតនស្ស ។ បេ ។
សោតាបត្តិមគ្គស្ស សោតាបត្តិផលស្ស សកទាគា-
មិមគ្គស្ស សកទាគាមិផលស្ស អនាគាមិមគ្គស្ស អ-
នាគាមិផលស្ស អរហត្តមគ្គស្ស អរហត្តផលស្ស បត្តិ
អសង្ខតាតិ ។ អាមន្តា ។ និព្វានំ ។ បេ ។ អច្ចុតំ
អមតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អរហត្តផលស្ស
បត្តិ អសង្ខតា និព្វានំ អសង្ខតន្តិ ។ អាមន្តា ។
ទ្វេ អសង្ខតានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ការបាននូវចីវរ ជាអសង្ខតៈ ការបាននូវបិណ្ឌបាត ។ បេ ។ នូវសេនា-
សនៈ ។ បេ ។ នូវគិលានប្បច្ចយភេសជ្ជបរិក្ខារ ជាអសង្ខតៈ ព្រះនិព្វាន
ជាអសង្ខតៈដែរឬ ។ អើ ។ អសង្ខតៈ មាន ៥ ឬ ។ អ្នកមិនគួរពោល
យ៉ាងនេះទេ ។ បេ ។ អសង្ខតៈ មាន ៥ ឬ ។ អើ ។ ទីពឹង មាន ៥
។ បេ ។ ការពិតាសក្តិឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៨៦) ការបាននូវបឋមជ្ឈាន ជាអសង្ខតៈ សេចក្តីទាំងអស់
អ្នកប្រាជ្ញគប្បីឲ្យពិស្តារផងចុះ ការបាននូវទុតិយជ្ឈាន នូវតតិយជ្ឈាន
នូវចតុត្ថជ្ឈាន នូវអាកាសានញ្ចាយតនៈ នូវវិញ្ញាណញ្ចាយតនៈ នូវអា-
កិញ្ចញ្ញាយតនៈ នូវនេវសញ្ញានាសញ្ញាយតនៈ ។ បេ ។ នូវសោតាបត្តិមគ្គ
នូវសោតាបត្តិផល នូវសកទាគាមិមគ្គ នូវសកទាគាមិផល នូវអនាគាមិមគ្គ
នូវអនាគាមិផល នូវអរហត្តមគ្គ នូវអរហត្តផល ជាអសង្ខតៈឬ ។ អើ ។
និព្វាន ។ បេ ។ មិនច្យុត មិនស្លាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។
ការបាននូវអរហត្តផល ជាអសង្ខតៈ ព្រះនិព្វាន ជាអសង្ខតៈដែរឬ ។
អើ ។ អសង្ខតៈ មានពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ទ្វេ អសង្ខតានីតិ ។ អាមន្តា ។ ទ្វេ តាណានិ ។ បេ ។ អន្តរិកា ភវតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សោតាបត្តិមគ្គស្ស បត្តិ អសង្ខតា សោតាបត្តិផលស្ស បត្តិ អសង្ខតា ។ បេ ។ អរហត្តមគ្គស្ស បត្តិ អសង្ខតា អរហត្តផលស្ស បត្តិ អសង្ខតា និព្វានំ អសង្ខតន្តិ ។ អាមន្តា ។ ឆ អសង្ខតានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ឆ អសង្ខតានីតិ ។ អាមន្តា ។ ឆ តាណានិ ។ បេ ។ អន្តរិកា ភវតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៨៣) ន វត្តព្វំ បត្តិ អសង្ខតាតិ ។ អាមន្តា ។ បត្តិ រូបំ វេទនា សញ្ញា សង្ខារា វិញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ បត្តិ អសង្ខតាតិ ។

បត្តិកថា ។

តថតាកថា

(៣៨៤) សព្វធម្មានំ តថតា អសង្ខតាតិ ។ អាមន្តា ។ និព្វានំ ។ បេ ។ អមតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សព្វធម្មានំ តថតា អសង្ខតា និព្វានំ អសង្ខតន្តិ ។ អាមន្តា ។ ទ្វេ អសង្ខតានីតិ ។

អភិធម្មបិដក កថាវត្ថុ

អសង្ខតៈ មានពីរឬ ។ អើ ។ ទីពឹង ក៏ពីរ ។ បេ ។ ការលើសគ្នាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ការបាននូវសោតាបត្តិមគ្គ ជាអសង្ខតៈ ការបាននូវសោតាបត្តិផល ជាអសង្ខតៈ ។ បេ ។ ការបាននូវអរហត្តមគ្គ ជាអសង្ខតៈ ការបាននូវអរហត្តផល ជាអសង្ខតៈ ចុះនិព្វាន ជាអសង្ខតៈដែរឬ ។ អើ ។ អសង្ខតៈ មាន៦ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អសង្ខតៈ មាន៦ឬ ។ អើ ។ ទីពឹង មាន៦ ។ បេ ។ ការលើសគ្នាឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៨៣) បុគ្គលមិនគួរនិយាយថា ការបាន ជាអសង្ខតៈទេឬ ។ អើ ។ ការបាន គឺជារូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ ការបាន ជាអសង្ខតៈ ។

ចប់ បត្តិកថា ។

តថតាកថា

(៣៨៤) សេចក្តីទៀងទាត់នៃធម៌ទាំងពួង (មានរូបជាដើម) ជាអសង្ខតៈឬ ។ អើ ។ និព្វាន ។ បេ ។ មិនស្លាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សេចក្តីទៀងទាត់នៃធម៌ទាំងពួង ជាអសង្ខតៈ ចុះនិព្វាន ជាអសង្ខតៈដែរឬ ។ អើ ។ អសង្ខតៈ មានពីរឬ ។

ន ហេវំ វត្តព្វេ ។ បេ ។ ទ្វេ អសង្ខតានីតិ ។ អាមន្តា ។ ទ្វេ តាណានិ ។ បេ ។ អន្តរិកា អត្ថីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៨៥) រូបស្ស រូបតា ន ច រូបតា អសង្ខតាតិ ។ អាមន្តា ។ និព្វានំ ។ បេ ។ អមតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ រូបស្ស រូបតា ន ច រូបតា អសង្ខតា និព្វានំ អសង្ខតន្តិ ។ អាមន្តា ។ ទ្វេ អសង្ខតានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទ្វេ អសង្ខតានីតិ ។ អាមន្តា ។ ទ្វេ តាណានិ ។ បេ ។ អន្តរិកា អត្ថីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ វេទនាយ វេទនតា ន ច វេទនតា ។ បេ ។ សញ្ញាយ សញ្ញតា ន ច សញ្ញតា ។ បេ ។ សង្ខារានំ សង្ខារតា ន ច សង្ខារតា ។ បេ ។ វិញ្ញាណស្ស វិញ្ញាណតា ន ច វិញ្ញាណតា អសង្ខតាតិ ។ អាមន្តា ។ និព្វានំ ។ បេ ។ អមតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ រូបស្ស រូបតា ន ច រូបតា អសង្ខតា ។ បេ ។ វិញ្ញាណស្ស វិញ្ញាណតា ន ច វិញ្ញាណតា អសង្ខតា និព្វានំ អសង្ខតន្តិ ។ អាមន្តា ។ ឆ អសង្ខតានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ឆ អសង្ខតានីតិ ។ អាមន្តា ។

អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អសង្ខតៈ មានពីរឬ ។ អើ ។ ទីពឹង មានពីរ ។ បេ ។ ការវិនាសក្តីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៨៥) ភាពជារូបនៃរូប ក្រែងភាពជារូប ជាអសង្ខតៈឬ ។ អើ ។ និព្វាន ។ បេ ។ មិនស្លាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ភាពជារូបនៃរូប ក្រែងភាពជារូប ជាអសង្ខតៈ និព្វាន ជាអសង្ខតៈឬ ។ អើ ។ អសង្ខតៈ មានពីរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អសង្ខតៈ មានពីរឬ ។ អើ ។ ទីពឹង មានពីរ ។ បេ ។ ការវិនាសក្តីឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ភាពជាវេទនានៃវេទនា ក្រែងភាពជាវេទនា ។ បេ ។ ភាពជាសញ្ញានៃសញ្ញា ក្រែងភាពជាសញ្ញា ។ បេ ។ ភាពជាសង្ខារនៃសង្ខារទាំងឡាយ ក្រែងភាពជាសង្ខារ ។ បេ ។ ភាពជាវិញ្ញាណនៃវិញ្ញាណ ក្រែងភាពជាវិញ្ញាណ ជាអសង្ខតៈឬ ។ អើ ។ និព្វាន ។ បេ ។ មិនស្លាប់ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ភាពជារូបនៃរូប ក្រែងភាពជារូប ជាអសង្ខតៈ ។ បេ ។ ភាពជាវិញ្ញាណនៃវិញ្ញាណ ក្រែងភាពជាវិញ្ញាណ ជាអសង្ខតៈ និព្វាន ជាអសង្ខតៈដែរឬ ។ អើ ។ អសង្ខតៈ មាន ៦ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អសង្ខតៈ មាន ៦ ឬ ។ អើ ។

ន ញាណានិ ។ បេ ។ អន្តរិកា ភវេ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៨៦) ន វត្តព្វំ សព្វេ ធម្មា តថា អសង្ខតា-តិ ។ អាមន្តា ។ សព្វេ ធម្មា តថា រូបំ វេទនា សញ្ញា សង្ខារា វិញ្ញាណន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ តេន ហិ សព្វេ ធម្មា តថា អសង្ខតាតិ ។

តថតាកថា ។

កុសលកថា

(៣៨៧) និព្ពានធាតុ កុសលាតិ ។ អាមន្តា ។ សារម្មណា អត្ថិ តាយ អាវដ្ដនា ។ បេ ។ បណិ-ធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ អនារម្មណា នត្ថិ តាយ អាវដ្ដនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ ហញ្ចិ អនារម្មណា នត្ថិ តាយ អាវដ្ដនា ។ បេ ។ បណិធិ នោ ច វត រេ វត្តព្វេ និព្ពានធាតុ កុសលាតិ ។

ទីពឹង មានឬ ។ បេ ។ ការរំពឹងសេចក្ដីឬ ។ អ្នកមិនគួរពោលយ៉ាងនេះ ទេ ។ បេ ។

(៣៨៦) បុគ្គលមិនគួរនិយាយថា សេចក្ដីទៀងទាត់នៃធម៌ទាំងពួង ជាអសង្ខតៈទេឬ ។ អើ ។ សេចក្ដីទៀងទាត់នៃធម៌ទាំងពួង គឺជារូប វេទនា សញ្ញា សង្ខារទាំងឡាយ វិញ្ញាណឬ ។ អ្នកមិនគួរពោល យ៉ាងនេះទេ ។ បេ ។ ព្រោះហេតុនោះ សេចក្ដីទៀងទាត់នៃធម៌ទាំងពួង ជាអសង្ខតៈ ។

ចប់ តថតាកថា ។

កុសលកថា

(៣៨៧) និព្វានធាតុ ជាកុសលឬ ។ អើ ។ និព្វានធាតុ ប្រកប ដោយអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក នៃនិព្វានធាតុនោះ មាននៅឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងនិព្វានធាតុ មិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក នៃនិព្វានធាតុ នោះ មិនមានទេឬ ។ អើ ។ ប្រសិនបើ និព្វានធាតុ មិនមាន អារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក នៃនិព្វានធាតុនោះ មិន មានទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា និព្វានធាតុ ជាកុ-សលទេ ។

(៣៨៨) អលោភោ កុសលោ សារម្មណោ អត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ វិញ្ញាណធាតុ កុសលា សារម្មណា អត្ថិ តាយ អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អទោសោ កុសលោ ។ បេ ។ អមោហោ កុសលោ ។ បេ ។ សទ្ធា វីរិយំ សតិ សមាធិ ។ បេ ។ បញ្ញា កុសលា សារម្មណា អត្ថិ តាយ អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ វិញ្ញាណធាតុ កុសលា សារម្មណា អត្ថិ តាយ អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៨៩) វិញ្ញាណធាតុ កុសលា អនារម្មណា នត្ថិ តាយ អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ អលោភោ កុសលោ អនារម្មណោ នត្ថិ តស្ស អាវជ្ជនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ វិញ្ញាណធាតុ កុសលា អនារម្មណា នត្ថិ តាយ អាវជ្ជនា ។ បេ ។ បណិធីតិ ។ អាមន្តា ។ អទោសោ

(៣៨៨) អលោភៈ ជាកុសល ប្រកបដោយអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក នៃអលោភៈនោះ មានដែរឬ ។ អើ ។ វិញ្ញាណធាតុ ជាកុសល ប្រកបដោយអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក នៃវិញ្ញាណធាតុនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អទោសៈ ជាកុសល ។ បេ ។ អមោហៈ ជាកុសល ។ បេ ។ សទ្ធា វីរិយៈ សតិ សមាធិ ។ បេ ។ បញ្ញា ជាកុសល ប្រកបដោយអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក នៃបញ្ញានោះ មានដែរឬ ។ អើ ។ វិញ្ញាណធាតុ ជាកុសល ប្រកបដោយអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក នៃវិញ្ញាណធាតុនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៨៩) វិញ្ញាណធាតុ ជាកុសល មិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក នៃវិញ្ញាណធាតុនោះ មិនមានទេឬ ។ អើ ។ អលោភៈ ជាកុសល មិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក នៃអលោភៈនោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វិញ្ញាណធាតុ ជាកុសល មិនមានអារម្មណ៍ ការរំពឹង ។ បេ ។ ការតាំងចិត្តទុក នៃវិញ្ញាណធាតុនោះ មិនមានទេឬ ។ អើ ។ អទោសៈ

កុសលោ ។ បេ ។ អលោភោ កុសលោ ។ បេ ។ សទ្ធា វីរិយំ សតិ សមាធិ ។ បេ ។ បញ្ញា កុសលា អនារម្មណា នត្ថិ តាយ អាវដ្ដនា ។ បេ ។ បណិធីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៦០) ន វត្តព្វំ និព្វានធាតុ កុសលាតិ ។ អាមន្តា ។ ននុ និព្វានធាតុ អនវជ្ជាតិ ។ អាមន្តា ។ ហញ្ចិ និព្វានធាតុ អនវជ្ជា តេន វត រេ វត្តព្វេ និព្វានធាតុ កុសលាតិ ។

កុសលកថា ។

អច្ចន្តនិយាមតាកថា

(៣៦១) អត្ថិ បុថុជ្ជនស្ស អច្ចន្តនិយាមតាតិ ។ អាមន្តា ។ មាតុឃាតកោ អច្ចន្តនិយតោ បិតុឃាតកោ ។ បេ ។ អរហន្តឃាតកោ ។ បេ ។ រុហិរុប្បាទកោ ។ បេ ។ សង្ឃភេទកោ អច្ចន្តនិយតោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ បុថុជ្ជនស្ស អច្ចន្តនិយាមតាតិ ។ អាមន្តា ។ អច្ចន្តនិយតស្ស បុគ្គលស្ស វិចិកិច្ឆា ឧប្បជ្ជេយ្យាតិ ។ អាមន្តា ។ ហញ្ចិ អច្ចន្តនិយតស្ស បុគ្គលស្ស វិចិកិច្ឆា ឧប្បជ្ជេយ្យ នោ វត រេ វត្តព្វេ អត្ថិ បុថុជ្ជនស្ស អច្ចន្តនិយាមតាតិ ។

ជាកុសល ។ បេ ។ អលោភៈ ជាកុសល ។ បេ ។ សទ្ធា វីរិយៈ សតិ សមាធិ ។ បេ ។ បញ្ញា ជាកុសល មិនមានអារម្មណ៍ ការនឹក ។ បេ ។ ការតាំងចិត្តទុក ក្នុងបញ្ញានោះ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៦០) បុគ្គលមិនគួរនិយាយថា និព្វានធាតុ ជាកុសលទេឬ ។ អើ ។ ក្រែងនិព្វានធាតុ មិនមានទោសទេឬ ។ អើ ។ ប្រសិនបើ និព្វានធាតុ មិនមានទោសទេ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា និព្វានធាតុ ជាកុសលដែរ ។

ចប់ កុសលកថា ។

អច្ចន្តនិយាមតាកថា

(៣៦១) សេចក្តីទៀងពិតតែម្យ៉ាង របស់បុថុជ្ជន មានដែរឬ ។ អើ ។ បុគ្គលសម្លាប់មាតា ជាបុគ្គលទៀងពិតតែម្យ៉ាង បុគ្គលសម្លាប់បិតា ។ បេ ។ បុគ្គលសម្លាប់ព្រះអរហន្ត ។ បេ ។ បុគ្គលញ៉ាំងព្រះលោហិតឲ្យពុះពោរឡើង ។ បេ ។ បុគ្គលបំបែកសង្ឃ ជាបុគ្គលទៀងពិតតែម្យ៉ាងឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សេចក្តីទៀងពិតតែម្យ៉ាង របស់បុថុជ្ជន មានដែរឬ ។ អើ ។ វិចិកិច្ឆា នៃបុគ្គលទៀងពិតតែម្យ៉ាង គប្បីកើតឡើងដែរឬ ។ អើ ។ ប្រសិនបើ វិចិកិច្ឆា នៃបុគ្គលទៀងពិតតែម្យ៉ាង គប្បីកើតឡើង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សេចក្តីទៀងពិតតែម្យ៉ាង របស់បុថុជ្ជន មានទេ ។

(៣៤៦) អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆា នុប្បជ្ជេយ្យាតិ ។ អាមន្តា ។ បហីយតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ បហីយតិ ។ អាមន្តា ។ សោតាបត្តិមគ្គេនាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សកទាគាមិមគ្គេន ។ បេ ។ អនាគាមិមគ្គេន ។ បេ ។ អរហត្តមគ្គេនាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កតមេន មគ្គេនាតិ ។ អកុសលេន មគ្គេនាតិ ។ អកុសលោ មគ្គោ និយ្យានិកោ ខយគាមី ពោធគាមី អបចយគាមី អនាសវោ ។ បេ ។ អសង្កិលេសិកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ អកុសលោ មគ្គោ អនិយ្យានិកោ ។ បេ ។ សង្កិលេសិកោតិ ។ អាមន្តា ។ ហញ្ចិ អកុសលោ មគ្គោ អនិយ្យានិកោ ។ បេ ។ សង្កិលេសិកោ នោ ច វត រេ វត្តព្វេ អដ្ឋមកស្ស បុគ្គលស្ស វិចិកិច្ឆា អកុសលេន មគ្គេន បហីយតីតិ ។

(៣៤៦) វិចិកិច្ឆា របស់បុគ្គលទៀងទាត់តែម្យ៉ាង មិនគប្បីកើតឡើងទេឬ ។ អើ ។ (បុគ្គលទៀងទាត់តែម្យ៉ាង) លះបង់ (វិចិកិច្ឆា) ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ (បុគ្គលទៀងទាត់តែម្យ៉ាង) លះបង់ (វិចិកិច្ឆា) ហើយឬ ។ អើ ។ (លះបង់) ដោយសោតាបត្តិមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ (លះបង់) ដោយសកទាគាមិមគ្គ ។ បេ ។ ដោយអនាគាមិមគ្គ ។ បេ ។ ដោយអរហត្តមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ (លះបង់) ដោយមគ្គ ដូចម្តេច ។ ដោយមគ្គ ជាអកុសល ។ មគ្គ ជាអកុសល ជាទីស្រោចស្រង់ ដល់នូវការអស់ទៅ ដល់នូវការត្រាស់ដឹង មិនដល់នូវការសន្សំកពូនឡើង មិនមានអាសវៈ ។ បេ ។ មិនគួរដល់សេចក្តីសៅហ្មងទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងមគ្គ ជាអកុសល មិនជាទីស្រោចស្រង់ ។ បេ ។ គួរដល់សេចក្តីសៅហ្មងឬ ។ អើ ។ ប្រសិនបើ មគ្គ ជាអកុសល មិនជាទីស្រោចស្រង់ ។ បេ ។ គួរដល់សេចក្តីសៅហ្មង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលទៀងទាត់តែម្យ៉ាង លះបង់វិចិកិច្ឆា ដោយមគ្គ ជាអកុសលទេ ។

(៣៦៣) សស្សតទិដ្ឋិយា និយតស្ស បុគ្គលស្ស ឧច្ឆេទទិដ្ឋិ ឧប្បជ្ជិស្សតីតិ ។ អាមន្តា ។ ហញ្ចិ សស្សតទិដ្ឋិយា និយតស្ស បុគ្គលស្ស ឧច្ឆេទទិដ្ឋិ ឧប្បជ្ជិស្សតិ នោ វត រេ វត្តព្វេ អត្ថិ បុថុជ្ជនស្ស អច្ចន្តនិយាមតាតិ ។

(៣៦៤) សស្សតទិដ្ឋិយា និយតស្ស បុគ្គលស្ស ឧច្ឆេទទិដ្ឋិ ឧប្បជ្ជិស្សតីតិ ។ អាមន្តា ។ បហីនាតិ ។ ន ហេវំ វត្តព្វេ ។បេ។ បហីនាតិ ។ អាមន្តា ។ សោតាបត្តិមគ្គេនាតិ ។ ន ហេវំ វត្តព្វេ ។បេ។ សកទាគាមិមគ្គេន ។បេ។ អនាគាមិមគ្គេន ។បេ។ អរហត្តមគ្គេនាតិ ។ ន ហេវំ វត្តព្វេ ។បេ។ កតមេន មគ្គេនាតិ ។ អកុសលេន មគ្គេនាតិ ។ អកុសលោ មគ្គោ ។បេ។ នោ វត រេ វត្តព្វេ សស្សតទិដ្ឋិយា និយតស្ស បុគ្គលស្ស ឧច្ឆេទទិដ្ឋិ អកុសលេន មគ្គេន បហីនាតិ ។

(៣៦៣) ឧច្ឆេទទិដ្ឋិ របស់បុគ្គលទៀង ដោយសស្សតទិដ្ឋិ គប្បីកើតឡើងដែរឬ ។ អើ ។ ប្រសិនបើ ឧច្ឆេទទិដ្ឋិ របស់បុគ្គលទៀង ដោយសស្សតទិដ្ឋិ គប្បីកើតឡើង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សេចក្តីទៀងដាច់តែម្យ៉ាង របស់បុថុជ្ជន មានទេ ។

(៣៦៤) ឧច្ឆេទទិដ្ឋិ របស់បុគ្គលទៀង ដោយសស្សតទិដ្ឋិ មិនគប្បីកើតឡើងទេឬ ។ អើ ។ (បុគ្គលនោះ) លះបង់ (ឧច្ឆេទទិដ្ឋិ) ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ (បុគ្គលនោះ) លះបង់ (ឧច្ឆេទទិដ្ឋិ) ហើយឬ ។ អើ ។ (លះបង់) ដោយសោតាបត្តិមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ (លះបង់) ដោយសកទាគាមិមគ្គ ។បេ។ ដោយអនាគាមិមគ្គ ។បេ។ ដោយអរហត្តមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ (លះបង់) ដោយមគ្គដូចម្តេច ។ ដោយមគ្គជាអកុសល ។ មគ្គជាអកុសល ។បេ។ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលទៀង ដោយសស្សតទិដ្ឋិ លះបង់ឧច្ឆេទទិដ្ឋិ ដោយមគ្គ ជាអកុសលទេ ។

(៣៦៥) ឧច្ឆេទទិដ្ឋិយា និយតស្ស បុគ្គលស្ស សស្សតទិដ្ឋិ ឧប្បជ្ជេយ្យាតិ ។ អាមន្តា ។ ហញ្ចិ ឧច្ឆេទទិដ្ឋិយា និយតស្ស បុគ្គលស្ស សស្សតទិដ្ឋិ ឧប្បជ្ជេយ្យ នោ វត រេ វត្តព្វេ អត្ថិ បុថុជ្ជនស្ស អច្ចន្តនិយាមតាតិ ។

(៣៦៦) ឧច្ឆេទទិដ្ឋិយា និយតស្ស បុគ្គលស្ស សស្សតទិដ្ឋិ នុប្បជ្ជេយ្យាតិ ។ អាមន្តា ។ បហីនាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ បហីនាតិ ។ អាមន្តា ។ សោតាបត្តិមគ្គេនាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សកទាគាមិមគ្គេន ។ បេ ។ អរហត្តមគ្គេនាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ កតមេន មគ្គេនាតិ ។ អកុសលេន មគ្គេនាតិ ។ អកុសលោ មគ្គោ ។ បេ ។ នោ វត រេ វត្តព្វេ ឧច្ឆេទទិដ្ឋិយា និយតស្ស បុគ្គលស្ស សស្សតទិដ្ឋិ អកុសលេន មគ្គេន បហីនាតិ ។

(៣៦៥) សស្សតទិដ្ឋិ របស់បុគ្គលទៀង ដោយឧច្ឆេទទិដ្ឋិ គប្បីកើតឡើងឬ ។ អើ ។ ប្រសិនបើ សស្សតទិដ្ឋិ របស់បុគ្គលទៀង ដោយឧច្ឆេទទិដ្ឋិ គប្បីកើតឡើង ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា សេចក្តីទៀងដាច់តែម្យ៉ាង របស់បុថុជ្ជន មានទេ ។

(៣៦៦) សស្សតទិដ្ឋិ របស់បុគ្គលទៀង ដោយឧច្ឆេទទិដ្ឋិ មិនគប្បីកើតឡើងទេឬ ។ អើ ។ (បុគ្គលនោះ) លះបង់ (សស្សតទិដ្ឋិ) ហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ (បុគ្គលនោះ) លះបង់ (សស្សតទិដ្ឋិ) ហើយឬ ។ អើ ។ (លះបង់) ដោយសោតាបត្តិមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ (លះបង់) ដោយសកទាគាមិមគ្គ ។ បេ ។ ដោយអរហត្តមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ (លះបង់) ដោយមគ្គដូចម្តេច ។ ដោយមគ្គ ជាអកុសល ។ មគ្គ ជាអកុសល ។ បេ ។ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គលទៀង ដោយឧច្ឆេទទិដ្ឋិ លះបង់ សស្សតទិដ្ឋិ ដោយមគ្គ ជាអកុសលទេ ។

(៣៦៧) ន វត្តព្វំ អត្ថិ បុថុជ្ជនស្ស អច្ចន្តនិយាមតាតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ សមន្នាគតោ ហោតិ ឯកន្តកាឡកេហិ អកុសលេហិ ធម្មេហិ សោ សកឹ និមុគ្គោ និមុគ្គោវ ហោតីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ អត្ថិ បុថុជ្ជនស្ស អច្ចន្តនិយាមតាតិ ។

(៣៦៨) វុត្តំ ភគវតា ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ សមន្នាគតោ ហោតិ ឯកន្តកាឡកេហិ អកុសលេហិ ធម្មេហិ សោ សកឹ និមុគ្គោ និមុគ្គោវ ហោតីតិ កត្វា តេន ច ការណេន អត្ថិ បុថុជ្ជនស្ស អច្ចន្តនិយាមតាតិ ។ អាមន្តា ។ វុត្តំ ភគវតា ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ឧម្មុជ្ជិត្វា និមុជ្ជតីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ សព្វកាលំ ឧម្មុជ្ជិត្វា និមុជ្ជតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៦៧) បុគ្គលមិនគួរនិយាយថា សេចក្ដីទៀងទាត់តែម៉្យាង របស់បុថុជ្ជន មានទេឬ ។ អើ ។ ក៏ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ប្រកបដោយពួកធម៌ជាអកុសល ខ្មៅតែម៉្យាង បុគ្គលនោះ មុជចុះហើយចេះតែមុជចុះទៅតែម្ដង ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ សេចក្ដីទៀងទាត់តែម៉្យាង របស់បុថុជ្ជន មាន ។

(៣៦៨) ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ប្រកបដោយពួកធម៌ ជាអកុសល ខ្មៅតែម៉្យាង បុគ្គលនោះ ឈ្មោះថាមុជចុះហើយចេះតែមុជចុះទៅតែម្ដង ព្រោះហេតុនោះ សេចក្ដីទៀងទាត់តែម៉្យាង របស់បុថុជ្ជន មាន ព្រោះធ្វើនូវសេចក្ដីចូលចិត្ត ដូច្នេះឬ ។ អើ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ងើបឡើងហើយមុជចុះទៅវិញ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បុគ្គល ងើបឡើងសព្វកាលហើយមុជចុះទៅវិញឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៦៩) វុត្តំ ភគវតា ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ សមន្នាគតោ ហោតិ ឯកន្តកាឡកេហិ អកុសលេហិ ធម្មេហិ សោ សកិំ និម្មុគ្គោ និម្មុគ្គោវ ហោតីតិ កត្វា តេន ច ការណេន អត្ថិ បុថុជ្ជនស្ស អច្ចន្តនិយាមតាតិ ។ អាមន្តា ។ វុត្តំ ភគវតា ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ឧម្មុជ្ជិត្វា ឋិតោ ហោតិ ឧម្មុជ្ជិត្វា វិបស្សតិ វិលោកេតិ ឧម្មុជ្ជិត្វា បតរតិ ឧម្មុជ្ជិត្វា បតិគាធប្បត្តោ ហោតីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ សព្វកាលំ ឧម្មុជ្ជិត្វា បតិគាធប្បត្តោ ហោតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

អច្ចន្តនិយាមតាកថា ។

ឥន្ទ្រិយកថា

(៣៧០) នត្ថិ លោកិយំ សទ្ធិន្ទ្រិយន្តិ ។ អាមន្តា ។ នត្ថិ លោកិយា សទ្ធាតិ ។ ន ហេវំ វត្តព្វេ ។បេ។ នត្ថិ លោកិយំ វីរិយិន្ទ្រិយំ ។បេ។ សតិន្ទ្រិយំ ។បេ។ សមាធិន្ទ្រិយំ ។បេ។

(៣៦៩) ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ប្រកបដោយពួកធម៌ ជាអកុសល ខ្មៅតែម្យ៉ាង បុគ្គលនោះ ឈ្មោះថាមុជចុះហើយចេះតែមុជចុះទៅតែម្តង ព្រោះហេតុនោះ សេចក្តីទៀងពិតតែម្យ៉ាង របស់បុថុជ្ជន មាន ព្រោះធ្វើនូវសេចក្តីចូលចិត្តដូច្នេះឬ ។ អើ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ងើបឡើងហើយឈរនៅ ងើបឡើងរកមើលសម្លឹងមើល ងើបឡើងហើយហែលទៅ ងើបឡើងហើយដល់ត្រើយខាងនាយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ បុគ្គល ងើបឡើងសព្វកាល ហើយឆ្លងទៅត្រើយខាងនាយបានឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

ចប់ អច្ចន្តនិយាមតាកថា ។

ឥន្ទ្រិយកថា

(៣៧០) សទ្ធិន្ទ្រិយ ជាលោកិយៈ មិនមានទេឬ ។ អើ ។ សទ្ធា ជាលោកិយៈ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ វីរិយិន្ទ្រិយ ។បេ។ សតិន្ទ្រិយ ។បេ។ សមាធិន្ទ្រិយ ។បេ។

បញ្ញិន្ទ្រិយន្តិ ។ អាមន្តា ។ អត្ថិ លោកិយា បញ្ញាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៧១) អត្ថិ លោកិយា សទ្ធាតិ ។ អាមន្តា ។ អត្ថិ លោកិយំ សទ្ធិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ លោកិយំ វីរិយំ ។ បេ ។ សតិ ។ បេ ។ សមាធិ ។ បេ ។ បញ្ញាតិ ។ អាមន្តា ។ អត្ថិ លោកិយំ បញ្ញិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៧២) អត្ថិ លោកិយោ មនោ អត្ថិ លោកិយំ មនិន្ទ្រិយន្តិ ។ អាមន្តា ។ អត្ថិ លោកិយា សទ្ធា អត្ថិ លោកិយំ សទ្ធិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ លោកិយោ មនោ អត្ថិ លោកិយំ មនិន្ទ្រិយន្តិ ។ អាមន្តា ។ អត្ថិ លោកិយា បញ្ញា អត្ថិ លោកិយំ បញ្ញិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៧៣) អត្ថិ លោកិយំ សោមនស្សំ អត្ថិ លោកិយំ សោមនស្សិន្ទ្រិយំ ។ បេ ។ អត្ថិ លោកិយំ ជីវិតំ អត្ថិ លោកិយំ ជីវិតិន្ទ្រិយន្តិ ។ អាមន្តា ។ អត្ថិ លោកិយា សទ្ធា អត្ថិ លោកិយំ សទ្ធិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ លោកិយំ ជីវិតំ អត្ថិ លោកិយំ ជីវិតិន្ទ្រិយន្តិ ។ អាមន្តា ។

បញ្ញិន្ទ្រិយ ជាលោកិយៈ មិនមានទេឬ ។ អើ ។ បញ្ញា ជាលោកិយៈ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៧១) សទ្ធា ជាលោកិយៈ មានដែរឬ ។ អើ ។ សទ្ធិន្ទ្រិយ ជាលោកិយៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វីរិយៈ ។ បេ ។ សតិ ។ បេ ។ សមាធិ ។ បេ ។ បញ្ញា ជាលោកិយៈ មានដែរឬ ។ អើ ។ បញ្ញិន្ទ្រិយ ជាលោកិយៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៧២) មនៈ ជាលោកិយៈ មាន ចុះមនិន្ទ្រិយ ជាលោកិយៈ មានដែរឬ ។ អើ ។ សទ្ធា ជាលោកិយៈ មាន ចុះសទ្ធិន្ទ្រិយ ជាលោកិយៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ មនៈ ជាលោកិយៈ មាន ចុះមនិន្ទ្រិយ ជាលោកិយៈ មានដែរឬ ។ អើ ។ បញ្ញា ជាលោកិយៈ មាន ចុះបញ្ញិន្ទ្រិយ ជាលោកិយៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៧៣) សោមនស្ស ជាលោកិយៈ មាន ចុះសោមនស្សិន្ទ្រិយ ជាលោកិយៈ មាន ។ បេ ។ ជីវិត ជាលោកិយៈ មាន ចុះជីវិតិន្ទ្រិយ ជាលោកិយៈ មានដែរឬ ។ អើ ។ សទ្ធា ជាលោកិយៈ មាន ចុះសទ្ធិន្ទ្រិយ ជាលោកិយៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ជីវិត ជាលោកិយៈ មាន ចុះជីវិតិន្ទ្រិយ ជាលោកិយៈ មានដែរឬ ។ អើ ។

អត្ថិ លោកិយា បញ្ញា នត្ថិ លោកិយំ បញ្ញិន្ទ្រិ-
យន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៧៤) អត្ថិ លោកិយា សទ្ធា នត្ថិ លោកិ-
យំ សទ្ធិន្ទ្រិយន្តិ ។ អាមន្តា ។ អត្ថិ លោកិយោ
មនោ នត្ថិ លោកិយំ មនិន្ទ្រិយន្តិ ។ ន ហេវំ
វត្តព្វេ ។ បេ ។ អត្ថិ លោកិយា បញ្ញា នត្ថិ លោ-
កិយំ បញ្ញិន្ទ្រិយន្តិ ។ អាមន្តា ។ អត្ថិ លោកិយោ
មនោ នត្ថិ លោកិយំ មនិន្ទ្រិយន្តិ ។ ន ហេវំ
វត្តព្វេ ។ បេ ។ អត្ថិ លោកិយា សទ្ធា នត្ថិ លោ-
កិយំ សទ្ធិន្ទ្រិយន្តិ ។ អាមន្តា ។ អត្ថិ លោកិយំ
សោមនស្សំ នត្ថិ លោកិយំ សោមនស្សិន្ទ្រិយន្តិ
។ បេ ។ អត្ថិ លោកិយំ ជីវិតំ នត្ថិ លោកិយំ ជី-
វិតិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ លោ-
កិយា បញ្ញា នត្ថិ លោកិយំ បញ្ញិន្ទ្រិយន្តិ ។ អា-
មន្តា ។ អត្ថិ លោកិយំ ជីវិតំ នត្ថិ លោកិយំ
ជីវិតិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

បញ្ញា ជាលោកិយៈ មាន ចុះបញ្ញិន្ទ្រិយ ជាលោកិយៈ មានដែរឬ ។
អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៧៤) សទ្ធា ជាលោកិយៈ មាន ចុះសទ្ធិន្ទ្រិយ ជាលោកិយៈ
មិនមានទេឬ ។ អើ ។ មនៈ ជាលោកិយៈ មាន ចុះមនិន្ទ្រិយ ជា
លោកិយៈ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។
បញ្ញា ជាលោកិយៈ មាន ចុះបញ្ញិន្ទ្រិយ ជាលោកិយៈ មិនមានទេឬ ។
អើ ។ មនៈ ជាលោកិយៈ មាន ចុះមនិន្ទ្រិយ ជាលោកិយៈ មិនមាន
ទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សទ្ធា ជាលោកិយៈ
មាន ចុះសទ្ធិន្ទ្រិយ ជាលោកិយ មិនមានទេឬ ។ អើ ។ សោម-
នស្ស ជាលោកិយៈ មាន ចុះសោមនស្សិន្ទ្រិយ ជាលោកិយៈ មិនមាន
។ បេ ។ ជីវិត ជាលោកិយៈ មាន ចុះជីវិតិន្ទ្រិយ ជាលោកិយៈ មិន
មានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បញ្ញា ជាលោ-
កិយៈ មាន ចុះបញ្ញិន្ទ្រិយ ជាលោកិយៈ មិនមានទេឬ ។ អើ ។ ជីវិត
ជាលោកិយៈ មាន ចុះជីវិតិន្ទ្រិយ ជាលោកិយៈ មិនមានទេឬ ។ អ្នក
មិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៧៥) អត្ថិ លោកុត្តរា សទ្ធា អត្ថិ លោកុត្តរំ សទ្ធិន្ទ្រិយន្តិ ។ អាមន្តា ។ អត្ថិ លោកិយា សទ្ធា អត្ថិ លោកិយំ សទ្ធិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ លោកុត្តរំ វីរិយំ ។ បេ ។ អត្ថិ លោកុត្តរា បញ្ញា អត្ថិ លោកុត្តរំ បញ្ញិន្ទ្រិយន្តិ ។ អាមន្តា ។ អត្ថិ លោកិយា បញ្ញា អត្ថិ លោកិយំ បញ្ញិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៧៦) អត្ថិ លោកិយា សទ្ធា នត្ថិ លោកិយំ សទ្ធិន្ទ្រិយន្តិ ។ អាមន្តា ។ អត្ថិ លោកុត្តរា សទ្ធា នត្ថិ លោកុត្តរំ សទ្ធិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ លោកិយំ វីរិយំ ។ បេ ។ អត្ថិ លោកិយា បញ្ញា នត្ថិ លោកិយំ បញ្ញិន្ទ្រិយន្តិ ។ អាមន្តា ។ អត្ថិ លោកុត្តរា បញ្ញា នត្ថិ លោកុត្តរំ បញ្ញិន្ទ្រិយន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៧៥) សទ្ធា ជាលោកុត្តរៈ មាន ចុះសទ្ធិន្ទ្រិយ ជាលោកុត្តរៈ មានដែរឬ ។ អើ ។ សទ្ធា ជាលោកិយៈ មាន ចុះសទ្ធិន្ទ្រិយ ជាលោកិយៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វីរិយៈ ជាលោកុត្តរៈ មាន ។ បេ ។ បញ្ញា ជាលោកុត្តរៈ មាន ចុះបញ្ញិន្ទ្រិយ ជាលោកុត្តរៈ មានដែរឬ ។ អើ ។ បញ្ញា ជាលោកិយៈ មាន ចុះបញ្ញិន្ទ្រិយ ជាលោកិយៈ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៧៦) សទ្ធា ជាលោកិយៈ មាន ចុះសទ្ធិន្ទ្រិយ ជាលោកិយៈ មិនមានទេឬ ។ អើ ។ សទ្ធា ជាលោកុត្តរៈ មាន ចុះសទ្ធិន្ទ្រិយ ជាលោកុត្តរៈ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ វីរិយៈ ជាលោកិយៈ មាន ។ បេ ។ បញ្ញា ជាលោកិយៈ មាន ចុះបញ្ញិន្ទ្រិយ ជាលោកិយៈ មិនមានទេឬ ។ អើ ។ បញ្ញា ជាលោកុត្តរៈ មាន ចុះបញ្ញិន្ទ្រិយ ជាលោកុត្តរៈ មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៧៧) នត្ថិ លោកិយានិ បញ្ចិន្ទ្រិយានីតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា អទ្ទសំ ខោ អហំ ភិក្ខវេ ពុទ្ធចក្ខុនា លោកំ វោលោកេន្តោ សត្តេ អប្បរជក្ខេ មហារជក្ខេ តិក្ខិន្ទ្រិយេ មុទិន្ទ្រិយេ ស្វាការេ ទ្វាការេ សុវិញ្ញាបយេ ទុវិញ្ញាបយេ អប្បេកច្ចេ បរលោកវជ្ជភយទស្សាវិនោ វិហរន្តេតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ អត្ថិ លោកិយានិ បញ្ចិន្ទ្រិយានីតិ ។

ឥន្ទ្រិយកថា ។

ឯកូនវីសតិមោ វគ្គោ ។

តស្សុទ្ទានំ

អតីតេ កិលេសេ ជហតិ អនាគតេ កិលេសេ ជហតិ បច្ចុប្បន្នេ កិលេសេ ជហតិ សុញ្ញតា សង្ខារក្ខន្ធបរិយាបន្នា សាមញ្ញផលំ អសង្ខតំ បត្តិ អសង្ខតា សព្វធម្មានំ តថតា អសង្ខតា និព្វានធាតុ កុសលា អត្ថិ បុថុជ្ជនស្ស អច្ចន្តនិយាមតា នត្ថិ លោកិយានិ បញ្ចិន្ទ្រិយានីតិ ។

(៣៧៧) បញ្ចិន្ទ្រិយ ជាលោកិយៈ មិនមានទេឬ ។ អើ ។ ត្រូវព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគត កាលប្រមើលមើលនូវសត្វលោក ដោយពុទ្ធចក្ខុ បានឃើញពួកសត្វមានធូលីតិចក្នុងភ្នែក មានធូលីច្រើនក្នុងភ្នែក មានឥន្ទ្រិយដ៏ក្លៀវក្លា មានឥន្ទ្រិយខ្ទន់ មានអាការល្អ មានអាការអាក្រក់ ដែលឲ្យដឹងបានដោយងាយ ដែលឲ្យដឹងបានដោយក្រ ពួកខ្លះ ឃើញទោសនិងភ័យក្នុងបរលោក ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ បញ្ចិន្ទ្រិយ ជាលោកិយៈ មានដែរ ។

ចប់ ឥន្ទ្រិយកថា ។

ចប់ ឯកូនវីសតិមវគ្គ ។

ឧទ្ទាននៃឯកូនវីសតិមវគ្គនោះ គឺ

និយាយ អំពីបុគ្គល លះបង់ពួកកិលេសជាអតីត លះបង់ពួកកិលេសជាអនាគត លះបង់ពួកកិលេសជាបច្ចុប្បន្ន ១ សេចក្ដីសូន្យ រាប់បញ្ចូលក្នុងសង្ខារក្ខន្ធ ១ សាមញ្ញផល ជាអសង្ខតៈ ១ ការបាន ជាអសង្ខតៈ ១ សេចក្ដីទៀងទាត់នៃធម៌ទាំងពួង ជាអសង្ខតៈ ១ និព្វានធាតុ ជាកុសល ១ សេចក្ដីទៀងទាត់តែម៉្យាង របស់បុថុជ្ជន មាន ១ បញ្ចិន្ទ្រិយ ជាលោកិយៈ មិនមាន ១ ។

អសញ្ចិច្ចកថា

(៣៧៨) អសញ្ចិច្ច មាតរំ ជីវិតា វោរោបេត្វា អានន្តរិកោ ហោតីតិ ។ អាមន្តា ។ អសញ្ចិច្ច បាណំ ហន្ត្វា បាណាតិបាតី ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អសញ្ចិច្ច មាតរំ ជីវិតា វោរោបេត្វា អានន្តរិកោ ហោតីតិ ។ អាមន្តា ។ អសញ្ចិច្ច អទិន្នំ អាទិយិត្វា ។ បេ ។ មុសា ភណិត្វា មុសាវាទី ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៧៩) អសញ្ចិច្ច បាណំ ហន្ត្វា បាណាតិបាតី ន ហោតីតិ ។ អាមន្តា ។ អសញ្ចិច្ច មាតរំ ជីវិតា វោរោបេត្វា អានន្តរិកោ ន ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អសញ្ចិច្ច អទិន្នំ អាទិយិត្វា ។ បេ ។ មុសា ភណិត្វា មុសាវាទី ន ហោតីតិ ។ អាមន្តា ។ អសញ្ចិច្ច មាតរំ ជីវិតា វោរោបេត្វា អានន្តរិកោ ន ហោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

អសញ្ចិច្ចកថា

(៣៧៨) បុគ្គល មិនត្រូវផ្តាច់បង់ជីវិតមាតា ឈ្មោះថាដល់អនន្តរិយកម្មឬ ។ ពើ ។ បុគ្គល មិនត្រូវសម្លាប់សត្វមានជីវិត ឈ្មោះថាជាអ្នកញុំាងសត្វមានជីវិតឲ្យធ្លាក់ចុះក្នុងវដ្តឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល មិនត្រូវផ្តាច់បង់ជីវិតមាតា ឈ្មោះថាដល់អនន្តរិយកម្មឬ ។ ពើ ។ បុគ្គល មិនត្រូវកាន់យកទ្រព្យដែលគេមិនបានឲ្យ ។ បេ ។ ពោលពាក្យកុហក ឈ្មោះថាជាអ្នកពោលពាក្យកុហកដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៧៩) បុគ្គល មិនត្រូវសម្លាប់សត្វមានជីវិត មិនបានឈ្មោះថាជាអ្នកញុំាងសត្វមានជីវិតឲ្យធ្លាក់ចុះក្នុងវដ្តទេឬ ។ ពើ ។ បុគ្គល មិនត្រូវផ្តាច់បង់ជីវិតមាតា មិនបានឈ្មោះថាដល់អនន្តរិយកម្មទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល មិនត្រូវកាន់យកទ្រព្យដែលគេមិនបានឲ្យ ។ បេ ។ ពោលពាក្យកុហក មិនបានឈ្មោះថាជាអ្នកពោលពាក្យកុហកទេឬ ។ ពើ ។ បុគ្គល មិនត្រូវផ្តាច់បង់ជីវិតមាតា មិនបានឈ្មោះថាដល់អនន្តរិយកម្មទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៨០) អសញ្ចិច្ច មាតរំ ជីវិតា វោរោបេត្វា អានន្តរិកោ ហោតីតិ ។ អាមន្តា ។ អសញ្ចិច្ច មាតរំ ជីវិតា វោរោបេត្វា អានន្តរិកោ ហោតីតិ អត្ថិ សុត្តន្តោតិ ។ នត្ថិ ។ សញ្ចិច្ច មាតរំ ជីវិតា វោរោបេត្វា អានន្តរិកោ ហោតីតិ អត្ថិ សុត្តន្តោតិ ។ អាមន្តា ។ ហញ្ចិ សញ្ចិច្ច មាតរំ ជីវិតា វោរោបេត្វា អានន្តរិកោ ហោតីតិ អត្ថិ សុត្តន្តោ នោ វត រេ វត្តព្វេ អសញ្ចិច្ច មាតរំ ជីវិតា វោរោបេត្វា អានន្តរិកោ ហោតីតិ ។

(៣៨១) ន វត្តព្វំ មាតុឃាតកោ អានន្តរិកោតិ ។ អាមន្តា ។ ននុ មាតា ជីវិតា វោរោបិតាតិ ។ អាមន្តា ។ ហញ្ចិ មាតា ជីវិតា វោរោបិតា តេន វត រេ វត្តព្វេ មាតុឃាតកោ អានន្តរិកោតិ ។ ន វត្តព្វំ បិតុឃាតកោ អានន្តរិកោតិ ។ អាមន្តា ។ ននុ បិតា ជីវិតា វោរោបិតោតិ ។ អាមន្តា ។ ហញ្ចិ បិតា ជីវិតា វោរោបិតោ តេន វត រេ វត្តព្វេ បិតុឃាតកោ អានន្តរិកោតិ ។ ន វត្តព្វំ អរហន្តឃាតកោ

(៣៨០) បុគ្គល មិនក្លែងផ្តាច់បង់ជីវិតមាតា ឈ្មោះថាដល់អនន្តរិយកម្មឬ ។ អើ ។ បុគ្គល មិនក្លែងផ្តាច់បង់ជីវិតមាតា ឈ្មោះថាដល់អនន្តរិយកម្ម ពាក្យដូច្នេះ មានក្នុងព្រះសូត្រដែរឬ ។ មិនមានទេ ។ បុគ្គល ក្លែងផ្តាច់បង់ជីវិតមាតា ឈ្មោះថាដល់អនន្តរិយកម្ម ពាក្យដូច្នេះ មានក្នុងព្រះសូត្រដែរឬ ។ អើ ។ ប្រសិនបើ បុគ្គល ក្លែងផ្តាច់បង់ជីវិតមាតា ឈ្មោះថាដល់អនន្តរិយកម្ម ពាក្យដូច្នេះ មានក្នុងព្រះសូត្រដែរ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា បុគ្គល មិនក្លែងផ្តាច់បង់ជីវិតមាតា ឈ្មោះថាដល់អនន្តរិយកម្មទេ ។

(៣៨១) បុគ្គលមិនគួរនិយាយថា បុគ្គល សម្លាប់មាតា ដល់អនន្តរិយកម្មទេឬ ។ អើ ។ ក្រែងមាតា បុគ្គលនោះផ្តាច់បង់ជីវិតហើយឬ ។ អើ ។ ប្រសិនបើ មាតា បុគ្គលនោះផ្តាច់បង់ជីវិតហើយ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គលសម្លាប់មាតា ដល់អនន្តរិយកម្ម ។ បុគ្គលមិនគួរនិយាយថា បុគ្គល សម្លាប់បិតា ដល់អនន្តរិយកម្មទេឬ ។ អើ ។ ក្រែងបិតា បុគ្គលនោះផ្តាច់បង់ជីវិតហើយឬ ។ អើ ។ ប្រសិនបើ បិតា បុគ្គលនោះផ្តាច់បង់ជីវិតហើយ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គលសម្លាប់បិតា ដល់អនន្តរិយកម្ម ។ បុគ្គលមិនគួរនិយាយថា បុគ្គល សម្លាប់ព្រះអរហន្ត

អានន្តរិកោតិ ។ អាមន្តា ។ ននុ អរហា ជីវិតា វោរោ-
បិតោតិ ។ អាមន្តា ។ ហញ្ចិ អរហា ជីវិតា វោរោបិតោ
តេន វត រេ វត្តព្វេ អរហន្តឃាតកោ អានន្តរិកោ-
តិ ។ ន វត្តព្វំ រុហិរុប្បាទកោ អានន្តរិកោតិ ។
អាមន្តា ។ ននុ តថាគតស្ស លោហិតំ ឧប្បាទិ-
តន្តិ ។ អាមន្តា ។ ហញ្ចិ តថាគតស្ស លោហិតំ
ឧប្បាទិតំ តេន វត រេ វត្តព្វេ រុហិរុប្បាទកោ អា-
នន្តរិកោតិ ។ សង្ឃភេទកោ អានន្តរិកោតិ ។
អាមន្តា ។ សព្វេ សង្ឃភេទកា អានន្តរិកាតិ ។
ន ហេវំ វត្តព្វេ ។ បេ ។ សព្វេ សង្ឃភេទកា អា-
នន្តរិកាតិ ។ អាមន្តា ។ ធម្មសញ្ញី សង្ឃភេទកោ
អានន្តរិកោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ធម្មសញ្ញី
សង្ឃភេទកោ អានន្តរិកោតិ ។ អាមន្តា ។ ននុ
វុត្តំ ភគវតា អត្ថុបាលិ សង្ឃភេទកោ អាបាយិ-
កោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ អត្ថុបាលិ
សង្ឃភេទកោ ន អាបាយិកោ ន នេរយិកោ

ដល់អនន្តរិយកម្មទេឬ ។ អើ ។ ក្រែងព្រះអរហន្ត បុគ្គលនោះផ្តាច់បង់
ជីវិតហើយឬ ។ អើ ។ ប្រសិនបើ ព្រះអរហន្ត បុគ្គលនោះផ្តាច់បង់ជីវិត
ហើយ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា បុគ្គល
សម្លាប់ព្រះអរហន្ត ដល់អនន្តរិយកម្ម ។ បុគ្គលមិនគួរនិយាយថា
បុគ្គលញុំាងព្រះលោហិតឲ្យពុះពារឡើង ដល់អនន្តរិយកម្មទេឬ ។ អើ ។
ក្រែងព្រះលោហិត របស់ព្រះតថាគត បុគ្គលនោះឲ្យពុះពារឡើងហើយ
ឬ ។ អើ ។ ប្រសិនបើ ព្រះលោហិត របស់ព្រះតថាគត បុគ្គលនោះឲ្យ
ពុះពារឡើងហើយ ម្នាលអ្នកដ៏ចម្រើន ព្រោះហេតុនោះ អ្នកគួរពោលថា
បុគ្គលញុំាងព្រះលោហិតឲ្យពុះពារឡើង ដល់អនន្តរិយកម្ម ។ បុគ្គល
បំបែកសង្ឃ ដល់អនន្តរិយកម្មឬ ។ អើ ។ បុគ្គលទាំងអស់បំបែកសង្ឃ
ដល់អនន្តរិយកម្មឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល
ទាំងអស់បំបែកសង្ឃ ដល់អនន្តរិយកម្មឬ ។ អើ ។ បុគ្គលមានសេចក្តី
សំគាល់ក្នុងធម៌ បំបែកសង្ឃ ដល់អនន្តរិយកម្មឬ ។ អ្នកមិនគួរពោល
យ៉ាងនេះទេ ។ បេ ។ បុគ្គលមានសេចក្តីសំគាល់ក្នុងធម៌ បំបែកសង្ឃ
ទើបដល់អនន្តរិយកម្មឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ត្រាស់ថា
ម្នាលឧបាលិ បុគ្គលជាអ្នកបំបែកសង្ឃ ទៅកើត ក្នុងអបាយ ទៅ
កើត ក្នុងនរក តាំងនៅអស់កប្ប កែមិនបាន ក៏មាន ម្នាលឧបាលិ
បុគ្គល ជាអ្នកបំបែកសង្ឃ មិនទៅកើតក្នុងអបាយ មិនទៅកើតក្នុងនរក

ន កប្បដ្ឋោ ន អតេកិច្ឆោតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ ន វត្តព្វំ ធម្មសញ្ញី សង្ឃភេទកោ អានន្តរិកោតិ ។

(៣៨២) ន វត្តព្វំ ធម្មសញ្ញី សង្ឃភេទកោ អានន្តរិកោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

អាបាយិកោ នេរយិកោ កប្បដ្ឋោ សង្ឃភេទកោ
វគ្គរតោ អធម្មដ្ឋោ យោគក្ខេមា បធំសតិ
សង្ឃំ សមគ្គំ ភេត្វាន កប្បំ និរយម្ហិ បច្ចតីតិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ សង្ឃភេទកោ អានន្តរិកោតិ ។

អសញ្ញិកថា ។

ញាណកថា

(៣៨៣) នត្ថិ បុថុជ្ជនស្ស ញាណន្តិ ។ អាមន្តា ។ នត្ថិ បុថុជ្ជនស្ស បញ្ញា បជាននា វិចយោ បវិចយោ ធម្មវិចយោ សល្លក្ខណា ឧបលក្ខណា បច្ចុបលក្ខណាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

មិនតាំងនៅអស់កប្ប មិនមែនថាកែមិនបាន ក៏មាន ពាក្យដូច្នេះ ក្នុងព្រះសូត្រមែន ។ អើ ។ ព្រោះហេតុនោះ អ្នកមិនគួរពោលថា បុគ្គលមានសេចក្តីសំគាល់ក្នុងធម៌ បំបែកសង្ឃ ដល់អនន្តរិយកម្មទេ ។

(៣៨២) បុគ្គលមិនគួរនិយាយថា បុគ្គលមានសេចក្តីសំគាល់ក្នុងធម៌ បំបែកសង្ឃ ដល់អនន្តរិយកម្មទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

បុគ្គលអ្នកបំបែកសង្ឃ ត្រេកអរក្នុងពួក មិនតាំងនៅក្នុងធម៌
ទៅកើតក្នុងអបាយ ទៅកើតក្នុងនរក តាំងនៅអស់កប្ប
ឃ្លាតចាកធម៌ក្សេមចាកយោគៈ (បុគ្គលនោះ) លុះបំបែក
សង្ឃដែលព្រមព្រៀងគ្នា រមែងទៅឆេះក្នុងនរកអស់កប្ប

ពាក្យដូច្នេះ មានក្នុងព្រះសូត្រមែន ។ អើ ។ ព្រោះហេតុនោះ បុគ្គលបំបែកសង្ឃ ដល់អនន្តរិយកម្ម ។

ចប់ អសញ្ញិកថា ។

ញាណកថា

(៣៨៣) ញាណ របស់បុថុជ្ជន មិនមានទេឬ ។ អើ ។ ការដឹង ការដឹងច្បាស់ ការពិចារណា ការពិចារណាសព្វ ការពិចារណាធម៌ ការកំណត់ព្រម ការចូលទៅដឹងកំណត់ ការចូលទៅដឹងកំណត់ចំពោះ របស់បុថុជ្ជន មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ននុ អត្ថិ បុថុជ្ជនស្ស បញ្ញា បជាននា វិចយោ
។ បេ ។ បច្ចុបលក្ខណាតិ ។ អាមន្តា ។ ហញ្ចិ
អត្ថិ បុថុជ្ជនស្ស បញ្ញា បជាននា វិចយោ ។ បេ ។
បច្ចុបលក្ខណា នោ ច វត រេ វត្តព្វេ នត្ថិ បុថុជ្ជនស្ស
ញាណន្តិ ។

(៣៨៥) នត្ថិ បុថុជ្ជនស្ស ញាណន្តិ ។ អា-
មន្តា ។ បុថុជ្ជនោ បឋមំ ឈានំ សមាបជ្ជេយ្យាតិ ។
អាមន្តា ។ ហញ្ចិ បុថុជ្ជនោ បឋមំ ឈានំ សមា-
បជ្ជេយ្យ នោ ច វត រេ វត្តព្វេ នត្ថិ បុថុជ្ជនស្ស
ញាណន្តិ ។

(៣៨៦) បុថុជ្ជនោ ទុតិយំ ឈានំ ។ បេ ។ តតិ-
យំ ឈានំ ... ចតុត្ថំ ឈានំ ។ បេ ។ អាកាសា-
នញ្ចាយតនំ សមាបជ្ជេយ្យ វិញ្ញាណញ្ចាយតនំ ... អា-
កិញ្ចញ្ញាយតនំ ... នេវសញ្ញានាសញ្ញាយតនំ សមា-
បជ្ជេយ្យ បុថុជ្ជនោ ទានំ ទទេយ្យ ។ បេ ។ ចីវរំ
ទទេយ្យ ។ បេ ។ បិណ្ឌបាតំ ទទេយ្យ សេនា-
សនំ ទទេយ្យ ។ បេ ។ គិលានបច្ចយភេសជ្ជប-
រិក្ខារំ ទទេយ្យាតិ ។ អាមន្តា ។ ហញ្ចិ បុថុជ្ជនោ

ក្រែងការដឹង ការដឹងច្បាស់ ការពិចារណា ។ បេ ។ ការចូលទៅ
ជិតកំណត់ចំពោះ របស់បុថុជ្ជន មានដែរឬ ។ អើ ។ ប្រសិនបើ ការដឹង
ការដឹងច្បាស់ ការពិចារណា ។ បេ ។ ការចូលទៅជិតកំណត់ចំពោះ
របស់បុថុជ្ជន មាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ញាណ
របស់បុថុជ្ជន មិនមានទេ ។

(៣៨៥) ញាណ របស់បុថុជ្ជន មិនមានទេឬ ។ អើ ។
បុថុជ្ជន គប្បីចូលកាន់បឋមជ្ឈាន បានដែរឬ ។ អើ ។ ប្រសិនបើ
បុថុជ្ជន គប្បីចូលកាន់បឋមជ្ឈាន បាន ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរ
ពោលថា ញាណ របស់បុថុជ្ជន មិនមានទេ ។

(៣៨៦) បុថុជ្ជន គប្បីចូលកាន់ទុតិយជ្ឈាន ។ បេ ។ កាន់
តតិយជ្ឈាន ... កាន់ចតុត្ថជ្ឈាន ។ បេ ។ កាន់អាកាសានញ្ចា-
យតនៈ គប្បីចូលកាន់វិញ្ញាណញ្ចាយតនៈ ... កាន់អាកិញ្ចញ្ញា-
យតនៈ ... កាន់នេវសញ្ញានាសញ្ញាយតនៈ បុថុជ្ជន គប្បីឲ្យទាន
។ បេ ។ ឲ្យចីវរ ។ បេ ។ ឲ្យបិណ្ឌបាត ឲ្យសេនាសនៈ ។ បេ ។
ឲ្យគិលានប្បច្ច័យភេសជ្ជបរិក្ខារដែរឬ ។ អើ ។ ប្រសិនបើ បុថុជ្ជន

កិលេសបច្ចយកេសម្ពារិក្ខារំ នាមេយ្យ ពោ វត ។ វត្តព្វេ នត្ថិ បុថុជ្ជនស្ស ញាណន្តិ ។

(៣៨៦) អត្ថិ បុថុជ្ជនស្ស ញាណន្តិ ។ អាមន្តា ។ បុថុជ្ជនោ តេន ញាណេន ទុក្ខំ បរិជានាតិ សមុទយំ បជហតិ និរោធំ សច្ឆិករោតិ មគ្គំ ភាវេតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

ញាណកថា ។

និរយបាលកថា

(៣៨៧) នត្ថិ និរយេសុ និរយបាលាតិ ។ អាមន្តា ។ នត្ថិ និរយេសុ កម្មការណាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ និរយេសុ កម្មការណាតិ ។ អាមន្តា ។ អត្ថិ និរយេសុ និរយបាលាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

គប្បីឲ្យគិលានប្បច្ច័យកេសដូចរៀបរាប់ ព្រោះហេតុនោះ អ្នកមិនគួរពោលថា ញាណ របស់បុថុជ្ជន មិនមានទេ ។

(៣៨៦) ញាណ របស់បុថុជ្ជន មានដែរឬ ។ អើ ។ បុថុជ្ជន កំណត់ដឹងទុក្ខ លះបង់សមុទយៈ ធ្វើឲ្យជាក់ច្បាស់និរោធ ចម្រើនមគ្គ ដោយញាណនោះឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ ញាណកថា ។

និរយបាលកថា

(៣៨៧) ពួកនិរយបាល ក្នុងនរក[១] មិនមានទេឬ ។ អើ ។ ហេតុនៃកម្ម ក្នុងនរក មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ហេតុនៃកម្ម ក្នុងនរក មានដែរឬ ។ អើ ។ ពួកនិរយបាល ក្នុងនរក មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

---

១ លទ្ធិរបស់មនុស្សខ្លះយល់ថា កម្មរបស់ខ្លួនឯងបៀតបៀនសត្វ ដែលកើតក្នុងនរក ដោយសភាពជាតាយនិរយបាល, ឯពួកសត្វដែលឈ្មោះថា តាយនិរយបាលនោះ មិនមានឡើយ, សកវាទីសួរដូច្នេះ អាស្រ័យកាន់សេចក្តីថា និរយបាលប្រាកដជាមានក្នុងឋាននរក (អដ្ឋកថា) ។

(៣៨៨) អត្ថិ មនុស្សេសុ កម្មការណា អត្ថិ ច ការណិកាតិ ។ អាមន្តា ។ អត្ថិ និរយេសុ កម្មការណា អត្ថិ ច ការណិកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ និរយេសុ កម្មការណា នត្ថិ ច ការណិកាតិ ។ អាមន្តា ។ អត្ថិ មនុស្សេសុ កម្មការណា នត្ថិ ច ការណិកាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៨៩) អត្ថិ និរយេសុ និរយបាលាតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

ន វេស្សភូ នោបិ ច បេត្តិរាជា
សោមោ យមោ វេស្សវណោ ច រាជា
សកានិ កម្មានិ ហនន្តិ តត្ថ
ឥតោ បណុន្នំ បរលោកបត្តន្តិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេនហិ នត្ថិ និរយេសុ និរយបាលាតិ ។

(៣៩០) នត្ថិ និរយេសុ និរយបាលាតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា តមេនំ ភិក្ខវេ និរយបាលា

(៣៨៨) ហេតុនៃកម្ម ក្នុងពួកមនុស្ស មាន ចុះពួកអ្នកធ្វើកម្ម (ធ្វើទោស) មានដែរឬ ។ អើ ។ ហេតុនៃកម្ម ក្នុងពួកនរក មាន ចុះពួកនិរយបាល មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ហេតុនៃកម្ម ក្នុងពួកនរក មាន ចុះពួកនិរយបាល មិនមានទេឬ ។ អើ ។ ហេតុនៃកម្ម ក្នុងពួកមនុស្ស មាន ចុះពួកនិរយបាល មិនមានទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៨៩) ពួកនិរយបាល ក្នុងស្ថាននរក មានដែរឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

ស្តេចវេស្សភូ មិនបៀតបៀន ស្តេចប្រេត ស្តេចសោមៈ
ស្តេចយមៈ ស្តេចវេស្សវ័ណ ក៏មិនបៀតបៀនដែរ មាន
តែកម្មរបស់ខ្លួន រមែងបៀតបៀនសត្វដែលច្យុតចាកលោក
នេះ ទៅកាន់បរលោក ក្នុងនរកនោះ

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ពួកនិរយបាល ក្នុងនរក មិនមានទេ ។

(៣៩០) ពួកនិរយបាល ក្នុងនរក មិនមានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល

បញ្ចវិធំ ពន្ធនំ នាម ការណំ ការេន្តិ តត្តំ អយោខិលំ ហត្ថេ គមេន្តិ តត្តំ អយោខិលំ ទុតិយេ ហត្ថេ គមេន្តិ តត្តំ អយោខិលំ បាទេ គមេន្តិ តត្តំ អយោខិលំ ទុតិយេ បាទេ គមេន្តិ តត្តំ អយោខិលំ មជ្ឈេ ឧរស្មឹ គមេន្តិ សោ តត្ថ ទុក្ខា តិព្វា ខរា កដុកា វេទនា វេទេតិ ន ច តាវ កាលំ ករោតិ យាវ ន តំ បាបកម្មំ ព្យន្តីហោតីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ អត្ថិ និរយេសុ និរយបាលាតិ ។

(៣៩១) នត្ថិ និរយេសុ និរយបាលាតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា តមេនំ ភិក្ខវេ និរយបាលា សំវេសេត្វា កុឋារីហិ តច្ឆន្តិ ។ បេ ។ តមេនំ ភិក្ខវេ និរយបាលា ឧទ្ធំបាទំ អធោសិរំ ឋបេត្វា វាសីហិ តច្ឆន្តិ ។ បេ ។ តមេនំ ភិក្ខវេ និរយបាលា រថេ យោជេត្វា អាទិត្តាយ បឋវិយា សម្បជ្ជលិតាយ សជោតិភូតាយ សារេន្តិបិ បច្ចាសារេន្តិបិ ។ បេ ។

ឲ្យធ្វើនូវហេតុ ឈ្មោះចំណង៥យ៉ាង ចំពោះបុគ្គលនោះ គឺយកដែកគោលក្តៅ មកបោះត្រង់ដៃ ១ យកដែកគោលក្តៅ មកបោះត្រង់ដៃទីពីរ ១ យកដែកគោលក្តៅ មកបោះត្រង់ជើង ១ យកដែកគោលក្តៅ មកបោះត្រង់ជើងទីពីរ ១ យកដែកគោលក្តៅ មកបោះត្រង់កណ្តាលដើមទ្រូង ១ បុគ្គលនោះ សោយវេទនា ជាទុក្ខ ក្លៀវក្លា រឹងរូស ក្នុងនរកនោះ បាបកម្មនោះ មិនទាន់អស់ទៅ ដរាបណា ក៏មិនធ្វើមរណកាល ដរាបនោះ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ពួកនិរយបាល ក្នុងនរក មាន ។

(៣៩១) ពួកនិរយបាល ក្នុងនរក មិនមានទេឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាលផ្តួលបុគ្គលនោះ ហើយចាំងដោយដឹងទាំងឡាយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ដាក់បុគ្គលនោះ ឲ្យមានជើងឡើងលើមានក្បាលចុះក្រោម ហើយច្រាសដោយកាំបិតទាំងឡាយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ទឹមបុគ្គលនោះក្នុងរថ បរទៅផង បរត្រឡប់មកវិញផង លើផែនដីដែលភ្លើងឆេះឆ្នោលច្រាលឆ្អៅ ។ បេ ។

តមេនំ ភិក្ខវេ និរយបាលា មហន្តំ អង្គារបព្វតំ អាទិត្តំ សម្បជ្ជលិតំ សជោតិភូតំ អារោបេន្តិបិ ឱរោបេន្តិបិ ។ បេ ។ តមេនំ ភិក្ខវេ និរយបាលា ឧទ្ធំបាទំ អធោសិរំ គហេត្វា តត្តាយ លោហកុម្ភិយា បក្ខិបន្តិ អាទិត្តាយ សម្បជ្ជលិតាយ សជោតិភូតាយ សោ តត្ថ ផេណុទ្ទេហកំ បច្ចតិ សោ តត្ថ ផេណុទ្ទេហកំ បច្ចមានោ សកិម្បិ ឧទ្ធំ គច្ឆតិ សកិម្បិ អធោ គច្ឆតិ សកិម្បិ តិរិយំ គច្ឆតិ សោ តត្ថ ទុក្ខា ។ បេ ។ តមេនំ ភិក្ខវេ និរយបាលា មហានិរយេ បក្ខិបន្តិ សោ ខោ បន ភិក្ខវេ មហានិរយោ

ចតុក្កណ្ណោ ចតុទ្វារោ វិភត្តោ ភាគសោ មិតោ
អយោបាការបរិយន្តោ អយសា បដិកុជ្ជិតោ
តស្ស អយោមយា ភូមិ ជលិតា តេជសា យុតា
សមន្តា យោជនសតំ ផរិត្វា តិដ្ឋតិ សព្វទាតិ

អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ អត្ថិ និរយេសុ និរយបាលាតិ ។

ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល [illegible] ឲ្យឡើងផង ឲ្យចុះផង កាន់ភ្នំរងើកភ្លើងដ៏ធំ ដែលភ្លើងឆេះរោលរាល ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ចាប់បុគ្គលនោះ ឲ្យមានជើងឡើងលើ ក្បាលចុះក្រោម ហើយបោះទៅក្នុងខ្ទះ ដ៏ពេញដោយទឹកខាប់ដែលក្តៅ ដែលភ្លើងឆេះរោលព្រាលឆ្អៅ បុគ្គលនោះ រមែងឆេះ នៅមានពពុះព្រាត ។ ក្នុងខ្ទះនោះ បុគ្គលនោះ កាលឆេះ នៅមានពពុះព្រាត ។ ក្នុងខ្ទះនោះ ទៅខាងលើម្តង ទៅខាងក្រោមម្តង ទៅទទឹងម្តង បុគ្គលនោះ ដល់នូវសេចក្តីទុក្ខ ក្នុងខ្ទះនោះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល បោះបុគ្គលនោះ ទៅក្នុងមហានរក ម្នាលភិក្ខុទាំងឡាយ មហានរកនោះឯង

មានជ្រុង ៤ មានទ្វារ ៤ ដែលឆ្មូតាចែក កំរាងដោយចំណែក
មានកំពែងដែកព័ទ្ធជុំវិញ គ្របដោយគម្របដែក ភូមិរបស់
មហានរក នោះជាវិការនៃដែក ដែលរុងរឿង ប្រកបដោយ
កំដៅ ផ្សាយទៅអស់ទីមួយរយយោជន៍ដោយជុំវិញ ហើយ
ឋិតនៅសព្វកាល

ពាក្យដូច្នេះ មានក្នុងព្រះសូត្រមែនឬ ។ អើ ។ ព្រោះហេតុនោះ ពួកនិរយ-បាល ក៏មានក្នុងនរក មាន ។

តិរច្ឆានកថា

(៣៩២) អត្ថិ ទេវេសុ តិរច្ឆានគតាតិ ។ អាមន្តា ។ អត្ថិ តិរច្ឆានគតេសុ ទេវាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ ទេវេសុ តិរច្ឆានគតាតិ ។ អាមន្តា ។ ទេវលោកោ តិរច្ឆានយោនីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ ទេវេសុ តិរច្ឆានគតាតិ ។ អាមន្តា ។ អត្ថិ តត្ថ កីដា បដង្គា មកសា មក្ខិកា អហី វិច្ឆិកា សតបទី គណ្ឌុប្បាទាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៩៣) ន វត្តព្វំ អត្ថិ ទេវេសុ តិរច្ឆានគតាតិ ។ អាមន្តា ។ ននុ អត្ថិ តត្ថ ឯរាវណោ នាម ហត្ថិនាគោ សហស្សយុត្តំ ទិព្វំ យានន្តិ ។ អាមន្តា ។ ហញ្ចិ អត្ថិ តត្ថ ឯរាវណោ នាម ហត្ថិនាគោ សហស្សយុត្តំ ទិព្វំ យានំ តេន វត រេ វត្តព្វេ អត្ថិ ទេវេសុ តិរច្ឆានគតាតិ ។

តិរច្ឆានកថា

(៣៩២) ពួកសត្វតិរច្ឆាន[១]កើតក្នុងទេវលោក មានដែរឬ ។ អើ ។ ពួកទេវតា កើតជាសត្វតិរច្ឆាន មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពួកសត្វតិរច្ឆាន កើតក្នុងទេវលោក មានដែរឬ ។ អើ ។ ទេវលោក មានកំណើតជាតិរច្ឆានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ពួកសត្វតិរច្ឆាន កើតក្នុងទេវលោក មានដែរឬ ។ អើ ។ ពួកក្រឡាត កន្ធាយ មូស រុយ ពស់ ខ្យាដំរី ក្អែប ជន្លេន កើតក្នុងទេវលោកនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៩៣) ពួកសត្វតិរច្ឆាន កើតក្នុងទេវលោក មិនមានទេឬ ។ អើ ។ ដំរីប្រសើរ ឈ្មោះឯរាវណ៍ ជាយានជាទិព្វ ដែលទឹមដោយសេះមួយពាន់ កើតក្នុងទេវលោកនោះ មានឬ ។ អើ ។ ប្រសិនបើ ដំរីប្រសើរ ឈ្មោះឯរាវណ៍ ជាយានជាទិព្វ ដែលទឹមដោយសេះមួយពាន់ កើតក្នុងទេវលោកនោះ មាន ព្រោះហេតុនោះ អ្នកគួរពោលថា ពួកសត្វតិរច្ឆាន កើតក្នុងទេវលោក មាន ។

---

១ តាមពិតក្នុងឋានទេវលោក មានតែពួកទេវបុត្រឈ្មោះឯរាវណៈជាដើម សំដែងខ្លួនជាដំរី សេះ ពួកសត្វតិរច្ឆានពិតៗ នោះមិនមានឡើយ ប៉ុន្តែលទ្ធិរបស់អ្នកល្ងង់ខ្លៅកាន់ប្រកាន់ ដោយបានឃើញពួកទេវបុត្ត មានភេទជាសត្វតិរច្ឆាន ទើបប្រកាន់ថា តិរច្ឆានក្នុងឋានទេវលោកក៏មាន (អដ្ឋកថា) ។

(៣៩៦) អត្ថិ ទេវេសុ តិរច្ឆានគតាតិ ។ អាមន្តា ។ អត្ថិ តត្ថ ហត្ថិពន្ធា អស្សពន្ធា យាវសិកា តោរណិកា ភត្តការកាតិ ។ ន ហេវំ វត្តព្វេ ។បេ។ តេន ហិ នត្ថិ ទេវេសុ តិរច្ឆានគតាតិ ។

តិរច្ឆានកថា ។

មគ្គកថា

(៣៩៧) បញ្ចង្គិកោ មគ្គោតិ ។ អាមន្តា ។ ននុ អដ្ឋង្គិកោ មគ្គោ វុត្តោ ភគវតា ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធីតិ ។ អាមន្តា ។ ហញ្ចិ អដ្ឋង្គិកោ មគ្គោ វុត្តោ ភគវតា ។ សេយ្យថីទំ ។ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ នោ ច វត រេ វត្តព្វេ បញ្ចង្គិកោ មគ្គោតិ ។ បញ្ចង្គិកោ មគ្គោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា

(៣៩៦) ពួកសត្វតិរច្ឆាន ក្នុងទេវលោក មានដែរឬ ។ អើ ។ ហ្មដំរី ហ្មសេះ ជនអ្នកឲ្យស្រូវដំណើប ជនអ្នកធ្វើកម្ម ជនអ្នកធ្វើភត្ត ក្នុងទេវលោកនោះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ ពួកសត្វតិរច្ឆាន ក្នុងទេវលោក មិនមានទេ ។

ចប់ តិរច្ឆានកថា ។

មគ្គកថា

(៣៩៧) មគ្គ ប្រកបដោយអង្គ ៥ ឬ ។ អើ ។ ក្រែងមគ្គប្រកបដោយអង្គ៨ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ។ មគ្គ ប្រកបដោយអង្គ ៨ គឺអ្វីខ្លះ ។ គឺសម្មាទិដ្ឋិ ១ ។បេ។ សម្មាសមាធិ ១ ឬ ។ អើ ។ ប្រសិនបើ មគ្គ ប្រកបដោយអង្គ៨ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ។ មគ្គ ប្រកបដោយអង្គ៨ គឺអ្វីខ្លះ ។ គឺសម្មាទិដ្ឋិ ១ ។បេ។ សម្មាសមាធិ ១ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា មគ្គ ប្រកបដោយអង្គ៥ ទេ ។ មគ្គ ប្រកបដោយអង្គ ៥ ឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា

មគ្គានដ្ឋង្គិកោ សេដ្ឋោ សច្ចានំ ចតុរោ បទា
វិរាគោ សេដ្ឋោ ធម្មានំ ទិបទានញ្ច ចក្ខុមាតិ

អត្ថិ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ អដ្ឋង្គិកោ មគ្គោតិ ។

(៣៩៦) សម្មាវាចា មគ្គង្គំ សា ច ន មគ្គោតិ ។ អាមន្តា ។ សម្មាទិដ្ឋិ មគ្គង្គំ សា ច ន មគ្គោតិ ។ ន ហេវំ វត្តព្វេ ។បេ។ សម្មាវាចា មគ្គង្គំ សា ច ន មគ្គោតិ ។ អាមន្តា ។ សម្មាសង្កប្បោ ។បេ។ សម្មាវាយាមោ ។បេ។ សម្មាសតិ ។បេ។ សម្មាសមាធិ មគ្គង្គំ សោ ច ន មគ្គោតិ ។ ន ហេវំ វត្តព្វេ ។បេ។ សម្មាកម្មន្តោ ។បេ។ សម្មាអាជីវោ មគ្គង្គំ សោ ច ន មគ្គោតិ ។ អាមន្តា ។ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ មគ្គង្គំ សោ ច ន មគ្គោតិ ។ ន ហេវំ វត្តព្វេ ។បេ។

អដ្ឋង្គិកមគ្គ ប្រសើរជាងមគ្គទាំងឡាយ បទគឺអរិយសច្ច ៤
ប្រសើរជាងសច្ចៈទាំងឡាយ ធម៌ប្រាសចាកតម្រេកប្រសើរហើយ
ប្រសើរជាងធម៌ទាំងឡាយ ព្រះមានព្រះភាគព្រះអង្គមានចក្ខុ
ប្រសើរជាងសត្វជើងពីរទាំងឡាយ

ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ មគ្គ ឈ្មោះថា ប្រកបដោយអង្គ ៨ ។

(៣៩៦) សម្មាវាចា ជាអង្គនៃមគ្គ សម្មាវាចានោះឯង មិនមែនជាតួមគ្គទេឬ ។ អើ ។ សម្មាទិដ្ឋិ ជាអង្គនៃមគ្គ សម្មាទិដ្ឋិនោះឯង មិនមែនជាតួមគ្គទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សម្មាវាចា ជាអង្គនៃមគ្គ សម្មាវាចានោះឯង មិនមែនជាតួមគ្គទេឬ ។ អើ ។ សម្មាសង្កប្បៈ ។បេ។ សម្មាវាយាមៈ ។បេ។ សម្មាសតិ ។បេ។ សម្មាសមាធិ ជាអង្គនៃមគ្គ សម្មាសមាធិនោះឯង មិនមែនជាតួមគ្គទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សម្មាកម្មន្តៈ ។បេ។ សម្មាអាជីវៈ ជាអង្គនៃមគ្គ សម្មាអាជីវៈនោះឯង មិនមែនជាតួមគ្គទេឬ ។ អើ ។ សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ ជាអង្គនៃមគ្គ សម្មាសមាធិនោះឯង មិនមែនជាតួមគ្គទេឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(៣៩៧) សម្មាទិដ្ឋិ មគ្គង្គំ សា ច មគ្គោតិ ។ អាមន្តា ។ សម្មាវាចា មគ្គង្គំ សា ច មគ្គោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សម្មាទិដ្ឋិ មគ្គង្គំ សា ច មគ្គោតិ ។ អាមន្តា ។ សម្មាកម្មន្តោ ។ បេ ។ សម្មាអាជីវោ មគ្គង្គំ សោ ច មគ្គោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សម្មាសង្កប្បោ ។ បេ ។ សម្មាវាយាមោ ។ បេ ។ សម្មាសតិ ។ បេ ។ សម្មាសមាធិ មគ្គង្គំ សោ ច មគ្គោតិ ។ អាមន្តា ។ សម្មាវាចា ។ បេ ។ សម្មាកម្មន្តោ ។ បេ ។ សម្មាអាជីវោ មគ្គង្គំ សោ ច មគ្គោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៣៩៨) អរិយោ អដ្ឋង្គិកោ មគ្គោតិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា បុព្វេ វា បនស្ស កាយកម្មំ វចីកម្មំ អាជីវោ សុបរិសុទ្ធោ ហោតិ ឯវមស្សាយំ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវនាបារិបូរឹ គច្ឆតីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេនហិ បញ្ចង្គិកោ មគ្គោតិ ។

(៣៩៧) សម្មាទិដ្ឋិ ជាអង្គនៃមគ្គ សម្មាទិដ្ឋិនោះឯង ជាតួមគ្គឬ ។ អើ ។ សម្មាវាចា ជាអង្គនៃមគ្គ សម្មាវាចានោះឯង ជាតួមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សម្មាទិដ្ឋិ ជាអង្គនៃមគ្គ សម្មាទិដ្ឋិនោះឯង ជាតួមគ្គឬ ។ អើ ។ សម្មាកម្មន្តៈ ។ បេ ។ សម្មាអាជីវៈ ជាអង្គនៃមគ្គ សម្មាអាជីវៈនោះឯង ជាតួមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សម្មាសង្កប្បៈ ។ បេ ។ សម្មាវាយាមៈ ។ បេ ។ សម្មាសតិ ។ បេ ។ សម្មាសមាធិ ជាអង្គនៃមគ្គ សម្មាសមាធិនោះឯង ជាតួមគ្គឬ ។ អើ ។ សម្មាវាចា ។ បេ ។ សម្មាកម្មន្តៈ ។ បេ ។ សម្មាអាជីវៈ ជាអង្គនៃមគ្គ សម្មាអាជីវៈនោះឯង ជាតួមគ្គឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៣៩៨) អរិយមគ្គ ប្រកបដោយអង្គ ៨ ឬ ។ អើ ។ ក្រែងព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ឯកាយកម្ម វចីកម្ម អាជីវៈ របស់បុគ្គលនោះ ជាធម្មជាតិបរិសុទ្ធស្អាត មានក្នុងកាលមុនពិត អរិយមគ្គ ប្រកបដោយអង្គ ៨ នេះ របស់បុគ្គលនោះ ដល់នូវកិរិយាពេញដោយភាវនា យ៉ាងនេះ ដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ មគ្គឈ្មោះថា ប្រកបដោយអង្គ ៥ ។

(៤០០) ទ្វាទសវត្ថុកំ ញាណំ លោកុត្តរន្តិ ។ អាមន្តា ។ ទ្វាទស លោកុត្តរញ្ញាណានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទ្វាទស លោកុត្តរញ្ញាណានីតិ ។ អាមន្តា ។ ទ្វាទស សោតាបត្តិមគ្គាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទ្វាទស សោតាបត្តិមគ្គាតិ ។ អាមន្តា ។ ទ្វាទស សោតាបត្តិផលានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទ្វាទស សកទាគាមិមគ្គា ។ បេ ។ អនាគាមិមគ្គា ។ បេ ។ អរហត្តមគ្គាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ទ្វាទស អរហត្តមគ្គាតិ ។ អាមន្តា ។ ទ្វាទស អរហត្តផលានីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤០១) ន វត្តព្វំ ទ្វាទសវត្ថុកំ ញាណំ លោកុត្តរន្តិ ។ អាមន្តា ។ ននុ វុត្តំ ភគវតា ឥទំ ទុក្ខំ អរិយសច្ចន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ញាណំ ឧទបាទិ បញ្ញា ឧទបាទិ វិជ្ជា ឧទបាទិ អាលោកោ ឧទបាទិ តំ ខោ បនិទំ ទុក្ខំ អរិយសច្ចំ បរិញ្ញេយ្យន្តិ មេ ភិក្ខវេ ។ បេ ។ បរិញ្ញាតន្តិ មេ ភិក្ខវេ ។ បេ ។

(៤០០) ញាណ មានវត្ថុ ១២ ជាលោកុត្តរៈឬ ។ អើ ។ លោកុត្តរញ្ញាណ មាន១២ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ លោកុត្តរញ្ញាណមាន១២ឬ ។ អើ ។ សោតាបត្តិមគ្គ មាន ១២ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សោតាបត្តិមគ្គ មាន១២ឬ ។ អើ ។ សោតាបត្តិផល មាន១២ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ សកទាគាមិមគ្គ ។ បេ ។ អនាគាមិមគ្គ ។ បេ ។ អរហត្តមគ្គ មាន១២ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ អរហត្តមគ្គ មាន ១២ ឬ ។ អើ ។ អរហត្តផល មាន ១២ ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤០១) បុគ្គលមិនគួរនិយាយថា ញាណ មានវត្ថុ១២ ជាលោកុត្តរៈទេឬ ។ អើ ។ ក៏ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ បញ្ញាកើតឡើងហើយ វិជ្ជាកើតឡើងហើយ ពន្លឺកើតឡើងហើយ ដល់តថាគត ក្នុងធម៌ទាំងឡាយដែលតថាគតមិនដែលបានឮក្នុងកាលមុនថា នេះទុក្ខឈ្មោះថាអរិយសច្ចដូច្នេះ ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ដល់តថាគតថា ទុក្ខឈ្មោះថាអរិយសច្ចនោះឯង បុគ្គលគួរកំណត់ដឹង ម្នាលភិក្ខុទាំងឡាយ ។ បេ ។

១ សំដៅយកញាណមានអាការៈ ១២ ក្នុងកាលរំលឹងធម្មចក្រគ្រប់សច្ចៈទាំង ៤ ក្នុងសច្ចៈមួយមានញាណបី ។ គឺសច្ចញ្ញាណ ១ កិច្ចញ្ញាណ ១ កតញ្ញាណ ១ ត្រូវជាញាណ ១២ ។

ឥទំ ទុក្ខសមុទយោ អរិយសច្ចន្តិ មេ ភិក្ខវេ ។ បេ ។ តំ ខោ បនិទំ ទុក្ខសមុទយោ អរិយសច្ចំ បហាតព្វន្តិ មេ ភិក្ខវេ ។ បេ ។ បហីនន្តិ មេ ភិក្ខវេ ។ បេ ។ ឥទំ ទុក្ខនិរោធោ អរិយសច្ចន្តិ មេ ភិក្ខវេ ។ បេ ។ តំ ខោ បនិទំ ទុក្ខនិរោធោ អរិយសច្ចំ សច្ឆិកាតព្វន្តិ មេ ភិក្ខវេ ។ បេ ។ សច្ឆិកតន្តិ មេ ភិក្ខវេ ។ បេ ។ ឥទំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចន្តិ មេ ភិក្ខវេ ។ បេ ។ តំ ខោ បនិទំ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ភាវេតព្វន្តិ មេ ភិក្ខវេ ។ បេ ។ ភាវិតន្តិ មេ ភិក្ខវេ បុព្វេ អននុស្សុតេសុ ធម្មេសុ ចក្ខុំ ឧទបាទិ ។ បេ ។

ដល់តថាគត ថា ទុក្ខ ឈ្មោះថាអរិយសច្ចនេះ តថាគត ក៏កំណត់ដឹងហើយ ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ដល់តថាគត ថា តណ្ហា នាំឲ្យកើតទុក្ខនេះ ឈ្មោះថាអរិយសច្ច ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ដល់តថាគត ថា តណ្ហា នាំឲ្យកើតទុក្ខ ឈ្មោះថាអរិយសច្ចនោះឯង បុគ្គលគួរលះបង់ ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ដល់តថាគត ថា តណ្ហា នាំឲ្យកើតទុក្ខ ឈ្មោះថាអរិយសច្ចនោះ តថាគតបានលះបង់ហើយ ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ដល់តថាគត ថា ទីរលត់ទុក្ខនេះ ឈ្មោះថាអរិយសច្ច ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ដល់តថាគត ថា ទីរលត់ទុក្ខ ឈ្មោះថាអរិយសច្ចនោះឯង បុគ្គលគួរធ្វើឲ្យជាក់ច្បាស់ ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ដល់តថាគត ថា ទីរលត់ទុក្ខ ឈ្មោះថាអរិយសច្ចនោះ តថាគតបានធ្វើឲ្យជាក់ច្បាស់ហើយ ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ដល់តថាគត ថា សេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខនេះ ឈ្មោះថាអរិយសច្ច ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ដល់តថាគត ថា សេចក្ដីប្រតិបត្តិជាដំណើរទៅកាន់ទីរលត់ទុក្ខ ឈ្មោះថាអរិយសច្ចនោះឯង បុគ្គលគួរចម្រើន ម្នាលភិក្ខុទាំងឡាយ ចក្ខុកើតឡើងហើយ ។ បេ ។

ភាវេតោ ឧប្បជ្ជតីតិ អត្ថេវ សុត្តន្តោតិ ។ អាមន្តា ។ តេន ហិ សោឡសវត្ថុកំ ញាណំ លោកុត្តរន្តិ ។

ញាណកថា ។

វីសតិមោ វគ្គោ ។

តស្សុទ្ទានំ

មាតុឃាតកោ អានន្តរិកោ

បិតុឃាតកោ អានន្តរិកោ

អរហន្តឃាតកោ អានន្តរិកោ

រុហិរុប្បាទកោ អានន្តរិកោ

សង្ឃភេទកោ អានន្តរិកោ

នត្ថិ បុថុជ្ជនស្ស ញាណំ

នត្ថិ និរយេសុ និរយបាលា

អត្ថិ ទេវេសុ តិរច្ឆានគតា

បញ្ចង្គិកោ មគ្គោ សោឡសវត្ថុកំ

ញាណំ លោកុត្តរន្តិ ។

ចតុត្ថោ បណ្ណាសកោ ។

និគ្គហោ បុញ្ញសំចយោ (១) អដ្ឋាសិ អភិឋេន ច មាតុឃាតកោតិ ។

---

១ ម. បុញ្ញុបចយោ ។

ពន្ទឺកើតឡើងហើយ ដល់កថាវត្ថុ ក្នុងបរិវារវិញ្ញូរ វែករកពាក្យ មិនដែលបានឮក្នុងកាលមុនថា សេចក្តីប្រតិបត្តិរបស់ដើម្បីដល់ទីលើ ទុក្ខ ឈ្មោះថាអរិយសច្ចនោះ គឺថាគតបានទ្រង់ត្រាស់ហើយ ពាក្យដូច្នេះ មានក្នុងព្រះសូត្រឬ ។ អើ ។ ព្រោះហេតុនោះ ញាណ មានវត្ថុ ១៦ ជាលោកុត្តរៈ ។

ចប់ ញាណកថា ។

ចប់ វីសតិមវគ្គ ។

ឧទ្ទាននៃវីសតិមវគ្គនោះ គឺ

និយាយ អំពីមាតុឃាតក៍ ដល់អនន្តរិយកម្ម បិតុឃាតក៍ ដល់អនន្តរិយកម្ម អរហន្តឃាតក៍ ដល់អនន្តរិយកម្ម រុហិរុប្បាទក៍ ដល់អនន្តរិយកម្ម សង្ឃភេទក៍ ដល់អនន្តរិយកម្ម ១ ញាណរបស់បុថុជ្ជន មិនមាន ១ ពួកនិរយបាល ក្នុងឋាននរកមិនមាន ១ ពួកសត្វតិរច្ឆាន ក្នុងទេវលោកមាន ១ មគ្គប្រកបដោយអង្គប្រាំ ១ ញាណ មានវត្ថុ ១៦ ជាលោកុត្តរៈ ១ ។

ចប់ ចតុត្ថបណ្ណាសកៈ ។

(ក្នុងបណ្ណាសកៈនេះ) និយាយអំពីការសង្កត់សង្កិនជាដើម ១ ការសន្សំបុណ្យជាដើម ១ ព្រះមានព្រះភាគឋិតនៅក្នុងមនុស្សលោកជាដើម ១ ការលះកិលេសជាអតីតជាដើម ១ មាតុឃាតក៍ ដល់អនន្តរិយកម្មជាដើម ១ ។

(៤០២) សាសនំ នវំ កតន្តិ ។ អាមន្តា ។ សតិប្បដ្ឋានា នវំ កតាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ សាសនំ នវំ កតន្តិ ។ អាមន្តា ។ សម្មប្បធានា ។ បេ ។ ឥទ្ធិបាទា ។ បេ ។ ឥន្ទ្រិយា ។ បេ ។ ពលា ។ បេ ។ ពោជ្ឈង្គា នវំ កតាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ បុព្វេ អកុសលំ បច្ឆា កុសលំ កតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ បុព្វេ សាសវំ ។ បេ ។ សញ្ញោជនិយំ គន្ថនិយំ ឱឃនិយំ យោគនិយំ នីវរណិយំ បរាមដ្ឋំ ឧបាទានិយំ ។ បេ ។ សង្កិលេសិកំ បច្ឆា អសង្កិលេសិកំ កតន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤០៣) អត្ថិ កោចិ តថាគតស្ស សាសនំ នវំ ករោតីតិ ។ អាមន្តា ។ អត្ថិ កោចិ សតិប្បដ្ឋានេ នវំ ករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ កោចិ សម្មប្បធានេ ។ បេ ។ ឥទ្ធិបាទេ ។ បេ ។ ឥន្ទ្រិយេ ។ បេ ។ ពលេ ។ បេ ។ ពោជ្ឈង្គេ នវំ ករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤០២) សាសនា គេធ្វើថ្មី[១]ក្រោយដែរឬ ។ អើ ។ សតិប្បដ្ឋាន គេធ្វើជាថ្មីបានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ពេ។ សាសនា គេធ្វើជាថ្មីបានដែរឬ ។ អើ ។ សម្មប្បធាន ។ពេ។ ឥទ្ធិបាទ ។ពេ។ ឥន្ទ្រិយ ។ពេ។ ពលៈ ។ពេ។ ពោជ្ឈង្គៈ គេធ្វើជាថ្មីបានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ពេ។ អកុសល គេធ្វើក្នុងកាលមុន កុសល គេធ្វើក្នុងកាលជាខាងក្រោយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ពេ។ អំពើប្រកបដោយអាសវៈ ។ពេ។ គួរដល់សញ្ញោជនៈ គួរដល់គន្ថៈ គួរដល់ឱឃៈ គួរដល់យោគៈ គួរដល់នីវរណៈ ដែលបរាមាសៈគប្បីស្ទាបអង្អែល ជាប្រយោជន៍ដល់ឧបាទាន ។ពេ។ ប្រកបដោយកិលេស គេធ្វើក្នុងកាលមុន អំពើមិនប្រកបដោយកិលេស គេធ្វើក្នុងកាលជាខាងក្រោយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ពេ។

(៤០៣) បុគ្គលណាមួយ ធ្វើសាសនា របស់ព្រះតថាគត ជាថ្មីបានដែរឬ ។ អើ ។ បុគ្គលណាមួយ ធ្វើសតិប្បដ្ឋានជាថ្មី បានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ពេ។ បុគ្គលណាមួយ ធ្វើសម្មប្បធាន ។ពេ។ ឥទ្ធិបាទ ។ពេ។ ឥន្ទ្រិយ ។ពេ។ ពលៈ ។ពេ។ ពោជ្ឈង្គៈជាថ្មី បានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ពេ។

១ សំដៅយកការបដ្ឋានទាំង ៣ លើកខាងដើម គឺសង្គាយនាទី ១ ទី ២ ទី ៣ ។

អត្ថិ កោចិ បុព្វេ អកុសលំ បច្ឆា កុសលំ ករោ-
តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ អត្ថិ កោចិ បុព្វេ
សាសវំ ។ បេ ។ សង្កិលេសិកំ បច្ឆា អសង្កិលេសិកំ
ករោតីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤០៤) លព្ភា តថាគតស្ស សាសនំ បុន នវំ
កាតុន្តិ ។ អាមន្តា ។ លព្ភា សតិប្បដ្ឋានា បុន
នវំ កាតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។ លព្ភា
សម្មប្បធានា ឥទ្ធិបាទា ឥន្ទ្រិយា ពលា ។ បេ ។
ពោជ្ឈង្គា បុន នវំ កាតុន្តិ ។ ន ហេវំ វត្តព្វេ ។ បេ ។
លព្ភា បុព្វេ អកុសលំ បច្ឆា កុសលំ កាតុន្តិ ។
ន ហេវំ វត្តព្វេ ។ បេ ។ លព្ភា បុព្វេ សាសវំ ។ បេ ។
សង្កិលេសិកំ បច្ឆា អសង្កិលេសិកំ កាតុន្តិ ។ ន
ហេវំ វត្តព្វេ ។ បេ ។

សាសនកថា ។

បុគ្គលណាមួយ ធ្វើអកុសល ក្នុងកាលមុន ធ្វើកុសល ក្នុងកាលជាខាង
ក្រោយ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល
ណាមួយ ធ្វើអំពើប្រកបដោយអាសវៈ ។ បេ ។ ប្រកបដោយកិលេស
ក្នុងកាលមុន ធ្វើអំពើមិនប្រកបដោយកិលេស ក្នុងកាលជាខាងក្រោយ
មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៤០៤) បុគ្គល បានធ្វើសាសនា របស់តថាគត ជាថ្មីវិញដែរឬ ។
អើ ។ បុគ្គល បានធ្វើសតិប្បដ្ឋាន ជាថ្មីវិញដែរឬ ។ អ្នកមិនគួរពោល
យ៉ាងនេះទេ ។ បេ ។ បុគ្គល បានធ្វើសម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ
ពលៈ ។ បេ ។ ពោជ្ឈង្គៈ ជាថ្មីវិញដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ
។ បេ ។ បុគ្គលបានធ្វើអកុសល ក្នុងកាលមុន ធ្វើកុសល ក្នុងកាល
ជាខាងក្រោយដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ បុគ្គល
បានធ្វើអំពើប្រកបដោយអាសវៈ ។ បេ ។ ប្រកបដោយកិលេស ក្នុង
កាលមុន ធ្វើអំពើមិនប្រកបដោយកិលេស ក្នុងកាលជាខាងក្រោយឬ ។
អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

ចប់ សាសនកថា ។

(២០៥) បុថុជ្ជនោ តេធាតុកេហិ ធម្មេហិ អវិវិត្តោតិ ។ អាមន្តា ។ បុថុជ្ជនោ តេធាតុកេហិ ផស្សេហិ ។បេ។ តេធាតុកេហិ វេទនាហិ សញ្ញាហិ ចេតនាហិ ចិត្តេហិ សទ្ធាហិ វីរិយេហិ សតីហិ សមាធីហិ តេធាតុកាហិ បញ្ញាហិ អវិវិត្តោតិ ។ ន ហេវំ វត្តព្វេ ។បេ។ បុថុជ្ជនោ តេធាតុកេហិ ធម្មេហិ អវិវិត្តោតិ ។ អាមន្តា ។ យស្មិំ ខណេ បុថុជ្ជនោ ចីវរំ ទេតិ តស្មិំ ខណេ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។បេ។ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតីតិ ។ ន ហេវំ វត្តព្វេ ។បេ។ យស្មិំ ខណេ បុថុជ្ជនោ បិណ្ឌបាតំ ទេតិ ។បេ។ សេនាសនំ ទេតិ ។បេ។ គិលានប្បច្ចយភេសជ្ជបរិក្ខារំ ទេតិ តស្មិំ ខណេ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតីតិ ។ ន ហេវំ វត្តព្វេ ។បេ។

(២០៦) ន វត្តព្វំ បុថុជ្ជនោ តេធាតុកេហិ ធម្មេហិ អវិវិត្តោតិ ។ អាមន្តា ។ បុថុជ្ជនស្ស រូបធាតុអរូបធាតូបគំ កម្មំ បរិញ្ញាតន្តិ ។ ន ហេវំ វត្តព្វេ ។បេ។

អវិវិត្តកថា

(២០៥) បុថុជ្ជន មិនស្ងប់ស្ងាត់ចាកពួកធម៌ ប្រកបដោយធាតុ ៣ ឬ ។ អើ ។ បុថុជ្ជន មិនស្ងប់ស្ងាត់ចាកផស្សៈ ប្រកបដោយធាតុ ៣ ។បេ។ ចាកវេទនា សញ្ញា ចេតនា ចិត្ត សទ្ធា វីរិយៈ សតិ សមាធិ ប្រកបដោយធាតុ ៣ ចាកបញ្ញា ប្រកបដោយធាតុ ៣ ឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ បុថុជ្ជន មិនស្ងប់ស្ងាត់ចាកពួកធម៌ ប្រកបដោយធាតុ ៣ ឬ ។ អើ ។ ក្នុងខណៈណា បុថុជ្ជន ឲ្យចីវរ ក្នុងខណៈនោះ ក៏បានដល់នូវបឋមជ្ឈាន ។បេ។ បានដល់នូវអាកាសានញ្ចាយតនៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ក្នុងខណៈណា បុថុជ្ជន ឲ្យបិណ្ឌបាត ។បេ។ ឲ្យសេនាសនៈ ។បេ។ ឲ្យគិលានប្បច្ចយភេសជ្ជបរិក្ខារ ក្នុងខណៈនោះ ក៏បានដល់នូវចតុត្ថជ្ឈាន បានដល់នូវនេវសញ្ញានាសញ្ញាយតនៈឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

(២០៦) បុគ្គលមិនគួរនិយាយថា បុថុជ្ជន មិនស្ងប់ស្ងាត់ចាកពួកធម៌ ប្រកបដោយធាតុ ៣ ឬ ។ អើ ។ កម្ម គួរដល់នូវរូបធាតុនិងអរូបធាតុ បុថុជ្ជន កំណត់ដឹងហើយឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។

តេន ហិ ពុទ្ធប្បមាណោ ហោមាត្ថុ(?) ... ។

អវិត្តកថា ។

សញ្ញោជនកថា

(៦០៧) អត្ថិ កិញ្ចិ សញ្ញោជនំ អប្បហាយ អរហត្តប្បត្តីតិ ។ អាមន្តា ។ អត្ថិ កិញ្ចិ សក្កាយទិដ្ឋឹ អប្បហាយ ។ បេ ។ វិចិកិច្ឆំ អប្បហាយ ។ បេ ។ សីលព្វតបរាមាសំ អប្បហាយ រាគំ អប្បហាយ ទោសំ អប្បហាយ មោហំ អប្បហាយ ។ បេ ។ អនោត្តប្បំ អប្បហាយ អរហត្តប្បត្តីតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៦០៨) អត្ថិ កិញ្ចិ សញ្ញោជនំ អប្បហាយ អរហត្តប្បត្តីតិ ។ អាមន្តា ។ អរហា សរាគោ សទោសោ សមោហោ សមានោ សមក្ខោ សបឡាសោ សឧបាយាសោ សកិលេសោតិ ។ ន ហេវំ វត្តព្វេ ។ បេ ។ ននុ អរហា វីតរាគោ វីតទោសោ វីតមោហោ វីតមានោ វីតមក្ខោ វីតបឡាសោ វីតុបាយាសោ វីតកិលេសោតិ ។ អាមន្តា ។ ហញ្ចិ អរហា វីតរាគោ ។ បេ ។ វីតកិលេសោ នោ ច វត រេ វត្តព្វេ អត្ថិ កិញ្ចិ សញ្ញោជនំ អប្បហាយ អរហត្តប្បត្តីតិ ។

ព្រោះហេតុនោះ ... មិនគួរ ... ព្រះភគវា ... ញាណទេ ។

ចប់អវិត្តកថា ។

សញ្ញោជនកថា

(៦០៧) ការដល់ព្រះអរហត្ត ព្រោះមិនលះបង់សញ្ញោជនៈតិចតួច មានដែរឬ ។ អើ ។ ការដល់ព្រះអរហត្ត ព្រោះមិនលះសក្កាយទិដ្ឋិ ។ បេ ។ ព្រោះមិនលះវិចិកិច្ឆា ។ បេ ។ ព្រោះមិនលះសីលព្វតបរាមាសៈ ព្រោះមិនលះរាគៈ ព្រោះមិនលះទោសៈ ព្រោះមិនលះមោហៈ ។ បេ ។ ព្រោះមិនលះអនោត្តប្បៈតិចតួច មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។

(៦០៨) ការដល់ព្រះអរហត្ត ព្រោះមិនលះសញ្ញោជនៈតិចតួច មានដែរឬ ។ អើ ។ ព្រះអរហន្ត ប្រកបដោយរាគៈ ប្រកបដោយទោសៈ ប្រកបដោយមោហៈ ប្រកបដោយមានៈ ប្រកបដោយមក្ខៈ ប្រកបដោយបឡាសៈ ប្រកបដោយឧបាយាសៈ ប្រកបដោយកិលេស ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។ បេ ។ ក្រែងព្រះអរហន្ត មិនមានរាគៈ មិនមានទោសៈ មិនមានមោហៈ មិនមានមានៈ មិនមានមក្ខៈ មិនមានបឡាសៈ មិនមានឧបាយាសៈ មិនមានកិលេសទេឬ ។ អើ ។ ប្រសិនបើ ព្រះអរហន្ត មិនមានរាគៈ ។ បេ ។ មិនមានកិលេសទេ ម្នាលអ្នកដ៏ចម្រើន អ្នកមិនគួរពោលថា ការដល់នូវព្រះអរហត្ត ព្រោះមិនលះសញ្ញោជនៈតិចតួច មានទេ ។

(៤០៩) ន វត្តព្វំ អត្ថិ កិញ្ចិ សញ្ញោជនំ អប្បហាយ អរហត្តប្បត្តីតិ ។ អាមន្តា ។ អរហា សព្វំ ពុទ្ធវិសយំ ជានាតីតិ ។ ន ហេវំ វត្តព្វេ ។បេ។ តេន ហិ អត្ថិ កិញ្ចិ សញ្ញោជនំ អប្បហាយ អរហត្តប្បត្តីតិ ។

សញ្ញោជនកថា ។

ឥទ្ធិកថា

(៤១០) អត្ថិ អធិប្បាយឥទ្ធិ ពុទ្ធានំ វា សាវកានំ វាតិ ។ អាមន្តា ។ និច្ចបណ្ណា រុក្ខា ហោន្តូតិ អត្ថិ អធិប្បាយឥទ្ធិ ពុទ្ធានំ វា សាវកានំ វាតិ ។ ន ហេវំ វត្តព្វេ ។បេ។ និច្ចបុប្ផា រុក្ខា ហោន្តុ ។បេ។ និច្ចផលិកា រុក្ខា ហោន្តុ និច្ចំ ជុណ្ហំ ហោតុ និច្ចំ ខេមំ ហោតុ និច្ចំ សុភិក្ខំ ហោតុ និច្ចំ សុវុដ្ឋិកំ ហោតូតិ អត្ថិ អធិប្បាយឥទ្ធិ ពុទ្ធានំ វា សាវកានំ វាតិ ។ ន ហេវំ វត្តព្វេ ។បេ។ អត្ថិ អធិប្បាយឥទ្ធិ ពុទ្ធានំ វា សាវកានំ វាតិ ។ អាមន្តា ។ ឧប្បន្នោ ផស្សោ មា និរុជ្ឈីតិ អត្ថិ អធិប្បាយឥទ្ធិ ពុទ្ធានំ វា សាវកានំ វាតិ ។

(៤០៩) បុគ្គលមិនគួរពោលថា ការដល់នូវព្រះអរហត្ត ព្រោះមិនលះសញ្ញោជនៈតិចតួច មានឬ ។ អើ ។ ព្រះអរហន្ត ដឹងនូវពុទ្ធវិស័យទាំងអស់ដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ ព្រោះហេតុនោះ ការដល់នូវព្រះអរហត្ត ព្រោះមិនលះសញ្ញោជនៈតិចតួចមាន ។

ចប់ សញ្ញោជនកថា ។

ឥទ្ធិកថា

(៤១០) សេចក្តីសម្រេចតាមប្រាថ្នា នៃព្រះពុទ្ធទាំងឡាយក្តី នៃសាវកទាំងឡាយក្តី មានដែរឬ ។ អើ ។ សេចក្តីសម្រេចតាមប្រាថ្នា នៃព្រះពុទ្ធទាំងឡាយក្តី នៃសាវកទាំងឡាយក្តី ថា ឈើទាំងឡាយ ចូរមានស្លឹកជានិច្ចដូច្នេះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សេចក្តីសម្រេចតាមប្រាថ្នា នៃព្រះពុទ្ធទាំងឡាយក្តី នៃសាវកទាំងឡាយក្តី ថា ឈើទាំងឡាយ ចូរមានផ្កាជានិច្ច ។បេ។ ឈើទាំងឡាយ ចូរមានផ្លែជានិច្ច ចូរត្រជាក់ត្រជុំជានិច្ច ចូរមានសេចក្តីក្សេមជានិច្ច ចូរមានបាយងាយជានិច្ច ចូរមានភ្លៀងស្រួលជានិច្ចដូច្នេះ មានដែរឬ ។ អ្នកមិនគួរពោលយ៉ាងនេះទេ ។បេ។ សេចក្តីសម្រេចតាមប្រាថ្នា នៃព្រះពុទ្ធទាំងឡាយក្តី នៃសាវកទាំងឡាយក្តី មានដែរឬ ។ អើ ។ សេចក្តីសម្រេចតាមប្រាថ្នា នៃព្រះពុទ្ធទាំងឡាយក្តី នៃសាវកទាំងឡាយក្តី ថា ផស្សៈ កើតឡើងហើយ កុំរលត់ទៅវិញឡើយដូច្នេះ មានដែរឬ ។

ន ហេវំ វត្តព្វេ ។ បេ ។ ឧប្បន្នា វេទនា ។ បេ ។ សញ្ញា ។ បេ ។ ចេតនា ។ បេ ។ ចិត្តំ សទ្ធា វីរិយំ សតិ សមាធិ ។ បេ ។ បញ្ញា មា និរុជ្ឈីតិ អត្ថិ អធិប្បាយទ្ធិ ពុទ្ធានំ វា សាវកានំ វាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

(៤០១) អត្ថិ អធិប្បាយទ្ធិ ពុទ្ធានំ វា សាវកានំ វាតិ ។ អាមន្តា ។ រូបំ និច្ចំ ហោតូតិ អត្ថិ អធិប្បាយទ្ធិ វេទនា សញ្ញា សង្ខារា ។ បេ ។ វិញ្ញាណំ និច្ចំ ហោតូតិ អត្ថិ អធិប្បាយទ្ធិ ពុទ្ធានំ វា សាវកានំ វាតិ ។ ន ហេវំ វត្តព្វេ ។ បេ ។

